ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

## រាជរដ្ឋាភិបាលកម្ពុជា

# យុទ្ធសាស្ត្រជាតិគាំពារសង្គម
# សម្រាប់ជនក្រីក្រ និងជនងាយរងគ្រោះ
# (២០១១-២០១៥)

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

# យុទ្ធសាស្ត្រជាតិគាំពារសង្គម សម្រាប់ជនក្រីក្រ និងជនងាយរងគ្រោះ (២០១១-២០១៥)

# សារលិខិត

# សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

# នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

ប្រជាជនកម្ពុជាបានធ្វើដំណើរលើផ្លូវមួយយ៉ាងវែងក្នុងប្រវត្តិសាស្ត្រ ក្នុងការតស៊ូការពារជីវិតរស់នៅ រក្សាការពារអធិបតេយ្យ ឯកភាពជាតិ ឯករាជ្យ បូរណភាពទឹកដី និងកិត្តិយសថ្លៃថ្នូររុងរឿង។ តាំងពីឆ្នាំ១៩៧៩មក ប្រជាជនកម្ពុជាបានខិតខំប្រឹងប្រែងយ៉ាងម៉ឺងម៉ាត់ ជម្នះគ្រប់ឧបសគ្គ ទាញយកឱកាសគ្រប់ការប្រឈម ដើម្បីដំណើរការកសាងជាតិយ៉ាងល្អប្រសើរ ដោយបានប្រែក្លាយព្រះរាជាណាចក្រកម្ពុជាមកជាប្រទេសមួយប្រកបដោយសេចក្តីសង្ឃឹមនិងកិត្តិយសនៅអាស៊ីអាគ្នេយ៍។ រាជរដ្ឋាភិបាលមានចក្ខុវិស័យច្បាស់លាស់ សម្លឹងមើលទៅអនាគតវែងឆ្ងាយក្នុងការជំរុញអនុវត្តកំណែទម្រង់នានាដែលបានដាក់ចេញ ដោយបានបន្សាំទៅគ្រប់ស្ថានភាពដែលអាចកើតមានឡើងជាយថាហេតុ និងធ្វើការកែលម្អជាបន្តបន្ទាប់ ដើម្បីជំរុញការអភិវឌ្ឍសេដ្ឋកិច្ចសង្គមឲ្យសម្រេចដល់គោលដៅដែលបានគ្រោងទុក។

ចាប់តាំងពីឆ្នាំ១៩៩៣ក្រោយការបោះឆ្នោតលើកទី១ រាជរដ្ឋាភិបាលបានខិតខំបំពេញភារកិច្ចរបស់ខ្លួន ហើយបានឆ្លងកាត់គ្រប់ស្ថានភាព និងបានជម្នះឧបសគ្គធំៗជាច្រើន ដើម្បីរក្សាស្ថិរភាពនយោបាយ ដំណើរការស្តារនិងកសាងឡើងវិញនូវហេដ្ឋារចនាសម្ព័ន្ធសង្គម រូបវន្តនិងស្ថាប័ន ដោយបានលើកឡើងនូវចក្ខុវិស័យរយៈពេលវែង។ ក្រោយឆ្នាំ១៩៩៨ រាជរដ្ឋាភិបាលសម្រេច និងធានាបានសន្តិភាពរឹងមាំ ដោយលុបបំបាត់ជាស្ថាពរនូវជម្លោះផ្ទៃក្នុងដែលកើតមានពីអតីតកាល។ កិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការថែរក្សាស្ថិរភាពនយោបាយនិងសង្គម សន្តិភាព និងសន្តិសុខផ្ទៃក្នុង និងការគ្រប់គ្រងសេដ្ឋកិច្ចដោយរឹងមាំនិងរីកចម្រើន បានធ្វើឲ្យយើងសម្រេចអត្រាកំណើនសេដ្ឋកិច្ចខ្ពស់ និងការកាត់បន្ថយភាពក្រីក្រជាបន្តបន្ទាប់ក្នុងទសវត្សរ៍ចុងក្រោយនេះ។ គោលដៅចម្បងរបស់យុទ្ធសាស្ត្រចតុកោណគឺការជំរុញលើកកម្ពស់កំណើនសេដ្ឋកិច្ចការដោះស្រាយការងារសម្រាប់ពលករកម្ពុជា ការធានា

សមធម៌និងយុត្តិធម៌សង្គម និងការលើកស្ទួយប្រសិទ្ធភាពវិស័យសាធារណៈ តាមរយៈផែនការសកម្មភាពអភិបាលកិច្ច និងកំណែទម្រង់ស៊ីជម្រៅនិងប្រទាក់ក្រឡាគ្នាក្នុងគ្រប់ផ្នែក គ្រប់វិស័យ។

ទិសដៅជាសារវន្តរបស់រាជរដ្ឋាភិបាលកម្ពុជា គឺការកសាងជាជំហានៗនូវសង្គមកម្ពុជាមួយដែលរឹងមាំ មានសន្តិភាព ស្ថិរភាពនយោបាយ សន្តិសុខនិងសណ្តាប់ធ្នាប់សង្គម មានការអភិវឌ្ឍប្រកបដោយចីរភាព និងសមធម៌ ជាមួយនឹងការគោរពយ៉ាងខ្ជាប់ខ្ជួននូវគោលការណ៍ប្រជាធិបតេយ្យសេរីពហុបក្ស ការគោរពសិទ្ធិនិងសេចក្តីថ្លៃថ្នូររបស់មនុស្ស ជាសង្គមមួយដែលមានកោសិកាផ្សារភ្ជាប់គ្នា និងត្រូវបានពង្រឹង ដើម្បីធានាថាប្រជាជនកម្ពុជាមានចំណេះដឹងខ្ពស់និងវប្បធម៌ជ្រៅជ្រះ មានជីវភាពសមរម្យ និងមានការរស់នៅប្រកបដោយសុខដុមរមនា ទាំងក្នុងក្រុមគ្រួសារ ទាំងក្នុងសង្គមជាតិ។

បញ្ហាប្រឈមដ៏ចម្បងរបស់រាជរដ្ឋាភិបាលកម្ពុជា គឺការកាត់បន្ថយភាពក្រីក្រ និងការលើកកម្ពស់កម្រិតជីវភាពរស់នៅនិងគុណភាពជីវិតរបស់ប្រជាជន ដែលកំពុងមានកំណើនយ៉ាងឆាប់រហ័ស។ រាជរដ្ឋាភិបាលកម្ពុជាចាត់ទុកថា ភាពក្រីក្រគឺជាការខាតបង់តម្លៃធនធានសេដ្ឋកិច្ច ដែលមិនត្រឹមតែមិនអាចទទួលយកបានខាងផ្នែកផ្លូវចិត្តប៉ុណ្ណោះទេ ប៉ុន្តែវាអាចបណ្តាលឲ្យមានការបែកខ្ញែក និងអស្ថិរភាពនៅក្នុងសង្គម ។

ដើម្បីបន្តអនុវត្តគោលនយោបាយស្តីពីសុវត្ថិភាពសង្គម រាជរដ្ឋាភិបាលកម្ពុជាសម្រាប់នីតិកាលទី៤នៃរដ្ឋសភា នឹងផ្តល់អាទិភាពទៅលើការធ្វើឲ្យប្រសើរឡើងនូវលក្ខខណ្ឌការងាររបស់កម្មករនិងនិយោជិត ដោយការអនុវត្តច្បាប់ស្តីពីរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ និងការបង្កើតបេឡាជាតិសន្តិសុខសង្គម។ រាជរដ្ឋាភិបាលកម្ពុជានឹងបន្តពង្រឹងការជួយឧបត្ថម្ភឲ្យបានដិតដល់ ចំពោះជនពិការនិងគ្រួសារយុទ្ធជនដែលបានបូជាជីវិតដើម្បីប្រទេសជាតិ ដោយជំរុញការអនុវត្តរបបសន្តិសុខសង្គមសម្រាប់អតីតយុទ្ធជន និងដំណើរការបេឡាជាតិអតីតយុទ្ធជនឲ្យមានប្រសិទ្ធភាព។ ព្រមជាមួយគ្នានេះ រាជរដ្ឋាភិបាលកំពុងខិតខំយកចិត្តទុកដាក់ឧបត្ថម្ភគាំទ្រចំពោះជនពិការនិងគ្រួសារងាយរងគ្រោះ ដោយបង្កើតច្បាប់ស្តីពីកិច្ចការពារនិងលើកកម្ពស់សិទ្ធិជនពិការ និងរបបគោលនយោបាយចំពោះជនពិការនិងគ្រួសារងាយរងគ្រោះនៅតាមសហគមន៍។

រាជរដ្ឋាភិបាលទទួលស្គាល់ថា សំណាញ់សុវត្ថិភាពសង្គមនៅកម្ពុជា នៅពុំទាន់មានលក្ខណៈជាប្រព័ន្ធនៅឡើយ ដូច្នេះយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី២បានលើកឡើងការជំរុញអភិបាលកិច្ចល្អនៅក្នុងការផ្តល់សុវត្ថិភាពសង្គម តាមរយៈការពង្រឹងស្ថាប័ន និងកិច្ចសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍនានា រួមទាំងការពង្រីកបន្ថែមទៀត នូវសេវាសង្គមកិច្ចនិងកម្មវិធីសង្គ្រោះបន្ទាន់ឲ្យបានកាន់តែទូលំទូលាយ។ កិច្ចគាំពារសង្គម ត្រូវបានដាក់បញ្ចូលទៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្ន

កម្ម២០០៩-២០១៣ ហើយប្រការនេះ ជាការបញ្ជាក់ពីការយកចិត្តទុកដាក់ខ្ពស់របស់រាជរដ្ឋាភិបាលកម្ពុជាមកលើគោលនយោបាយគាំពារសង្គម និងជាការឆ្លើយតបទៅនឹងវិបត្តិនិងការអភិវឌ្ឍសង្គមសេដ្ឋកិច្ចសម្រាប់រយៈពេលវែង។

រាជរដ្ឋាភិបាលមានកាតព្វកិច្ចផ្តល់សេវាសង្គមសំខាន់ៗ សម្រាប់ការបង្កើត និងលើកកម្ពស់មូលធនមនុស្ស (វិស័យសុខាភិបាល អប់រំ ជីវភាពរស់នៅ) ហើយក្នុងន័យនេះ ត្រូវបង្កើតបរិស្ថានមួយដែលអាចឲ្យបុគ្គលគ្រប់រូបធ្វើការស្វែងរកឲ្យឃើញ និងធ្វើឲ្យសម្រេចសក្តានុពលពេញលេញរបស់ពួកគាត់ និងរួមចំណែកលើកកម្ពស់សុខុមាលភាពផ្ទាល់ខ្លួនរបស់ពួកគាត់និងការរីកចម្រើនរបស់ប្រទេសជាតិ។ ទន្ទឹមនេះ រាជរដ្ឋាភិបាលនឹងបន្តផ្តល់អន្តរាគមន៍សម្រាប់វិស័យសង្គមកិច្ច ដែលក្នុងនោះរួមមាន ទី១-ការកាត់បន្ថយភាពងាយរងគ្រោះរបស់ជនក្រីក្រ ទី២-វិធានការដើម្បីសម្រាលផលប៉ះពាល់នៃគ្រោះធម្មជាតិ ទី៣-ការជួយជនរងគ្រោះដោយសារបាតុភូតទាំងនោះ ទី៤-ការពង្រីកកម្មវិធីស្តារលទ្ធភាពពលកម្មនិងកម្មវិធីសមាហរណកម្មឡើងវិញសម្រាប់ជនពិការ ជនដែលរងគ្រោះដោយគ្រឿងញៀន ជនរងគ្រោះដោយសារការជួញដូរនិងអំពើកេងប្រវ័ញ្ច និងកុមារដែលប្រព្រឹត្តល្មើសច្បាប់ ក៏ដូចជាការពង្រីកកម្មវិធីសុខុមាលភាពដល់ជនចាស់ជរា កុមារកំព្រា ស្ត្រីមេម៉ាយនិងពោះម៉ាយក្រីក្រ គ្រួសារក្រីក្រដែលមានស្ត្រីជាមេគ្រួសារ ស្ត្រីរងគ្រោះ ជនគ្មានទីលំនៅ និងអតីតយុទ្ធជនព្រមទាំងគ្រួសាររបស់ពួកគាត់ ទី៥-ការទប់ស្កាត់បទល្មើស និងការការពារសុវត្ថិភាពសហគមន៍នៅថ្នាក់ឃុំ សង្កាត់ ស្រុក ខណ្ឌ ខេត្ត ក្រុង និងថ្នាក់ជាតិ ដោយសហការក្នុងភាពជាដៃគូអភិវឌ្ឍ។

រាជរដ្ឋាភិបាលកម្ពុជា តាមរយៈក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ រួមជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ និងដៃគូអភិវឌ្ឍ បានខិតខំរៀបចំចងក្រងយុទ្ធសាស្ត្រគាំពារសង្គមនេះឡើងដោយឆ្លុះបញ្ចាំងពីការប្តេជ្ញាចិត្តយ៉ាងមុតមាំរបស់រាជរដ្ឋាភិបាលផង អំពីបទពិសោធនៅកម្ពុជាផង និងឈរលើមូលដ្ឋាននិងបរិការណ៍សមស្របនៃកម្ពុជា ដើម្បីរួមចំណែកមិនត្រឹមតែក្នុងការស្តារនិងការធ្វើឲ្យសេដ្ឋកិច្ចមានស្ថិរភាពឡើងវិញនៅពេលចំពោះមុខប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងក្នុងការកែលម្អសូចនាករអភិវឌ្ឍន៍មនុស្ស ការអប់រំ សុខភាព និងការរីកចម្រើន ឆ្ពោះទៅសម្រេចឲ្យបាននូវគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជានិងទៅអនាគតយូរអង្វែង តាមរយៈការរក្សាបានកំណើនសេដ្ឋកិច្ចខ្ពស់ និងការអភិវឌ្ឍប្រកបដោយចីរភាព ដោយបានដាក់ចេញយុទ្ធសាស្ត្រនេះឡើងជាចក្ខុវិស័យនៃការគាំពារសង្គមនៅកម្ពុជា ដែលមានលក្ខណៈទូលំទូលាយ ចម្រុះ និងមានស្ថិរភាពសម្រាប់ទាំងអស់គ្នា ជាពិសេសជនក្រីក្រនិងជនងាយរងគ្រោះ។

គោលបំណងចម្បងនៃយុទ្ធសាស្ត្រគាំពារសង្គមនេះ គឺទី១-គាំទ្រដល់ជនក្រីក្របំផុតនិងជនជួបការលំបាកបំផុតដែលមិនអាចជួយខ្លួនឯងបាន ដើម្បីទប់ទល់នឹងភាពក្រីក្រ អសន្តិសុខស្បៀង និងការកេងប្រវ័ញ្ច ទី២-កាត់បន្ថយផលប៉ះពាល់នៃហានិភ័យ ដែលអាចនាំឲ្យប្រជាជនត្រូវប្រើប្រាស់

ដំណោះស្រាយបែបអវិជ្ជមាន និងទី៣-គាំទ្រដល់ជនក្រីក្រឲ្យចាកចេញផុតពីភាពក្រីក្រ តាមរយៈការកសាងមូលធនមនុស្សនិងការបង្កើនកាលានុវត្តភាព រួមមានការទទួលសេវាសុខភាព អាហារូបត្ថម្ភ និងអប់រំសម្រាប់គ្រួសារក្រីក្រ ដើម្បីឲ្យពួកគាត់អាចចេញផុតពីបន្ទាត់នៃភាពក្រីក្រ និងប្រែក្លាយជនក្រីក្រ ជនងាយរងគ្រោះ និងសហគមន៍កម្ពុជា ឲ្យទៅជាកម្លាំងមូលដ្ឋានផលិតរបស់ជាតិទាំងមូល និងចូលរួមចំណែកយ៉ាងសកម្មជាចលនាឋាមវន្តក្នុងការអភិវឌ្ឍសេដ្ឋកិច្ចសង្គមកម្ពុជា។

ខ្ញុំសូមអំពាវនាវដល់ក្រសួង ស្ថាប័នពាក់ព័ន្ធទាំងអស់ ទាំងនៅថ្នាក់ជាតិ ទាំងនៅថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍនៅក្នុងនិងក្រៅប្រទេសទាំងអស់ សូមអនុវត្តឲ្យបានខ្ជាប់ខ្ជួន គ្រប់លក្ខខណ្ឌ គ្រប់ជ្រុងជ្រោយដែលបានលើកឡើងនៅក្នុងយុទ្ធសាស្ត្រគាំពារសង្គមសម្រាប់ជនក្រីក្រ និងជនងាយរងគ្រោះ ក្នុងការរៀបចំនិងអនុវត្តគម្រោង កម្មវិធី ឲ្យមានប្រសិទ្ធភាពនិងចំគោលដៅដែលបានគ្រោងទុក។

រាជធានីភ្នំពេញ ថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១១

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

# បុព្វកថា

## ឯកឧត្តមឧបនាយករដ្ឋមន្ត្រី យឹម ឆៃលី
## ប្រធានក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ

ការគាំពារសង្គម ជាគោលនយោបាយអាទិភាពរបស់រាជរដ្ឋាភិបាលកម្ពុជា ហើយគោលគំនិតផ្តួចផ្តើមដើម្បីរៀបចំប្រព័ន្ធគាំពារសង្គម ជាបំណងប្រាថ្នាដ៏ថ្លៃថ្លានៃរាជរដ្ឋាភិបាល ដើម្បីបម្រើជូនប្រជាពលរដ្ឋកម្ពុជា ដូចដែលមានចែងនៅក្នុងរដ្ឋធម្មនុញ្ញ នៅក្នុងយុទ្ធសាស្ត្រចតុកោណដើម្បីកំណើនការងារ សមធម៌ និងប្រសិទ្ធភាពនៅកម្ពុជា ដំណាក់កាលទី២ ហើយបានរំលេចយ៉ាងច្បាស់ថែមទៀតនៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្ម ២០០៩-២០១៣ ក៏ដូចជាក្របខណ្ឌច្បាប់គតិយុត្ត និងអនុសញ្ញាអន្តរជាតិជាច្រើនទៀតដែលរាជរដ្ឋាភិបាលកម្ពុជាជាហត្ថលេខី។

នៅក្នុងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី១ រាជរដ្ឋាភិបាលកម្ពុជាមានឆន្ទៈក្នុងការបង្កើនអន្តរាគមន៍ទៅលើវិស័យសង្គមកិច្ច ដោយបង្កើនកាលានុវត្តភាពការងារ កាត់បន្ថយភាពងាយរងគ្រោះរបស់ជនក្រីក្រ បង្កើនជំនួយសង្គ្រោះបន្ទាន់សម្រាប់គ្រោះមហន្តរាយធម្មជាតិនិងភាពរឹតត្បិត ពង្រីកកម្មវិធីស្តារលទ្ធភាពពលកម្មសម្រាប់ជនពិការ ចាស់ជរា កុមារកំព្រា ស្ត្រីរងគ្រោះ ជនគ្មានផ្ទះសំបែង និងអតីតយុទ្ធជននិងគ្រួសាររបស់ពួកគាត់។ យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី២បានលើកឡើងនូវការជំរុញអភិបាលកិច្ចល្អនៅក្នុងការផ្តល់សំណាញ់សុវត្ថិភាពសង្គម តាមរយៈការពង្រឹងស្ថាប័ននិងកិច្ចសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍនានា និងការពង្រីកបន្ថែមសេវាសង្គមកិច្ចនិងកម្មវិធីសង្គ្រោះបន្ទាន់ឲ្យបានកាន់តែទូលំទូលាយ ។

ភាពចាំបាច់នៃការរៀបចំឲ្យមានជាយុទ្ធសាស្ត្រគាំពារសង្គមសម្រាប់ជនក្រីក្រ និងជនងាយរងគ្រោះ គឺដើម្បីជំរុញឲ្យមានការរីកចម្រើនជីវភាពរស់នៅរបស់ប្រជាជន និងបង្កើនប្រសិទ្ធភាពឆ្ពោះទៅសម្រេចគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា។ ការអភិវឌ្ឍវិស័យសេដ្ឋកិច្ចជនបទ នឹងត្រូវស្វែងឡើងមិនត្រឹមតែតាមរយៈការស្តារនិងកសាងហេដ្ឋារចនាសម្ព័ន្ធជនបទ ការដោះស្រាយនិកម្មភាពជាលក្ខណៈរដូវកាល ការបណ្តុះបណ្តាលវិជ្ជាជីវៈ ឬការផ្តល់មីក្រូឥណទានប៉ុណ្ណោះទេ តែថែមទាំងជាសកម្មភាពដែលនឹងត្រូវធានាគុណភាពជីវិត ដោយមានការបំពេញបន្ថែមជាមួយការអភិវឌ្ឍសង្គមកិច្ច។

ដំណើរនៃការរៀបចំចងក្រងយុទ្ធសាស្ត្រជាតិគាំពារសង្គមនេះ បានចាប់ផ្តើមចេញពីសម័យប្រជុំវេទិកាសហប្រតិបត្តិការអភិវឌ្ឍកម្ពុជាលើកទី២ កាលពីថ្ងៃទី៣-៤ ខែធ្នូ ឆ្នាំ២០០៨ នៅរាជធានី

ភ្នំពេញ។ ក្នុងឱកាសនោះ រាជរដ្ឋាភិបាលកម្ពុជា និងដៃគូអភិវឌ្ឍបានកត់សម្គាល់ឃើញនូវវឌ្ឍនភាពជាច្រើនដែលត្រូវបានសម្រេចឡើងនាពេលកន្លងមក ពិសេសក្នុងការកាត់បន្ថយភាពក្រីក្រ ប៉ុន្តែស្របពេលជាមួយគ្នា ក៏បានទទួលស្គាល់ថាប្រជាជនកម្ពុជាមួយចំនួនកំពុងស្ថិតនៅក្នុងស្ថានភាពដែលងាយនឹងទទួលរងគ្រោះពីវិបត្តិសង្គមនិងសេដ្ឋកិច្ចមួយចំនួន ដែលអាចនឹងរុញច្រានពួកគាត់ឲ្យធ្លាក់ទៅក្នុងភាពក្រីក្រ។ ឆ្លើយតបនឹងបញ្ហានេះ រាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍបានព្រមព្រៀងពិនិត្យឡើងវិញនូវវិសាលភាពនៃសំណាញ់សុវត្ថិភាពសង្គម ក្នុងការទប់ទល់ទៅនឹងហានិភ័យដែលបណ្តាលមកពីអស្ថិរភាពថ្លៃអាហារនិងកលិយុគសេដ្ឋកិច្ច ដែលអាចនឹងជះឥទ្ធិពលអវិជ្ជមានទៅលើជីវភាពរស់នៅរបស់ប្រជាជនក្រីក្រ និងជនងាយរងគ្រោះ។ ការរៀបចំយុទ្ធសាស្ត្រនេះ គឺស្របគ្នានឹងដំណាក់កាលនៅក្រោយវិបត្តិហិរញ្ញវត្ថុនិងសេដ្ឋកិច្ចសកល និងការឡើងថ្លៃទំនិញនិងប្រេងឥន្ធនៈ ដែលបានជះឥទ្ធិពលអវិជ្ជមានពិសេសទៅលើក្រុមជនក្រីក្រនិងជនងាយរងគ្រោះ ហើយបានរារាំងនិងពន្យឺតដល់ការសម្រេចគោលដៅអភិវឌ្ឍសហស្សវត្សរ៍កម្ពុជា។ ជំហានដំបូងនៃការងារនេះ គឺការសិក្សា ការពិនិត្យ និងការវិភាគទូទៅដើម្បីកំណត់វិសាលភាពនៃសំណាញ់សុវត្ថិភាពសង្គមដែលមានស្រាប់ និងការកំណត់ទិសដៅគោលនយោបាយនិងជម្រើសជាយុទ្ធសាស្ត្រ សម្រាប់ការបង្កើតសំណាញ់សុវត្ថិភាពសង្គមមួយ ដែលមានលក្ខណៈចម្រុះនិងជាប្រព័ន្ធ និងស្របតាមស្ថានភាពសង្គមសេដ្ឋកិច្ចនៅកម្ពុជា។

ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ ត្រូវបានផ្តល់ភារកិច្ចដើម្បីធានាឲ្យមានប្រសិទ្ធភាព ក្នុងយន្តការសម្របសម្រួលអន្តរក្រសួង ដោយមានការចូលរួមពីក្រសួងនិងស្ថាប័នពាក់ព័ន្ធដែលមានសកម្មភាពការងារផ្តោតលើការផ្តល់ និងការគាំទ្រកម្មវិធីសំណាញ់សុវត្ថិភាពសង្គមទៅឲ្យជនក្រីក្រនិងជនងាយរងគ្រោះ។ នៅឆមាសទី១នៃឆ្នាំ២០០៩ ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ ដោយមានការគាំទ្រពីក្រសួងពាក់ព័ន្ធនិងដៃគូអភិវឌ្ឍ បានធ្វើការរួមគ្នាដើម្បីកសាងនូវការឯកភាពគ្នាលើទស្សនាទានគន្លឹះនិងទិសដៅទូលំទូលាយ សម្រាប់ការបង្កើតគោលនយោបាយសំណាញ់សុវត្ថិភាពសង្គម។ លទ្ធផលនៃការរកឃើញ ព្រមទាំងអនុសាសន៍នានា ត្រូវបានបង្ហាញក្នុងឱកាសវេទិកាជាតិស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ក្រោមប្រធានបទសំណាញ់សុវត្ថិភាពសង្គមនៅកម្ពុជា នាថ្ងៃទី៦-៧ ខែកក្កដា ឆ្នាំ២០០៩។ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី បានផ្តល់សុន្ទរកថាបិទវេទិកាដោយបានសង្កត់ធ្ងន់ថា ការពង្រឹងសំណាញ់សុវត្ថិភាពសង្គមសម្រាប់ក្រុមជនងាយរងគ្រោះ គឺជាយុទ្ធសាស្ត្រចម្បងមួយរបស់រាជរដ្ឋាភិបាលក្នុងការទប់ទល់នឹងបច្ច័យអវិជ្ជមាន និងហានិភ័យនានា ដែលបានកើតមានពីកលិយុគសេដ្ឋកិច្ចសកល។ តួនាទីស្នូលនៃសំណាញ់សុវត្ថិភាពសង្គមគឺការពារដល់ក្រុមជនងាយរងគ្រោះ និងដើម្បីកាត់បន្ថយផលប៉ះពាល់នៃវិបត្តិ ក៏ដូចជាការកសាងមូលធនមនុស្សនិងសង្គមសម្រាប់ការពង្រីកកាលានុវត្តភាពសេដ្ឋកិច្ច។ នៅឆមាសទី២នៃឆ្នាំ២០០៩ រាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍ បានធ្វើការរួមគ្នាដើម្បីរៀបចំបង្កើតនូវយុទ្ធសាស្ត្រគាំពារសង្គមសម្រាប់កម្ពុជា

ដោយពិចារណាទៅលើការកំណត់អាទិភាព សម្រាប់កម្មវិធីសំណាញ់សុវត្ថិភាពសង្គមនៅឆ្នាំ២០១១-២០១៥។

កម្មវិធីសំណាញ់សុវត្ថិភាពសង្គម មិនមែនជាការងារថ្មីសម្រាប់កម្ពុជាទេ ប៉ុន្តែការយល់ដឹងពីទស្សនៈនិងអត្ថន័យ នៅមានការយល់ផ្សេងៗពីគ្នា។ កម្ពុជាបានអនុវត្តកម្មវិធីនិងគម្រោងទាំងនោះជាច្រើនមកហើយ ក្នុងការធ្វើសមាហរណកម្មនីតិសម្បទានិងដើម្បីលើកកម្ពស់សន្តិសុខស្បៀង ដែលឆ្លើយតបទៅនឹងស្ថានភាពសង្គ្រោះបន្ទាន់ផង និងដើម្បីបង្កើនជីវភាពរស់នៅរបស់ប្រជាជនក្រីក្រផង។ កម្មវិធីសំណាញ់សុវត្ថិភាពសង្គមដែលជាផ្នែកសំខាន់នៃយុទ្ធសាស្ត្រគាំពារសង្គម ត្រូវបានចងក្រងសមស្របទៅតាមបរិបទកម្ពុជា ព្រមទាំងមានលក្ខណៈចម្រុះនិងជាប្រព័ន្ធ ដែលរាជរដ្ឋាភិបាលអាចឆ្លើយតបភ្លាមៗតាមសភាពការណ៍និងប្រភេទនៃហានិភ័យទាន់ពេលវេលា និងស៊ីសង្វាក់គ្នារវាងស្ថាប័នពាក់ព័ន្ធទាំងអស់ ប្រកបដោយប្រសិទ្ធភាពនិងមានភាពស័ក្តិសិទ្ធិ សម្រាប់រយៈពេលបន្ទាន់ ពេលមធ្យម និងរយៈពេលវែង។ ឯកសារនេះក៏បំពេញបន្ថែមទៅលើឯកសារយុទ្ធសាស្ត្រ និងផែនការនៃវិស័យដទៃទៀតដែលមានជាប់ទាក់ទងដោយផ្ទាល់ ឬដោយប្រយោលទៅនឹងការគាំពារសង្គម ឆ្ពោះទៅកាន់ការកសាងប្រព័ន្ធគាំពារសង្គមដ៏ទូលំទូលាយ មានលក្ខណៈចម្រុះនិងស៊ីសង្វាក់គ្នា សម្រាប់ជួយដល់ជនក្រីក្រនិងជនងាយរងគ្រោះនៅកម្ពុជា។ម្យ៉ាងទៀតដើម្បីឲ្យមានប្រសិទ្ធភាពក្នុងការអនុវត្ត ក្របខណ្ឌនៃយុទ្ធ-សាស្ត្រជាតិគាំពារសង្គមសម្រាប់ជនក្រីក្រនិងជនងាយរងគ្រោះ ត្រូវបានរៀបចំតាក់តែងឡើងដោយមានការថ្លឹងថ្លែងរវាងដំណោះស្រាយដើម្បីកាត់បន្ថយភាពក្រីក្ររ៉ាំរ៉ៃ និងជួយជនក្រីក្រឲ្យមានសមត្ថភាពឆ្លើយតបនូវហានិភ័យដែលកើតឡើងដោយសារហេតុផលសង្គម សេដ្ឋកិច្ច និងបរិស្ថាន ព្រមជាមួយការលើកកម្ពស់សមត្ថភាព ធនធានមនុស្សដើម្បីអាចជៀសផុតពីភាពក្រីក្រដោយខ្លួនឯងនាពេលអនាគត។

ឯកសារយុទ្ធសាស្ត្រគាំពារសង្គមនេះ បានរៀបចំចងក្រងតាមលំដាប់លំដោយ ដោយចាប់ផ្តើមពីការកំណត់និយមន័យ វិសាលភាពនៃក្របខណ្ឌការងារ និងទស្សនាទាននៃការគាំពារសង្គមនិងសំណាញ់សុវត្ថិភាពសង្គម និងការធ្វើបញ្ជីសារពើភ័ណ្ឌនិងបទពិសោធន៍នៃការងារគម្រោងសកម្មភាពគាំពារសង្គមនៅកម្ពុជាគ្រប់ប្រភេទដែលបានអនុវត្តកន្លងមក។ ក្របខណ្ឌច្បាប់គតិយុត្ត សន្ធិសញ្ញា និងអនុសញ្ញាអន្តរជាតិ ព្រមទាំងឯកសារយុទ្ធសាស្ត្រទាំងឡាយនៅកម្ពុជាដែលទាក់ទងនឹងការគាំពារសង្គមបានត្រូវលើកយកមកពិចារណាស្វែងយល់ពីទិដ្ឋភាពផ្នែកច្បាប់នៅក្នុងការរៀបចំយុទ្ធសាស្ត្រនេះ ក្នុងទិសដៅរក្សាបាននូវសកម្មភាពបំពេញបន្ថែមគ្នាទៅវិញទៅមក ជាមួយនឹងការប្រើប្រាស់ថវិកាដែលមានកម្រិតឲ្យមានប្រសិទ្ធភាព និងជៀសវាងការជាន់ភារកិច្ចនិងភាពច្រំដែលៗនៃការងារ។ ឯកសារនេះក៏បានធ្វើការសិក្សាវិភាគទៅលើទ្រង់ទ្រាយនិងប្រភេទហានិភ័យ និងឫសគល់នៃភាពក្រីក្រ និងភាពងាយរងគ្រោះ ដើម្បីលើកឡើងនូវគោលនយោបាយ វិធីសាស្ត្រ និងក្របខណ្ឌឧបករណ៍ឆ្លើយតប ឲ្យបានសមស្របនិងមានប្រសិទ្ធភាព ទៅតាមមុខសញ្ញានីមួយៗ។ ឯកសារនេះក៏បានបង្ហាញពីការងារគាំពារ

សង្គមដែលមានស្រាប់សម្រាប់ជនក្រីក្រនិងជនងាយរងគ្រោះនៅកម្ពុជា ព្រមទាំងបទពិសោធន៍ និងសកម្មភាពអនុវត្តការងារគាំពារសង្គមទាំងនៅកម្ពុជានិងទាំងនៅក្រៅប្រទេស។

យុទ្ធសាស្ត្រគាំពារសង្គមនេះបានកំណត់ជាចក្ខុវិស័យថា ប្រជាជនកម្ពុជាគ្រប់រូប ពិសេសជនក្រីក្រនិងជនងាយរងគ្រោះ នឹងបានទទួលផលប្រយោជន៍ ពីសំណាញ់សុវត្ថិភាពសង្គមនិងរបបសន្តិសុខសង្គមឲ្យកាន់តែប្រសើរឡើង ដែលជាផ្នែកនៃប្រព័ន្ធគាំពារសង្គមដ៏មានប្រសិទ្ធភាព សមស្របដែលអាចអនុវត្ត និងមាននិរន្តរភាព។ គោលបំណងចម្បងនៃយុទ្ធសាស្ត្រគាំពារសង្គមគឺ ជនក្រីក្រ និងជនងាយរងគ្រោះនៅកម្ពុជា នឹងទទួលការគាំពារកាន់តែប្រសើរឡើង ពីភាពក្រីក្ររ៉ាំរ៉ៃនិងភាពអត់ឃ្លាន ភាពខ្វះខាត វិបត្តិ និងមូលហេតុសង្គមនានា ព្រមទាំងទទួលបានប្រយោជន៍ពីការធ្វើវិនិយោគលើធនធានមូលធនមនុស្សរបស់ពួកគាត់។ គោលដៅចម្បងៗ នៃយុទ្ធសាស្ត្រជាតិគាំពារសង្គមរួមមាន ៖

- ឆ្លើយតបទៅនឹងតម្រូវការមូលដ្ឋានរបស់ជនក្រីក្រនិងជនងាយរងគ្រោះក្នុងស្ថានភាពរងគ្រោះអាសន្ន និងកលិយុគ
- កាត់បន្ថយភាពក្រីក្រនិងភាពងាយរងគ្រោះនៃកុមារនិងមាតា ព្រមទាំងបង្កើនការអភិវឌ្ឍធនធានមនុស្សរបស់ពួកគាត់
- ឆ្លើយតបទៅនឹងភាពខ្វះការងារ និងនិកម្មភាពដែលកើតមានឡើងតាមរដូវកាល និងផ្ដល់ឱកាសសម្រាប់ជនក្រីក្រនិងជនងាយរងគ្រោះ ដើម្បីលើកកម្ពស់ជីវភាពរស់នៅរបស់ពួកគាត់
- បង្កើនការថែទាំសុខភាពដែលអាចទទួលយកបានដល់ជនក្រីក្រនិងជនងាយរងគ្រោះ
- បង្កើនការគាំពារសង្គមសម្រាប់ជនងាយរងគ្រោះពិសេសមួយចំនួន។

ការសម្រេចឲ្យបានគោលដៅទាំងនេះ ទាមទារនូវការពង្រីកបន្ថែមនិងការធ្វើសុខដុមនីយកម្មលើអន្តរាគមន៍ការគាំពារសង្គមដែលមានស្រាប់ និងការចាប់អនុវត្តនូវកម្មវិធីថ្មី ដើម្បីបំពេញចន្លោះប្រហោងនៃការគាំពារសង្គម។ ក្នុងលក្ខណៈជាអាទិភាព កម្មវិធីសំណង់សាធារណៈដើម្បីផ្ដល់ឱកាសការងារនិងប្រាក់ចំណូលសម្រាប់ជនក្រីក្រនិងជនងាយរងគ្រោះ នឹងត្រូវពង្រីកជាបន្ត។ គម្រោងឧបត្ថម្ភសាច់ប្រាក់សម្រាប់គ្រួសារក្រីក្រដែលមានកូនច្រើន ដោយផ្ដោតលើការធ្វើឲ្យប្រសើរឡើងនូវអាហារូបត្ថម្ភនិងការសិក្សាអប់រំនឹងត្រូវអនុវត្តដើម្បីផ្ដល់ការគាំពារដល់កុមារពីផលប៉ះពាល់ក្នុងរយៈពេលខ្លីនៃកលិយុគនាពេលបច្ចុប្បន្ន និងការធ្វើឲ្យប្រសើរឡើងនូវការអភិវឌ្ឍធនធានមនុស្សក្នុងរយៈពេលវែង។

ការអនុវត្តអន្តរាគមន៍គាំពារសង្គម ជាភារកិច្ចនិងការទទួលខុសត្រូវនៃក្រសួងជំនាញ ស្ថាប័ននិងអាជ្ញាធរមូលដ្ឋានគ្រប់ថ្នាក់។ យុទ្ធសាស្ត្រជាតិគាំពារសង្គមនឹងបំពេញបន្ថែមលើកិច្ចខិតខំប្រឹងប្រែងរបស់ក្រសួងជំនាញ ក្នុងការសម្រេចឲ្យបាននូវគោលដៅតាមវិស័យ តាមរយៈការផ្ដល់នូវក្របខណ្ឌនៃ

សង្គមមានចរិតជាអន្តរវិស័យ និងទាមទារនូវការសម្របសម្រួលអន្តរក្រសួង និងស្ថាប័ននៃរាជរដ្ឋាភិបាល ដើម្បីជៀសវាងការត្រួតជាន់គ្នាជាលក្ខណៈវិស័យនិងតំបន់ភូមិសាស្ត្រ ក៏ដូចជាដើម្បីធ្វើសុខដុមនីយកម្មលើការអនុវត្តនីតិវិធី និងដើម្បីសម្របសម្រួលការប្រើប្រាស់ធនធានដែលទទួលបានពីថវិកាជាតិ និងដៃគូអភិវឌ្ឍ ប្រកបដោយប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធិ។ ប្រការនេះតម្រូវឲ្យមានការប្រាស្រ័យទាក់ទងដោយសកម្ម ជាមួយដៃគូអភិវឌ្ឍ វិស័យឯកជន និងសង្គមស៊ីវិល។

ដើម្បីអនុវត្តយុទ្ធសាស្ត្រជាតិគាំពារសង្គម រាជរដ្ឋាភិបាលកម្ពុជានឹងពិចារណាបន្ថែមទៀតនូវយន្តការនិងរចនាសម្ព័ន្ធសមស្របសម្រាប់ការសម្របសម្រួលលើការគាំពារសង្គម ដើម្បីផ្តល់ការគាំទ្រគោលនយោបាយ ការពិនិត្យតាមដាននិងវាយតម្លៃ ការគ្រប់គ្រងព័ត៌មាននិងចំណេះដឹង និងការកសាងសមត្ថភាព។ អាទិភាពចម្បងចំពោះមុខ គឺការរៀបចំស្ថាប័ន ការកសាងសមត្ថភាពស្ថាប័ននៅក្នុងយន្តការសម្របសម្រួលថ្នាក់កណ្តាលនិងថ្នាក់ក្រោមជាតិ និងការសម្របសម្រួលដោយមានតួនាទីជាក់លាក់ ព្រមទាំងរចនាសម្ព័ន្ធត្រួតពិនិត្យសម្រាប់ការបន្តយុទ្ធសាស្ត្រគាំពារសង្គម ក្នុងដំណាក់កាលមធ្យម និងវែង។ កម្មវិធីគាំពារសង្គមដែលកំពុងមានសកម្មភាព និងការសាកល្បងអនុវត្តសកម្មភាពសង្គមកិច្ចថ្មីៗនឹងកាន់តែមានសុខដុមនីយកម្ម និងត្រូវពិចារណាវាយតម្លៃធ្វើសមាហរណកម្មទៅក្នុងកម្មវិធីកម្រិតជាតិកាន់តែធំជាងមុន ក្នុងការអនុវត្តយុទ្ធសាស្ត្រគាំពារសង្គមក្នុងដំណាក់កាលមធ្យម និងវែង ដើម្បីនាំយកមកនូវគម្រោងការផ្សេងៗមួយចំនួនទៀត ឲ្យស្ថិតនៅក្រោមកម្មវិធីដែលមានលក្ខណៈចម្រុះមួយយ៉ាងហោចណាស់ក្នុងរាល់គោលដៅនីមួយៗនៃយុទ្ធសាស្ត្រ។

ក្នុងនាមក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ ខ្ញុំសូមសំដែងនូវការអរគុណយ៉ាងជ្រាលជ្រៅចំពោះការចូលរួមរបស់ឯកឧត្តម លោកជំទាវ លោក លោកស្រី ថ្នាក់ដឹកនាំ តំណាងក្រសួង ស្ថាប័ន និងភាគីដៃគូអភិវឌ្ឍនានា ក្នុងការរៀបចំចងក្រងយុទ្ធសាស្ត្រនេះចាប់តាំងពីដើមរហូតដល់ចប់ និងស្នើសុំការគាំទ្រ និងសហការជាបន្តទៀតនៅពេលអនុវត្តយុទ្ធសាស្ត្រនេះជាបន្តបន្ទាប់ ដើម្បីសម្រេចបានតាមគោលដៅអភិវឌ្ឍសង្គម-សេដ្ឋកិច្ច និងគោលដៅអភិវឌ្ឍសហស្សវត្សរ៍នៅកម្ពុជា។

រាជធានីភ្នំពេញ ថ្ងៃទី៣០ខែ មីនា ឆ្នាំ២០១១

**ឧបនាយករដ្ឋមន្ត្រី**

**ប្រធានក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ**

**យឹម ឆៃលី**

# មាតិកា

**ជំពូកទី១. សេចក្តីផ្តើម** ........ ៣
១.១ និយមន័យ ........ ៣
១.២ វិសាលភាពនៃយុទ្ធសាស្ត្រ ........ ៦
១.៣ ដំណើរការរៀបចំយុទ្ធសាស្ត្រ ........ ៩
១.៤ ផែនទីគោចរ ........ ១២
**ជំពូកទី២. ការគាំពារសង្គមក្នុងអាទិភាពមួយរបស់រាជរដ្ឋាភិបាល** ........ ១៥
២.១ ច្បាប់និងបទប្បញ្ញត្តិជាធរមាន ........ ១៥
២.២ យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី២និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ បច្ចុប្បន្នកម្ម ២០០៩-២០១៣ ........ ១៦
២.៣ សេចក្តីសម្រេចចិត្តនៃវេទិកាកិច្ចសហប្រតិបត្តិការអភិវឌ្ឍកម្ពុជាលើកទី២ ឆ្នាំ២០០៨ ១៨
២.៤ សេចក្តីសម្រេចនៃវេទិកាជាតិស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ........ ១៨
២.៥ ការឯកភាពជាលក្ខណៈអន្តរជាតិ ........ ១៩
**ជំពូកទី៣. ស្ថានភាពនៃភាពក្រីក្រ និងភាពងាយរងគ្រោះ** ........ ២៣
៣.១ ហានិភ័យ វិបត្តិ និងភាពងាយរងគ្រោះ ........ ២៥
៣.១.១ គ្រោះអាសន្ន និងវិបត្តិ ........ ២៦
៣.១.២ បញ្ហាអភិវឌ្ឍន៍មនុស្ស ........ ២៨
៣.១.៣ ភាពងាយរងគ្រោះទៅនឹងនិកម្មភាព និងអសន្តិសុខស្បៀង ........ ២៨
៣.១.៤ វិបត្តិផ្នែកសុខភាព ........ ៣០
៣.២ ក្រុមជនងាយរងគ្រោះ ........ ៣២
៣.២.១ ទារក និងកុមារ ........ ៣២
៣.២.២ នារី និងស្ត្រីក្នុងវ័យបន្តពូជ ........ ៣៣
៣.២.៣ ក្រុមជនងាយរងគ្រោះទៅនឹងនិកម្មភាព និងអសន្តិសុខស្បៀង ........ ៣៤
៣.២.៤ ក្រុមជនងាយរងគ្រោះផ្សេងទៀត ........ ៣៥
៣.៣ បញ្ហាដែលកើតឡើងពីការដោះស្រាយវិបត្តិរបស់ជនក្រីក្រ ........ ៣៧
៣.៤ តារាងសង្ខេប ........ ៣៨
**ជំពូកទី៤. កម្មវិធី ឬគម្រោងគាំពារសង្គមដែលមានស្រាប់សម្រាប់ជនក្រីក្រ និងជនងាយរងគ្រោះ** ........ ៤៥

៤.១ រចនាសម្ព័ន្ធស្ថាប័ននាពេលបច្ចុប្បន្នសម្រាប់ការគាំពារសង្គម ............................... ៤៥
៤.២ កម្មវិធី ឬគម្រោងដែលមានស្រាប់ក្នុងការផ្តល់សេវាគាំពារសង្គម ....................... ៤៧
៤.៣ ចន្លោះប្រហោង និងបញ្ហាប្រឈមក្នុងការផ្តល់សេវាគាំពារសង្គម............................ ៥៤
**ជំពូកទី៥. យុទ្ធសាស្ត្រជាតិគាំពារសង្គមសម្រាប់ជនក្រីក្រនិងជនងាយរងគ្រោះ** ........................ ៦៣
៥.១ ទស្សនវិស័យ ........................................................................................ ៦៣
៥.២ គោលបំណង ........................................................................................ ៦៤
៥.៣ យុទ្ធសាស្ត្ររួមដើម្បីសម្រេចបានគោលបំណង ........................................... ៦៤
៥.៤ គោលដៅ ........................................................................................ ៦៦
៥.៤.១ គោលដៅទី ១ ........................................................................ ៦៨
៥.៤.២ គោលដៅទី ២ ........................................................................ ៧០
៥.៤.៣ គោលដៅទី ៣ ........................................................................ ៧៤
៥.៤.៤ គោលដៅទី ៤ ........................................................................ ៧៧
៥.៤.៥ គោលដៅទី ៥ ........................................................................ ៧៩
**ជំពូកទី៦. ការសម្របសម្រួលលើការអនុវត្ត ការពិនិត្យតាមដាន និងវាយតម្លៃ យ.ជ.គ.ស.** ............ ៨៥
៦.១ ការសម្របសម្រួលលើការអនុវត្តយុទ្ធសាស្ត្រជាតិគាំពារសង្គម ............................ ៨៥
៦.១.១ ការត្រួតពិនិត្យគោលនយោបាយ ................................................... ៨៧
៦.១.២ ការពិនិត្យតាមដាន និងវាយតម្លៃ ................................................... ៨៧
៦.១.៣ ការគ្រប់គ្រងព័ត៌មាន និងចំណេះដឹង ស្តីពីការគាំពារសង្គម .................. ៨៩
៦.១.៤ ការកសាងសមត្ថភាពក្នុងកិច្ចគាំពារសង្គម ......................................... ៩០
៦.២ ការជ្រើសរើស និងការកំណត់អត្តសញ្ញាណអ្នកទទួលផល ................................. ៩១
៦.៣ តម្រូវការធនធានថវិកា ........................................................................ ៩៥
៦.៤ សកម្មភាពអាទិភាពសម្រាប់អនាគតដ៏ខ្លី ....................................................... ៩៦
**ឯកសារពិគ្រោះ** ........................................................................................ ១១៥

# រូបភាព


រូបភាពទី១. ការគាំពារសង្គម និងវិភាគទានទៅក្នុងការអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គម និងការឆ្លើយតបទៅនឹងគ្រោះមហន្តរាយ........................................................................................ ៥

រូបភាពទី២. វិសាលភាពនៃ យ.ជ.គ.ស. ដោយផ្តោតលើជនក្រីក្រ និងជនងាយរងគ្រោះ ........ ៧

រូបភាពទី៣. ដំណើរការជាលំដាប់ ឆ្ពោះទៅកាន់ការគាំពារសង្គមដ៏ស៊ីជម្រៅដូចមានចែងក្នុងទស្សនវិស័យក្នុងដំណាក់កាលវែងនៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ............ ៨

រូបភាពទី៤. ភាពក្រីក្ររាប់តាមចំនួនមនុស្ស ឆ្នាំ ១៩៩៤-២០០៧ ..................................... ២៣

រូបភាពទី៥. ភាពខុសគ្នានៃអត្រាភាពក្រីក្រតាមតំបន់ភូមិសាស្ត្រ ....................................... ២៤

រូបភាពទី៦. ភាពក្រីក្រ និងភាពងាយរងគ្រោះ ................................................................ ២៥

រូបភាពទី៧. ការផ្សារភ្ជាប់កិច្ចគាំពារសង្គមសម្រាប់កុមារ វិធីសាស្ត្រវដ្តជីវិត ........................ ៧២

រូបភាពទី៨. និន្នាការក្នុងការចំណាយលើកិច្ចការសង្គមទាំងមូល (គិតជាភាគរយនៃផលិតផលក្នុងស្រុកសរុប) ........................................................................................ ៩៥

# តារាង


តារាងទី១. ការសង្ខេបស្ដីពីដំណើរការពិភាក្សាពិគ្រោះយោបល់លើ យ.ជ.គ.ស ................... ៩

តារាងទី២. ហានិភ័យ វិបត្តិ កត្តាកំណត់នៃភាពងាយរងគ្រោះ និងក្រុមងាយរងគ្រោះ ........... ៣៨

តារាងទី៣. ទិដ្ឋភាពនៃអន្តរាគមន៍ជាលក្ខណៈកិច្ចគាំពារសង្គមរបស់រាជរដ្ឋាភិបាល នាពេលបច្ចុប្បន្ន ........................................................................................ ៥០

តារាងទី៤. ចន្លោះប្រហោង និងបញ្ហាប្រឈមនៅក្នុងកិច្ចអន្តរាគមន៍ដែលមានស្រាប់ ............ ៥៥

តារាងទី៥. គោលដៅរបស់ យ.ជ.គ.ស. និងការផ្សារភ្ជាប់ជាមួយគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា ........................................................................................ ៦៦

តារាងទី៦. យន្តការកំណត់គោលដៅសម្រាប់ យ.ជ.គ.ស. ........................................ ៩៤

តារាងទី៧. សកម្មភាពជាអាទិភាពក្នុងដំណាក់កាលខ្លីរបស់ យ.ជ.គ.ស. និងការប៉ាន់ស្មានចំណាយ ........................................................................................ ៩៩

តារាងទី៨. ម៉ាទ្រិចនៃលទ្ធផលសម្រាប់ យ.ជ.គ.ស ........................................................ ១០៨


# ប្រអប់


ប្រអប់ទី១. មាត្រាមួយចំនួននៃរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ ទាក់ទងនឹងការគាំពារសង្គម ............. ១៥

ប្រអប់ទី២. អនុសាសន៍ដ៏ខ្ពង់ខ្ពស់នៃសម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ........................................................ ១៩

# អក្សរកាត់

| | | |
|---|---|---|
| ក.ក.ជ. | : | ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ |
| គ.អ.ស.ក. | : | គោលដៅអភិវឌ្ឍន៍សហស្សវត្សកម្ពុជា<br>Cambodian Mellenium Development Goals |
| យ.ជ.គ.ស. | : | យុទ្ធសាស្ត្រជាតិគាំពារសង្គមសម្រាប់ជនក្រីក្រ និងជនងាយរងគ្រោះ<br>National Social Protection Strategy |
| ADB | : | Asian Development Bank (ធនាគារអភិវឌ្ឍន៍អាស៊ី) |
| AusAID | : | Australian Agency for International Development<br>(ទីភ្នាក់ងារអូស្ត្រាលី សម្រាប់ការអភិវឌ្ឍអន្តរជាតិ) |
| CDCF | : | Cambodian Development Cooperation Forum<br>(វេទិកាកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជា) |
| DFID | : | UK Department for International Development<br>(នាយកដ្ឋានអភិវឌ្ឍន៍អន្តរជាតិនៃចក្រភពអង់គ្លេស) |
| GDCC | : | Government–Development Parner Coordination Committee<br>(គណៈកម្មាធិការសម្របសម្រួលរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍) |
| GIZ | : | Deutsche Gesellschaft für Internationale Zusammenarbeit<br>(ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិអាល្លឺម៉ង់) |
| IFPRI | : | International Food Policy Research Institute<br>(វិទ្យាស្ថានស្រាវជ្រាវគោលនយោបាយស្បៀងអន្តរជាតិ) |
| ILO | : | International Labour Organization (អង្គការពលកម្មអន្តរជាតិ) |
| JFPR | : | Japan Fund for Poverty Reduction<br>(មូលនិធិនៃប្រទេសជប៉ុនសម្រាប់ការកាត់បន្ថយភាពក្រីក្រ) |
| ODA | : | Official Development Assistance (ជំនួយអភិវឌ្ឍន៍ផ្លូវការ) |
| OECD | : | Organisation for Economic Co-operation and Development<br>(អង្គការអភិវឌ្ឍន៍ និងសហប្រតិបត្តិការសេដ្ឋកិច្ច) |
| SPF | : | Social Protection Floor (ការគាំពារសង្គមមូលដ្ឋាន) |
| SPFI | : | Social Protection Floor Initiative |

(គំនិតផ្តួចផ្តើមសម្រាប់ការគាំពារសង្គមមូលដ្ឋាន)

| | | |
|---|---|---|
| UNAIDS | : | Joint United Nations Programme on HIV/AIDS (កម្មវិធីនៃអង្គការសហប្រជាជាតិស្តីពីជំងឺអេដស៍) |
| UNDAF | : | United Nations Development Assistance Framework (ក្របខណ្ឌជំនួយអភិវឌ្ឍន៍នៃអង្គការសហប្រជាជាតិ) |
| UNESCO | : | United Nations Educational, Scientific and Cultural Organization (អង្គការសហប្រជាជាតិសម្រាប់ការអប់រំ វិទ្យាសាស្រ្ត និងវប្បធម៌) |
| UNICEF | : | United Nations Children's Fund (មូលនិធិអង្គការសហប្រជាជាតិសម្រាប់កុមារ) |
| USAID | : | United States Agency for International Development (ទីភ្នាក់ងារនៃសហរដ្ឋអាមេរិក សម្រាប់ការអភិវឌ្ឍអន្តរជាតិ) |
| WB | : | World Bank (ធនាគារពិភពលោក) |
| WFP | : | World Food Programme (កម្មវិធីស្បៀងអាហារពិភពលោកនៃអង្គការសហប្រជាជាតិ) |
| WHO | : | World Health Organization (អង្គការសុខភាពពិភពលោក) |

# ខ្លឹមសារសង្ខេប
# យុទ្ធសាស្ត្រជាតិគាំពារសង្គមសម្រាប់ជនក្រីក្រ
# និងជនងាយរងគ្រោះ

**យុទ្ធសាស្ត្រជាតិគាំពារសង្គមសម្រាប់ជនក្រីក្រនិងជនងាយរងគ្រោះ** (យ.ជ.គ.ស.) ជាយុទ្ធសាស្ត្របំពេញបន្ថែមដល់យុទ្ធសាស្ត្រនិងផែនការតាមវិស័យដទៃទៀតនៃក្រសួងស្ថាប័នពាក់ព័ន្ធ ដែលជាប់ទាក់ទងដោយផ្ទាល់ ឬដោយប្រយោលទៅនឹងការគាំពារសង្គម។ ឯកសារនេះមានភាពស្របគ្នា ព្រមទាំងធ្វើឲ្យមានសកម្មភាពប្រតិបត្តិការទៅលើអាទិភាពនានា ដែលមានចែងនៅក្នុងឯកសារយុទ្ធសាស្ត្រចតុកោណ និងឯកសារផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្ម ឆ្នាំ២០០៩-២០១៣។

**យ.ជ.គ.ស.** បានរៀបចំឡើងតាមរយៈដំណើរការពិភាក្សាពិគ្រោះយោបល់ដោយមានការចូលរួមយ៉ាងសកម្មពីតំណាងក្រសួងស្ថាប័នពាក់ព័ន្ធនៃរាជរដ្ឋាភិបាលនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ព្រមទាំងដៃគូអភិវឌ្ឍ និងសង្គមស៊ីវិលមួយចំនួន។ នាឱកាសនៃកិច្ចប្រជុំវេទិកាសហប្រតិបត្តិការអភិវឌ្ឍកម្ពុជាលើកទី២ កាលពីថ្ងៃទី៣-៤ ខែធ្នូ ឆ្នាំ២០០៨ រាជរដ្ឋាភិបាលកម្ពុជានិងដៃគូអភិវឌ្ឍបានព្រមព្រៀងរៀបចំកិច្ចការវិភាគទូទៅ ដើម្បីកំណត់វិសាលភាពនៃសំណាញ់សុវត្ថិភាពសង្គមដែលមានស្រាប់ និងកំណត់ទិសដៅគោលនយោបាយសម្រាប់បង្កើតសំណាញ់សុវត្ថិភាពសង្គមមួយ ដែលមានលក្ខណៈចម្រុះនិងជាប្រព័ន្ធ និងស្របតាមស្ថានភាពសង្គមសេដ្ឋកិច្ចនៅកម្ពុជា។ ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ (**ក.ក.ជ.**) បានទទួលភារកិច្ចធានាឲ្យមានប្រសិទ្ធភាព ក្នុងយន្តការសម្របសម្រួលអន្តរក្រសួងដោយមានការចូលរួមពីក្រសួងស្ថាប័នពាក់ព័ន្ធ។ នៅខែកុម្ភៈ ឆ្នាំ២០០៩ **ក.ក.ជ.**បានបង្កើតក្រុមការងារបណ្តោះអាសន្នស្តីពីបណ្តាញសុវត្ថិភាពសង្គម ដែលមានសមាសភាពចូលរួមដោយក្រសួងស្ថាប័នពាក់ព័ន្ធនៃរាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍ ដើម្បីរៀបចំឯកសារទស្សនាទានបណ្តាញសុវត្ថិភាពសង្គមនិងបញ្ជីសារពើភណ្ឌ។ នៅខែកក្កដា ឆ្នាំ២០០៩ ក.ក.ជ.បានរៀបចំវេទិកាជាតិស្តីពីសន្តិសុខស្បៀងនិងអាហារូបត្ថម្ភក្រោមប្រធានបទសំណាញ់សុវត្ថិភាពសង្គមនៅកម្ពុជា ហើយបានទទួលភារកិច្ចបន្តការសម្របសម្រួលរៀបចំបង្កើតយុទ្ធសាស្ត្រជាតិគាំពារសង្គម សម្រាប់ជនក្រីក្រ និងជនងាយរងគ្រោះ។ កិច្ចពិភាក្សាពិគ្រោះយោបល់ និងទស្សនកិច្ចសិក្សាមួយចំនួនត្រូវបានរៀបចំឡើងជាបន្តបន្ទាប់ដើម្បីពិនិត្យសាជាថ្មីទៅលើជម្រើសនៃគោលនយោបាយគាំពារសង្គម ដោយផ្តោតទៅលើអន្តរាគមន៍

សង្គមកិច្ចមួយចំនួន រួមមានការឧបត្ថម្ភសាច់ប្រាក់ (ដោយផ្តោតលើកង្វះអាហារូបត្ថម្ភមាតានិងកុមារ កម្មវិធីសំណង់សាធារណៈ[១] ការសិក្សា និងពលកម្មកុមារ។ នៅដើមខែមិថុនា ឆ្នាំ ២០១០ **យ.ជ.គ.ស.** ត្រូវបានដាក់បង្ហាញនៅក្នុងឱកាសនៃវេទិកាសហប្រតិបត្តិការអភិវឌ្ឍកម្ពុជាលើកទី៣ ដើម្បីស្នើសុំការគាំទ្រនិងសហប្រតិបត្តិការ។ ការវិភាគស៊ីជម្រៅនិងការគណនាថវិកាចំណាយលម្អិតនឹងជាការងារចាំបាច់បន្តទៅទៀត សម្រាប់ការលើកគម្រោងនៃកម្មវិធីជាក់លាក់ផ្សេងៗនៅក្នុងយុទ្ធសាស្ត្រ។

ឯកសារ **យ.ជ.គ.ស.**បានរៀបចំឡើងដោយចែកចេញជា៦ជំពូក។ នៅក្នុងជំពូកទី១ ស្តីពី "**សេចក្តីផ្តើម**" ឯកសារនេះបរិយាយពីទស្សនាទាននិងនិយមន័យនៃការគាំពារសង្គម សំណាញ់សុវត្ថិភាពសង្គម និងវាក្យសព្ទផ្សេងៗទៀតដែលទាក់ទងនឹងការគាំពារសង្គម ព្រមទាំងការកំណត់វិសាលភាពនៃគោលនយោបាយ សកម្មភាព និងដំណើរការរៀបចំយុទ្ធសាស្ត្រនេះ។ **ការគាំពារសង្គម** គឺជាការឧបត្ថម្ភដែលផ្តល់ទៅដល់ប្រជាជន ដើម្បីឆ្លើយតបទៅនឹងបញ្ហាជាឫសគល់នៃភាពក្រីក្រនិងភាពងាយរងគ្រោះ ព្រមទាំងដើម្បីបង្កើនការអភិវឌ្ឍមូលធនមនុស្សក្នុងពេលជាមួយគ្នា។ ការគាំពារសង្គមរួមបញ្ចូលនូវការរៀបចំនិងប្រើប្រាស់ឧបករណ៍ជាច្រើនប្រភេទ ដើម្បីការពារបុគ្គល គ្រួសារ និងសហគមន៍ ពីប្រភេទផ្សេងៗនៃផលវិបាកផ្នែកហិរញ្ញវត្ថុ សេដ្ឋកិច្ច និងសង្គម ដែលកើតឡើងពីហានិភ័យឬវិបត្តិ ដើម្បីជួយពួកគាត់ឲ្យចាកផុតពីភាពក្រីក្រ។ អន្តរាគមន៍នៃការគាំពារសង្គមក្នុងកម្រិតអប្បបរមា រួមមានការធានារ៉ាប់រងសង្គម គោលនយោបាយទីផ្សារពលកម្ម បណ្តាញសុវត្ថិភាពសង្គម និងសេវាកម្មសុខុមាលភាពសង្គម។

ជំពូកទី២ ស្តីពី "**ការគាំពារសង្គមក្នុងអាទិភាពមួយរបស់រាជរដ្ឋាភិបាល**" លើកឡើងពីភាពចាំបាច់ និងសារៈសំខាន់នៃការរៀបចំយុទ្ធសាស្ត្រនេះ ដោយឈរលើមូលដ្ឋាននៃរដ្ឋធម្មនុញ្ញ ឯកសារយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី២ ដើម្បីកំណើន ការងារ សមធម៌ និងប្រសិទ្ធភាព នៅកម្ពុជា ផែនការយុទ្ធ-សាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្ម២០០៩-២០១៣ ក៏ដូចជាលិខិតបទដ្ឋានគតិយុត្តនិងអនុសញ្ញាអន្តរជាតិជាច្រើន។

"**ស្ថានភាពនៃភាពក្រីក្រនិងភាពងាយរងគ្រោះ**" ត្រូវបានលើកឡើងនៅក្នុងជំពូកទី៣ ដែលបង្ហាញពីស្ថានភាព ប្រភេទ និងការវិនិច្ឆ័យទៅលើភាពក្រីក្រនិងភាពងាយរងគ្រោះនៅកម្ពុជា ព្រមទាំងការវិភាគទៅលើប្រភេទនៃហានិភ័យ គ្រោះអាសន្ននិងវិបត្តិដែលបានកើតឡើង និងដែលអាចនឹងកើតឡើងនា

---

[១] កម្មវិធីសំណង់សាធារណៈ សំដៅលើគ្រប់សកម្មភាពទាំងអស់ដែលពាក់ព័ន្ធនឹងការងារសាងសង់ ជួសជុល ថែទាំសំណង់ ហេដ្ឋារចនាសម្ព័ន្ធរូបវន្តផង និងការបង្កើតការងារផង។

ពេលអនាគត ដោយយោងលើឯកសារស្រាវជ្រាវនិងវិភាគនានា និងការអង្កេតសង្គមកិច្ចសេដ្ឋកិច្ច ឆ្នាំ ២០០៨-២០០៩។ ជំពូកនេះក៏បានលើកឡើងពីផលប៉ះពាល់ជាអវិជ្ជមានដោយសារវិបត្តិសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសកល និងការប្រែប្រួលអាកាសធាតុ មកលើជីវភាពរស់នៅរបស់ប្រជាជន។

ជំពូកទី៤ នៃឯកសារនេះ លើកឡើងពី "**កម្មវិធីឬគម្រោងគាំពារសង្គមដែលមានស្រាប់ សម្រាប់ជនក្រីក្រ និងជនងាយរងគ្រោះ**" ដែលរៀបរាប់ពីរចនាសម្ព័ន្ធស្ថាប័ន អាណត្តិការងារ គោលនយោបាយ យុទ្ធសាស្ត្រតាមវិស័យ និងកម្មវិធីសកម្មភាពអន្តរាគមន៍របស់ក្រសួងស្ថាប័ននីមួយៗរបស់រាជរដ្ឋាភិបាល ក្នុងការផ្តល់សេវាគាំពារសង្គមជូនប្រជាជន។ សំណាញ់សុវត្ថិភាពសង្គមក្រៅផ្លូវការ និងសកម្មភាពអន្តរាគមន៍របស់អង្គការសង្គមស៊ីវិល ក៏បានលើកយកមកបង្ហាញដោយសង្ខេបក្នុងឯកសារនេះដែរ ដើម្បីជាមូលដ្ឋានក្នុងការរៀបចំយុទ្ធសាស្ត្រឲ្យមានសង្គតិភាព។ ជំពូកទី៤ ដើរតួនាទីជាស្ពានផ្សារភ្ជាប់នូវសកម្មភាព និងអន្តរាគមន៍គាំពារសង្គមដែលមានស្រាប់ ជាមួយនឹងស្ថានភាពនៃភាពក្រីក្រនិងភាពងាយរងគ្រោះរបស់ប្រជាជន ដើម្បីបង្ហាញនូវគម្លាតនិងចន្លោះប្រហោងក្នុងការអនុវត្ត ដែលត្រូវបំពេញបន្ថែមនៅពេលអនាគត។ ប្រទេសកម្ពុជាបានអនុវត្តគម្រោងនិងកម្មវិធីបណ្តាញសុវត្ថិភាពសង្គមជាច្រើន ដែលភាគច្រើនជាការផ្តល់ហិរញ្ញប្បទានពីប្រភពខាងក្រៅ នៅក្នុងការធ្វើសមាហរណកម្មនិងការស្តារឡើងវិញ ដើម្បីកែលម្អសន្តិសុខស្បៀងនិងជីវភាពជូនប្រជាជនក្រីក្រ និងដើម្បីឆ្លើយតបទៅនឹងស្ថានភាពបន្ទាន់ អស់រយៈពេលជាង២០ឆ្នាំមកហើយ។ ជោគជ័យជាច្រើន ជាពិសេសនៅក្នុងការផ្តល់ជូនអ្នកទទួលផលក្នុងចំនួនដ៏ច្រើន និងក្នុងការបង្កើនលទ្ធភាពទទួលបាននូវសេវាកម្ម ស្បៀងអាហារ និងសន្តិសុខនៃការរកប្រាក់ចំណូលរួមមាន ៖

- **ការចែកចាយស្បៀង** ទៅតាមតំបន់អសន្តិសុខស្បៀង ការផ្តល់អាហារនៅសាលារៀន របបស្បៀងយកទៅផ្ទះ និងកម្មវិធីស្បៀងពលកម្ម បានផ្តល់ជាមូលដ្ឋានក្នុងការឆ្លើយតបទៅនឹងអសន្តិសុខស្បៀង ភាពក្រីក្ររ៉ាំរ៉ៃ និងក្នុងករណីខ្លះ បញ្ហាកង្វះអាហារូបត្ថម្ភ។
- **អាហារូបករណ៍** បានផ្តល់ជាមូលដ្ឋានដោះស្រាយស្ថានភាពក្រីក្រ ចំពោះកុមារដែលពេញវ័យចូលរៀន។
- **កម្មវិធីសំណង់សាធារណៈ** បានផ្តល់ជាមូលដ្ឋានដល់ការឆ្លើយតបទៅនឹងបញ្ហាអសន្តិសុខស្បៀង ភាពខ្វះការងារ និងភាពក្រីក្ររ៉ាំរ៉ៃ នៃប្រជាជនដែលពេញវ័យការងារ។
- **មូលនិធិសមធម៌សុខភាព និងគម្រោងការធានារ៉ាប់រងសុខភាពនៅសហគមន៍** បានផ្តល់ជាមូលដ្ឋានក្នុងការគាំពារសុខភាពសម្រាប់ជនក្រីក្រ។
- **សេវាកម្មសុខុមាលភាពសង្គមដល់ក្រុមជនងាយរងគ្រោះពិសេស** ដូចជាជនពិការ ចាស់ជរា កុមារកំព្រា ...។ល។

- កម្មវិធីផ្សេងៗទៀតមួយចំនួនដែលជាប្រពៃណី និងវប្បធម៌នៃការចែករំលែកធនធាន សម្រាប់ **បុណ្យហោតុមនុស្សធម៌។**

ប៉ុន្តែកម្ពុជាពុំទាន់មានបណ្តាញសុវត្ថិភាពសង្គមដែលមានប្រសិទ្ធភាព និងមានលក្ខណៈចម្រុះ និងជាប្រព័ន្ធនៅឡើយ។ អន្តរាគមន៍ភាគច្រើននៅមានភាពរាយប៉ាយនិងមានលក្ខណៈបណ្តោះអាសន្ន ហើយមានភាពពឹងផ្អែកខ្លាំងទៅលើប្រភពហិរញ្ញប្បទានពីស្ថាប័នផ្តល់ជំនួយ និងវិភាគទានជាលក្ខណៈបុគ្គល។ វិសាលភាពនៃកម្មវិធីគាំពារសង្គមដែលមានស្រាប់សម្រាប់ជនក្រីក្រនិងជនងាយរងគ្រោះនៅមានកម្រិតបំផុត ហើយសកម្មភាពទាំងនោះពុំបានផ្តោតខ្លាំងទៅលើតំបន់ដែលមានភាពក្រីក្របំផុតទេ នៅក្នុងកិច្ចខិតខំប្រឹងប្រែងដែលមានភាពបែកខ្ញែកពីគ្នា ដោយសារការសម្របសម្រួលរវាងក្រសួងនិងស្ថាប័នដែលចូលរួមពាក់ព័ន្ធនៅមានកម្រិត។

ផ្អែកលើមូលដ្ឋាននៃការវិភាគស្តីពីក្របខណ្ឌផ្នែកច្បាប់នៃការគាំពារសង្គមនៅកម្ពុជា នៅក្នុងជំពូកទី២ និងស្ថានភាពនៃភាពក្រីក្រនិងភាពងាយរងគ្រោះ នៅក្នុងជំពូកទី៣ ព្រមទាំងអន្តរាគមន៍គាំពារសង្គមដែលមានស្រាប់ និងចន្លោះប្រហោងក្នុងការអនុវត្ត នៅក្នុងជំពូកទី៤ ជំពូកទី៥ ស្តីពី **"យុទ្ធសាស្ត្រជាតិគាំពារសង្គមសម្រាប់ជនក្រីក្រ និងជនងាយរងគ្រោះ"** នឹងបកស្រាយជាពិស្តារអំពីអភិក្រម ទស្សនវិស័យ គោលបំណង និងគោលដៅនៃ **យ.ជ.គ.ស**។ យុទ្ធសាស្ត្រជាតិគាំពារសង្គមសម្រាប់ជនក្រីក្រ និងជនងាយរងគ្រោះដ៏មានប្រសិទ្ធភាពមួយ ទាមទារនូវតុល្យភាពរវាងអភិក្រមបីយ៉ាងដូចខាងក្រោម ៖

- ការទ្រទ្រង់ដល់ជនក្រីក្របំផុតនិងជនដែលងាយរងគ្រោះបំផុត ដែលពុំអាចមានលទ្ធភាពជួយខ្លួនឯង **តាមរយៈសេវាកម្ម និងការឧបត្ថម្ភសង្គម**។
- **ការកាត់បន្ថយផលប៉ះពាល់នៃហានិភ័យ** ដែលអាចនឹងនាំទៅរកយុទ្ធសាស្ត្រដោះស្រាយដែលមានលក្ខណៈអវិជ្ជមាន។
- ការទ្រទ្រង់ដល់ជនក្រីក្រ ឲ្យបានឆ្លងផុតពីភាពក្រីក្រ តាមរយៈ**ការកសាងមូលធនមនុស្ស និងការពង្រីកកាលានុវត្តភាព** របស់ពួកគាត់។

ទស្សនវិស័យទូលំទូលាយនៃ **យ.ជ.គ.ស.** រួមបញ្ចូលគម្រោងការគាំពារសង្គមដោយមាន**នាគទាន** (ការធានារ៉ាប់រងសង្គម) សម្រាប់និយោជិតនៃវិស័យឯកជននិងមន្ត្រីរាជការស៊ីវិល ហើយសំដៅឆ្ពោះទៅកាន់ការអភិវឌ្ឍមនុស្សក្នុងកម្រិតខ្ពស់មួយ ក៏ដូចជាជម្រើសនិងកាលានុវត្តភាពដ៏សមស្របសម្រាប់ប្រជាជនកម្ពុជាគ្រប់រូប ៖ "ប្រជាជនកម្ពុជារាល់រូប ពិសេស**ជនក្រីក្រ និងជនងាយរងគ្រោះ** នឹងបាន

ទទួលផលប្រយោជន៍ពីបណ្ដាញសុវត្ថិភាពសង្គម និងរបបសន្តិសុខសង្គម ឲ្យកាន់តែប្រសើរឡើង ដែលជាផ្នែកនៃប្រព័ន្ធគាំពារសង្គមដ៏មានប្រសិទ្ធភាពសមស្របដែលអាចអនុវត្តនិងមាននិរន្តរភាព"។

គោលបំណងក្នុងដំណាក់កាលមធ្យមនៃ**យ.ជ.គ.ស.**គឺ ៖ **"ជនក្រីក្រ និងជនងាយរងគ្រោះកម្ពុជា នឹងទទួលការគាំពារកាន់តែប្រសើរឡើងពីភាពក្រីក្ររ៉ាំរ៉ៃ ភាពអត់ឃ្លាន វិបត្តិ ភាពខ្វះខាតនិងមូលហេតុសង្គម និងទទួលបានប្រយោជន៍ពីការធ្វើវិនិយោគលើធនធានមូលធនមនុស្សរបស់ពួកគាត់"**។

ក្នុងក្របខណ្ឌឆ្ពោះទៅកាន់ឆ្នាំគោលដៅ២០១៥ **យ.ជ.គ.ស.**នឹងផ្សារភ្ជាប់ស្ថានភាពដែលមានស្រាប់នាពេលបច្ចុប្បន្ន ជាមួយនឹងការរៀបចំគោលដៅដែលមានលក្ខណៈចម្រុះនិងជាប្រព័ន្ធ និងឆ្ពោះទៅកាន់ការផ្តល់ជូនដល់ប្រជាជនក្រីក្រនិងងាយរងគ្រោះ នូវការគាំពារឲ្យកាន់តែប្រសើរឡើងពីភាពក្រីក្រ និងការវិនិយោគលើធនធានមនុស្ស។ ដើម្បីសម្រេចបានការផ្សារភ្ជាប់នេះ **យ.ជ.គ.ស.**បានរៀបចំជំហានមួយចំនួនដូចខាងក្រោម ៖

- ជំរុញឲ្យមានការបញ្ចូលគ្នានៃកម្មវិធីដែលគ្របដណ្តប់លើ ភាពក្រីក្ររ៉ាំរ៉ៃ និងភាពក្រីក្រដែលទើបនឹងកើតឡើង ក៏ដូចជាភាពអត់ឃ្លាន ព្រមទាំងជួយលើកកម្ពស់មូលធនមនុស្ស។
- ពង្រឹងការសម្របសម្រួល ការពង្រីក និងការធ្វើសុខដុមនីយកម្មលើអន្តរាគមន៍ដែលមានស្រាប់ ដើម្បីផ្សារភ្ជាប់ប្រភពសំខាន់នៃភាពងាយរងគ្រោះទៅនឹងកម្មវិធីដែលមានស្រាប់។
- វាយតម្លៃដើម្បីធ្វើការកែលម្អក្នុងករណីចាំបាច់ លើយន្តការកម្មវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រដែលមានស្រាប់នាពេលបច្ចុប្បន្ន។
- ពង្រីកវិសាលភាពនៃអន្តរាគមន៍មួយចំនួនដែលកំពុងតែដំណើរការ ដើម្បីបង្កើនឥទ្ធិពល និងប្រសិទ្ធភាព។
- អនុវត្តសាកល្បង វាយតម្លៃ និងពង្រីក ដោយផ្អែកលើប្រសិទ្ធភាពនិងនិរន្តរភាពនូវប្រភេទកម្មវិធីថ្មី ដើម្បីបំពេញចន្លោះប្រហោងនៃកិច្ចគាំពារសង្គមដែលមានស្រាប់សម្រាប់ជនក្រីក្រ និងងាយរងគ្រោះ។

គោលដៅចម្បងៗនៃ **យ.ជ.គ.ស.** រួមមាន ៖

- ជនក្រីក្រនិងជនងាយរងគ្រោះ ទទួលបានការគាំទ្រដែលរួមមានស្បៀង អនាម័យ ទឹក និងជម្រក ។ល។ ដើម្បីបំពេញតាមតម្រូវការរបស់ពួកគាត់ ក្នុងពេលវេលាមានគ្រោះអាសន្ននិងវិបត្តិ។

- ជនក្រីក្រ កុមារ និងមាតាងាយរងគ្រោះ ទទួលបានផលប្រយោជន៍ពីសំណាញ់សុវត្ថិភាពសង្គមដើម្បីកាត់បន្ថយភាពក្រីក្រនិងអសន្តិសុខស្បៀង និងពង្រឹងការអភិវឌ្ឍមូលធនមនុស្សតាមរយៈការបង្កើនគុណភាពអាហារូបត្ថម្ភ សុខភាពមាតានិងកុមារ ការលើកកម្ពស់ការអប់រំ និង ការលុបបំបាត់ពលកម្មកុមារ ជាពិសេសទម្រង់ធ្ងន់ធ្ងរ។
- ជនក្រីក្រនិងជនងាយរងគ្រោះ ដែលពេញវ័យធ្វើការងារ ទទួលបានផលប្រយោជន៍ពីកាលានុវត្តភាពការងារ ដើម្បីធានាឲ្យមានប្រាក់ចំណូល ស្បៀង និងមានការងារធ្វើ ព្រមទាំងចូលរួមក្នុងការកសាងធនធានរូបវន្ត និងធនធានហេដ្ឋារចនាសម្ព័ន្ធសង្គមដែលមាននិរន្តរភាព។
- ជនក្រីក្រនិងជនងាយរងគ្រោះ ទទួលបានការថែរក្សាសុខភាពដែលមានគុណភាព និងដែលអាចទទួលប្រើបាន និងការគាំពារផ្នែកហិរញ្ញវត្ថុពេលមានជំងឺ។
- ក្រុមជនងាយរងគ្រោះពិសេស រួមមានក្មេងកំព្រា ចាស់ជរា ស្ត្រីជាមេគ្រួសារ ជនពិការ ជនផ្ទុកមេរោគអេដស៍ ឬអ្នកជំងឺរបេង ។ល។ ទទួលបានការគាំទ្រជាប្រាក់ចំណូល សម្ភារៈ និងចិត្តសាស្ត្រសង្គម ព្រមទាំងការថែទាំសង្គមគ្រប់គ្រាន់។

ជំពូកទី៦នៃឯកសារនេះ លើកឡើងពី "**ការសម្របសម្រួលលើការអនុវត្ត ការពិនិត្យតាមដាន និងវាយតម្លៃ យ.ជ.គ.ស.**"។ ជំពូកនេះសង្កត់ធ្ងន់លើការរៀបចំយន្តការសម្របសម្រួល ពិនិត្យតាមដាន និងវាយតម្លៃលើការអនុវត្ត**យ.ជ.គ.ស.** ដោយមានការចូលរួមពីគ្រប់ស្ថាប័នពាក់ព័ន្ធ ព្រមទាំងតម្រូវការធនធានថវិកាសម្រាប់ការអនុវត្ត **យ.ជ.គ.ស.** ក្នុងដំណាក់កាលមធ្យម។ ការអនុវត្តអន្តរាគមន៍គាំពារសង្គមជាភារកិច្ចនិងជាការទទួលខុសត្រូវនៃក្រសួងស្ថាប័នជំនាញ និងអាជ្ញាធរមូលដ្ឋាន។ យុទ្ធសាស្ត្រនេះមានគោលបំណងបំពេញបន្ថែមនូវកិច្ចខិតខំប្រឹងប្រែងរបស់ក្រសួងជំនាញ ក្នុងការសម្រេចឲ្យបាននូវគោលដៅតាមវិស័យពាក់ព័ន្ធនឹងការគាំពារសង្គម តាមរយៈការផ្តល់នូវ**ក្របខណ្ឌនៃការអនុវត្តប្រកបដោយនិរន្តរភាព ប្រសិទ្ធភាព និងភាពសក្តិសិទ្ធិ**។ កម្មវិធីភាគច្រើននៃយុទ្ធសាស្ត្រគាំពារសង្គម មានលក្ខណៈអន្តរវិស័យ និងទាមទារនូវការសម្របសម្រួលជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ ដើម្បីជៀសវាងការត្រួតជាន់គ្នាជាលក្ខណៈវិស័យនិងតំបន់ភូមិសាស្ត្រ ក៏ដូចជាដើម្បីធ្វើ**សុខដុមនីយកម្មលើនីតិវិធីនៃការអនុវត្ត** និងដើម្បីសម្របសម្រួលលើការប្រើប្រាស់ធនធានថវិកាប្រកបដោយប្រសិទ្ធភាព និងភាពសក្តិសិទ្ធិ។ ប្រការនេះតម្រូវឲ្យមាន**ការប្រាស្រ័យទាក់ទងដោយសកម្ម** ជាមួយដៃគូអភិវឌ្ឍនិងសង្គមស៊ីវិល និង**ការគ្រប់គ្រងនិងចែកចាយពត៌មាន**។ **ការកសាងសមត្ថភាពស្ថាប័ន** នៅក្នុងយន្តការសម្របសម្រួលថ្នាក់កណ្តាល និងស្ថាប័នពាក់ព័ន្ធនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ នឹងជាអាទិភាពចម្បងសម្រាប់អនាគតឆាប់ៗខាងមុខនេះ រួមមានការរៀបចំស្ថាប័ន និងការសម្របសម្រួលដោយមានតួនាទីជាក់លាក់ ព្រមទាំងរចនាសម្ព័ន្ធពិនិត្យតាមដាន និងវាយតម្លៃលើការអនុវត្ត **យ.ជ.គ.ស.** ក្នុងដំណាក់កាលមធ្យម និងវែង។

# ជំពូកទី១

# សេចក្តីផ្តើម

# ជំពូកទី១
# សេចក្តីផ្តើម

## ១.១. និយមន័យ

**ការគាំពារសង្គម** គឺជាការឧបត្ថម្ភដែលផ្តល់ទៅដល់ប្រជាជន ដើម្បីឆ្លើយតបទៅនឹងបញ្ហាជាឫសគល់នៃភាពក្រីក្រនិងភាពងាយរងគ្រោះ ព្រមទាំងដើម្បីបង្កើនការអភិវឌ្ឍធនធានមនុស្សក្នុងពេលជាមួយគ្នា។ ការគាំពារសង្គមរួមបញ្ចូលនូវការរៀបចំ និងប្រើប្រាស់ឧបករណ៍ជាច្រើនប្រភេទ ដើម្បីការពារបុគ្គល គ្រួសារ និងសហគមន៍ ពីប្រភេទផ្សេងៗនៃផលវិបាកផ្នែកហិរញ្ញវត្ថុ សេដ្ឋកិច្ច និងសង្គមដែលកើតឡើងពីហានិភ័យ ឬវិបត្តិ ដើម្បីជួយពួកគាត់ឲ្យចាកផុតពីភាពក្រីក្រ។ អន្តរាគមន៍នៃការគាំពារសង្គមក្នុងកម្រិតអប្បបរមា រួមមានការធានារ៉ាប់រងសង្គម គោលនយោបាយទីផ្សារពលកម្ម បណ្តាញសុវត្ថិភាពសង្គម និងសេវាកម្មសុខុមាលភាពសង្គម។

**កម្មវិធីធានារ៉ាប់រងសង្គម** ជាកម្មវិធីដែលរៀបចំឡើងដើម្បីជួយដល់គ្រួសារនានា ក្នុងការការពារពួកគាត់ពីការធ្លាក់ចុះភ្លាមៗនៃប្រាក់ចំណូលពីការងារ ដែលបណ្តាលមកពីជំងឺ លំហែមាតុភាព គ្រោះថ្នាក់ការងារ និកម្មភាព ទុព្វលភាព ជរាភាព (ឧទាហរណ៍ ប្រាក់សោធននិវត្តន៍) និងមរណភាពនៃអ្នកដែលរកចំណូលសម្រាប់គ្រួសារ។ កម្មវិធីទាំងនេះ រួមបញ្ចូលទាំងការធានារ៉ាប់រងដោយមានអាណត្តិការងារ ឬដែលផ្តល់ជាសាធារណៈ ដូចជាគម្រោងធានារ៉ាប់រងសុខភាពសង្គម ដែលផ្តល់ជូនប្រជាជននូវការទទួលបានការថែរក្សាសុខភាព។ កម្មវិធីធានារ៉ាប់រងសង្គម ជាកម្មវិធីដែលត្រូវការ**ភាគទាន** គឺមានន័យថាអ្នកទទួលផលត្រូវទទួលប្រយោជន៍ ឬសេវាកម្ម ដែលបានពីការធ្វើភាគទានរបស់ពួកគាត់ទៅកាន់គម្រោងធានារ៉ាប់រង។ ទស្សនាទាននៃការធានារ៉ាប់រងសង្គម តែងត្រូវបានប្រើប្រាស់ច្របល់គ្នាជាមួយនឹងរបបសន្តិសុខសង្គម។

**គោលនយោបាយទីផ្សារការងារ** រួមបញ្ចូលអន្តរាគមន៍នានាដែលផ្តោតគោលបំណងលើការលើកឡើងនូវការបង្កើតការងារដោយផ្ទាល់ សេវាកម្មការងារ និងការអភិវឌ្ឍជំនាញ ក៏ដូចជាការទ្រទ្រង់ប្រាក់ចំណូលសម្រាប់ជនក្រីក្រដែលប្រកបការងារ និងការរៀបចំតាក់តែងច្បាប់ស្តីពីកម្រិតអប្បបរមានៃប្រាក់កម្រៃការងារ ភាគទានសម្រាប់ការធានារ៉ាប់រងសង្គម ឬរបបសន្តិសុខសង្គម និងបទដ្ឋានពលកម្មនានា ការទប់ស្កាត់ពលកម្មកុមារ ដើម្បីធានានូវការរកប្រាក់ចំណូលនិងបទដ្ឋានរស់នៅដោយសេចក្តីថ្លៃថ្នូរ។

**កម្មវិធីបណ្តាញសុវត្ថិភាពសង្គម** រួមបញ្ចូលអន្តរាគមន៍ដោយមានគោលដៅដែលត្រូវបានរៀបចំឡើងសម្រាប់ជនក្រីក្រនិងជនងាយរងគ្រោះបំផុត និងឧបត្ថម្ភហិរញ្ញប្បទានដែលមានប្រភពចេញពីផលទុនទូទៅ រួមមានពន្ធអាករ ឬជំនួយអភិវឌ្ឍផ្លូវការដែលប្រការនេះមានភាពផ្ទុយពីការធានារ៉ាប់រងសង្គមដែលពឹងផ្អែកលើការចូលរួមភាគទានជាមុនពីអ្នកទទួលផល។ កម្មវិធីបណ្តាញសុវត្ថិភាពសង្គមរួមមាន **កម្មវិធីសំណង់សាធារណៈ** (កម្មវិធីប្រាក់ពលកម្ម ឬស្បៀងពលកម្ម) **កម្មវិធីឧបត្ថម្ភដោយមានឬគ្មានលក្ខខណ្ឌ** (ឧបត្ថម្ភជាសាច់ប្រាក់ឬសម្ភារៈ) ព្រមទាំង **ការឧបត្ថម្ភធនដោយមានគោលដៅ** ដែលត្រូវបានរៀបចំឡើងដើម្បីធានាថាជនក្រីក្រ និងជនងាយរងគ្រោះអាចទទួលបាននូវសេវាថែទាំសុខភាព ការសិក្សាអប់រំ ផ្ទះសំបែង ឬមធ្យោបាយសាធារណៈផ្សេងៗទៀត ដូចជាទឹកនិងអគ្គិសនី (ក.ក.ជ ២០០៩)។

**សេវាកម្មសុខុមាលភាពសង្គម** គ្របដណ្តប់លើការថែទាំកុមារ ការថែទាំជនពិការ ជនចាស់ជរាគ្មានទីពឹង ការថែទាំតាមផ្ទះ ការទ្រទ្រង់បង្អែកសម្រាប់អ្នកផ្ទុកជំងឺរ៉ាំរ៉ៃ ការថែទាំគ្រួសារ សេវាកម្មទ្រទ្រង់គ្រួសារនិងសហគមន៍ ការថែរក្សាបន្ត ការធ្វើមាតុភូមិនិវត្តន៍និងសមាហរណកម្មនៃជនភៀសខ្លួន ការឧបត្ថម្ភជនរងគ្រោះដោយការជួញដូរមនុស្សនិងអាជីវកម្មផ្លូវភេទ ការទ្រទ្រង់នីតិសម្បទាដល់សិស្សគេចសាលារៀន អ្នកញៀនគ្រឿងញៀន និងពលករកុមារ ក៏ដូចជាសេវាកម្មចិត្តសាស្ត្រសង្គម និងការឧបត្ថម្ភក្នុងស្ថានភាពគ្រោះអាសន្ន និងទុក្ខព្រួយ។ សកម្មភាពទាំងនេះជាការជំរុញឥទ្ធិពល និងបំពេញបន្ថែមដល់ការឧបត្ថម្ភជាសាច់ប្រាក់ឬសម្ភារៈ។ ការកំណត់ឲ្យឃើញនូវចំណុចប្រសព្វគ្នានៃការឧបត្ថម្ភសាច់ប្រាក់និងសេវាកម្មសុខុមាលភាពសង្គម ជាប្រការចាំបាច់មួយនៅក្នុងអភិក្រមចម្រុះ និងដោយមានការសម្របសម្រួលនៃការគាំពារសង្គម។

**ការគាំពារសង្គមមូលដ្ឋាន** រួមបញ្ចូលការធានាជាមូលដ្ឋាននូវការគាំពារសង្គមដល់ប្រជាជនទាំងអស់តាមរយៈកញ្ចប់នៃប្រយោជន៍ និងសេវាកម្មសង្គមបំពេញបន្ថែម ដើម្បីដោះស្រាយឫសគល់នៃភាពងាយរងគ្រោះចម្បងនានាដែលកើតមានក្នុងវដ្តជីវិតចំពោះកុមារ ស្ត្រីមានផ្ទៃពោះនិងមាតា ប្រជាជនពេញវ័យការងារ និងជនចាស់ជរា។ ការគាំពារសង្គមមូលដ្ឋានកំណត់យកអភិក្រមរួមគ្នា រវាងការផ្តោតលើផ្នែកតម្រូវការ (តម្រូវការសុខភាព ការអប់រំ អាហារ ប្រាក់ចំណូលកម្រិតអប្បរមាដែលប្រជាជនអាចរស់បាន ...) និងការធានានូវភាពអាចរកបាននៃសេវាកម្មសង្គម។

ដូច្នេះ ក្របខណ្ឌគាំពារសង្គមដែលមានលក្ខណៈទូលំទូលាយ រួមបញ្ចូលវិស័យផ្លូវការ និងកម្មវិធីដែលទាមទារការធ្វើភាគទាន ហើយជាផ្នែកមួយនៃយុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រ។ ដោយសារក្រុមអ្នកទទួលផលរបស់អន្តរាគមន៍ក្នុងបណ្តាញសុវត្ថិភាពសង្គម ខុសគ្នាពីគម្រោងធានារ៉ាប់រងសង្គម បណ្តាញសុវត្ថិភាពសង្គម ដើរតួនាទីបំពេញបន្ថែមដល់គម្រោងធានារ៉ាប់រងសង្គម នៅក្នុងវិស័យសុខាភិ

បាល ការសិក្សាអប់រំ និងសេវាកម្មហិរញ្ញវត្ថុ ដោយការផ្តល់នូវមធ្យោបាយ និងហេដ្ឋារចនាសម្ព័ន្ធមូលដ្ឋាន និងគោលនយោបាយដទៃទៀត ដែលមានគោលដៅកាត់បន្ថយភាពក្រីក្រ គ្រប់គ្រងហានិភ័យ និងភាពងាយរងគ្រោះទាំងមូល។ ការគាំពារសង្គមមានទំនាក់ទំនងយ៉ាងជិតស្និទ្ធ ទៅនឹងវិស័យអភិវឌ្ឍដទៃទៀត។ ការគាំពារសង្គម ការផ្តល់ការងារ និងការអភិវឌ្ឍវិស័យកសិកម្មនិងជនបទ មានទំនាក់ទំនង និងផ្តល់ឥទ្ធិពលឲ្យគ្នាទៅវិញទៅមក។ រូបទី ១ បង្ហាញពីទំនាក់ទំនងរវាងការគាំពារសង្គម និងបណ្តាញសុវត្ថិភាពសង្គម និងរវាងការគាំពារសង្គម ជាមួយការអភិវឌ្ឍសេដ្ឋកិច្ច ការអភិវឌ្ឍសង្គម និងការឆ្លើយតបនឹងគ្រោះមហន្តរាយ។

**រូបទី១. ការគាំពារសង្គម និងវិភាគទានទៅក្នុងការអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គម និងការឆ្លើយតបទៅនឹងគ្រោះមហន្តរាយ**




**រាជរដ្ឋាភិបាលកម្ពុជា** បង្កើនការវិនិយោគនៅក្នុងវិស័យគាំពារសង្គម ទាំងក្នុងភាពជាវិភាគទានទៅកាន់គោលដៅកាត់បន្ថយភាពក្រីក្រក្នុងរយៈពេលវែង ទាំងក្នុងភាពជាវិធានការឆ្លើយតបទៅនឹងគ្រោះអាសន្នឬវិបត្តិក្នុងរយៈពេលខ្លី ដើម្បីដោះស្រាយផលវិបាកនៃកលិយុគនានាដែលជាបញ្ហាប្រឈមរបស់កម្ពុជា និងប្រជាពលរដ្ឋទាំងអស់។ ជាពិសេស ស្ថានភាពនៃភាពក្រីក្រនិងងាយរងគ្រោះនៃ

ប្រជាជនជាច្រើន បានបង្កើនបន្ទុកឡើងចាប់តាំងពី ឆ្នាំ២០០៧ ដោយអតិផរណានៃថ្លៃស្បៀងអាហារ ក៏ដូចជាកលិយុគសេដ្ឋកិច្ច និងហិរញ្ញវត្ថុសកល។ បញ្ហាទាំងនេះ បានជះឥទ្ធិពលទៅលើវិស័យដែលកំពុងមានកំណើន (ពិសេសវិស័យកម្មន្តសាល សំណង់ និងទេសចរណ៍) និងធ្វើឲ្យមានកំណើននិកម្មភាព ការធ្លាក់ចុះនៃប្រាក់ចំណូល ការខូចខាតបណ្តាញប្រាក់បញ្ញើ និងកង្វះការទទួលបានសេវាកម្មចាំបាច់នានារបស់ប្រជាជន។ ការគាំពារសង្គម ជាការវិនិយោគសំដៅកាត់បន្ថយភាពក្រីក្រ ការអភិវឌ្ឍមនុស្ស និងការចូលរួមនៅក្នុងការកសាងកំណើនដែលអាចបំពេញចន្លោះប្រហោងនានា ដែលបានកើនឡើងដោយសារកលិយុគសេដ្ឋកិច្ច ឆ្ពោះទៅកាន់ការសម្រេចបានគោលដៅកាត់បន្ថយភាពក្រីក្រ។ **យុទ្ធសាស្ត្រជាតិគាំពារសង្គមសម្រាប់ជនក្រីក្រ និងជនងាយរងគ្រោះ (យ.ជ.គ.ស.)** នឹងដើរតួនាទីយ៉ាងសំខាន់នៅក្នុងការកាត់បន្ថយភាពក្រីក្រ និងវិសមភាព។

## ១.២. វិសាលភាពនៃយុទ្ធសាស្ត្រ

អនុលោមទៅតាមទិសដៅគោលនយោបាយដែលចែងនៅក្នុង **ឯកសារយុទ្ធសាស្ត្រចតុកោណដើម្បីកំណើន ការងារ សមធម៌ និងប្រសិទ្ធភាពនៅកម្ពុជា** ក្នុងដំណាក់កាលទី២ រាជរដ្ឋាភិបាលកម្ពុជាកំពុងមានដំណើរការជឿនលឿនលើការគាំពារសង្គមសម្រាប់វិស័យសាធារណៈ ហើយកំពុងដាក់ចេញជាអាទិភាពនូវការពង្រីកកិច្ចអន្តរាគមន៍ ក្នុងគោលដៅកាត់បន្ថយភាពក្រីក្រភាពងាយរងគ្រោះ និងហានិភ័យនៃជនក្រីក្រ និងជនងាយរងគ្រោះ។

ក្នុងដំណាក់កាលមធ្យម **យ.ជ.គ.ស.** នឹងផ្តោតលើការគាំពារសង្គមសម្រាប់ជនក្រីក្រ និងជនងាយរងគ្រោះ។ ជនក្រីក្រ និងជនងាយរងគ្រោះគឺជា ៖

- ប្រជាជនដែលរស់នៅក្រោមបន្ទាត់ភាពក្រីក្ររបស់ជាតិ
- ប្រជាជនដែលពុំអាចទប់ទល់បាននឹងវិបត្តិ ឬដែលមានភាពប្រឈមខ្ពស់ទៅនឹងវិបត្តិ (ក្នុងនោះគឺប្រជាជនដែលកំពុងរស់នៅក្រោម ឬក្បែរបន្ទាត់ភាពក្រីក្រ ហើយមានភាពងាយរងគ្រោះខ្ពស់ជាងគេ)

**យ.ជ.គ.ស.** ដាក់ចេញអាទិភាពនូវការរៀបចំបណ្តាញសុវត្ថិភាពសង្គមដែលមានប្រសិទ្ធភាព និងមាននិរន្តរភាពសម្រាប់ជនក្រីក្រនិងជនងាយរងគ្រោះ ជាមួយនឹងសេវាកម្មសុខុមាលភាពសាធារណៈបំពេញបន្ថែមសម្រាប់ក្រុមជនងាយរងគ្រោះពិសេស ដូចជាអ្នកផ្ទុកមេរោគអេដស៍[២] និងកុមារកំព្រាដែល

[២] ច្បាប់ស្តីពីការបង្ការ និងការប្រយុទ្ធទប់ស្កាត់ការរីករាលដាលមេរោគអេដស៍/ជំងឺអេដស៍ (មាត្រាទី ២៦) ក៏បានតម្កល់សិទ្ធិជនដែលមានផ្ទុកមេរោគអេដស៍ ក្នុងការទទួលបានសេវាកម្មសុខភាពបឋមដោយពុំគិតតម្លៃនៅតាមបណ្តាបណ្តាញសុខភាពសាធារណៈ។

ប្រឈមឬរងឥទ្ធិពលដោយមេរោគអេដស៍[៣]។ ការធានារ៉ាប់រងសុខភាពនៅសហគមន៍ (អន្តរាគមន៍ដោយមានភាគទាន) ក៏ត្រូវបានរាប់បញ្ចូលដោយសារកម្មវិធីនេះផ្តោតគោលដៅទៅលើប្រជាជនដែលរស់នៅក្បែរបន្ទាត់នៃភាពក្រីក្រ ហើយមានភាពងាយរងគ្រោះខ្ពស់ក្នុងការធ្លាក់ចូលទៅក្នុងភាពក្រីក្រ ដែលបណ្តាលមកពីវិបត្តិសុខភាព។ រូបទី ២ នឹងធ្វើការបកស្រាយពីវិសាលភាពនៃ **យ.ជ.គ.ស.**។

**រូបទី២. វិសាលភាពនៃ យ.ជ.គ.ស. ដោយផ្តោតលើជនក្រីក្រ និងជនងាយរងគ្រោះ**




ក្នុងពេលជាមួយគ្នានេះ **យ.ជ.គ.ស.** ដាក់ចេញនូវក្របខណ្ឌសម្រាប់ការគាំពារសង្គមដែលមានលក្ខណៈស៊ីជម្រៅ និងនិរន្តរភាពសម្រាប់ប្រជាជនកម្ពុជាគ្រប់រូប ក្នុងដំណាក់កាលវែង។ ប្រការនេះរាប់បញ្ចូលទាំងគម្រោងដោយមាន និងដោយពុំមានភាគទាន។ រូបទី ៣ នឹងបកស្រាយពីទំនាក់ទំនងរវាងការគ្របដណ្តប់នៃការគាំពារសង្គមដោយពុំមានភាគទាន (ដោយពុំទាមទារឲ្យអ្នកទទួលផលត្រូវធ្វើភាគទាន) សម្រាប់ប្រជាជនគ្រប់រូប និងការគ្របដណ្តប់នៃការធានារ៉ាប់រងសង្គមដោយមានភាគទានសម្រាប់ប្រជាជនដែលមានកម្រិតប្រាក់ចំណូលខ្ពស់ ជាពិសេសមន្ត្រីរាជការក្នុងវិស័យសាធារណៈ។

---

[៣] បញ្ជីនៃក្រុមជនងាយរងគ្រោះពិសេស នឹងមានបង្ហាញក្នុងជំពូកទី ៣.២។

**រូបទី៣. ដំណើរការជាលំដាប់ឆ្ពោះទៅកាន់ការគាំពារសង្គមដ៏ស៊ីជម្រៅដូចមានចែងក្នុងទស្សនវិស័យក្នុងដំណាក់កាលវែងនៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ**




ការបង្កើតឡើងនូវការគាំពារសង្គមដែលមានលក្ខណៈទូលំទូលាយ និងស៊ីជម្រៅ គឺមានន័យថាជាការធានាឲ្យមានការពាក់ព័ន្ធគ្នារវាងសមាសភាពនានា (ដោយមាន និងពុំមានភាគទាន) ហើយត្រូវបានរៀបចំឡើងស្របគ្នា ឆ្ពោះទៅកាន់ប្រព័ន្ធមួយដែលមាននិរន្តរភាព ដែលក្នុងនោះសម្រាប់អ្នកដែលអាចមានលទ្ធភាពបង់ថ្លៃដល់កម្មវិធីគាំពារសង្គម អាចទទួលយកដោយពឹងផ្អែកទៅលើភាគទានជាផ្លូវការរបស់ពួកគាត់ ហើយសម្រាប់អ្នកដែលពុំអាចមានលទ្ធភាព គាត់នឹងពឹងផ្អែកទៅលើរដ្ឋក្នុងការឧបត្ថម្ភរហូតដល់ពេលដែលពួកគាត់អាចបង្កើតឡើងនូវសមត្ថភាពក្នុងអំឡុងពេលមួយ។ សមាសភាពទាំងពីរនេះ មានទំនាក់ទំនងនិងបំពេញបន្ថែមឲ្យគ្នាទៅវិញទៅមក នៅក្នុងប្រព័ន្ធស៊ីជម្រៅនៃការគាំពារសង្គម[៤]។

---

[៤] រួមបញ្ចូលការគ្របដណ្តប់បន្ថែមនៃអ្នកទទួលផល និងសេវាកម្មសម្រាប់ក្រុមប្រជាជនដែលមានលទ្ធភាពខុសៗគ្នា និងយន្តការហិរញ្ញប្បទានបន្ថែមឆ្ពោះទៅកាន់និរន្តរភាពហិរញ្ញវត្ថុ ដែលក្នុងនោះប្រព័ន្ធដែលទាមទារភាគទាន នឹងផ្តល់ថវិកាដល់ប្រព័ន្ធដែលពុំទាមទារភាគទាន តាមរយៈតួនាទីអន្តរឧបត្ថម្ភធនរបស់វា និងវិភាគទានដោយផ្ទាល់ពីថវិកាចំណូលសាធារណៈ ក៏ដូចជាតាមរយៈការគាំទ្រពីសង្គមកាន់តែខ្លាំងដោយរួមបញ្ចូលទាំងការដកហូតពន្ធ។ គោលបំណងសំខាន់

## ១.៣. ដំណើរការរៀបចំយុទ្ធសាស្ត្រ

ក្នុងការរៀបចំតាក់តែង **យ.ជ.គ.ស.** ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ (ក.ក.ជ.) នាឆ្នាំ២០០៩និងក្នុងឆ្នាំ២០១០ បានរៀបចំប្រជុំនិងពិភាក្សាពិគ្រោះយោបល់ជាមួយស្ថាប័នពាក់ព័ន្ធជាច្រើន រួមមានតំណាងក្រសួងស្ថាប័នពាក់ព័ន្ធនៃរាជរដ្ឋាភិបាលកម្ពុជា (ថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ) ដៃគូអភិវឌ្ឍ សង្គមស៊ីវិល និងស្ថាប័នអភិវឌ្ឍមួយចំនួន ដើម្បីផ្តល់ឱកាសក្នុងការស្វែងរកជម្រើសនិងអាទិភាពឲ្យបានស៊ីជម្រៅ។ ដំណើរការពិភាក្សាពិគ្រោះយោបល់ដ៏មានតម្លាភាព និងរស់រវើកនេះបានធានាថា លទ្ធផលនៃការវិភាគនិងគោលនយោបាយ បានឆ្លងកាត់កិច្ចពិភាក្សាជាច្រើនជុំ និងជាលទ្ធផលនៃកិច្ចខិតខំប្រឹងប្រែងរួមគ្នារវាងបណ្តាស្ថាប័នពាក់ព័ន្ធទាំងអស់។

**តារាងទី១. ការសង្ខេបស្តីពីដំណើរការពិភាក្សាពិគ្រោះយោបល់លើ យ.ជ.គ.ស.**

| កាលបរិច្ឆេទ | សកម្មភាព / ព្រឹត្តិការណ៍ | លទ្ធផល |
|---|---|---|
| ៣-៤ ធ្នូ ២០០៨ | វេទិកាកិច្ចសហប្រតិបត្តិការអភិវឌ្ឍកម្ពុជា | រាជរដ្ឋាភិបាលកម្ពុជាព្រមព្រៀងរៀបចំបង្កើត និងអនុវត្តយុទ្ធសាស្ត្រជាតិ ដែលមានលក្ខណៈចម្រុះ សម្រាប់បណ្តាញសុវត្ថិភាពសង្គម។ |
| មករា-មិថុនា ២០០៩ | ក្រុមការងារបណ្តោះអាសន្នសម្រាប់បណ្តាញសុវត្ថិភាពសង្គម (ចេញពីក្រុមការងារបច្ចេកទេសសន្តិសុខស្បៀង និងអាហារូបត្ថម្ភ) | ផ្លាស់ប្តូរចំណេះដឹង និងកសាងការព្រមព្រៀងគ្នាលើទស្សនាទានគន្លឹះ និងទិសដៅទូលំទូលាយនៃការរៀបចំគោលនយោបាយ និងបញ្ជីសារពើភណ្ឌ នៃបណ្តាអន្តរាគមន៍ក្នុងការគាំពារសង្គម ដែលកំពុងមានដំណើរការ។ |
| ៦-៧ កក្កដា ២០០៩ | វេទិកាជាតិស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ក្រោមប្រធានបទបណ្តាញសុវត្ថិភាពសង្គម នៅកម្ពុជា | ក្នុងអំឡុងពេល ២ ថ្ងៃនៃដំណើរការវេទិកា អ្នកចូលរួមចំនួនប្រហែល ៤០០ នាក់ (មកពីស្ថាប័នរាជរដ្ឋាភិបាល ដៃគូអភិវឌ្ឍ សង្គមស៊ីវិល) បានពិភាក្សា យ៉ាងផុលផុស និងបានទទួលអនុសាសន៍ដ៏ខ្ពង់ខ្ពស់ពី **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ក្នុងឱកាសបិទវេទិកា។ |
| ១៩-២២ តុលា ២០០៩ | កិច្ចពិភាក្សាពិគ្រោះយោបល់បច្ចេកទេស ស្តីពីការឧបត្ថម្ភសាច់ប្រាក់ ដោយផ្តោតលើការលើកឡើងនូវបញ្ហាកង្វះ អាហារូបត្ថម្ភមាតា និងកុមារ | អ្នកចូលរួមពីក្រសួង ស្ថាប័ននៃរាជរដ្ឋាភិបាល ដៃគូអភិវឌ្ឍ និងសង្គមស៊ីវិល បានផ្តោតការពិភាក្សាក្នុងអំឡុងសិក្ខាសាលានៅរាជធានីភ្នំពេញ។ អ្នកចូលរួមមួយក្រុម បានធ្វើទស្សនកិច្ចស្វែងយល់ពីសេវាកម្មអប់រំនិងសុខាភិបាល និងបានពិភាក្សាជាមួយក្រុមប្រឹក្សាឃុំ និងមន្ត្រីសាលាខេត្តកំពង់ស្ពឺ។ កិច្ចពិភាក្សាបានទទួលគំនិតពីអ្នកពាក់ព័ន្ធសំខាន់ៗ ក្នុងការ |

បំផុតនៃប្រព័ន្ធនេះ គឺការធានានូវការគ្របដណ្តប់ជាលក្ខណៈសកល ដើម្បីការពារប្រជាជនពីហានិភ័យ វិបត្តិ និងស្ថានភាពរ៉ាំរ៉ៃ និងភាពងាយរងគ្រោះនានា។

| | | |
|---|---|---|
| | | បង្កើតឡើងនូវ **"ឯកសារស្តីពីការឧបត្ថម្ភសាច់ប្រាក់"**។ |
| ១២-១៤ មករា ២០១០ | កិច្ចពិភាក្សាពិគ្រោះយោបល់បច្ចេកទេស ស្តីពីកម្មវិធីសំណង់សាធារណៈ | អ្នកចូលរួមជាង ៨០នាក់ (មកពីក្រសួងស្ថាប័ននៃរាជរដ្ឋាភិបាល ដៃគូអភិវឌ្ឍ និងសង្គមស៊ីវិល) បានចូលរួមពិភាក្សាក្នុងសិក្ខាសាលានារាជធានីភ្នំពេញ។ ក្រុមស្នូល (ប្រហែល ៣០នាក់) ក៏បានធ្វើទស្សនកិច្ចសិក្សានៅតំបន់ **គម្រោងឧបត្ថម្ភស្បៀងបន្ទាន់** ដែលប្រើប្រាស់កម្មវិធីស្បៀង និងសាច់ប្រាក់ពលកម្ម (គម្រោងឧបត្ថម្ភដោយធនាគារអភិវឌ្ឍន៍អាស៊ី និងកម្មវិធីស្បៀងអាហារ ពិភពលោក) នៅខេត្តកំពង់ឆ្នាំង ដោយមានការជួបពិភាក្សាជាមួយតំណាងក្រុមប្រឹក្សាឃុំ និងអ្នកទទួលផលនៃគម្រោង។ កិច្ចពិភាក្សាបានឈានដល់ការបង្កើតឡើងនូវ **"ឯកសារស្តីពីកម្មវិធីសំណង់សាធារណៈ"**។ |
| ៣-៤ កុម្ភៈ ២០១០ | កិច្ចពិភាក្សាពិគ្រោះយោបល់បច្ចេកទេស ស្តីពីតួនាទីនៃយុទ្ធសាស្ត្រជាតិគាំពារសង្គមក្នុងការលើកកម្ពស់មូលធនមនុស្សតាមរយៈការបង្កើនការអប់រំ ការកាត់បន្ថយ និងការលុបបំបាត់ទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារ | អ្នកចូលរួមជាង១០០ នាក់ (មកពីក្រសួងស្ថាប័ននៃរាជរដ្ឋាភិបាល ដៃគូអភិវឌ្ឍ និងសង្គមស៊ីវិល) បានចូលរួមពិភាក្សាក្នុងសិក្ខាសាលារយៈពេល២ថ្ងៃ នៅរាជធានីភ្នំពេញ ហើយបានកសាងការឯកភាពគ្នាលើការដាក់បញ្ចូលបញ្ហាពលកម្មកុមារនិងការអប់រំទៅក្នុង **យ.ជ.គ.ស.** ពិសេសជាមួយឧបករណ៍មួយចំនួនដូចជាការឧបត្ថម្ភសាច់ប្រាក់ ក៏ដូចជាតម្រូវការក្នុងការស្វែងរក និងការទទួលបានកាន់តែទូលាយនូវបណ្តាញសុវត្ថិភាពសង្គម ដើម្បីរារាំងបញ្ហាពលកម្មកុមារ និងទាញយកកុមារងាយរងគ្រោះពីបញ្ហានេះ ពិសេសពីទម្រង់ធ្ងន់ធ្ងរនានា។ **"ឯកសារស្តីពីពលកម្មកុមារនិងការអប់រំ"** បានរៀបចំឡើងដោយ ក្រុមស្នូលនៃដៃគូអភិវឌ្ឍ ក្នុងភាពជាវិភាគទានមួយដល់ **យ.ជ.គ.ស.**។ |
| មិនា-មេសា ២០១០ | កិច្ចពិភាក្សាលើសេចក្តីព្រាងនៃ **យ.ជ.គ.ស.** | ក្រុមការងារតាក់តែងសេចក្តីព្រាងបានបង្កើតឡើង ដើម្បីរៀបចំ និងច្របាច់បញ្ចូលគ្នានូវយោបល់នានាទៅក្នុងសេចក្តីព្រាងនៃ **យ.ជ.គ.ស.**។ សេចក្តីព្រាងនៃ **យ.ជ.គ.ស.** ត្រូវបានចែកចាយ និង ពិភាក្សាវែកញែកជាច្រើនដំណាក់នៅក្នុងក្រុមការងារបណ្តោះអាសន្នស្តីពីបណ្តាញសុវត្ថិភាពសង្គម។ ការពិភាក្សាលើខ្លឹមសារ និងគោលដៅ **យ.ជ.គ.ស.** បានធ្វើឡើងជាច្រើនដង ឆ្ពោះទៅកាន់ការសម្រេចជារូបរាងនៃយុទ្ធសាស្ត្រដែលមានភាពប្រទាក់ក្រឡាគ្នា។ |

លទ្ធផលនៃដំណើរការពិភាក្សាពិគ្រោះយោបល់ទាំងនេះ បានស្តែងឡើងនៅក្នុង **ឯកសារមូលដ្ឋានស្តីពី យ.ជ.គ.ស.** មួយចំនួន ហើយដែលឯកសារទាំងអស់នេះត្រូវបានចងក្រងឡើងជាឯកសារពិគ្រោះដាច់ដោយឡែកពីគ្នា សម្រាប់ **យ.ជ.គ.ស.** រួមមាន ៖

- **ឯកសារទី១ "បណ្តាញសុវត្ថិភាពសង្គមនៅកម្ពុជា : ទស្សនាទាន និងបញ្ជីសារពើភណ្ឌ"** (ខែមិថុនា ឆ្នាំ ២០០៩ រៀបចំដោយ ក.ក.ជ. កម្មវិធីស្បៀងអាហារពិភពលោក និងធនាគារពិភពលោក) ឯកសារនេះបង្ហាញពីលក្ខណៈចម្បង សមិទ្ធផល ចន្លោះប្រហោង និងបញ្ហាប្រឈមនៃបណ្តាកម្មវិធីបណ្តាញសុវត្ថិភាពសង្គមនៅកម្ពុជា។ ឯកសារនេះផ្តល់ការពិនិត្យឡើងវិញនូវទស្សនាទានមូលដ្ឋាន សេចក្តីសង្ខេបនៃហានិភ័យនិងភាពងាយរងគ្រោះ បញ្ជីសារពើភណ្ឌនៃបណ្តាញសុវត្ថិភាពសង្គមដែលមានស្រាប់ និងការវិភាគលើចន្លោះប្រហោងរវាងហានិភ័យនិងភាពងាយរងគ្រោះទៅនឹងបណ្តាញសុវត្ថិភាពសង្គមដែលមានស្រាប់។
- **ឯកសារទី២ "ឯកសារពិភាក្សាស្តីពីកម្មវិធីឧបត្ថម្ភសាច់ប្រាក់ក្នុងការទ្រទ្រង់ដល់ជនក្រីក្រ ព្រមទាំងផ្តោតលើបញ្ហាកង្វះអាហារូបត្ថម្ភមាតានិងកុមារ"** (ខែមិនា ឆ្នាំ២០១០ រៀបចំដោយធនាគារពិភពលោក ដោយមានការចូលរួមពីមូលនិធិអង្គការសហប្រជាជាតិដើម្បីកុមារ កម្មវិធីស្បៀងអាហារពិភពលោក ទីភ្នាក់ងារសហប្រតិបត្តិការបច្ចេកទេសអាល្លឺម៉ង់ អង្គការសុខភាពពិភពលោក និងក.ក.ជ.) ឯកសារនេះជាលទ្ធផលនៃកិច្ចពិភាក្សាពិគ្រោះយោបល់បច្ចេកទេស បង្ហាញពីស្ថានភាពកង្វះអាហារូបត្ថម្ភមាតានិងទារកនៅកម្ពុជា ដើម្បីវាយតម្លៃលើសនិទានភាពដែលស្ថិតនៅពីក្រោយការវិនិយោគលើកម្មវិធីអាហារូបត្ថម្ភ។ ឯកសារនេះផ្តល់ការបរិយាយអំពីលទ្ធភាពនៃការរៀបចំកម្មវិធីឧបត្ថម្ភសាច់ប្រាក់ ក៏ដូចជាការពិភាក្សានិងវាយតម្លៃលើការប៉ាន់ស្មានលើការចំណាយនិងហិរញ្ញប្បទាន។
- **ឯកសារទី៣ "ឯកសារមូលដ្ឋានស្តីពីកម្មវិធីសំណង់សាធារណៈ: ជាផ្នែកមួយនៃការគាំពារសង្គមសម្រាប់ជនក្រីក្រ និងជនងាយរងគ្រោះ"** (ខែមិនា ឆ្នាំ២០១០ អង្គការពលកម្មអន្តរជាតិ) ឯកសារនេះ ជាលទ្ធផលនៃកិច្ចពិភាក្សាពិគ្រោះយោបល់ ដែលបង្ហាញពីភាពងាយរងគ្រោះ និងការវិភាគលើសេចក្តីត្រូវការ ព្រមទាំងមានការវាយតម្លៃមួយលើសនិទានភាពក្នុងការវិនិយោគលើកម្មវិធីសំណង់សាធារណៈ និងការពិនិត្យជាទូទៅលើបញ្ហាអភិក្រម និងការលើកគម្រោង។
- **ឯកសារទី៤ "ឯកសារស្តីពីការផ្តោតលើពលកម្មកុមារ និងការបង្កើនការទទួលបាននូវការសិក្សាអប់រំ"** (ខែមិនា ឆ្នាំ២០១០ រៀបចំដោយអង្គការពលកម្មអន្តរជាតិ ដោយមានការចូលរួមពីមូលនិធិអង្គការសហប្រជាជាតិដើម្បីកុមារ និងអង្គការអប់រំវិទ្យាសាស្ត្រ និងវប្បធម៌ នៃអង្គការសហប្រជាជាតិ) ឯកសារនេះ ជាលទ្ធផលនៃកិច្ចពិភាក្សាពិគ្រោះយោបល់ ដោយធ្វើការវាយតម្លៃលើការគាំពារសង្គម និងតួនាទីនៅក្នុងការការពារកុមារងាយរងគ្រោះ ជាពិសេសដោយ

ផ្តោតលើការសិក្សាអប់រំនិងពលកម្មកុមារ និងទំនាក់ទំនងរវាងបញ្ហាទាំងនេះ។ ទាក់ទងទៅនឹង **យ.ជ.គ.ស.** ឯកសារនេះធ្វើការបកស្រាយយ៉ាងពិស្តារទៅលើទម្រង់លើកទឹកចិត្តដល់គ្រួសារទាំងឡាយ ដើម្បីធានាឲ្យកូនចៅរបស់ពួកគាត់ចូលរៀននៅសាលារៀន សេវាកម្មនានាសម្រាប់កុមារងាយរងគ្រោះ (រួមទាំងកុមារដែលស្ថិតនៅក្រោមទម្រង់ធ្ងន់ធ្ងរ) និងកម្មវិធីសំណង់សាធារណៈ។

- **ឯកសារទី៨ "ឯកសារមូលដ្ឋាន : ឆ្ពោះទៅកាន់យុទ្ធសាស្ត្រគាំពារសង្គមសម្រាប់ជនក្រីក្រ និងជនងាយរងគ្រោះ"** (រៀបចំដោយ ក.ក.ជ. និងដៃគូអភិវឌ្ឍ) បង្ហាញពីលទ្ធផលនៃដំណើរការពិភាក្សាពិគ្រោះយោបល់ទាំងឡាយ។ ឯកសារនេះ បានបង្ហាញយ៉ាងពិស្តារនូវភាពក្រីក្រ និងភាពងាយរងគ្រោះនៅកម្ពុជា ក៏ដូចជាបណ្តាញសុវត្ថិភាពសង្គមដែលកំពុងដំណើរការ និងបញ្ហាប្រឈម ផ្នែកគោលនយោបាយ ក្នុងគោលបំណងទាញចេញជាសេចក្តីសន្និដ្ឋានស្តីពីយុទ្ធសាស្ត្រជាតិគាំពារសង្គមសម្រាប់ជនក្រីក្រនិងជនងាយរងគ្រោះ គោលដៅ និងជម្រើសនានាសម្រាប់អនាគតឆាប់ៗខាងមុខ។

## ១.៤. ផែនទីគោចរ

**យ.ជ.គ.ស.** បានដាក់ឆ្លងសម័យប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី នៅក្នុងឆ្នាំ២០១១។ ជំហានបន្ទាប់មកទៀត គឺការរៀបចំបង្កើតនិងការអនុវត្តផែនការសកម្មភាពជាអាទិភាព រហូតដល់ឆ្នាំ២០១៣។ ការអនុវត្តនឹងត្រូវទទួលការពិនិត្យតាមដានជាប្រចាំ ព្រមជាមួយនឹងការពិនិត្យតាមដានពាក់កណ្តាលអាណត្តិក្នុងឆ្នាំ២០១៣ ដែលប្រការនេះនឹងផ្តល់ព័ត៌មានបច្ចុប្បន្នភាពផែនការសកម្មភាពសម្រាប់ឆ្នាំ ២០១៤-២០១៥។ នៅក្នុងឆ្នាំ២០១៥ ការអនុវត្តកម្មវិធីនឹងត្រូវធ្វើការវាយតម្លៃ ហើយ **យ.ជ.គ.ស.** នឹងត្រូវធ្វើបច្ចុប្បន្នកម្ម និងកែសម្រួលជាថ្មីក្នុងករណីចាំបាច់។

| | | |
|---|---|---|
| ២០០៩-២០១១ | : | ការរៀបចំបង្កើតយុទ្ធសាស្ត្រ និងទទួលការអនុម័តពីគណៈរដ្ឋមន្ត្រី |
| ២០១១-២០១៣ | : | ការអនុវត្តផែនការសកម្មភាពអាទិភាពក្នុងដំណាក់កាលខ្លី |
| ២០១៣ | : | ការពិនិត្យតាមដានពាក់កណ្តាលអាណត្តិនិងការកែតម្រូវឬធ្វើបច្ចុប្បន្នកម្មលើផែនការសកម្មភាព |
| ២០១៤-២០១៥ | : | ការអនុវត្តផែនការសកម្មភាពបច្ចុប្បន្នកម្ម |
| ២០១៥ | : | ការវាយតម្លៃ និងការធ្វើបច្ចុប្បន្នកម្ម ឬកែសម្រួល លើ យ.ជ.គ.ស. |

# ជំពូកទី២

# ការគាំពារសង្គម ក្នុងអាទិភាពមួយ របស់រាជរដ្ឋាភិបាល

# ជំពូកទី២
# ការគាំពារសង្គមក្នុងអាទិភាពមួយរបស់
# រាជរដ្ឋាភិបាល

**ការគាំពារសង្គម** ជាអាទិភាពមួយរបស់រាជរដ្ឋាភិបាល។ ការរៀបចំបង្កើត **យ.ជ.គ.ស.** ធ្វើឡើងដោយឈរលើមូលដ្ឋាននៃរដ្ឋធម្មនុញ្ញ ឯកសារយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី១ និងដំណាក់កាលទី២ ឯកសារផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងឯកសារផ្លូវច្បាប់ដទៃទៀត ក៏ដូចជាអនុសញ្ញាអន្តរជាតិនានាដែលរាជរដ្ឋាភិបាលកម្ពុជាជាហត្ថលេខី។

## ២.១. ច្បាប់និងបទប្បញ្ញត្តិជាធរមាន

**រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា** ជាក្របខណ្ឌនៃការកំណត់ទំហំដែនកំណត់សម្រាប់ការឧបត្ថម្ភ តាមការគាំពារសង្គមដល់ប្រជាពលរដ្ឋ។ រដ្ឋធម្មនុញ្ញគ្របដណ្តប់លើសិទ្ធិនៃប្រជាពលរដ្ឋគ្រប់រូបក្នុងការទទួលបាននូវរបបសន្តិសុខសង្គម និងផលប្រយោជន៍សង្គមផ្សេងទៀត ដូចជាការឧបត្ថម្ភសង្គមសម្រាប់របបសន្តិសុខសង្គមនៅក្នុងវិស័យសាធារណៈ។ រដ្ឋធម្មនុញ្ញកំណត់អត្តសញ្ញាណក្រុមប្រជាជនពិសេស ដែលអាចទាមទារនូវកិច្ចជំនួយពិសេស ដូចជាស្ត្រីក្រីក្រ កុមារ ជនពិការ ចាស់ជរា និងគ្រួសារយោធិនពលីក្នុងបុព្វហេតុការពារជាតិមាតុភូមិ។

### ប្រអប់ទី១. មាត្រាមួយចំនួននៃរដ្ឋធម្មនុញ្ញ[៥] ទាក់ទងនឹងការគាំពារសង្គម

| | |
|---|---|
| មាត្រា ៣៦ | ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ មានសិទ្ធិទទួលការធានារ៉ាប់រងសង្គម និងអត្ថប្រយោជន៍ខាងសង្គមកិច្ចដែលមានចែងក្នុងច្បាប់។ |
| មាត្រា ៤៦ | រដ្ឋ និងសង្គមយកចិត្តទុកដាក់បង្កលក្ខណៈឱ្យនារី ជាពិសេសនារីនៅជនបទដែលគ្មានទីពឹង បានទទួលការឧបត្ថម្ភដើម្បីមានមុខរបរ មានលទ្ធភាពព្យាបាលជំងឺ ឱ្យកូនទៅរៀន និងមានជីវភាពរស់នៅសមរម្យ។ |
| មាត្រា ៧៣ | រដ្ឋយកចិត្តទុកដាក់ចំពោះកុមារ និងមាតា។ រដ្ឋរៀបចំឱ្យមានទារកដ្ឋាន និងឧបត្ថម្ភនារីដែលមានកូនច្រើនក្នុងបន្ទុក ហើយឥតទីពឹង។ |
| មាត្រា ៧៤ | រដ្ឋជួយឧបត្ថម្ភដល់ជនពិការ និងដល់គ្រួសារយុទ្ធជនដែលបានបូជាជីវិតដើម្បីប្រទេសជាតិ។ |
| មាត្រា ៧៥ | រដ្ឋចាត់ចែងឱ្យមានរបបសន្តិសុខសង្គម ដល់កម្មករ និងនិយោជិត។ |

[៥] រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣

ឯកសារច្បាប់ពាក់ព័ន្ធនឹងការផ្តល់របបសន្តិសុខសង្គម រួមមាន **ច្បាប់ស្តីពីការងារ ច្បាប់ធានារ៉ាប់រង ច្បាប់ស្តីពីរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ** និង**អនុក្រឹត្យស្តីពីបេឡាជាតិសន្តិសុខសង្គម** ដែលគ្របដណ្តប់លើការធានារ៉ាប់រងការរងរបួសរបស់និយោជិត គម្រោងប្រាក់សោធននិវត្តន៍ និងប្រព័ន្ធទទួលប្រយោជន៍រយៈពេលខ្លី **ព្រះរាជក្រឹត្យស្តីពីរបបសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល** ដែលធានារបបសន្តិសុខសង្គមសម្រាប់អ្នកបម្រើការងារនៅក្នុងវិស័យសាធារណៈ ក៏ដូចជា**ច្បាប់ស្តីពីរបបសោធននិវត្តន៍ និងសោធនបាត់បង់សមត្ថភាពការងារចំពោះយោធិននៃកងយោធពលខេមរភូមិន្ទ**។ ការគាំពារដោយច្បាប់សម្រាប់ជនងាយរងគ្រោះមួយចំនួនទៀត មានដូចជា**ច្បាប់ស្តីពីការការពារនិងលើកកម្ពស់សិទ្ធិជនពិការ ច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ ច្បាប់ស្តីពីស្នុំកូនអន្តរប្រទេស ច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្សនិងអាជីវកម្មផ្លូវភេទ**។ល។

## ២.២. យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី២ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្ម២០០៩-២០១៣

**យុទ្ធសាស្ត្រចតុកោណនៃរាជរដ្ឋាភិបាលកម្ពុជា** បានកំណត់ទិសដៅគោលនយោបាយទូលាយ ដើម្បីកែលម្អការគាំពារសង្គម និងកំណត់អាទិភាពសម្រាប់ការបង្កើតបណ្តាញសុវត្ថិភាពសង្គម។ ឯកសារនេះក៏បានលើកកម្ពស់ការអភិវឌ្ឍប្រកបដោយនិរន្តរភាព និងសមភាព ព្រមទាំងកំណត់អាទិភាពលើការកែលម្អការឧបត្ថម្ភនៃការគាំពារសង្គម។ តាមរយៈបណ្តាញសុវត្ថិភាពសង្គម រាជរដ្ឋាភិបាលកម្ពុជាមាននិន្នាការក្នុងការបង្កើនអន្តរាគមន៍ទៅលើវិស័យសង្គម ៖

- ធ្វើឲ្យប្រសើរឡើងនូវជំនួយសង្គ្រោះបន្ទាន់ ដល់ជនរងគ្រោះដោយសារគ្រោះមហន្តរាយ និងគ្រោះធម្មជាតិ។
- កាត់បន្ថយភាពងាយរងគ្រោះនៃជនក្រីក្រ។
- កាត់បន្ថយភាពខុសគ្នានៃសុខភាពមាតា និងទារក និងអសមធម៌នៅក្នុងការប្រើប្រាស់សេវាកម្មសុខាភិបាលរវាងក្រុមអ្នកមាន និងអ្នកក្រ។
- ការពារ និងដកហូតកុមារពីបញ្ហាពលកម្មកុមារ ពិសេសក្នុងទម្រង់ធ្ងន់ធ្ងរ។
- ធ្វើឲ្យប្រសើរឡើងការទទួលបានការអប់រំសម្រាប់កុមារ ដោយមានគុណភាព។
- បង្កើនកាលានុវត្តភាពការងារ។

- ធ្វើឲ្យប្រសើរឡើងនូវការឧបត្ថម្ភការលើកលែងថ្លៃ តាមរយៈមូលនិធិសមធម៌សុខភាព[៦] និងគម្រោងឧបត្ថម្ភធន ដើម្បីធានានូវលទ្ធភាពដែលអាចទទួលបាន ទៅកាន់សេវាកម្មថែទាំសុខភាព។
- ពង្រីកកម្មវិធីស្តារលទ្ធភាពពលកម្មសម្រាប់ជនពិការ ក៏ដូចជាកម្មវិធីសុខុមាលភាពសម្រាប់ជនចាស់ជរា កុមារ កំព្រា ស្ត្រីរងគ្រោះ ជនមានផ្ទុកជំងឺអេដស៍ និងរបេង ជនគ្មានផ្ទះសំបែង អតីតយុទ្ធជន និងក្រុមគ្រួសាររបស់ពួកគាត់។

**ឯកសារផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ បច្ចុប្បន្នកម្ម ២០០៩-២០១៣** បន្តលើកឡើងភាពជាក់លាក់នៃសេចក្តីត្រូវការពង្រឹងការគាំពារសង្គម។ ក្នុងការបង្ហាញផ្លូវដល់ការរៀបចំបង្កើត **យ.ជ.គ.ស.** និងអាទិភាពសម្រាប់ដំណាក់កាលខ្លីទៅមធ្យម ឯកសារនេះរំលេចសេចក្តីត្រូវការក្នុងការ ៖

- គាំទ្រវិធានការគាំពារសង្គម ដែលពុំត្រឹមតែផ្តល់ការសម្រាលបន្ទុកជាបន្ទាន់ប៉ុណ្ណោះទេ តែថែមទាំងផ្តល់វិភាគទានទៅឲ្យការកសាងលទ្ធភាព ឬសមត្ថភាពនៃក្រុមប្រជាជនអ្នកទទួលផល ក្នុងការចូលរួមការអភិវឌ្ឍសង្គមនិងសេដ្ឋកិច្ចក្នុងសហគមន៍របស់ពួកគាត់។
- ធានាឲ្យការកំណត់គោលដៅកាន់តែប្រសើរនិងមានតម្លាភាព ក្នុងការផ្តល់ការគាំពារសង្គមដល់ជនក្រីក្រ តាមរយៈការប្រើប្រាស់**កម្មវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ**[៧] និងតាមរយៈយន្តការកំណត់គោលដៅសមរម្យផ្សេងមួយទៀត ដែលនឹងត្រូវបង្កើតឡើងសម្រាប់ជនក្រីក្រនៅតំបន់ទីប្រជុំជន ក្នុងពេលដែលនីតិវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រដែលមានស្រាប់ ទទួលការកែសម្រួលដើម្បីប្រើប្រាស់នៅតំបន់ទីប្រជុំជន។
- កាត់បន្ថយឲ្យបានដល់កម្រិតអប្បបរមា នូវការចំណាយលើការធ្វើផែនការ និងការផ្តល់សេវា (ចំណាយរដ្ឋបាល) សម្រាប់កម្មវិធីបណ្តាញសុវត្ថិភាពសង្គម ដើម្បីសម្រេចបានការឧបត្ថម្ភជាអតិបរមានៃធនធានទៅដល់ក្រុមប្រជាជនអ្នកទទួលផល។
- ធានាឲ្យបាននូវការសម្របសម្រួលអន្តរវិស័យ និងការធ្វើសមាហរណកម្មវិធានការគាំពារសង្គមដល់ការធ្វើផែនការអភិវឌ្ឍថ្នាក់ក្រោមជាតិ។

---

[៦] មូលនិធិសមធម៌សុខភាព គឺជាយន្តការមួយក្នុងការបង់តម្លៃចំណាយលើមធ្យោបាយថែទាំសុខភាពសម្រាប់ការព្យាបាលអ្នកជំងឺ ដែលត្រូវបានចាត់ទុកថាមានភាពក្រីក្រខ្លាំងក្នុងការបង់តម្លៃព្យាបាល។ កម្មវត្ថុនៃប្រការនេះ គឺដើម្បីផ្តល់ជូនដល់ជនក្រីក្រនូវលទ្ធភាពទទួលបានសេវាកម្មថែទាំសុខភាពសមរម្យ និងការពារពួកគាត់ពីការធ្លាក់ខ្លួនទៅក្នុងភាពក្រីក្រដែលបណ្តាលមកពីបញ្ហាសុខភាព។ មូលនិធិសមធម៌សុខភាព បានបង្កើតឡើងក្នុងក្របខណ្ឌថ្នាក់ជាតិកាលពីឆ្នាំ២០០៣ និងក្នុងគម្រោងទ្រទ្រង់វិស័យសុខាភិបាលឆ្នាំ២០០៤-២០០៨ ហើយបន្តទៅក្នុងគម្រោងទ្រទ្រង់វិស័យសុខាភិបាលលើកទី២ ឆ្នាំ២០០៩-២០១៣។

[៧] គម្រោងអត្តសញ្ញាណកម្មគ្រួសារក្រីក្រ គឺជាប្រព័ន្ធបទដ្ឋាននៃរាជរដ្ឋាភិបាលកម្ពុជា សម្រាប់ការធ្វើបុរេអត្តសញ្ញាណកម្មគ្រួសារក្រីក្រ។

## ២.៣. សេចក្តីសម្រេចនៃវេទិកាកិច្ចសហប្រតិបត្តិការអភិវឌ្ឍកម្ពុជាលើកទី២ ឆ្នាំ២០០៨

ការសម្រេចរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការចាត់ទុកការគាំពារសង្គមជាអាទិភាពគន្លឹះ បានបង្ហាញឡើងក្នុងឱកាស**វេទិកាកិច្ចសហប្រតិបត្តិការអភិវឌ្ឍកម្ពុជាលើកទី២** នាខែធ្នូ ឆ្នាំ២០០៨។ រាជរដ្ឋាភិបាលបានគូសបញ្ជាក់ថា ក្នុងពេលដែលវឌ្ឍនភាពដ៏គួរឲ្យកត់សម្គាល់កំពុងតែសម្រេចបានក្នុងការកាត់បន្ថយភាពក្រីក្រ ប្រជាជនមួយចំនួននៅតែមានភាពងាយរងគ្រោះដោយសារកលិយុគសេដ្ឋកិច្ចនិងសង្គម ដែលរុញច្រានពួកគាត់ឲ្យធ្លាក់ទៅក្នុងភាពក្រីក្រ និងបង្អាក់ពួកគាត់ពីសមភាពនៃកាលានុវត្តភាពក្នុងការចូលរួមក្នុងកំណើនសេដ្ឋកិច្ច។ ការធ្វើឲ្យប្រសើរឡើងនូវការគាំពារសង្គម ត្រូវបានជ្រើសរើសជាអន្តរាគមន៍អាទិភាពសម្រាប់រាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍ ក្នុងការឆ្លើយតបទៅនឹងកលិយុគ និងជាគោលបំណងក្នុងដំណាក់កាលវែងឆ្ងាយដើម្បីបង្កើនសមត្ថភាពរបស់ប្រជាជន ក្នុងការទប់ទល់ទៅនឹងឥទ្ធិពលនៃព្រឹត្តិហេតុស្រដៀងគ្នាផ្សេងទៀតនាពេលអនាគត។

## ២.៤. សេចក្តីសម្រេចនៃវេទិកាជាតិស្តីពីសន្តិសុខស្បៀងនិងអាហារូបត្ថម្ភ

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ក្នុងឱកាសចូលរួមដ៏ខ្ពង់ខ្ពស់ជាគណៈអធិបតីនៃពិធីបិទ **វេទិកាជាតិស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ក្រោមប្រធានបទបណ្តាញសុវត្ថិភាពសង្គមនៅកម្ពុជា** កាលពីខែកក្កដា ឆ្នាំ២០០៩ បានបញ្ជាក់សាជាថ្មីនូវសេចក្តីតាំងចិត្តរបស់រាជរដ្ឋាភិបាលកម្ពុជាចំពោះវិស័យគាំពារសង្គម និងការបង្កើតឡើងនូវបណ្តាញសុវត្ថិភាពសង្គមក្នុងភាពជាផ្នែកដ៏មានសារៈសំខាន់មួយនៃយុទ្ធសាស្ត្រជំរុញកំណើនក្នុងរយៈពេលយូរ។ ប្រអប់ទី ២ បង្ហាញពីអនុសាសន៍ដ៏ខ្ពង់ខ្ពស់នៃ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី** ។

អង្គវេទិកា បានបញ្ចប់ដោយបានដាក់ចេញនូវអនុសាសន៍មួយចំនួនដូចខាងក្រោម ៖

- សេចក្តីត្រូវការក្នុងការរៀបចំបង្កើតឡើងនូវយុទ្ធសាស្ត្រ ឬគោលនយោបាយជាតិ និងសកម្មភាពការងារសម្រាប់បណ្តាញសុវត្ថិភាពសង្គមដែលមានលក្ខណៈចម្រុះនិងជាប្រព័ន្ធ ក៏ដូចជាការពង្រីកបន្ថែម និងពង្រឹងបណ្តាញសុវត្ថិភាពសង្គមដែលមានស្រាប់នៅកម្ពុជា។
- សារៈសំខាន់នៃការឆ្លើយតបទៅនឹងឥទ្ធិពលនៃកលិយុគ និងការលើកឡើងតម្រូវការរបស់បណ្តាជនងាយរងគ្រោះនៅតំបន់ជនបទ ដែលអាចជួបប្រទះបញ្ហាកង្វះខាតស្បៀងក្នុងកម្រិតគ្រួសារ បណ្តាលមកពីកលិយុគសេដ្ឋកិច្ចសកល និងកំណើនថ្លៃស្បៀងអាហារ។
- ការបង្កើតវិធានការដើម្បីបង្ការ ឆ្លើយតប និងសម្របសម្រួលទៅនឹងកលិយុគដែលអាចកើតមានជាយថាហេតុនៅពេលអនាគត។

- ការពង្រឹងដំណើរការក្នុងការអនុវត្តកម្មវិធីបណ្តាញសុវត្ថិភាពសង្គម តាមរយៈរដ្ឋបាលមូលដ្ឋាន ដើម្បីផ្តល់លទ្ធភាពក្នុងការផ្តល់នូវកិច្ចជំនួយឧបត្ថម្ភដ៏មានប្រសិទ្ធភាព និងតម្លាភាពទៅដល់ក្រុមជនងាយរងគ្រោះ។
- ការពង្រឹងយន្តការក្នុងការធ្វើអត្តសញ្ញាណកម្មគ្រួសារក្រីក្រ និងជនងាយរងគ្រោះ។
- ការអភិវឌ្ឍសមត្ថភាពនៃអាជ្ញាធរគ្រប់កម្រិត ក្នុងការអនុវត្តបណ្តាញសុវត្ថិភាពសង្គមក្នុងលក្ខណៈប្រកបដោយប្រសិទ្ធភាព គណនេយ្យភាព និងតម្លាភាព អនុលោមទៅតាមគោលនយោបាយ និង យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី២។
- ការផ្តល់អាណត្តិការងារដល់ ក.ក.ជ. ក្នុងការទទួលខុសត្រូវលើការសម្របសម្រួលជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ និងដៃគូអភិវឌ្ឍ ក្នុងការរៀបចំបង្កើត និងអនុវត្តកម្មវិធីបណ្តាញសុវត្ថិភាពសង្គម។

**ប្រអប់ទី២. អនុសាសន៍ដ៏ខ្ពង់ខ្ពស់នៃសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា**

"... រាជរដ្ឋាភិបាលបាន និងកំពុងប្រែក្លាយវិបត្តិសេដ្ឋកិច្ច និងហិរញ្ញវត្ថុពិភពលោកនាពេលបច្ចុប្បន្ននេះ ឱ្យទៅជាមេរៀនបទពិសោធ និងកាលានុវត្តភាពសម្រាប់កម្ពុជា តាមរយៈការរិះរកមធ្យោបាយយុទ្ធសាស្ត្រ ជម្រើសគោលនយោបាយ និងយន្តការសម្របសម្រួលនានា ដើម្បីជំរុញដំណើរការអភិវឌ្ឍសង្គមសេដ្ឋកិច្ចជាតិឱ្យរីកលូតលាស់យ៉ាងឆាប់រហ័ស។ ក្នុងន័យនេះ រាជរដ្ឋាភិបាលបាននិងកំពុងបន្តការពង្រឹង និងពង្រីកកិច្ចសហការជាមួយបណ្តាដៃគូអភិវឌ្ឍវិស័យឯកជន និងសង្គមស៊ីវិលដើម្បីបន្តជំរុញការឧបត្ថម្ភគាំទ្រសំដៅលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាជន ឈានទៅកាត់បន្ថយភាពក្រីក្រ និងធានាបាននូវសន្តិសុខស្បៀងជូនប្រជាជន ស្របតាមគោលនយោបាយ និងយុទ្ធសាស្ត្រអភិវឌ្ឍជាតិរបស់រាជរដ្ឋាភិបាលនៅក្នុងនីតិកាលទី ៤ នៃរដ្ឋសភានេះ។ ក្នុងបរិការណ៍នេះ ការពង្រឹង **ប្រព័ន្ធបណ្តាញសុវត្ថិភាពសង្គម** សម្រាប់សង្គ្រោះ និងផ្តល់ឧបត្ថម្ភគាំទ្រដល់ប្រជាជនក្រីក្រ និងជនងាយរងគ្រោះនៅក្នុងសង្គម គឺជាយុទ្ធសាស្ត្រដ៏ចម្បងរបស់រាជរដ្ឋាភិបាល ក្នុងការសម្រាលផលប៉ះពាល់អវិជ្ជមាន និងហានិភ័យទាំងឡាយដែលអាចនឹងកើតមានឡើងដោយសារឥទ្ធិពលនៃវិបត្តិសេដ្ឋកិច្ចពិភពលោក។... "

# ២.៥. ការឯកភាពជាលក្ខណៈអន្តរជាតិ

រាជរដ្ឋាភិបាលកម្ពុជា ជាហត្ថលេខីនៃអនុសញ្ញាអន្តរជាតិមួយចំនួន ដែលផ្តល់នូវក្របខណ្ឌផ្លូវច្បាប់ដល់ការទទួលស្គាល់សិទ្ធិទទួលបានការគាំពារសង្គម និងការជំរុញឲ្យមានការផ្តល់ឧបត្ថម្ភកិច្ចគាំពារសង្គមដល់ប្រជាពលរដ្ឋ។ ក្នុងចំណោមអនុសញ្ញាទាំងនោះ រួមមាន ៖

- សេចក្តីថ្លែងការណ៍ជាសកលស្តីពីសិទ្ធិមនុស្ស
- អនុសញ្ញានៃអង្គការសហប្រជាជាតិស្តីពីសិទ្ធិកុមារ
- អនុសញ្ញាអន្តរជាតិស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងនារីភេទ

- កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌
- អនុសញ្ញាស្តីពីសិទ្ធិជនពិការ
- ផែនការសកម្មភាពអន្តរជាតិទីក្រុងម៉ាឌ្រីតស្តីពីមនុស្សចាស់

ព្រះរាជាណាចក្រកម្ពុជាក៏បានផ្តល់សច្ចាប័នលើគ្រប់បទដ្ឋានពលកម្មស្នូល ក៏ដូចជាអនុសញ្ញាមួយចំនួននៃអង្គការពលកម្មអន្តរជាតិ រួមមានអនុសញ្ញាលេខ១៣៨ ស្តីពីការកំណត់អាយុអប្បបរមាក្នុងការចូលធ្វើការងារ និងអនុសញ្ញាលេខ១៨២ ស្តីពីការលុបបំបាត់រាល់ទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារ។

# ជំពូកទី៣

# ស្ថានភាព

# នៃភាពក្រីក្រ

# និងភាពងាយរងគ្រោះ

# ជំពូកទី៣

# ស្ថានភាពនៃភាពក្រីក្រនិងភាពងាយរងគ្រោះ[៨]

ព្រះរាជាណាចក្រកម្ពុជាមានកំណើនសេដ្ឋកិច្ចគួរឲ្យកត់សម្គាល់ ក្នុងអំឡុងពេលមួយទសវត្សកន្លងទៅ។ ទិន្នន័យដែលគ្របដណ្តប់ទូទាំងប្រទេសសម្រាប់ឆ្នាំ២០០៤និង២០០៧បង្ហាញថា អត្រាភាពក្រីក្រសម្រាប់ទូទាំងប្រទេសធៀបនឹងខ្សែបន្ទាត់រួមនៃភាពក្រីក្រ បានធ្លាក់ចុះពី៣៤,៧% នៅឆ្នាំ២០០៤ មកត្រឹម៣០,១%នៅឆ្នាំ២០០៧ ដែលបញ្ជាក់ឲ្យឃើញពីការធ្លាក់ចុះនៃភាពក្រីក្រប្រមាណ ១,២%ក្នុងមួយឆ្នាំ ហើយនៅឆ្នាំ២០១០ អត្រានៃភាពក្រីក្រធ្លាក់ចុះនៅត្រឹម២៥,៨% (ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្ម ២០០៩-២០១៣ និងប្រព័ន្ធទិន្នន័យថ្នាក់ឃុំ ឆ្នាំ២០០៩)។ ប៉ុន្តែគម្លាតរវាងអ្នកមាននិងអ្នកក្រ ជាពិសេសវិសមភាពរវាងទីប្រជុំជននិងជនបទ នៅតែជាបញ្ហាប្រឈមនៅឡើយ។

**រូបទី៤. ភាពក្រីក្ររាប់តាមចំនួនមនុស្ស ឆ្នាំ ១៩៩៤-២០០៧**




ប្រភព : ការអង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជា (២០០៤) និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ បច្ចុប្បន្នកម្ម ២០០៩-២០១៣

ភាពក្រីក្រមានលក្ខណៈផ្សេងៗគ្នា ពីតំបន់មួយទៅតំបន់មួយ។ ទិន្នន័យតាមតំបន់ចុងក្រោយបំផុតនៅឆ្នាំ២០១០ដែលប្រើប្រាស់ប្រភពទិន្នន័យថ្នាក់ឃុំ បានបង្ហាញថាតំបន់បឹងទន្លេសាប និងតំបន់

[៨] ឯកសារយោងសម្រាប់ការពិពណ៌នាពីជនក្រីក្រ និងជនងាយរងគ្រោះ មានក្នុងឯកសារមូលដ្ឋាននៃយ.ជ.គ.ស.។

ខ្ពង់រាបនិងតំបន់ភ្នំ មានអត្រានៃភាពក្រីក្រខ្ពស់បំផុតបើរាប់តាមចំនួនមនុស្ស (តំបន់ខ្ពង់រាបនិងតំបន់ភ្នំមាន៣៦,៦% តំបន់បឹងទន្លេសាបមាន៣០,៨% តំបន់វាលទំនាបមាន២២,១% និងតំបន់ឆ្នេរសមុទ្រមាន២១,៣% ធៀបនឹងអត្រាមធ្យមភាគជាតិ២៥,៨% នៅឆ្នាំ២០១០)[៩]។

## រូបទី៨. ភាពខុសគ្នានៃអត្រាភាពក្រីក្រតាមតំបន់ភូមិសាស្ត្រ




ប្រភព ៖ ប្រភពទិន្នន័យថ្នាក់ឃុំ (២០០៩)

ចាប់តាំងពីដំណាក់កាលនៃការប្រមូលទិន្នន័យស្ដីពីភាពក្រីក្រនេះ ព្រះរាជាណាចក្រកម្ពុជាបានរងការប៉ះទង្គិចដោយសារកលិយុគសេដ្ឋកិច្ចសកល ដែលបន្តប៉ះពាល់ដល់លទ្ធភាពរបស់ប្រជាជនក្រីក្រនិងជនងាយរងគ្រោះ ក្នុងការទប់ទល់នឹងវិបត្តិមួយចំនួន ដូចជាវិបត្តិស្បៀងនិងប្រេង។ ផលប៉ះពាល់ពីវិបត្តិទាំងនេះមានភាពស្មុគស្មាញ និងធ្វើឲ្យប៉ះពាល់ដល់ជីវភាពនិងសុខុមាលភាពរបស់ប្រជាជនជាច្រើន ជាពិសេសប្រជាជនដែលរស់នៅក្បែរឬក្រោមបន្ទាត់នៃភាពក្រីក្រ។

[៩] ទិន្នន័យដែលប្រើប្រាស់នៅក្នុងជំពូកនេះ ត្រូវបានដកស្រង់ចេញពីឯកសារដែលបានធ្វើបច្ចុប្បន្នកម្មចុងក្រោយបំផុតតាមដែលអាចរកបាន ប៉ុន្តែដោយសារការអង្កេតមួយចំនួនត្រូវបានធ្វើឡើងតាំងពីឆ្នាំ២០០៥ ឬ២០០៨ ដូច្នេះទើបធ្វើឲ្យការបកស្រាយមួយចំនួនអាចនឹងពុំឆ្លុះបញ្ចាំងពីវឌ្ឍនភាពនៃស្ថានភាពនាពេលបច្ចុប្បន្ន។

## ៣.១. ហានិភ័យ វិបត្តិ និងភាពងាយរងគ្រោះ

នៅពេលគ្រួសារមួយប្រឈមនឹងហានិភ័យ គ្រួសារនោះនឹងស្ថិតក្នុងស្ថានភាពកាន់តែងាយរងគ្រោះ និងរុញច្រានឲ្យធ្លាក់ចូលទៅក្នុងភាពក្រីក្រ។ នៅពេលដែលហានិភ័យទាំងនេះកើតមានឡើង គ្រួសារដែលជួបនឹងវិបត្តិនេះ អាចនឹងផ្លាស់ប្តូរស្ថានភាពសេដ្ឋកិច្ចសង្គមកិច្ចរបស់ខ្លួនទាំងស្រុង។ កម្រិតនៃការផ្លាស់ប្តូរនេះអាចកើតមានឡើង អាស្រ័យលើទំហំនៃភាពងាយរងគ្រោះរបស់គ្រួសារនោះ។ ភាពងាយរងគ្រោះរបស់មនុស្សម្នាក់ៗឬគ្រួសារនីមួយៗ អាស្រ័យលើកម្រិតនៃការប្រឈម និងលទ្ធភាពរបស់ពួកគាត់ក្នុងការដោះស្រាយវិបត្តិនោះ។

ភាពក្រីក្រនិងភាពងាយរងគ្រោះ មានទំនាក់ទំនងគ្នាយ៉ាងខ្លាំង។ ភាពងាយរងគ្រោះ ជាមូលហេតុនៃភាពក្រីក្រ ព្រមទាំងជាសមាសធាតុដែលកំណត់ និងបង្កើនភាពក្រីក្រនេះ។ គ្រួសារក្រីក្រហាក់ដូចជាមានយុទ្ធសាស្ត្រតិចតួច ដើម្បីដោះស្រាយ និងទប់ទល់ទៅនឹងវិបត្តិទាំងនេះ ហើយគ្រួសារងាយរងគ្រោះអាចនឹងងាយរងឥទ្ធិពលដែលអាចជំរុញឲ្យធ្លាក់ចូលក្នុងភាពក្រីក្រ។

**រូបទី៦. ភាពក្រីក្រ និងភាពងាយរងគ្រោះ**




ហានិភ័យ និងវិបត្តិសំខាន់ៗ អាចដាក់បញ្ចូលជាបួនប្រភេទគឺ ៖ ១) គ្រោះអាសន្ន និងវិបត្តិ ២) ឧបសគ្គក្នុងការអភិវឌ្ឍធនធានមនុស្ស ៣) និកម្មភាពតាមរដូវកាល និងកង្វះខាតឱកាសប្រកបរបរចិញ្ចឹមជីវិត និង ៤) វិបត្តិផ្នែកសុខភាព។

## ៣.១.១. គ្រោះអាសន្ននិងវិបត្តិ

សេដ្ឋកិច្ចនិងជីវភាពគ្រួសារក្នុងព្រះរាជាណាចក្រកម្ពុជា បានរងការប៉ះទង្គិចដោយ **វិបត្តិស្បៀងអាហារ ប្រេងឥន្ធនៈ ហិរញ្ញវត្ថុ និងសេដ្ឋកិច្ច** នាពេលថ្មីៗនេះ។ ដោយសារព្រះរាជាណាចក្រកម្ពុជាធ្វើសមាហរណកម្មទៅក្នុងសេដ្ឋកិច្ចពិភពលោក ដូច្នេះព្រះរាជាណាចក្រកម្ពុជាអាចរងផលប៉ះពាល់វិបត្តិសេដ្ឋកិច្ចពីខាងក្រៅ។

ផលប៉ះពាល់នៃបម្រែបម្រួលថ្លៃស្បៀងនិងគ្រឿងឧបភោគមួយចំនួន គឺជាបញ្ហាស្មុគស្មាញមួយ ហើយការសិក្សាស្តីពីផលប៉ះពាល់នៃកំណើនថ្លៃទៅលើភាពក្រីក្រក្នុងឆ្នាំ២០០៧និងឆ្នាំ២០០៨ (ថ្លៃអង្ករដែលជាស្បៀងចាំបាច់របស់កម្ពុជាបានកើនឡើងប្រហែល១០០%ក្នុងរវាងឆ្នាំ២០០៧ និងឆ្នាំ២០០៨) នៅមិនទាន់បានវិភាគឃើញនៅឡើយ (ការវិភាគលើព័ត៌មានប្រមូលបានពីការអង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជាឆ្នាំ២០០៨)។ ថ្លៃអង្ករបានកើនឡើងទ្វេដងនៅទីផ្សារអន្តរជាតិនៅក្នុងចន្លោះត្រីមាសទី១ឆ្នាំ២០០៧ និងត្រីមាសទី១ឆ្នាំ២០០៨ ហើយបានកើនឡើងទ្វេដងជាថ្មីម្តងទៀតតែនៅក្នុង៤ខែដំបូងនៃឆ្នាំ២០០៨។ ប្រជាជនក្រីក្រដែលជាអ្នកទិញស្បៀងអាហារសុទ្ធសាធ មានលទ្ធភាពតិចតួចណាស់ក្នុងការដោះស្រាយ នៅពេលដែលថ្លៃអង្ករកើនឡើងគំហុក។ ប្រជាជនមួយចំនួនបានទទួលផលចំណេញពីកលិយុគនេះ (ដូចជាអ្នកលក់អង្ករ អ្នកលក់ប្រេងឥន្ធនៈ និងអ្នកលក់កម្លាំងពលកម្មក្នុងការងារកសិកម្ម)។

គ្រួសារក្រីក្រនិងងាយរងគ្រោះ បានទទួលរងផលប៉ះពាល់ដោយសារកលិយុគសេដ្ឋកិច្ច ពិសេសផលប៉ះពាល់លើភាពក្រីក្រនិងសង្គម ហើយស្ថិតក្នុងកាលៈទេសៈនៃឧបសគ្គ។ ស្ត្រីជាច្រើនអាចរងផលប៉ះពាល់ខ្លាំងពីវិបត្តិនេះ ដោយសារការបាត់បង់ការងារយ៉ាងច្រើននៅក្នុងវិស័យឧស្សាហកម្មកម្មន្តសាល (ដែលភាគច្រើនជាកម្មការិនី) អំពើហិង្សាក្នុងគ្រួសារកើតមានច្រើន និងភាពងាយរងគ្រោះដោយសារការជួញដូរកម្លាំងពលកម្ម និងការកេងប្រវញ្ចផ្លូវភេទ។ កម្មករដែលពុំមានជំនាញខ្ពស់ ក៏ទទួលរងគ្រោះពីវិបត្តិនេះដែរ ពិសេសកម្មករដែលធ្វើការក្នុងវិស័យសំណង់។ ផលប៉ះពាល់នៃវិបត្តិសេដ្ឋកិច្ចនាពេលបច្ចុប្បន្នលើកុមារមកពីគ្រួសារក្រីក្រនិងងាយរងគ្រោះ ក៏អាចមានច្រើនគួរឲ្យកត់សម្គាល់ដែរ ដែលធ្វើឲ្យមានហានិភ័យនៃកំណើនពលកម្មកុមារ ហើយធ្វើឲ្យគ្រួសារក្រីក្រផ្លាស់ប្តូរមកទទួលទានអាហារដែលមានតម្លៃអាហារូបត្ថម្ភតិចតួច និងពន្យារពេលទៅព្យាបាលជំងឺ។

ព្រះរាជាណាចក្រកម្ពុជាក៏មានភាពងាយរងគ្រោះទៅនឹង **មហន្តរាយធម្មជាតិ** ដោយសារលក្ខណៈពិសេសនៃរបបទឹក និងកង្វះហេដ្ឋារចនាសម្ព័ន្ធគ្រប់គ្រងទឹក។ គ្រោះធម្មជាតិទាំងនេះប៉ះពាល់ដល់ជីវភាពរស់នៅរបស់ប្រជាជននិងសន្តិសុខស្បៀង ហើយធ្វើឲ្យប៉ះពាល់ជាអវិជ្ជមានដល់ការរស់នៅ

របស់ប្រជាជន ដែលជំរុញឲ្យប្រជាជនជាច្រើនធ្លាក់ចូលក្នុងភាពក្រីក្រ។ គ្រួសារភាគច្រើនបំផុតនៅជនបទ ពឹងផ្អែកទាំងស្រុងលើកសិកម្មចិញ្ចឹមជីវិត ពោលគឺប្រជាជនកម្ពុជាប្រមាណ៧២% ពឹងផ្អែកទាំងស្រុងលើការនេសាទនិងកសិកម្មសម្រាប់ជីវភាពរស់នៅរបស់ពួកគាត់។ ការនេសាទនិងកសិកម្ម (ដែលជាប្រភពនៃសន្តិសុខស្បៀងរបស់គ្រួសារ) ត្រូវពឹងផ្អែកយ៉ាងខ្លាំងលើលក្ខខណ្ឌអាកាសធាតុ និងអាចប្រែប្រួលពីមួយឆ្នាំទៅមួយឆ្នាំ។

អំឡុងមួយទសវត្សរ៍កន្លងទៅ ទឹកជំនន់និងគ្រោះរាំងស្ងួតខុសពីធម្មតា បានប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់តំបន់ជនបទភាគច្រើន ដែលធ្វើឲ្យប៉ះពាល់ជាអវិជ្ជមានលើផលិតផលកសិកម្មក្នុងរយៈពេល ៣ ឆ្នាំ (ឆ្នាំ២០០០ ២០០២ និង២០០៤)។ នៅឆ្នាំ២០០៩ ខ្យល់ព្យុះកេតសាណា បានធ្វើឲ្យមនុស្សស្លាប់ចំនួន៤៣នាក់ និងរបួសធ្ងន់ចំនួន៦៧នាក់ ព្រមទាំងធ្វើឲ្យខូចខាតផ្ទះសំបែង ទ្រព្យសម្បត្តិ និងជីវភាពរស់នៅរបស់ប្រជាជនចំនួន៤៩ ០០០គ្រួសារ ឬប្រជាជនចំនួន១៨០ ០០០នាក់ (ស្មើនឹង១,៤% នៃចំនួនប្រជាជនសរុប)។ ស្រុកភាគច្រើនដែលទទួលរងផលប៉ះពាល់ គឺជាស្រុកដែលមានប្រជាជនក្រីក្របំផុតនៅប្រទេសកម្ពុជា ហើយការខូចខាតយ៉ាងច្រើនលើទ្រព្យសម្បត្តិ ជីវភាពរស់នៅ និងហេដ្ឋារចនាសម្ព័ន្ធសាធារណៈ នឹងបង្កឲ្យមានការប៉ះពាល់ដល់ជីវភាពរស់នៅរបស់សហគមន៍ ក្នុងរយៈពេលវែង (គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ឆ្នាំ២០១០)។

ទឹកជំនន់ និងគ្រោះរាំងស្ងួត គឺជាវិបត្តិដ៏ចម្បងបំផុតសម្រាប់គ្រួសារក្រីក្រ ហើយ **ការប្រែប្រួលអាកាសធាតុ** នឹងធ្វើឲ្យមានភាពធ្ងន់ធ្ងរពីវិបត្តិទាំងនេះកើនឡើងខ្ពស់មួយកម្រិតទៀត។ ទោះបីតំបន់ជាច្រើនក្នុងប្រទេសកម្ពុជា មានលក្ខណសម្បត្តិការពារពីគ្រោះថ្នាក់បណ្តាលមកពីអាកាសធាតុ តែបណ្តាខេត្តស្ទើរតែទាំងអស់អាចនឹងងាយរងគ្រោះខ្លាំងពីផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ ដោយសារតែសមត្ថភាពសម្របខ្លួនទាប ដែលបណ្តាលមកពីបញ្ហាហិរញ្ញវត្ថុ បច្ចេកវិទ្យា ហេដ្ឋារចនាសម្ព័ន្ធ និងបញ្ហាស្ថាប័ន។ ផលប៉ះពាល់របស់ការប្រែប្រួលអាកាសធាតុនេះ នឹងបង្កឲ្យមានផលវិបាកគួរឲ្យកត់សម្គាល់មួយចំនួនដល់សន្តិសុខស្បៀង។

ប្រជាជនមួយចំនួនត្រូវការជំនួយពិសេសក្នុងពេលមានវិបត្តិ ដោយសារសមត្ថភាពរបស់ពួកគាត់នៅមានកម្រិតដើម្បីជួយខ្លួនឯង។ ជាពិសេស ប្រសិនបើប្រជាជនទាំងនោះមិនត្រូវបានរួមបញ្ចូលទៅក្នុងបណ្តាញសង្គមនោះទេ ពួកគាត់នឹងជួបការលំបាកក្នុងការវិលត្រឡប់មកកាន់ស្ថានភាពដើមវិញ ហើយពួកគាត់នឹងត្រូវការអន្តរាគមន៍ជាបន្ទាន់ ដើម្បីធានាលទ្ធភាពទទួលបានសេវាជាប្រចាំដើម្បីរស់រានមានជីវិត (ឧទាហរណ៍ លទ្ធភាពទទួលបានឱសថប្រឆាំងនឹងមេរោគអេដស៍ ការស្តារលទ្ធភាពពលកម្ម ។ល។)។

## ៣.១.២. បញ្ហាអភិវឌ្ឍន៍មនុស្ស

វិបត្តិដែលអាចកើតមានជាលក្ខណៈបុគ្គលនៅក្នុង **វដ្តជីវិត** ក៏មានផលប៉ះពាល់ជាអវិជ្ជមានលើការអភិវឌ្ឍមនុស្សដែរ។ កង្វះអាហារូបត្ថម្ភ បណ្តាលមកពី**ទម្លាប់ផ្តល់ចំណីអាហារមិនបានគ្រប់គ្រាន់ដល់ទារក និងកុមារ កម្រិតខ្ពស់នៃជំងឺឆ្លងរាគរូស និងអសមត្ថភាពក្នុងការទទួលបាន និងលទ្ធភាពទិញចំណីអាហារដែលមានជីវជាតិគ្រប់គ្រាន់**។ ទោះបីជាមានកិច្ចខិតខំប្រឹងប្រែងដោះស្រាយបុព្វហេតុសំខាន់ៗ ដែលបង្កឲ្យមានកង្វះអាហារូបត្ថម្ភយ៉ាងណាក៏ដោយ ក៏អត្រាកុមារស្គមស្គាំង (៨,៩%) កុមារក្រិន (៣៩,៥%) និងកុមារទម្ងន់ស្រាល (២៨,៨%) នៅតែស្ថិតក្នុងកម្រិតខ្ពស់ (ការអង្កេតមនុស្សសាស្ត្រកម្ពុជា ឆ្នាំ២០០៨)។

ដោយ **អនក្ខរភាព** ជាប្រភពមួយនៃភាពងាយរងគ្រោះ **លទ្ធភាពទទួលបានការអប់រំប្រកបដោយគុណភាព** នៅតែជាអាទិភាពដែលក្រសួងអប់រំ យុវជន និងកីឡា ត្រូវបន្តដោះស្រាយ ក្នុងនោះរួមមាន អគារសិក្សានៅមូលដ្ឋាន សៀវភៅសិក្សា និងការផ្តល់គ្រូបង្រៀនឲ្យបានគ្រប់គ្រាន់។ តាមស្ថិតិក្រសួងអប់រំ យុវជន និងកីឡា ក្នុងឆ្នាំសិក្សា២០០៩-២០១០ អត្រាពិតនៃការសិក្សានៅកម្រិតបឋមសិក្សាមាន ៩៤.៨% នៅកម្រិតមធ្យមសិក្សាបឋមភូមិមាន៣១.៩% និងនៅកម្រិតមធ្យមសិក្សាទុតិយភូមិមាន ១៩.៤%។ អត្រាត្រួតថ្នាក់ និងអត្រាបោះបង់ការសិក្សានៅកម្រិតបឋមសិក្សា នៅតែជាកង្វល់របស់ក្រសួងអប់រំ យុវជន និងកីឡា ដែលទាមទារឲ្យមានការកាត់បន្ថយបន្ថែមទៀត ឲ្យស្ថិតនៅក្រោម ១០%។ ជាមធ្យម សិស្សដែលអាចបន្តការសិក្សារហូតដល់បញ្ចប់ភូមិសិក្សាបឋមសិក្សាមាន៨៣% មធ្យមសិក្សាបឋមភូមិមាន៤៨.៧% និងមធ្យមសិក្សាទុតិយភូមិមាន២៦%។ គ្រូម្នាក់ត្រូវបង្រៀនសិស្សចំនួន៤៩នាក់នៅកម្រិតបឋមសិក្សា ២៤នាក់នៅកម្រិតមធ្យមសិក្សាបឋមភូមិ និង២៩នាក់នៅកម្រិតមធ្យមសិក្សាទុតិយភូមិ។ កុមាររស់នៅតាមតំបន់ជនបទ ដែលអាចបន្តការសិក្សាទៅកម្រិតមធ្យមសិក្សាបឋមភូមិបាន មានចំនួនតិចជាងពីរដងនៃកុមាររស់នៅក្នុងរាជធានីភ្នំពេញ (២៥%នៃកុមាររស់នៅតំបន់ជនបទ និង៦១%នៃកុមាររស់នៅរាជធានីភ្នំពេញ)។

## ៣.១.៣. ភាពងាយរងគ្រោះនៅនឹងនិកម្មភាព និងអសន្តិសុខស្បៀង

កម្លាំងពលកម្ម មានការប្រែប្រួលយ៉ាងខ្លាំងក្នុងអំឡុងទសវត្សចុងក្រោយនេះ។ នៅឆ្នាំ២០១០ ប្រជាជនដែលមានអាយុលើសពី១៥ឆ្នាំ មានសមមាត្រស្មើនឹង៦១,៨%នៃប្រជាជនសរុប។ អត្រាកម្លាំងពលកម្មដែលជាយុវជន បានធ្លាក់ចុះបន្តិចពី៦០,៧%នៅឆ្នាំ១៩៩៨ មក៦០,១%នៅឆ្នាំ២០០៨ ដែលឆ្លុះបញ្ចាំងឲ្យឃើញពីនិន្នាការវិជ្ជមាននៃការចំណាយពេលកាន់តែយូររបស់យុវជន នៅក្នុងប្រព័ន្ធអប់រំ។

យោងតាមរបាយការណ៍ស្តីពី**និន្នាការសង្គមនិងពលកម្ម ឆ្នាំ២០១០** របស់ក្រសួងផែនការ និកម្មភាពមានអត្រាទាបនៅកម្ពុជា។ ប៉ុន្តែ កម្មករប្រហែល៨២,៥% បន្តស្ថិតក្នុង **ការងារដែលមានភាពងាយរងគ្រោះ** រួមមានការងារក្នុងគ្រួសារដោយពុំគិតប្រាក់កម្រៃ និងកម្មករធ្វើការឲ្យខ្លួនឯង។ អត្រាកុមារមិនបានចូលរៀននៅមានកម្រិត១៥%ក្នុងឆ្នាំ២០១០នេះ ទោះបីអត្រានេះបានធ្លាក់ចុះពី១៨,៧%ក្នុងឆ្នាំ២០០៥។ នេះជាបញ្ហាសំខាន់មួយ ដោយសារកុមារដែលមិនបានចូលរៀនទាំងនេះ នឹងចូលប្រឡូកក្នុងទីផ្សារពលកម្ម ដែលទទួលបានការងារនិងប្រាក់ចំណូលទាប។ ក្នុងបរិបទនៃទំនាក់ទំនងទៅនឹងការអប់រំ យុវជនត្រូវប្រឈមទៅនឹងហានិភ័យពីរ គឺ**ការលំបាកក្នុងការស្វែងរកឱកាសការងារ**ចំពោះយុវជនដែលបោះបង់ការសិក្សានិងដែលពុំបានចូលរៀន និង**ភាពមិនត្រូវគ្នារវាងមុខជំនាញដែលបានរៀនជាមួយនឹងតម្រូវការទីផ្សារការងារ** ចំពោះយុវជនដែលបានចូលរៀន តែដែលមានកាលានុវត្តភាពទាបក្នុងការទទួលបានឱកាសការងារ។ សមមាត្រនៃអនក្ខរជន និងជនដែលមិនបានរៀនចប់កម្រិតសិក្សាបឋមសិក្សាដែលមានអាយុលើសពី ១៥ឆ្នាំ ក្នុងចំណោមជនដែលមានការងារធ្វើ បានធ្លាក់ចុះពី៧១,៦%នៅឆ្នាំ១៩៩៨ មកនៅ ៥៨,៨% នៅឆ្នាំ២០០៨ ប៉ុន្តែតួរលេខនេះនៅតែជាអត្រាដែលមានកម្រិតខ្ពស់។ កម្មករដែលគ្មានជំនាញ ជាក្រុមជនងាយរងគ្រោះដែលរងសម្ពាធធ្ងន់ធ្ងរក្នុងការស្វែងរកការងារ ហើយភាគច្រើនពួកគាត់នឹងទទួលបានការងារដែលពុំសូវមានសុវត្ថិភាពនិងមានអចាវរភាព (ដែលមិនទៀងទាត់ហើយងាយនឹងបាត់បង់ទៅវិញ) និងទទួលបានប្រាក់ឈ្នួលទាប។

បញ្ហាប្រឈមជាមូលដ្ឋានសម្រាប់វិស័យការងារនៅព្រះរាជាណាចក្រកម្ពុជា គឺតម្រូវការបង្កើន **កំណើនផលិតភាពការងារ** និងការធានាឲ្យបានថាកំណើននេះនឹងត្រូវដើរទន្ទឹមគ្នាជាមួយនឹងការធ្វើឲ្យប្រសើរឡើងនៃលក្ខខណ្ឌការងារ និងកំណើនប្រាក់កម្រៃការងារ។ កំណើននៃផលិតភាពការងារក្នុងវិស័យកសិកម្មដែលជាវិស័យផ្តល់ការងារធំជាងគេ (៧២,១%នៃអ្នកមានការងារ) មានត្រឹម១,៧% ប៉ុណ្ណោះ គិតជាមធ្យមប្រចាំឆ្នាំ (របាយការណ៍ស្តីពីនិន្នាការសង្គមនិងពលកម្ម ឆ្នាំ២០១០ របស់ក្រសួងផែនការ)។

នៅក្នុងឯកសារ**គោលនយោបាយជំរុញផលិតកម្មស្រូវនិងការនាំចេញអង្ករ** ដែលរៀបចំដោយឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ បានគូសបញ្ជាក់ថាជាមួយនឹងផលិតកម្មស្រូវបាន៧,៥៩លានតោន ព្រះរាជាណាចក្រកម្ពុជាមានលទ្ធភាពផ្គត់ផ្គង់តម្រូវការក្នុងស្រុកនិងអាចនាំចេញស្រូវទៅក្រៅប្រទេសប្រមាណ ៣,៥១លានតោន នៅក្នុងឆ្នាំ២០០៩។ នេះសរបញ្ជាក់ថាព្រះរាជាណាចក្រកម្ពុជាមានលទ្ធភាពគ្រប់គ្រាន់ក្នុងការធានាសន្តិសុខស្បៀងនៅកម្រិតថ្នាក់ជាតិ។

**អសន្តិសុខស្បៀង** នៅកម្រិតថ្នាក់គ្រួសារ និងសហគមន៍អាចកើតមានឡើងដោយមានឫសគល់ចេញពីភាពក្រីក្ររ៉ាំរ៉ៃ។ ចំនួនប្រជាជនជួបប្រទះនឹងបញ្ហាអសន្តិសុខស្បៀង កើតឡើងក្នុងអំឡុងរដូវខ្វះខាត និងនៅពេលមានគ្រោះធម្មជាតិ មហន្តរាយ និងគ្រោះអាសន្ន។ ក្នុងចំណោមប្រជាជនក្រីក្ររស់នៅតំបន់ជនបទ មូលហេតុសំខាន់ៗដែលបណ្តាលឲ្យមានអសន្តិសុខស្បៀង គឺកង្វះខាតដីធ្លី សត្វចិញ្ចឹម ឥណទាន ទីផ្សារ ទុន និងសម្ភារៈកសិកម្ម។ គ្រួសារក្រីក្រនៅតាមតំបន់ជនបទភាគច្រើនពឹងផ្អែកតែលើការផលិតស្បៀងអាហារបានត្រឹមចិញ្ចឹមជីវិត និងការលក់កម្លាំងពលកម្មដែលទទួលបានប្រាក់ឈ្នួលទាបនិងមិនទៀងទាត់។

ប្រជាជនក្រីក្រភាគច្រើនរស់នៅតាមតំបន់ជនបទ។ ភាពក្រីក្រពាក់ព័ន្ធនឹងផលិតភាពទាបនៃវិស័យកសិកម្ម និងកាលានុវត្តភាពនៃការប្រកបរបរចិញ្ចឹមជីវិតដែលមានជម្រើសតិចតួច។ តម្រូវការកម្លាំងពលកម្មតាមរដូវកាលក្នុងវិស័យកសិកម្ម ជំរុញឲ្យគ្រួសារជាច្រើន ជាពិសេសគ្រួសារដែលមានដីតិចតួចឬគ្មានដីធ្លីសោះ ត្រូវបង្ខំចិត្តស្វែងរកការងារក្រៅពីកសិកម្មនៅរដូវ ដែលមិនសូវសម្បូរការងារកសិកម្ម ដើម្បីរកប្រាក់ចំណូលបន្ថែមផ្គត់ផ្គង់គ្រួសាររបស់ខ្លួន។ ដោយសារការងារក្រៅពីកសិកម្មនៅមានកម្រិតចង្អៀត គ្រួសារជាច្រើន ជាពិសេសគ្រួសារដែលមានដីតិចតួចឬគ្មានដីសោះ ចាំបាច់ត្រូវពឹងផ្អែកលើប្រាក់ចំណូលដែលទទួលបានពីការងារគ្មានជំនាញច្បាស់លាស់នៅតំបន់ប្រជុំជន ឬប្រទេសជិតខាង ដោយទទួលបានប្រាក់ឈ្នួលតិចតួច។ ការធ្វើចំណាកស្រុកដោយប្រថុយប្រថានរបស់កម្មករតាមរដូវកាល គឺជាបញ្ហាដែលកើតមានជាប្រចាំ ជាពិសេសនៅតាមបណ្តាខេត្តដែលនៅជិតព្រំដែនថៃ និងវៀតណាម។

## ៣.១.៤. វិបត្តិផ្នែកសុខភាព

**វិបត្តិសុខភាព**ប៉ះពាល់ដល់ប្រជាជនក្រីក្រជាច្រើន ដោយសារកត្តាបីយ៉ាង។ ទីមួយ ប្រជាជនក្រីក្រអាចមានប្រេវ៉ាឡង់នៃជំងឺឆ្លង ឧប្បត្តិហេតុនៃការរងរបួស និងជំងឺផ្សេងៗ ខ្ពស់ជាងប្រជាជនដែលពុំក្រីក្រ ដោយសារជាញឹកញយជនក្រីក្រត្រូវធ្វើការងារដោយប្រើកម្លាំងដែលប្រឈមនឹងហានិភ័យខ្ពស់ បណ្តាលឲ្យមានគ្រោះថ្នាក់និងរងរបួស ការទទួលទានអាហារពុំសូវមានជីវជាតិ ការប្រើទឹកមិនស្អាត និងមិនមានអនាម័យល្អ[១០] រស់នៅផ្ទះសំបែងមិនសមរម្យ ហើយមានលទ្ធភាពតិចតួចក្នុងការទទួលបានសេវាថែទាំសុខភាពនិងសង្គម។ ទីពីរ គឺប្រជាជនក្រីក្រត្រូវរងផលប៉ះពាល់តាមរយៈប្រាក់ចំណូលមិនគ្រប់គ្រាន់ ហើយគ្មានលទ្ធភាពសន្សំប្រាក់។ ទីបី គឺគ្រួសារក្រីក្រនឹងធ្លាក់ចូលក្នុងស្ថានភាពមិនល្អ ១) ការចំណាយក្នុងការថែទាំសុខភាពខ្ពស់ ២) ការចំណាយអស់ប្រាក់ពីក្នុងគ្រួសារលើសេវាថែទាំសុខភាព

[១០] គ្រួសារក្រីក្រចំនួនពាក់កណ្តាលនៃបញ្ជាភាគប្រជាជនក្រីក្របំផុត មិនមានលទ្ធភាពប្រើប្រាស់ប្រភពទឹកដែលបានកែលម្អហើយនោះទេ ហើយគ្រួសារក្រីក្រចំនួន៨៧,២%រស់នៅកន្លែងគខ្វក់ខ្វះអនាម័យ។

៣) ការជំពាក់បំណុលដែលមានអត្រាការប្រាក់ខ្ពស់នៅពេលគ្រួសារខ្វះធនធាន[១១] និង ៤) ការលក់ទ្រព្យសម្បត្តិ (ជាធម្មតាដីធ្លី) បន្ទាប់ពីចំណាយប្រាក់អស់។ នៅពេលដែលស្ថានភាពនៃភាពក្រីក្រដោយសារវិបត្តិសុខភាពនេះចាប់ផ្តើម គ្រួសារក្រីក្រនឹងមានការលំបាកក្នុង ការចាកចេញពីស្ថានភាពនេះណាស់ ដូចនេះប្រការសំខាន់គឺត្រូវគាំពារគ្រួសារកុំឲ្យធ្លាក់ចូលទៅក្នុងស្ថានភាពនេះ ដោយចាប់ផ្តើមដោះស្រាយចំណាយលើការថែទាំសុខភាព និង**ការចំណាយប្រាក់អស់ពីក្នុងគ្រួសារ**។

មកទល់បច្ចុប្បន្ននេះ វឌ្ឍនភាពក្នុងការលើកកម្ពស់ការផ្តល់សេវាសុខភាព មានសភាពធំធេង គួរឲ្យកោតសរសើរ។ រាជរដ្ឋាភិបាលកម្ពុជាបានប្រកាន់យកនូវ **អនុក្រមគ្រប់គ្រងទូទាំងវិស័យ** ដើម្បីតម្រង់ទិសដល់ការអភិវឌ្ឍនៃវិស័យ។ គិតមកដល់ឆ្នាំ២០០៨ មូលដ្ឋានសុខាភិបាលជួរមុខដែលផ្តល់**សំណុំសកម្មភាពអប្បបរមា** រួមមានមណ្ឌលសុខភាព និងប៉ុស្តសុខភាព បានកើនចំនួនរហូតដល់៩៦៧ និង ១០៨ ដោយមានទីតាំងក្នុងតំបន់ជនបទដាច់ស្រយាល ហើយចំនួនមន្ទីរពេទ្យបង្អែកបានកើនឡើងដល់ ៨៤។ ទោះជាយ៉ាងណា **ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ បច្ចុប្បន្នកម្ម២០០៩-២០១៣** ក៏បានទទួលស្គាល់ថាបញ្ហាមួយចំនួន នៅកើតមានឡើងក្នុងការផ្តល់សេវាសុខាភិបាលជូនប្រជាជន។ ភាពខុសគ្នានៃ**ស្ថានភាពសុខភាពនិងអត្រាប្រើប្រាស់សេវា** នៅក្នុងក្រុមប្រជាជនដែលមានស្ថានភាពសង្គមសេដ្ឋកិច្ចខុសៗគ្នា បង្ហាញឲ្យឃើញពីបញ្ហាសមធម៌ ដែលចាំបាច់ត្រូវយកចិត្តទុកដាក់ថែមទៀត។ ការពង្រាយមិនទាន់សព្វនៅទូទាំងប្រទេសនៃ **សេវាសង្គ្រោះថែទាំសម្ភពបន្ទាន់និងថែទាំទារក** និងភាពចាំបាច់ក្នុងការបង្កើនគុណភាពនៃសេវាថែទាំបន្តសម្រាប់**កម្មវិធីសុខភាពបន្តពូជមាតា-ទារកនិងកុមារ**។ **អត្រាមរណភាពមាតា**នៅមានកម្រិតខ្ពស់ ដោយមានស្ត្រីចំនួន ៤៦១ នាក់ស្លាប់ ក្នុងចំណោមស្ត្រីសម្រាលកូន ១០០ ០០០ នាក់ ដែលប្រការនេះត្រូវការចាំបាច់នូវការវិនិយោគជាបន្តបន្ទាប់បន្ថែមទៀត ក្នុងការផ្តល់សេវា និងក្នុងអន្តរាគមន៍បន្ទាន់[១២]។ ឆ្នាំ២០០៩ មានតែការផ្តល់កំណើតចំនួន ៦៣% ប៉ុណ្ណោះដែលធ្វើឡើងដោយបុគ្គលិកសុខាភិបាលដែលបានទទួលការបណ្តុះបណ្តាល ថ្វីត្បិតតែអត្រានេះបង្ហាញពីការកើនឡើងគួរឲ្យកត់សម្គាល់ ២២% ពីឆ្នាំ២០០០ ក៏ដោយ (ក្រសួងសុខាភិបាល ឆ្នាំ២០១០)។ មរណភាពកុមារអាយុក្រោម៥ឆ្នាំ មានចំនួន៨៣នាក់ ក្នុងចំណោមកុមារចំនួន១០០០នាក់នៃកុមារក្នុងបញ្ចភាគគ្រួសារក្រីក្របំផុត ដោយហានិភ័យនៃការស្លាប់មុនពេលកុមារទាំងនេះមានអាយុបានប្រាំឆ្នាំ មានស្ទើរតែបីដងច្រើនជាងកុមារក្នុងបញ្ចភាគខ្ពស់បំផុតនៃគ្រួសារដែលមានទ្រព្យសម្បត្តិ។

---

[១១] ការអង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជាឆ្នាំ២០០៧ បង្ហាញថាអត្រាការប្រាក់មធ្យមនៃបំណុលដែលទាក់ទងនឹងសុខភាពនៅចន្លោះពី៥០-៦០% ក្នុងមួយឆ្នាំ។

[១២] ឯកសារផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្ម ឆ្នាំ២០០៩-២០១៣ ទទួលស្គាល់ថាការស្លាប់របស់មាតា គឺជាបញ្ហាអន្តរវិស័យដែលរងឥទ្ធិពលពីការអប់រំនិងអក្ខរកម្មរបស់ស្ត្រី ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ និងកម្រិតនៃការចូលរួមរបស់ស្ត្រី ព្រមទាំងបញ្ហាសមធម៌ផ្នែកយេនឌ័រ។

ប្រព័ន្ធហិរញ្ញប្បទានល្អ ជាមធ្យោបាយដ៏សំខាន់ ដើម្បីធានាគុណភាពសេវាសម្រាប់ប្រជាជនទាំងអស់។ ក្នុងអំឡុង២០ឆ្នាំកន្លងមកនេះ ការវិភាជថវិកាសម្រាប់វិស័យសុខាភិបាលពីរាជរដ្ឋាភិបាល និងពីដៃគូអភិវឌ្ឍ មានការកើនឡើងខ្លាំង។ ក្នុងឆ្នាំ២០០៨ ការរួមចំណែកពីរាជរដ្ឋាភិបាលនិងពីដៃគូអភិវឌ្ឍគឺប្រហាក់ប្រហែលគ្នា គឺប្រមាណ៨,២៧ដុល្លារអាមេរិកក្នុងប្រជាជនម្នាក់ក្នុងមួយឆ្នាំ។ ប៉ុន្តែប្រជាជនកម្ពុជាត្រូវការ**ចំណាយថវិកាខ្ពស់ដើម្បីទទួលបាន និងប្រើប្រាស់សេវាថែទាំសុខភាពចាំបាច់។** ការចំណាយប្រចាំឆ្នាំសរុបលើសុខភាព គឺប្រហែល៤០ដុល្លារអាមេរិកសម្រាប់ប្រជាជនម្នាក់ ដែលក្នុងនោះប្រមាណ៦០%គឺជាការចំណាយចេញពីគ្រួសារ។ **បញ្ញត្តិស្តីពីហិរញ្ញប្បទានសុខាភិបាល** ដែលបានដាក់ឲ្យប្រើប្រាស់ក្នុងឆ្នាំ១៩៩៦ ចែងពីការកំណត់របៀបបង់ថ្លៃសេវានៅតាមមណ្ឌលសុខភាពរបស់រដ្ឋ។ បញ្ញត្តិស្តីពីហិរញ្ញប្បទានសុខាភិបាលនេះ ក៏បានអនុញ្ញាតផងដែរចំពោះប្រព័ន្ធលើកលែងមិនយកថ្លៃសេវាសម្រាប់ប្រជាជនក្រីក្រក្នុងការបង់ថ្លៃសេវាកម្មថែទាំសុខភាព ដើម្បីឲ្យពួកគាត់មានលទ្ធភាពទទួលបានសេវាថែទាំនៅមណ្ឌលសុខភាពឬមន្ទីរពេទ្យរដ្ឋ ដោយឥតគិតថ្លៃនៅពេលចាំបាច់។ បច្ចុប្បន្ននេះ **មូលនិធិសមធម៌ និងគម្រោងបង់ថ្លៃជួស** កំពុងត្រូវបានអនុវត្តនៅក្នុងស្រុកប្រតិបត្តិចំនួន៥០ (គ្របដណ្តប់លើមន្ទីរពេទ្យបង្អែកចំនួន៥១ និងមណ្ឌលសុខភាពចំនួន១២០)។ **គម្រោងធានារ៉ាប់រងសុខភាពសហគមន៍** ចំនួន១២ ត្រូវបានដាក់ឲ្យដំណើរការនៅក្នុងស្រុកប្រតិបត្តិចំនួន១១ (ក្នុងខេត្តចំនួន៧និងរាជធានីភ្នំពេញ) ដោយគ្របដណ្តប់លើ មណ្ឌលសុខភាពចំនួន៨១និងមន្ទីរពេទ្យបង្អែកចំនួន១១។ តាមការជាក់ស្តែង ប្រព័ន្ធលើកលែងការយកថ្លៃសេវានេះ អនុវត្តបានតែចំពោះប្រជាជនជាងពាក់កណ្តាលនៃចំនួនប្រជាជនដែលក្រីក្រពេកគ្មានលទ្ធភាពបង់ថ្លៃសេវាប៉ុណ្ណោះ (៦៨%នៃប្រជាជនក្រីក្រ ត្រូវបានការពារដោយមូលនិធិសមធម៌និងគម្រោងបង់ថ្លៃជួស គឺស្មើនឹង២ ៨៣២ ៨៤៤នាក់នៃប្រជាជនដែលរស់នៅក្រោមបន្ទាត់នៃភាពក្រីក្រ ហើយអ្នកទទួលផលពីគម្រោងធានារ៉ាប់រងសុខភាពសហគមន៍ មានចំនួន៧៣ ៨២៨នាក់)។

## ៣.២. ក្រុមជនងាយរងគ្រោះ

ទារកនិងកុមារ ព្រមទាំងនារីនិងស្ត្រីដែលស្ថិតនៅក្នុងវ័យបន្តពូជ និងជាពិសេសគ្រួសារដែលជួបប្រទះអសន្តិសុខស្បៀង មានភាពងាយរងគ្រោះខ្ពស់ដោយសារវិបត្តិដែលបានរៀបរាប់ខាងលើ ដូច្នេះហើយ ពួកគាត់គួរតែជាគោលដៅនៃអន្តរាគមន៍គាំពារសង្គម។

### ៣.២.១. ទារក និងកុមារ

**ទារកនិងកុមារ** មានចំនួនច្រើនជាងមួយភាគបីនៃចំនួនប្រជាជនទាំងអស់។ ក្នុងរយៈពេលប៉ុន្មានឆ្នាំកន្លងមកនេះ ស្ថានភាពមរណភាពកុមារមានសភាពប្រសើរឡើងគួរឲ្យកត់សម្គាល់ ដោយបាន

ថយចុះពី៩៥មកត្រឹម៦០នាក់ក្នុងទារក១០០០នាក់ ពីឆ្នាំ២០០០ដល់២០០៨ (ជាការសម្រេចបានគោលដៅអភិវឌ្ឍន៍សហស្សវត្ស) ហើយអត្រាមរណរបស់កុមារក្រោមអាយុ៥ឆ្នាំ បានថយចុះពី១២៤ មកត្រឹម៨៣នាក់ ក្នុងកំណើតទារក១០០០នាក់ (ស្ទើរតែសម្រេចបានគោលដៅអភិវឌ្ឍន៍សហស្សវត្សដែលកំណត់យក៧៥នាក់)។ ប៉ុន្តែភាពខុសគ្នាតាមតំបន់នៅមានកម្រិតខ្ពស់ ព្រោះមរណភាពទារកនិងកុមារអាយុក្រោម៥ឆ្នាំ នៅតែមានចំនួនស្ទើរតែ២ដងនៃអត្រាមធ្យមភាគជាតិ ក្នុងខេត្តកំពង់ស្ពឺ ព្រះវិហារ ស្ទឹងត្រែង ព្រៃវែង មណ្ឌលគិរី និងរតនគិរី ដែលនេះជាបញ្ហាដែលត្រូវដោះស្រាយ (ឯកសារ ក្រសួងផែនការ ឆ្នាំ២០១០)។

ភាពក្រីក្រអាចបង្កឲ្យមានឧបសគ្គខ្លះដល់លទ្ធភាពបញ្ចប់ការសិក្សាឲ្យបានពេញលេញ។ ការចំណាយដោយប្រយោលមួយចំនួន បានបន្ថែមបន្ទុកលើឪពុកម្តាយកុមារ រួមមានការចំណាយលើឯកសណ្ឋាន សម្ភារៈសិក្សា ចំណីអាហារនៅសាលារៀន ការធ្វើដំណើរ និងថ្លៃសាលារៀនក្រៅផ្លូវការ រួមទាំងតម្រូវការរបស់ឪពុកម្តាយក្នុងការធ្វើចំណាកស្រុកស្វែងរកការងារ និងការទទួលស្គាល់ **តម្លៃឱកាស** ក្នុងការឲ្យកុមារចូលរៀននៅសាលារៀន ធៀបជាមួយនឹងការមិនចូលរៀន ដើម្បីជួយរកប្រាក់សម្រាប់គ្រួសារ។

ទារកនិងកុមារអាចប្រឈមនឹងហានិភ័យ ដោយសារ**យុទ្ធសាស្ត្រដោះស្រាយនឹងវិបត្តិដែលមានលក្ខណៈអវិជ្ជមាន** ហើយអាចបង្កឲ្យមានផលប៉ះពាល់ដល់កុមារអស់មួយជីវិត ដូចជាការទទួលបានចំណីអាហារដែលមានជីវជាតិបំប៉នតិចតួចឬមិនល្អ ការមិនបានទៅសាលារៀន ការចូលរួមធ្វើការដោយប្រើកម្លាំងពលកម្មកុមារ និងការក្លាយជាជនរងគ្រោះនៃការជួញដូរមនុស្ស។ ទារកនិងកុមារជាជនងាយរងគ្រោះបំផុតពីសំណាក់វិបត្តិនានា ពីព្រោះពួកគាត់ខ្វះសមត្ថភាពកាត់បន្ថយហានិភ័យ និងគ្រប់គ្រងស្ថានភាពមិនបានល្អ។ យោងតាម **ការអង្កេតប្រជាសាស្ត្រ និងសុខនាពកម្ពុជា** ឆ្នាំ២០០៥ កុមារចំនួន៦៤% នៅព្រះរាជាណាចក្រកម្ពុជាប្រឈមនឹងកង្វះខាតសុខុមាលភាព យ៉ាងហោចណាស់លើចំណោមបញ្ហា២ ក្នុងចំណោមបញ្ហាចំនួន៧ រួមមាន អាហារ សុខភាព ការអប់រំ ព័ត៌មាន ទឹក អនាម័យ និងជម្រក។

## ៣.២.២. នារី និងស្ត្រីក្នុងវ័យបន្តពូជ

**នារី និងស្ត្រីក្នុងវ័យបន្តពូជ** (អាយុ ១៥ ដល់ ៤៩ឆ្នាំ) ក៏ជាជនងាយរងគ្រោះ ទោះបីជាសមភាពនិងឱកាសយេនឌ័រ មានភាពប្រសើរឡើងសម្រាប់ស្ត្រីនៅព្រះរាជាណាចក្រកម្ពុជាក៏ដោយ។ ស្ត្រីមានលក្ខណៈពិសេសក្នុងការប្រឈមទៅនឹងភាពងាយរងគ្រោះ ដោយសារតែតម្រូវការសុខភាពរបស់ខ្លួន។ អត្រាមរណភាពមាតា បានថយចុះពី៨៣៧នាក់ក្នុងឆ្នាំ២០០៦ មកត្រឹម៣៤១នាក់ក្នុងឆ្នាំ២០០៩

ក្នុងទារក១០០ ០០០នាក់ ប៉ុន្តែតួរលេខនេះនៅស្ថិតក្នុងកម្រិតខ្ពស់មួយ (គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ឆ្នាំ២០១០)។ ជាងនេះទៅទៀត ស្ត្រីស្ថិតក្នុងសមមាត្រខ្ពស់ក្នុងចំណោមមនុស្សពេញវ័យដែលឆ្លងមេរោគអេដស៍ ច្រើនជាងរយៈពេលកន្លងមក (៥២% ក្នុងឆ្នាំ២០០៩ ធៀបនឹង ៣៨% ក្នុងឆ្នាំ១៩៩៧)[១៣]។ ចំនួនស្ត្រីសរុបដែលជួបបញ្ហាក្នុងការទទួលបានសេវាកម្មថែទាំសុខភាពនៅមានកម្រិតខ្ពស់[១៤]នៅឡើយ ។

## ៣.២.៣. ក្រុមជនងាយរងគ្រោះនៅនឹងនិកម្មភាព និងអសន្តិសុខស្បៀង

ទោះបីជាបច្ចុប្បន្នអត្រាបោះបង់ចោលការសិក្សាមានការថយចុះ ហើយការចុះឈ្មោះចូលរៀនមានការកើនឡើងគួរឲ្យកត់សំគាល់ ប៉ុន្តែដោយសារសង្គ្រាមជាង២ទសវត្សរ៍ កុមារជាច្រើនដែលដល់វ័យចូលរៀននាពេលនោះ ពុំបានចុះឈ្មោះចូលរៀន ឬបានចុះឈ្មោះចូលរៀនមួយរយៈដែរប៉ុន្តែបានបោះបង់ចោលការសិក្សាវិញដោយសារកង្វះខាតជីវភាពក្នុងគ្រួសារ។ ក្រុមជនទាំងនេះជា**ក្រុមជនបោះបង់ចោលការសិក្សានិងអនក្ខរជន** ហើយបច្ចុប្បន្នកុមារទាំងនោះមួយចំនួនបានក្លាយខ្លួនជាកសិករ ឬកម្មករ ឬអ្នកប្រកបមុខរបរផ្សេងៗក្នុងសង្គម។ ពួកគាត់ភាគច្រើនអាចមានកម្រិតជីវភាពរស់នៅក្បែរបន្ទាត់ក្រីក្រ ហើយអាចប្រឈមនឹងហានិភ័យជាច្រើនដែលតម្រូវឲ្យមានការគាំពារនិងយកចិត្តទុកដាក់។

ជាមួយនិងកំណើនសេដ្ឋកិច្ចនិងកិច្ចអន្តរាគមន៍របស់រាជរដ្ឋាភិបាល កម្លាំងពលកម្មដែលមានជំនាញទាបបានទទួលបានការងារនិងមុខរបរជាច្រើន ជាពិសេសក្នុងការងារឬមុខរបរដែលមានការប្រើប្រាស់កម្លាំងច្រើន **(ការងារអតិពលកម្ម)** ឬធ្វើទេសន្តរប្រវេសន៍។ **ក្រុមជនដែលធ្វើការដោយប្រើកម្លាំងនិងមានជំនាញទាប**ក៏អាចប្រឈមនិងការបាត់បង់ការងារឬប្រាក់ចំណូល ក្នុងករណីមានវិបត្តិសេដ្ឋកិច្ច ឬធម្មជាតិណាមួយកើតឡើង។

**គ្រួសារជួបប្រទះអសន្តិសុខស្បៀង** មានភាពងាយរងគ្រោះខ្ពស់ចំពោះប្រភេទនៃគ្រោះអាសន្នផ្សេងៗ ដោយសារអាហារូបត្ថម្ភមិនល្អនិងវិធីសាស្ត្រដោះស្រាយនៅមានកម្រិត។ បញ្ហាកង្វះខាតស្បៀងអាហារដែលអាចកើតក្នុងកម្រិតគ្រួសារណាមួយ នឹងបង្កើនឱកាសដល់គ្រួសារនោះឲ្យប្រឈមនឹងវិបត្តិ

[១៣] ស្ត្រីដែលទើបមានជំងឺថ្មីក្នុងចំណោមស្ត្រីមានជំងឺ ស្ត្រីចំនួនពីរភាគបីស្ថិតជាស្ត្រីដែលមិនបម្រើផ្លូវភេទ ឬជាក្រុមស្ត្រីដែលប្រឈមនឹង "ហានិភ័យទាប"។

[១៤] នៅឆ្នាំ២០០៥ ស្ត្រីចំនួន៨៩% មានបញ្ហាមួយយ៉ាងតិចក្នុងការទទួលបានសេវាថែទាំសុខភាព។ ការរកប្រាក់សម្រាប់ព្យាបាលជំងឺនៅតែជាបញ្ហាដ៏សំខាន់មួយ ហើយបន្ទាប់មកគឺបញ្ហាដែលគ្មានអ្នកផ្តល់សេវាឬឱសថ និងអ្នកជំងឺមិនចង់ទៅទទួលសេវាថែទាំសុខភាពតែម្នាក់ឯង (ការអង្កេតប្រជាសាស្ត្រ និងសុខភាព កម្ពុជា ឆ្នាំ២០០៥)។

សុខភាព ដោយសារសុខភាពរបស់ពួកគាត់ត្រូវបំផ្លាញនាពេលកន្លងមក។ លើសពីនេះ គ្រួសារក្រីក្រដែលជួបបញ្ហានេះ មានជម្រើសតិចតួចបំផុតក្រៅពីការដោះស្រាយតាមរយៈការកាត់បន្ថយចំណាយលើស្បៀងអាហារ ដើម្បីដោះស្រាយកលិយុគសេដ្ឋកិច្ចដ៏ធ្ងន់ធ្ងរទាំងនេះ។

## ៣.២.៤. ក្រុមជនងាយរងគ្រោះផ្សេងទៀត

ក្រុមជនងាយរងគ្រោះផ្សេងទៀត ត្រូវបានកំណត់ឡើងក្នុងយុទ្ធសាស្ត្រចតុកោណ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្ម២០០៩-២០១៣ និងយុទ្ធសាស្ត្រនៃវិស័យផ្សេងៗ ទៅតាមអាយុស្ថានភាពឬលក្ខខណ្ឌរបស់ក្រុមជនងាយរងគ្រោះទាំងនេះ។ ក្រុមទាំងនេះរួមមាន អ្នកផ្ទុកមេរោគអេដស៍ និងគ្រួសាររបស់ពួកគាត់ ប្រជាជនគ្មានផ្ទះសំបែង ជនពិការ កុមារកំព្រា កុមារនិងយុវជនដែលប្រឈមនឹងហានិភ័យខ្ពស់ ជនរងគ្រោះដោយអំពើហិង្សា ការរំលោភបំពាន និងការកេងប្រវ័ញ្ច ជនជាតិដើមភាគតិច គ្រួសាររបស់ជនចំណាកស្រុកដោយប្រចុយប្រចាន អតីតយុទ្ធជន ចាស់ជរា ។ល។ បញ្ហាប្រឈមសម្រាប់ប្រជាជនទាំងនេះ គឺភាពងាយរងគ្រោះដែលកើតឡើងបណ្តាលមកពីស្ថានភាពរបស់ពួកគាត់ ហើយដែលបន្ថែមបន្ទុកទៅលើភាពក្រីក្រ។ ក្រុមជនងាយរងគ្រោះទាំងនេះត្រូវការជំនួយដែលមានលក្ខណៈធំទូលាយ ពីព្រោះការឧបត្ថម្ភសង្គមតែមួយមុខមិនគ្រប់គ្រាន់ដើម្បីធានាឲ្យអ្នកទាំងនោះមានសុខុមាលភាព និងមានសិទ្ធិទទួលបានការគាំពារសង្គមពីរដ្ឋឡើយ។ ក្រុមទាំងនេះអាចចាត់ទុកថាជា **ក្រុមជនងាយរងគ្រោះពិសេស** ដោយសារ ១) ស្ថានភាពរបស់ពួកគាត់ទាមទារនូវអាទិភាពក្នុងការពង្រឹងការគាំពារសង្គមសម្រាប់ពួកគាត់ និង ២) ពួកគាត់ត្រូវការអន្តរាគមន៍ផ្នែកការគាំពារសង្គមពិសេសមួយ (ឧទាហរណ៍ តាមរយៈនីតិវិធីកំណត់គោលដៅពិសេស ការពិនិត្យតាមដាន និងការរៀបចំកម្មវិធីពិសេស។ល។)។ រាជរដ្ឋាភិបាលកម្ពុជានឹងធ្វើការពិភាក្សាជាមួយស្ថាប័នពាក់ព័ន្ធ ស្តីពីវិធីបន្តកែលម្អការគាំពារសង្គមរបស់ក្រុមងាយរងគ្រោះដែលគ្មាន ឬមានសមត្ថភាពជួយខ្លួនឯងតែបន្តិចបន្តួច។

**ជនជាតិដើមភាគតិច** ប្រឈមនឹងអត្រានៃភាពក្រីក្រ និងគម្លាតនៃភាពក្រីក្រខ្ពស់ជាងអត្រាមធ្យមភាគជាតិ។ ទោះបីជាជនជាតិដើមភាគតិចទាំងនោះមានចំនួនតិចតួចយ៉ាងណាក៏ដោយ ក៏កម្រិតជីវភាពរស់នៅរបស់ពួកគាត់នៅមានកម្រិតទាបជាងមធ្យមភាគថ្នាក់ជាតិ។ លើសពីនេះទៀត ក្រុមជនជាតិដើមភាគតិច ត្រូវប្រឈមមុខនឹងការលំបាកដែលមិនមែនជាបញ្ហាហិរញ្ញវត្ថុ ដូចជាបញ្ហាភាសា ការរស់នៅដាច់ស្រយាល ការទទួលបានសេវាអប់រំនិងសុខភាពមូលដ្ឋានទាប។ ដូច្នេះ ជនជាតិដើមភាគតិច សមនឹងទទួលបានកិច្ចគាំពារសង្គមពិសេស ដែលត្រូវរៀបចំឲ្យបានសមស្របទៅនឹងតម្លៃវប្បធម៌និងយន្តការកំណត់គោលដៅសមស្រប (ឧទាហរណ៍ ខាងផ្នែកភូមិសាស្ត្រ) ដែលអាចឲ្យកម្មវិធីទាំងនេះឆ្លើយតបទៅនឹងតម្រូវការចាំបាច់របស់ជនជាតិដើមភាគតិចទាំងនោះ។ បច្ចុប្បន្ននេះ រាជរដ្ឋា-

ភិបាលកម្ពុជាបានដាក់ចេញគោលនយោបាយជាតិចំនួនពីរ គឺស្ដីពី**ការអភិវឌ្ឍជនជាតិដើមភាគតិច** និងស្ដីពី**ការចុះបញ្ជីនិងសិទ្ធិប្រើប្រាស់ដីសហគមន៍ជនជាតិដើមភាគតិចនៅព្រះរាជាណាចក្រកម្ពុជា។**

**មនុស្សចាស់ជរា** ត្រូវការការថែទាំជាពិសេស ដោយសារតែពួកគាត់ខ្វះលទ្ធភាពក្នុងការចូលរួមក្នុងសកម្មភាពសេដ្ឋកិច្ចសម្រាប់ចិញ្ចឹមជីវិត។ ឧទាហរណ៍ មនុស្សចាស់ក្នុងប្រទេសកម្ពុជាមានស្ថានភាពសុខភាពខ្សោយជាងមនុស្សចាស់ក្នុងបណ្ដាប្រទេសជិតខាងផ្សេងៗទៀតក្នុងតំបន់អាស៊ី។ ការថយចុះទ្រព្យសម្បត្តិ ទោះបីជាក្នុងទ្រង់ទ្រាយតូចក៏ដោយ ក៏អាចនឹងធ្វើឲ្យមានកំណើនបញ្ហាសុខភាពគួរឲ្យកត់សម្គាល់។ ស្ត្រីវ័យចំណាស់ ជាក្រុមដែលអាចនឹងងាយរងគ្រោះជាងបុរសវ័យចំណាស់ ក្នុងនោះស្ត្រីវ័យចំណាស់ចំនួន ១០% ត្រូវពឹងផ្អែកទាំងស្រុងលើមនុស្សពេញវ័យក្នុងគ្រួសារ បើធៀបជាមួយនឹងបុរសវ័យចំណាស់ ដែលមានត្រឹមតែ ២% ប៉ុណ្ណោះ។

**ប្រជាជនដែលមានជំងឺរ៉ាំរ៉ៃ** ត្រូវការការគាំទ្រពីសង្គម ដើម្បីឲ្យពួកគាត់មានភាពម្ចាស់ការ និងនិរន្តរភាពលើជីវភាពរស់នៅរបស់ខ្លួន។ កុមារក្នុងគ្រួសារទាំងនេះ ជាញឹកញាប់ប្រឈមនឹងហានិភ័យខ្ពស់។ នៅពេលឪពុកឬម្ដាយមានជំងឺរ៉ាំរ៉ៃ ការចំណាយលើការថែទាំសុខភាពនឹងត្រូវកើនឡើង ហើយធ្វើឲ្យគ្រួសារត្រូវកាត់បន្ថយចំណាយថវិកាសម្រាប់ស្បៀងអាហារ ការសិក្សា និងការចំណាយផ្សេងៗទៀត។ លើសពីនោះទៀត កុមារតូចៗត្រូវដើរតួនាទីដូចមនុស្សពេញវ័យ ដូចជាក្នុងការថែទាំមនុស្សចាស់ដែលមានជំងឺ ការរៀបចំផ្ទះសំបែង ឬមើលថែកុមារតូចដទៃទៀត។

ជំងឺរបេងនៅតែជាកង្វល់ដ៏ចម្បងសម្រាប់វិស័យសុខភាពសាធារណៈ ហើយប្រទេសកម្ពុជាស្ថិតនៅលេខរៀងទី២១ ក្នុងចំណោមបណ្ដាប្រទេសមានបន្ទុកខ្ពស់នៃជំងឺរបេង។ អត្រាប្រេវ៉ាឡង់នៃជំងឺរបេងគ្រប់ប្រភេទ គឺមានអ្នកជំងឺរបេង៥០០នាក់ ក្នុងចំណោមមនុស្ស១០០ ០០០នាក់ ក្នុងមួយឆ្នាំ។ បន្ទុកទ្វេដងនៃអ្នកជំងឺដែលមានផ្ទុកមេរោគអេដស៍និងរបេង អាចធ្វើឲ្យមានការបាត់បង់អាយុជីវិតកើនឡើងខ្ពស់។

ករណីអ្នកជំងឺគ្រុនចាញ់ ដែលមកទទួលការព្យាបាលនៅមណ្ឌលសុខភាពសាធារណៈក្នុងមនុស្ស១០០០នាក់ បានថយចុះពី១១,៤នៅឆ្នាំ២០០០ មកនៅ៤,៤នៅឆ្នាំ២០០៨ (មាន៥៩ ០០០ករណីក្នុងឆ្នាំ២០០៨) ទោះបីមានកំណើនរហូតដល់១០១ ០០០ករណីនៅឆ្នាំ២០០៦ក៏ដោយ។

**គ្រួសារដែលមានអ្នកផ្ទុកមេរោគអេដស៍** ត្រូវទទួលបានការយកចិត្តទុកដាក់ជាពិសេស ដោយសារពួកគាត់មានភាពងាយរងគ្រោះខ្ពស់បំផុត។ បច្ចុប្បន្ន មានមនុស្សពេញវ័យចំនួន៥៧ ៩០០នាក់ កំពុង

រស់នៅដោយមានផ្ទុកមេរោគអេដស៍ក្នុងប្រទេសកម្ពុជា ហើយកុមារចំនួន៥ ៤៧៣នាក់ បានឆ្លងមេរោគនេះ។ ភាពក្រីក្រ បង្កឲ្យមានកំណើនជំងឺឱកាសនិយម ហើយអាចប៉ះពាល់ជាអវិជ្ជមានដល់ការព្យាបាល និងការប្រើថ្នាំពន្យារជីវិត។

**ជនពិការកម្ពុជា** ជាច្រើននៅពឹងផ្អែកលើការឧបត្ថម្ភដ៏ស្តួចស្តើងពីសំណាក់គ្រួសារដើម្បីរស់។ ជនពិការតិចតួចណាស់ ដែលទទួលបានការស្តារលទ្ធភាពពលកម្មនិងសេវាកម្មជាមូលដ្ឋានសមស្រប។ ភាពងាយរងគ្រោះរបស់អ្នកទាំងនោះ គឺលើសពីកង្វះខាតធនធានហិរញ្ញវត្ថុនៅកម្រិតបុគ្គលឬគ្រួសារ ដែលហ៊ុមព័ទ្ធដោយរបាំងវប្បធម៌និងសង្គម មានការទទួលបានសេវាកម្មអប់រំសុខភាព និងសេវាស្តារលទ្ធភាពពលកម្មមិនគ្រប់គ្រាន់ កង្វះការយល់ដឹងអំពីសិទ្ធិ និងការពឹងផ្អែកខ្លាំងលើអ្នកដទៃ។

មនុស្សចាស់ ជនដែលមានជំងឺរ៉ាំរ៉ៃ និងជនពិការ ជាញឹកញាប់ពឹងផ្អែកលើជំនួយពីសហគមន៍ និងសាច់ញាតិ (ក្រីក្រ) ដើម្បីរស់។ ដូច្នេះ ការពង្រឹងការគាំពារសង្គមដល់ក្រុមទាំងនេះនាពេលបច្ចុប្បន្ន អាចបន្ធូរបន្ថយបន្ទុកខ្លះរបស់សហគមន៍ក្រីក្រ និងជាពិសេសកាត់បន្ថយផលប៉ះពាល់លើកុមារ។

## ៣.៣. បញ្ហាដែលកើតឡើងពីការដោះស្រាយវិបត្តិរបស់ជនក្រីក្រ

គ្រួសារជាច្រើន បានប្រើប្រាស់យុទ្ធសាស្ត្រដោះស្រាយតាមវិធីខុសៗគ្នា នៅពេលប្រឈមនឹងវិបត្តិដែលមិនធ្លាប់បានជួបប្រទះ។ គ្រួសារងាយរងគ្រោះ អាចនឹងប្រើយុទ្ធសាស្ត្រដោះស្រាយខ្លះដែលបង្កអន្តរាយ ដែលអាចមានផលប៉ះពាល់អវិជ្ជមានលើក្រុមមួយចំនួនដូចជាស្ត្រី និងកុមារ។ យុទ្ធសាស្ត្រដោះស្រាយបែបអវិជ្ជមាន ច្រើនបង្កផលវិបាកយូរអង្វែងដែលអាចនាំទៅរកការប្រឈម និងការកាត់បន្ថយសមត្ថភាពគ្រប់គ្រងហានិភ័យថែមទៀតផង។ ហានិភ័យមួយចំនួន (គ្រោះមហន្តរាយធម្មជាតិ និងកលិយុគសេដ្ឋកិច្ចសកល) មានផលប៉ះពាល់ដល់ប្រជាជនគ្រប់រូប ទាំងគ្រួសារដែលមានប្រាក់ចំណូលខ្ពស់ ទាំងគ្រួសារក្រីក្រ សូម្បីតែនៅប្រទេសដែលមានការអភិវឌ្ឍខ្ពស់ក៏ដោយ។ ប៉ុន្តែ គ្រួសារក្រីក្រមានភាពងាយរងគ្រោះខ្ពស់ នឹងត្រូវប្រើប្រាស់យុទ្ធសាស្ត្រដោះស្រាយបែបអវិជ្ជមានខ្លាំងជាងគ្រួសារដែលមានជីវភាពធូរធារ។

យុទ្ធសាស្ត្រដោះស្រាយដែលប្រជាជនប្រើប្រាស់ជាញឹកញាប់ក្នុងពេលមានវិបត្តិ មានដូចជា ការខ្ចីប្រាក់ដែលមានអត្រាការប្រាក់ខ្ពស់ ការប្រើប្រាស់ប្រាក់សន្សំផ្ទាល់ខ្លួន ការកាត់បន្ថយការចំណាយលើអាហារ ការប្តូរទៅប្រើអាហារដែលមានថ្លៃថោកជាងមុន និងជាញឹកញាប់ជាអាហារដែលមានជីវជាតិទាប ការកាត់បន្ថយការបរិភោគអាហារ (ជាពិសេសចំពោះស្ត្រី និងក្មេងស្រីវ័យជំទង់) ដែលជំរុញឲ្យមានជាវដ្តនៃសុខភាពខ្សោយ ការទិញអាហារដោយជំពាក់ប្រាក់ ការស្វែងរកការងារថ្មី ការបញ្ឈប់

កុមារមិនឲ្យចូលរៀន និងការលក់ទ្រព្យសម្បត្តិ (រួមបញ្ចូលទាំងដីធ្លី)។ ការកាត់បន្ថយការប្រើប្រាស់អាហារជះឥទ្ធិពលយ៉ាងខ្លាំងដល់ស្ត្រី ហើយការបញ្ឈប់កុមារមិនឲ្យចូលរៀន ជាញឹកញាប់បង្កឲ្យមានជាបញ្ហាពលកម្មកុមារ។ ពលកម្មកុមារជាយុទ្ធសាស្ត្រដោះស្រាយអវិជ្ជមានមួយដែលគួរឲ្យព្រួយបារម្ភ ពីព្រោះចំនួនពាក់កណ្ដាលនៃកុមារដែលមានអាយុពី៥ ដល់១៤ឆ្នាំ ត្រូវធ្វើការនៅក្នុងទម្រង់ការងារគ្រោះថ្នាក់ ឬទម្រង់ធ្ងន់ធ្ងរបំផុតដោយគ្មានលក្ខខណ្ឌ។

**យុទ្ធសាស្ត្រជាតិគាំពារសង្គមសម្រាប់ជនក្រីក្រនិងជនងាយរងគ្រោះ** (យ.ជ.គ.ស.) លើកឡើងនូវបញ្ហានៃដំណោះស្រាយដែលបង្កឲ្យមានការអន្តរាយទាំងនេះ និងផលវិបាកដែលមិនធ្លាប់ជួបប្រទះចំពោះក្រុមជនងាយរងគ្រោះ។ តាមរយៈការកំណត់គោលដៅក្រុមដែលទទួលផលប៉ះពាល់បំផុតក្នុងកម្មវិធីដែលមានគោលបំណងបំបាត់វដ្តវិលចុះឡើងនៃភាពក្រីក្រនិងភាពខ្វះខាត **យ.ជ.គ.ស.** នឹងផ្ដល់ជម្រើសជាច្រើនដែលអាចបង្កើនសុខុមាលភាពរបស់គ្រួសារនិងបុគ្គលម្នាក់ៗ។

## ៣.៤. តារាងសង្ខេប

តារាងទី២ សង្ខេបពីហានិភ័យ វិបត្តិ កត្តាកំណត់នៃភាពងាយរងគ្រោះ និងក្រុមជនងាយរងគ្រោះដែលបានរៀបរាប់ដោយពិស្ដារខាងលើ។

**តារាងទី២. ហានិភ័យ វិបត្តិ កត្តាកំណត់នៃភាពងាយរងគ្រោះ និងក្រុមងាយរងគ្រោះ**

| ហានិភ័យ និងវិបត្តិសំខាន់ៗ | | កត្តាកំណត់នៃភាព ងាយរងគ្រោះ | ផលវិបាក | ជនងាយ រងគ្រោះបំផុត |
|---|---|---|---|---|
| ស្ថានភាព គ្រោះអាសន្ន និងវិបត្តិ | *កលិយុគសេដ្ឋកិច្ច (ថ្លៃកើនឡើង សេដ្ឋកិច្ចធ្លាក់ចុះ)* | - មានកាលានុវត្តភាពតិចតួចក្នុងការបង្កើតប្រាក់ចំណូល<br>- ពើបប្រទះនឹងអសន្តិសុខស្បៀង<br>- ទទួលការងារអសុវត្ថិភាព និងមិនមានស្ថិរភាព<br>- ការកាត់បន្ថយចំនួនការងារក្នុងវិស័យសំខាន់ៗនៃសេដ្ឋកិច្ច<br>- ការធ្លាក់ចុះលទ្ធភាពនៃការទិញរបស់បៀវត្សនិងប្រាក់ចំណេញ | - ការកើនឡើងនូវនិកម្មភាព និងកង្វះការងារ<br>- ការកើនឡើងនូវការងារដែលមានប្រាក់បំណាច់ឆ្នាំតិចតួច អសុវត្ថិភាព និងប្រកបដោយគ្រោះថ្នាក់<br>- ការធ្វើប្រាក់បានតិចតួច<br>- កំណើននៃអសន្តិសុខស្បៀង | - អ្នកក្រ និងក្បែរបន្ទាត់នៃភាពក្រីក្រ |
| | *មហន្តរាយធម្មជាតិ បរិស្ថាន* | - ពឹងផ្អែកលើការដាំដុះដំណាំ និងការចិញ្ចឹមសត្វសម្រាប់ | - ការបំផ្លិចបំផ្លាញ ឬការសឹករេចរឹលនៃទ្រព្យ | - អ្នកក្រ និងក្បែរបន្ទាត់នៃភាព |

| ហានិភ័យ និងវិបត្តិសំខាន់ៗ | | កត្តាកំណត់នៃភាពងាយរងគ្រោះ | ផលវិបាក | ជនងាយរងគ្រោះបំផុត |
|---|---|---|---|---|
| | *អាកាសធាតុ (ទឹកជំនន់ គ្រោះរាំងស្ងួត)* | ផលិតកម្មស្បៀង និងការរកប្រាក់ចំណូលបានត្រឹមតែចិញ្ចឹមក្រពះ<br>- ពឹងផ្អែកលើធនធានធម្មជាតិ (ដែលជាញឹកញាប់មានភាពរេចរឹល ប្រើប្រាស់ហួសកម្រិត និងមានវិវាទ) ដើម្បីចិញ្ចឹមជីវិត<br>- រស់នៅតំបន់ដាច់ស្រយាល និងទទួលរងផលប៉ះពាល់ពីកង្វះហេដ្ឋារចនាសម្ព័ន្ធរបស់សហគមន៍<br>- មានមូលដ្ឋានសន្សំប្រាក់ និងទ្រព្យសម្បត្តិតិចតួច សម្រាប់ដោះស្រាយតម្រូវការបន្ទាន់ | សម្បត្តិ និងធនធានធម្មជាតិ<br>- ការកើនឡើងនូវនិកម្មភាព និងកង្វះការងារ<br>- ការកើនឡើងនូវឧប្បត្តិហេតុ និងភាពធ្ងន់ធ្ងរនៃអសន្តិសុខស្បៀង<br>- ប្រាក់ចំណូលទាប | ក្រីក្រ<br>- អ្នកដែលរស់នៅតំបន់ដែលងាយរងគ្រោះដោយទឹកជំនន់ និងគ្រោះរាំងស្ងួត |
| ឧបសគ្គលើការអភិវឌ្ឍមនុស្ស | *កង្វះអាហារូបត្ថម្ភ និងសុខភាពមាតា និងទារក* | - មានប្រាក់ចំណូលទាប និងងាយរងគ្រោះដោយសារអសន្តិសុខស្បៀង<br>- មានលទ្ធភាពតិចតួច ក្នុងការទទួលបានការថែទាំសុខភាពមាតា ទារក និងកុមារ ដែលមានគុណភាព | - អត្រាមរណមាតា ខ្ពស់<br>- អត្រាមរណទារក ខ្ពស់<br>- កំណើនឧប្បត្តិហេតុ និងភាពធ្ងន់ធ្ងរនៃកង្វះអាហាររូបត្ថម្ភ ជំងឺគ្រិន និងការអភិវឌ្ឍផ្នែកបញ្ញាស្មារតី មានកម្រិតទាប | - នារី និងស្ត្រីនៅវ័យបន្តពូជ<br>- ស្ត្រីមានផ្ទៃពោះ<br>- កុមារតូច (០-៥ឆ្នាំ) |
| | *ការទទួលបានការអប់រំដែលមានគុណភាពនៅមានកម្រិត* | - កំណើននៃកត្តាអូសទាញឲ្យបម្រើការងារក្នុងស្រុក ជួយការងារជំនួញគ្រួសារ ឬទទួលយកការងារក្រៅស្រុក ដោយសារទទួលបានប្រាក់ចំណូលទាប និងអសន្តិសុខស្បៀងក្នុងគ្រួសារ<br>- មានលទ្ធភាពទទួលបានសេវាកម្មអប់រំ ដែលមានគុណភាពបានតិចតួច | - អត្រាបោះបង់ការសិក្សាខ្ពស់ និងការទទួលបានជំនាញនៅមានកម្រិតទាប<br>- កំណើននៃឧប្បត្តិហេតុនៃពលកម្មកុមារ (ពីអាយុ៦-១៤ឆ្នាំ)<br>- ការកើនឡើងនូវភាពគ្មានការងារ និងកង្វះការងារ | - កុមារពេញវ័យចូលរៀន (៦-១៤ ឆ្នាំ) |

| ហានិភ័យ និងវិបត្តិសំខាន់ៗ | | កត្តាកំណត់នៃភាពងាយរងគ្រោះ | ផលវិបាក | ជនងាយរងគ្រោះបំផុត |
|---|---|---|---|---|
| | *ការទទួលបានកម្មវិធីឱកាសថ្មី ដែលមានគុណភាពនៅមានកម្រិត* | - កំណើននៃកត្តាអូសទាញឲ្យស្ថិតក្នុងការងារដែលគ្រោះថ្នាក់ និងទទួលបានប្រាក់កម្រៃ ទាប<br>- មានលទ្ធភាពទទួលបានតិចតួច នូវសេវាកម្មបណ្តុះបណ្តាលដែលមានគុណភាព | - កំណើននៃការងារដែលទទួលបានប្រាក់បំណាច់តិចតួច ប្រកបដោយគ្រោះថ្នាក់ និងអសុវត្ថិភាព<br>- កំណើននៃគ្រោះថ្នាក់ ឬទម្រង់ធ្ងន់ធ្ងរ និងដោយគ្មានលក្ខខណ្ឌនៃពលកម្មកុមារ (១៥-១៧ ឆ្នាំ) | - យុវជន (១៥-២៤ ឆ្នាំ) |
| និកម្មភាពតាមរដូវកាល និងខ្វះកាលានុវត្តភាពជីវភាព | *កង្វះ និងកម្រិតទាបនៃអាហារូបត្ថម្ភ* | - ពឹងផ្អែកលើការដាំដុះដំណាំ និងការចិញ្ចឹមសត្វ សម្រាប់ផលិតកម្មស្បៀង និងការរកប្រាក់ចំណូលបានត្រឹមតែចិញ្ចឹមក្រពះ<br>- គ្មានការងារជាប់លាប់ដើម្បីរកប្រាក់ចំណូលបន្ថែម ក្រៅពីការធ្វើកសិកម្ម<br>- ពឹងផ្អែកលើធនធានធម្មជាតិ (ដែលជាញឹកញាប់មានភាពរេចរឹល ប្រើប្រាស់ហួសកម្រិត និងមានវិវាទ) ដើម្បីចិញ្ចឹមជីវិត<br>- មានសមាជិកគ្រួសារស្ថិតក្នុងបន្ទុកច្រើន<br>- មិនមានដីកម្មសិទ្ធិ ឬមានលទ្ធភាពទទួលបានដីមានកម្រិត និងមានដីកាន់កាប់តិចតួច | - អត្រាមរណមាតាខ្ពស់<br>- កំណើនឧប្បត្តិហេតុ និងភាពធ្ងន់ធ្ងរនៃកង្វះអាហារូបត្ថម្ភ ជំងឺគ្រិន និងការអភិវឌ្ឍផ្នែកបញ្ញាស្មារតី មានកម្រិតទាប<br>- កំណើនការប្រកបរបរចិញ្ចឹមជីវិត នៅពេលមានជំងឺ<br>- ការធ្លាក់ចុះសមត្ថភាពសិក្សា ឬការងារប្រកបដោយផលិតភាព | - អ្នកក្រ និងក្បែរបន្ទាត់នៃភាពក្រីក្រ<br>- គ្រួសារដែលមានសមាជិកក្នុងបន្ទុកច្រើន<br>- អ្នកគ្មាន និងអ្នកខ្វះដីធ្លី<br>- ស្ត្រីមានផ្ទៃពោះ<br>- កុមារតូច (០-៥ ឆ្នាំ) |
| វិបត្តិសុខភាព | *សុខភាពខ្សោយ របួស ជំងឺ និងជំងឺរាតត្បាត មរណភាព* | - មានលទ្ធភាពតិចតួចក្នុងការទទួលបានទឹកស្អាត និងអនាម័យ<br>- រស់នៅក្នុងផ្ទះស្ថានភាពទុរគត<br>- មានមូលដ្ឋានសន្សំប្រាក់ និង | - អត្រាមរណមាតាខ្ពស់<br>- អត្រាមរណទារកខ្ពស់<br>- កំណើនឧប្បត្តិហេតុ និងភាពធ្ងន់ធ្ងរនៃកង្វះអាហារូបត្ថម្ភ ជំងឺគ្រិន | - អ្នកក្រ និងក្បែរបន្ទាត់នៃភាពក្រីក្រ<br>- ស្ត្រីមានផ្ទៃពោះ<br>- កុមារតូច (០-៥ឆ្នាំ)<br>- ជនចាស់ជរា |

| ហានិភ័យ និងវិបត្តិសំខាន់ៗ | | កត្តាកំណត់នៃភាពងាយរងគ្រោះ | ផលវិបាក | ជនងាយរងគ្រោះបំផុត |
|---|---|---|---|---|
| | | ទ្រព្យសម្បត្តិតិចតួច ហើយត្រូវចំណាយប្រាក់អស់ពីខ្លួនសម្រាប់ការថែទាំសុខភាព និងមានលទ្ធភាពតិចតួចក្នុងការទទួលបានសេវាកម្មគាំពារ និងថែទាំសុខភាពដែលមានគុណភាព<br>- ធ្វើការងារប្រើកម្លាំងកាយដែលប្រកបដោយគ្រោះថ្នាក់ និងរបួស | និងការអភិវឌ្ឍផ្នែកបញ្ញាស្មារតីមានកម្រិតទាប<br>- ការបាត់បង់ទ្រព្យសម្បត្តិ និងកំណើននៃបំណុល | - ជនពិការ |
| ក្រុមជនងាយរងគ្រោះពិសេស | *អសមត្ថភាពការងារ ភាពឯកោ* | - មានលទ្ធភាពតិចតួចក្នុងការទទួលបានការងាររកប្រាក់ចំណូល<br>- ទទួលរងគ្រោះពីភាពឯកោក្នុងសង្គម មានលទ្ធភាពតិចតួចក្នុងការទទួលបានសេវាកម្ម និងការមិនរាប់បញ្ចូលក្នុងកាលានុវត្តភាពផ្សេងៗ | - កំណើនអសន្តិសុខប្រាក់ចំណូល និងស្បៀងអាហារ<br>- កំណើនរបរចិញ្ចឹមជីវិតដែលក្លាយជាជនរងគ្រោះនៃអំពើហិង្សា ការកេងប្រវ័ញ្ច និងការរំលោភបំពានលើពលកម្ម និងផ្លូវភេទ | - ជនចាស់ជរា<br>- ជនពិការ<br>- អ្នកផ្ទុកជំងឺរ៉ាំរ៉ៃ<br>- ជនជាតិដើមភាគតិច<br>- កុមារកំព្រា<br>- ពលករកុមារ<br>- ជនរងគ្រោះដោយអំពើហិង្សា ការកេងប្រវ័ញ្ច និងការរំលោភ<br>- អតីតយុទ្ធជន<br>- គ្រួសារអ្នកចំណាកស្រុក<br>- ស្ត្រីជាមេគ្រួសារ |

- **ហានិភ័យ និងវិបត្តិសំខាន់ៗ** ៖ ហានិភ័យ ជាប្រភពនៃគ្រោះថ្នាក់ ជាលទ្ធភាពនៃការបាត់បង់ឬសំណាងមិនល្អ។ នៅពេលដែលហានិភ័យកើតឡើង វានឹងបង្កឲ្យមានវិបត្តិ។
- **កត្តាកំណត់នៃភាពងាយរងគ្រោះ** ៖ ភាពងាយរងគ្រោះរបស់បុគ្គលឬគ្រួសារ អាស្រ័យលើកម្រិតនៃការប្រឈមមុខ និងសមត្ថភាពដោះស្រាយវិបត្តិ។ ប្រជាជនដែលរស់នៅក្រោម ឬក្បែរបន្ទាត់នៃភាពក្រីក្រអាចងាយរងគ្រោះដោយសារផលវិបាកអវិជ្ជមាននៃវិបត្តិ។
- **ផលវិបាក** ៖ អាស្រ័យលើភាពងាយរងគ្រោះនៃបុគ្គល និងគ្រួសារ។ ផលវិបាកអាចកើតចេញពីការជួបប្រទះវិបត្តិ។
- **ក្រុមងាយរងគ្រោះបំផុត** ៖ ខណៈពេលដែលជនក្រីក្រនិងជនដែលនៅក្បែរបន្ទាត់នៃភាពក្រីក្រ មានភាពងាយរងគ្រោះដោយសារវិបត្តិនានា ក្រុមប្រជាជនមួយចំនួនមានភាពងាយរងគ្រោះជាងគេ ដោយសារវិបត្តិ។

# ជំពូកទី៤

# កម្មវិធីឬគម្រោង គាំពារសង្គម ដែលមានស្រាប់ សម្រាប់ជនក្រីក្រ និងជនងាយរងគ្រោះ

# ជំពូកទី៤
# កម្មវិធីឬគម្រោងគាំពារសង្គមដែលមានស្រាប់ សម្រាប់ជនក្រីក្រនិងជនងាយរងគ្រោះ

## ៤.១. រចនាសម្ព័ន្ធស្ថាប័ននាពេលបច្ចុប្បន្នសម្រាប់ការគាំពារសង្គម

ក្រសួងស្ថាប័ននីមួយៗនៃរាជរដ្ឋាភិបាល មានអាណត្តិការងារផ្សេងៗគ្នាក្នុងការផ្តល់សេវាជូនប្រជាជន ដូច្នេះការអនុវត្តសកម្មភាពការងារនានា គឺមានលក្ខណៈជាក់លាក់ទៅតាមវិស័យនីមួយៗ ដើម្បីអនុញ្ញាតឲ្យជនក្រីក្រ និងជនងាយរងគ្រោះមានលទ្ធភាពទទួលបានសេវាទាំងនោះ។ សកម្មភាពការងារទាំងនេះច្រើនអនុវត្តទៅតាមផែនការយុទ្ធសាស្ត្រនៃវិស័យ ដែលមានចរិតលក្ខណៈជាបណ្តាញសុវត្ថិភាពសង្គមនៃការគាំពារសង្គម ដែលចូលរួមចំណែកក្នុងការកាត់បន្ថយភាពក្រីក្រ ការកសាងមូលធនមនុស្ស និងការទប់ទល់ទៅនឹងវិបត្តិ។

ក្រសួងដែលមានអាណត្តិការងារពាក់ព័ន្ធជាមួយ **វិស័យសង្គមកិច្ច** ពិសេសគឺក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងសុខាភិបាល ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងកិច្ចការនារី និងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដើរតួនាទីយ៉ាងសំខាន់នៅក្នុងការអនុវត្តការគាំពារសង្គម និងផ្តល់នូវជំនួយឧបត្ថម្ភ និងសេវាកម្មផ្សេងៗដល់ជនក្រីក្រនិងងាយរងគ្រោះ។ កិច្ចគាំពារសង្គមបានក្លាយទៅជាផ្នែកមួយដ៏សំខាន់ នៃការកំណត់សកម្មភាពការងាររបស់ក្រសួងដែលពាក់ព័ន្ធនឹងវិស័យសង្គមកិច្ច ពិសេសលើការផ្តោតការយកចិត្តទុកដាក់របស់យុទ្ធសាស្ត្រ និងផែនការនៃវិស័យនីមួយៗទៅលើការកាត់បន្ថយវិសមភាពនៃការទទួលយកបាន និងការប្រើប្រាស់សេវាកម្មសង្គមចាំបាច់នានា ពិសេសនៅថ្នាក់ក្រោមជាតិ។

ក្រសួងជំនាញ ដែលមានអាណត្តិការងារពាក់ព័ន្ធនឹង **ការកសាងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត** ដូចជាក្រសួងអប់រំ យុវជន និងកីឡា ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងសាធារណការ និងដឹកជញ្ជូន ក្រសួងអភិវឌ្ឍន៍ជនបទ និងក្រសួងធនធានទឹក និងឧតុនិយម មានតួនាទីនៅក្នុងការគាំពារសង្គម ទាំងការធានាដល់ការកសាងហេដ្ឋារចនាសម្ព័ន្ធរូបវន្តដោយនិរន្តរភាព និងការធានាសន្តិសុខស្បៀង ព្រមទាំងការបង្កើនប្រាក់ចំណូលដល់ជនក្រីក្រ និងជនងាយរងគ្រោះ។

ក្រៅពីក្រសួងជំនាញដែលមានអាណត្តិការងារពាក់ព័ន្ធនឹងវិស័យសង្គមកិច្ច និងហេដ្ឋារចនាសម្ព័ន្ធ ស្ថាប័នមួយចំនួនទៀតមានសូលនៃអាណត្តិការងារក្នុង **ការគាំពារសង្គម**។ កាកបាទក្រហមកម្ពុជា និងគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ជួយដល់ប្រជាជនក្នុងការទប់ទល់ និងសម្របខ្លួនទៅនឹងឥទ្ធិពលនៃមហន្តរាយ។ ស្ថាប័នទាំងនេះបានចូលរួមដោយជោគជ័យនៅក្នុងការដោះស្រាយបញ្ហាអសន្តិសុខស្បៀង កង្វះទីជម្រក និងការទទួលបានសេវាកម្មមូលដ្ឋាន រួមមានស្បៀង ទឹក និងអនាម័យ សម្រាប់ប្រជាជនដែលរងផលប៉ះពាល់ដោយសារទឹកជំនន់ និងមហន្តរាយធម្មជាតិផ្សេងទៀត។

ទាក់ទងដល់ **ការផ្តល់សុខុមាលភាពដល់កុមារងាយរងគ្រោះ** ក្រសួងអប់រំ យុវជន និងកីឡា មានអាណត្តិការងារក្នុងការជំរុញគោលដៅការអប់រំមូលដ្ឋានឲ្យបានដល់ថ្នាក់ទី៩ ដូចដែលមានចែងនៅក្នុងរដ្ឋធម្មនុញ្ញ និងចំណុចដៅនៅក្នុង **ផែនការជាតិអប់រំសម្រាប់ទាំងអស់គ្នា ឆ្នាំ២០០៣-២០១៥**។ ដើម្បីដោះស្រាយបញ្ហាទាំងឡាយនៅក្នុងវិស័យអប់រំ រាជរដ្ឋាភិបាលបានជំរុញឲ្យអនុវត្ត **អនុក្រមគ្រប់គ្រងទូទាំងវិស័យ** តាមរយៈការបង្កើតភាពជាដៃគូក្នុងការកសាងផែនការនិងកម្មវិធីសម្រាប់វិស័យអប់រំ។ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានបង្កើតកាលានុវត្តភាពនៃ **ការងារសមរម្យ** សម្រាប់ក្រុមជនងាយរងគ្រោះ និងបោះជំហានយ៉ាងវិជ្ជមានលើការសម្រេចបាននូវ **គោលដៅឆ្ពោះនៃពលកម្មកុមារ** តាមរយៈការកាត់បន្ថយគ្រប់ទម្រង់នៃពលកម្មកុមារឲ្យបាន៨%នៅឆ្នាំ២០១៥ និងលុបបំបាត់គ្រប់ទម្រង់នៃពលកម្មកុមារនៅឆ្នាំ២០១៦។ ក្នុងវិស័យសុខាភិបាល ក្របខណ្ឌយុទ្ធសាស្ត្ររបស់ **ផែនការយុទ្ធសាស្ត្រសុខាភិបាល ២០០៣-២០០៧** រួមមានកម្មវិធីចម្បងបីរបស់ក្រសួងសុខាភិបាល គឺសុខភាពបន្តពូជមាតា-ទារកនិងកុមារ ជំងឺឆ្លង និងជំងឺមិនឆ្លងនិងបញ្ហាសុខភាពសាធារណៈដទៃទៀត។

ស្ថាប័នមួយចំនួនទៀតដែលមានសកម្មភាពការងារដោយផ្ទាល់ឬដោយប្រយោល ក្នុង**ការគាំទ្រការអនុវត្តកម្មវិធីកិច្ចគាំពារសង្គម** ឲ្យកាន់តែមានប្រសិទ្ធភាពក្នុងរយៈពេលខ្លីឬវែង រួមមានក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងមហាផ្ទៃ ក្រសួងផែនការ ក្រសួងកិច្ចការនារី ក៏ដូចជាអាជ្ញាធរដែនដី។ ក្រសួងមហាផ្ទៃ ដើរតួនាទីយ៉ាងសំខាន់ ក្នុងការធ្វើឲ្យកាន់តែប្រសើរឡើងនូវការផ្តល់សេវាកម្មតាមបែបវិមជ្ឈការដែលជាអាទិភាពមួយនៃរាជរដ្ឋាភិបាល ក្នុងការកំណត់នូវច្រកចូលដើម្បីធានាគុណភាព និងសមភាពនៃការផ្តល់សេវាកិច្ចគាំពារសង្គមនៅថ្នាក់ក្រោមជាតិ។ ក្រសួងផែនការ មានតួនាទីយ៉ាងសំខាន់ក្នុងការធ្វើអត្តសញ្ញាណកម្មនិងកំណត់គោលដៅនៃជនក្រីក្រ តាមរយៈ**កម្មវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ**ដែលត្រូវបានគេទទួលស្គាល់ថាជាការបង្កើតមូលដ្ឋានសម្រាប់ពង្រឹងការផ្តល់សេវា កិច្ចគាំពារសង្គម និងការធានា

អភិក្រមដែលមានសុខដុមនីយកម្មក្នុងការផ្តល់កិច្ចគាំពារសង្គម។ នៅក្នុងរយៈពេលកន្លងមក ព្រះរាជាណាចក្រកម្ពុជាបានទទួលជោគជ័យនិងសម្រេចបានសមិទ្ធផលគួរឲ្យកត់សម្គាល់ជាច្រើន ក្នុងការលើកកម្ពស់សមភាពយេនឌ័រ តាមរយៈការអនុវត្ត **ផែនការនារីរតនៈទី២ ២០០៤-២០០៨** របស់ក្រសួងកិច្ចការនារីដែលផ្តោតជាសំខាន់ទៅលើ វិស័យអាទិភាពចំនួន៥គឺ ការអភិវឌ្ឍសេដ្ឋកិច្ចស្ត្រី ការបង្កើនការអប់រំដល់ស្ត្រីនិងក្មេងស្រី ការការពារផ្លូវច្បាប់ដល់ស្ត្រីនិងក្មេងស្រី ការលើកកម្ពស់សុខភាពស្ត្រីនិងក្មេងស្រី ការបង្កើនចំនួនស្ត្រីក្នុងតួនាទីធ្វើសេចក្តីសម្រេច និងការបញ្ជ្រាបយេនឌ័រក្នុងគោលនយោបាយនិងកម្មវិធីជាតិ។

## ៤.២. កម្មវិធីឬគម្រោងដែលមានស្រាប់ក្នុងការផ្តល់សេវាកិច្ចគាំពារសង្គម

កម្មវិធីផ្សេងៗខាងក្រោមនេះ ជាប្រភេទកម្មវិធីដែលទទួលបានជោគជ័យក្នុងការផ្តល់ជូនដល់អ្នកទទួលផលក្នុងចំនួនច្រើន គឺការទទួលយកបានដោយមានប្រសិទ្ធភាពនូវសេវាកម្មស្បៀងអាហារ និងប្រាក់ចំណូលនៅកម្ពុជា។

**អន្តរាគមន៍ស្បៀងនិងអាហារូបត្ថម្ភ**

- ការចែកចាយស្បៀងទូទៅ ទៅកាន់តំបន់អសន្តិសុខស្បៀង ក្នុងអំឡុងពេលអាសន្ន
- ការផ្តល់អាហារនៅសាលារៀន និងរបបស្បៀងយកទៅផ្ទះ ឬអាហារូបករណ៍ស្បៀង
- កម្មវិធីស្បៀងពលកម្ម ក្នុងការដោះស្រាយបញ្ហាអសន្តិសុខស្បៀង កង្វះការងារតាមរដូវកាល ភាពក្រីក្ររ៉ាំរ៉ៃ និងការបង្កើតហេដ្ឋារចនាសម្ព័ន្ធដោយនិរន្តរភាព
- កម្មវិធីអាហារូបត្ថម្ភ និងសុខភាពមាតា និងទារក រួមមានការផ្តល់អាហារដែលបញ្ចូលមីក្រូសារជាតិ ដោយមានលក្ខខណ្ឌលើការចូលរួមវគ្គបណ្តុះបណ្តាលស្តីពីអាហារូបត្ថម្ភ
- ជំនួយស្បៀង ដល់ជនដែលមានផ្ទុកមេរោគហ៊ីវ អ្នកជំងឺរបេង និងកុមារកំព្រា និងកុមារងាយរងគ្រោះ។

**អន្តរាគមន៍សុខាភិបាល**

- វិធានការអប់រំនិងលើកកម្ពស់សុខភាព និងការចាក់ថ្នាំបង្ការ
- មូលនិធិសមធម៌សុខាភិបាល និងការធានារ៉ាប់រងសុខភាពសហគមន៍មូលដ្ឋាន ដែលឆ្លើយតបដល់ការគាំពារសុខភាពមូលដ្ឋានសម្រាប់ប្រជាជនទូទៅ។

**អន្តរាគមន៍សិក្សាអប់រំ បណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ**

- កម្មវិធីផ្តល់អាហារនៅសាលារៀន និងរបបស្បៀងយកទៅផ្ទះ។

- អាហារូបករណ៍ ដែលឆ្លើយតបដល់បញ្ហាភាពក្រីក្រ និងកង្វះប្រាក់ចំណូលនៃគ្រួសារដែលមានកុមារដល់អាយុត្រូវចូលរៀន។
- កម្មវិធីបណ្តុះបណ្តាលរបស់មូលនិធិជាតិកាត់បន្ថយភាពក្រីក្រ។
- កម្មវិធីបណ្តុះបណ្តាលរបស់មូលនិធិពិសេសសម្តេចតេជោនាយករដ្ឋមន្ត្រី។
- កម្មវិធីបណ្តុះបណ្តាលតាមលិខិតបញ្ជាក់ របស់គម្រោងសាកល្បងលើបច្ចេកទេសក្រោយប្រមូលផល និងកម្មវិធីស្ពានចម្លងបន្តជំនាញ។
- កម្មវិធីបណ្តុះបណ្តាលតាមគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ និងតាមវគ្គបណ្តុះបណ្តាលតាមសហគមន៍របស់មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត។
- កម្មវិធីបណ្តុះបណ្តាលពិសេសដល់ជនជាតិភាគតិច និងជនងាយរងគ្រោះ។
- វគ្គសហគ្រិនភាពដល់សិក្ខាកាមក្នុងកម្មវិធីបណ្តុះបណ្តាល។
- កម្មវិធីបណ្តុះបណ្តាលតាមមុខសញ្ញារបស់ក្រសួងស្ថាប័នជំនាញនានា។
- កម្មវិធីអប់រំនិងបណ្តុះបណ្តាលដោយអង្គការ សមាគមន៍ និងស្ថាប័នឯកជន ដែលមានការទទួលស្គាល់ពីស្ថាប័នរដ្ឋ។

**អន្តរាគមន៍សុខុមាលភាពសង្គម និងលក្ខខណ្ឌការងារ**

- អធិការកិច្ចការងារនិងអធិការកិច្ចពេទ្យការងារ ដើម្បីធានាលក្ខខណ្ឌការងារនៅនឹងកន្លែងធ្វើការ សុខភាព និងសុវត្ថិភាពនៅនឹងកន្លែងធ្វើការ។
- ការពារសុខភាពនិងសុវត្ថិភាពការងារដល់សហគ្រាសខ្នាតតូច និងសេដ្ឋកិច្ចក្រៅប្រព័ន្ធ។
- ចុះបញ្ជីការទំនាក់ទំនងវិជ្ជាជីវៈដើម្បីបង្កើតជាយន្តការផ្សះផ្សាវិវាទនៅនឹងកន្លែង និងយន្តការក្រុមប្រឹក្សាអាជ្ញាកណ្តាល សំដៅបង្កើនភាពសុខដុមនីយកម្មរវាងកម្មករនិយោជិត និងនិយោជក។
- របបធានារ៉ាប់រងហានិភ័យការងារ។
- ការធានាបណ្តាញសុវត្ថិភាពសម្រាប់ពលករទេសន្តរប្រវេសន៍។
- កម្មវិធីទប់ស្កាត់រាល់ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ និងការងារដោយបង្ខំ។
- សេវាកម្មសុខុមាលភាពសង្គមដល់ក្រុមជនងាយរងគ្រោះពិសេស រួមមានជនពិការ ជនចាស់ជរា កុមារកំព្រា ...។

**អន្តរាគមន៍ទីផ្សារការងារ**

- រៀបចំក្របខណ្ឌគុណវុឌ្ឍិជាតិ ស្តង់ដារជាតិសមត្ថភាព និងកញ្ចប់តេស្តសមត្ថភាពដែលជាឧបករណ៍ជាតិក្នុងការវាស់កំរិតសមត្ថភាពរបស់កម្លាំងពលកម្មជម្រុញផលិតភាព និងធ្វើជា

ស្ថានចម្លងសម្រាប់អ្នកដែលមានតែចំណេះធ្វើ ឲ្យក្លាយទៅជាអ្នកដែលមានចំណេះដឹងមានសញ្ញាប័ត្រ។ ឧបករណ៍ជាតិនេះ ក៏ជាឧបករណ៍សម្រាប់ធានាគុណភាពអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ តាមរយៈការទទួលស្គាល់វគ្គឬកម្មវិធីបណ្តុះបណ្តាល ក៏ដូចជាគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈរដ្ឋ អង្គការ សមាគម និងឯកជនផងដែរ។

- សេវាការងារសាធារណៈរបស់ទីភ្នាក់ងារជាតិមុខរបរ និងការងារ ដែលជាសេវាបំពេញបន្ថែមលើសេវាឯកជនដែលមានស្រាប់ សំដៅធ្វើឲ្យមានសមភាពព័ត៌មានទីផ្សារការងារក្នុងចំណោមកម្លាំងពលកម្មនៅតាមបណ្តាខេត្ត។
- ការធ្វើអធិការកិច្ចហ្វឹកហ្វឺនកូនជាង សំដៅបង្កើនសមត្ថភាពជំនាញនិងលទ្ធភាពទទួលបានពហុជំនាញ។
- ស្រាវជ្រាវគោលនយោបាយការងារនិងជំនាញវិជ្ជាជីវៈដែលជាតម្រូវការទីផ្សារ សំដៅគ្រប់គ្រង និងធ្វើសមាហរណកម្មកម្លាំងពលកម្មទៅតាមលំដាប់ និងអាទិភាពនៃការបែងចែកកម្លាំងពលកម្មក្នុងទីផ្សារការងារ។

គម្រោងកម្មវិធី និងសេវាកម្មដែលទាក់ទងនឹងកម្មវិធីទាំងនេះភាគច្រើន ជាការចូលរួមកសាង **ប្រព័ន្ធគាំពារសង្គមដ៏ទូលំទូលាយ** សម្រាប់ជនក្រីក្រ និងជនងាយរងគ្រោះនៅកម្ពុជា។

តារាងទី៣ បង្ហាញពីទិដ្ឋភាពនាពេលបច្ចុប្បន្ននៃអន្តរាគមន៍ជាលក្ខណៈគាំពារសង្គមសំខាន់ៗរបស់រាជរដ្ឋាភិបាល។ តារាងសារពើភណ្ឌពិស្តារ មាននៅក្នុងឧបសម្ព័ន្ធទី១ ដែលបកស្រាយយ៉ាងល្អិតល្អន់ពីការចំណាយ អ្នកទទួលផល និងវិសាលភាព។ តារាងបញ្ជីសារពើភណ្ឌនេះ កំពុងស្ថិតនៅក្រោមការរៀបចំនៅឡើយ ហើយបញ្ជីដែលមានលក្ខណៈកាន់តែពិស្តារជាងនេះនឹងត្រូវរៀបចំឡើងក្នុងអំឡុងពេលអនុវត្ត **យ.ជ.គ.ស.**។ កម្មវិធីខាងក្រោមមួយចំនួនបានអនុវត្តដោយប្រើប្រាស់ **ទិន្នន័យកម្មវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ** ដែលអនុវត្តវិធីសាស្ត្រសម្រាប់កំណត់គ្រួសារក្រីក្រដោយប្រើប្រាស់សូចនាករមួយចំនួនសម្រាប់វាស់វែងភាពក្រីក្រ និងដោយមានការរកការឯកភាពទទួលស្គាល់ពីសហគមន៍នៅមូលដ្ឋាន។ កម្មវិធិនេះអនុវត្តដោយក្រសួងផែនការ រដ្ឋបាលថ្នាក់ក្រោមជាតិ និងរចនាសម្ព័ន្ធនៅតាមសហគមន៍មូលដ្ឋាន។ រាជរដ្ឋាភិបាលមាននិន្នាការក្នុងការដាក់ឲ្យប្រើទិន្នន័យកម្មវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រនេះ ជាវិធីសាស្ត្រកំណត់គោលដៅចំបងសម្រាប់គ្រប់កម្មវិធីគាំពារសង្គម ក៏ប៉ុន្តែនៅតែអនុញ្ញាតឲ្យប្រើប្រាស់វិធីសាស្ត្របំពេញបន្ថែមផ្សេងទៀត បើសិនជាមានមូលហេតុសមស្រប។

## តារាងទី៣. ទិដ្ឋភាពនៃអន្តរាគមន៍ជាលក្ខណៈកិច្ចគាំពារសង្គមរបស់រាជរដ្ឋាភិបាលនាពេលបច្ចុប្បន្ន

| ហានិភ័យ/វិបត្តិ | ប្រភេទកម្មវិធី | កម្មវិធី | ក្រសួងដឹកនាំ |
|---|---|---|---|
| ស្ថានភាពគ្រោះអាសន្ន និងវិបត្តិ | *ការចែកស្បៀង* | គម្រោងឧបត្ថម្ភស្បៀងសង្គ្រោះបន្ទាន់ (ការចែកអង្ករដោយមិនគិតថ្លៃ) | ក្រ.សេដ្ឋកិច្ច |
| | | ការឆ្លើយតប និងបង្ការគ្រោះមហន្តរាយ, ការចែកស្បៀងទូទៅ (ព្យុះ កេតសាណា) | គ.ជ.គ.គ |
| | | កញ្ចប់ជំនួយសង្គ្រោះបន្ទាន់សម្រាប់ជនងាយរងគ្រោះ និងជនរងគ្រោះដោយសារគ្រោះអាសន្ន (រាប់បញ្ចូលទាំងជនរងគ្រោះដោយសារមីន) | ក្រ.សង្គមកិច្ច |
| | *ការទ្រទ្រង់ថវិកា* | គម្រោងកសិកម្មខ្នាតតូច និងប្រតិបត្តិការរៀបចំគោលនយោបាយកិច្ចគាំពារសង្គម | ក្រ.សេដ្ឋកិច្ច |
| | *ការឧបត្ថម្ភជំនួយសង្គ្រោះបន្ទាន់តាមរយៈឃុំ សង្កាត់* | ជំនួយសង្គ្រោះបន្ទាន់-ជំនួយជាសាច់ប្រាក់ ឬជាសម្ភារៈដល់ឃុំ សង្កាត់ ដើម្បីជំរុញការសម្រេចបានគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា | ក្រ.មហាផ្ទៃ |
| ឧបសគ្គលើការអភិវឌ្ឍមនុស្ស | | | |
| កង្វះអាហារូបត្ថម្ភ និងសុខភាពមាតា និងទារក | *កម្មវិធីអាហារូបត្ថម្ភ* | ការរស់រាននៃកុមារ  សមាសភាគក្នុងគម្រោងបង្កើនការថែរក្សាសុខភាពមាតា និងទារកទើបកើត និងការបង្កើនការអនុវត្តគន្លឹះនៃអាហារូបត្ថម្ភ និងសុខភាព | ក្រ.សុខាភិបាល |
| | | កម្មវិធីអាហារូបត្ថម្ភ និងសុខភាពមាតា និងកុមារ | |
| | | កម្មវិធីអន្តរាគមន៍ផ្សេងទៀត | |
| | | កម្មវិធីផលិតនិងចែកចាយអំបិលមានជាតិអ៊ីយ៉ូត | ក្រ.ផែនការ |
| ការទទួលបានការអប់រំដែលមានគុណភាពនៅមានកម្រិត | *អាហារូបករណ៍ជាប្រាក់* | គំនិតផ្តួចផ្តើមតាមដានរហ័ស (ថ្នាក់ទី៤-៦)<br>គម្រោងទ្រទ្រង់វិស័យអប់រំកម្ពុជា (ថ្នាក់ទី៧-៩)<br>មូលនិធិនៃប្រទេសជប៉ុនសម្រាប់ការកាត់បន្ថយភាពក្រីក្រ (ថ្នាក់ទី៧-៩) កម្មវិធីបណ្តុះបណ្តាលគ្រូ និងការអប់រំមូលដ្ឋាន (ថ្នាក់ទី៧-៩) កម្មវិធីកែលម្អគុណភាពអប់រំ (ថ្នាក់ទី១០-១២) អន្តេវាសិកដ្ឋាន (ថ្នាក់ទី១០-១១) គម្រោងផ្សេងៗទៀត (ថ្នាក់ទី៧-៩) | ក្រ.អប់រំ |
| | | គម្រោងឧបត្ថម្ភស្បៀងបន្ទាន់ (ថ្នាក់ទី៥-៦ និងថ្នាក់ទី ៨-៩) | ក្រ.សេដ្ឋកិច្ច |
| | *កម្មវិធីអប់រំសម្រាប់ឱកាសលើកទី២* | កម្មវិធីបណ្តុះបណ្តាលរបស់មូលនិធិជាតិកាត់បន្ថយភាពក្រីក្រ | ក្រ.ការងារ |
| | | កម្មវិធីបណ្តុះបណ្តាលរបស់មូលនិធិពិសេសសម្តេចតេជោនាយករដ្ឋមន្ត្រី | |
| | | កម្មវិធីបណ្តុះបណ្តាលតាមលិខិតបញ្ជាក់<br>គម្រោងសាកល្បងលើបច្ចេកទេសក្រោយប្រមូលផល និងកម្មវិធី | |

| ហានិភ័យ/វិបត្តិ | ប្រភេទកម្មវិធី | កម្មវិធី | ក្រសួងដឹកនាំ |
|---|---|---|---|
| | | ស្ពានចម្លងបន្តជំនាញ | |
| | | កម្មវិធីបណ្តុះបណ្តាលតាមគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ និងតាមវគ្គបណ្តុះបណ្តាលតាមសហគមន៍របស់មន្ទីរការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត | |
| | | កម្មវិធីបណ្តុះបណ្តាលពិសេសដល់ជនជាតិភាគតិច និងជនងាយរងគ្រោះ | |
| | | វគ្គសហគ្រិនភាពដល់សិក្ខាកាមក្នុងកម្មវិធីបណ្តុះបណ្តាល | |
| | *អាហារូបករណ៍ជាប្រាក់* | ប្រាក់ឧបត្ថម្ភជីវភាពសិក្ខាកាមមូលនិធិពិសេសសម្តេចតេជោនាយករដ្ឋមន្ត្រី | |
| ពលកម្មកុមារពិសេសក្នុងទម្រង់ធ្ងន់ធ្ងរ | *អន្តរាគមន៍ដោយផ្ទាល់ និងការលើកកម្ពស់កម្រិតជីវភាព* | គម្រោងទ្រទ្រង់ដល់ផែនការសកម្មភាពជាតិដើម្បីលុបបំបាត់រាល់ទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារ ២០០៨-២០១២ | ក្រ.ការងារ |
| និកម្មភាពជាលក្ខណៈរដូវកាល និងកាលានុវត្តភាពជីវភាព | *កម្មវិធីសំណង់សាធារណៈ* | ស្បៀងពលកម្ម | ក្រ.ជនបទ |
| | | ស្បៀងពលកម្ម (គម្រោងឧបត្ថម្ភស្បៀងបន្ទាន់) | ក្រ.សេដ្ឋកិច្ច |
| | | សាច់ប្រាក់ពលកម្ម (គម្រោងឧបត្ថម្ភស្បៀងបន្ទាន់) | ក្រ.សេដ្ឋកិច្ច |
| | *ការផ្តល់អាហារនៅសាលារៀន* | ការផ្តល់អាហារនៅសាលារៀន | ក្រ.អប់រំ |
| | | គម្រោងឧបត្ថម្ភស្បៀងបន្ទាន់ | ក្រ.សេដ្ឋកិច្ច |
| | *របបស្បៀងយកទៅផ្ទះ* | របបស្បៀងយកទៅផ្ទះ | ក្រ.អប់រំ |
| | *ការទ្រទ្រង់ថវិកា* | ឥណទានខ្នាតតូចសម្រាប់បង្កើតមុខរបរខ្លួនឯង នៃមូលនិធិជាតិកាត់បន្ថយភាពក្រីក្រ | ក្រ.ការងារ |
| | | ឥណទានខ្នាតតូចសម្រាប់បង្កើតមុខរបរខ្លួនឯង នៃមូលនិធិពិសេសសម្តេចតេជោនាយករដ្ឋមន្ត្រី | |
| វិបត្តិសុខភាព | *ការលើកលែងការបង់ថ្លៃ* | ការលើកលែងនៅតាមមជ្ឈមណ្ឌលសុខភាពជនបទសម្រាប់ជនក្រីក្រ | ក្រ.សុខាភិបាល |
| | *មូលនិធិសមធម៌សុខភាព* | មូលនិធិសមធម៌សុខភាពនៅមន្ទីរពេទ្យប្រតិបត្តិចំនួន ៥០ | |
| | *ការធានារ៉ាប់រងសុខភាពនៅសហគមន៍* | គម្រោងការធានារ៉ាប់រងសុខភាពនៅសហគមន៍ ចំនួន ១៣ | |
| ក្រុមជនងាយរងគ្រោះពិសេស | *សុខុមាលភាពសង្គមសម្រាប់ជន* | សេវាកម្ម និងការទ្រទ្រង់ដល់សមាគមជនចាស់ជរា | ក្រ.សង្គមកិច្ច |

| ហានិភ័យ/វិបត្តិ | ប្រភេទកម្មវិធី | កម្មវិធី | ក្រសួងដឹកនាំ |
|---|---|---|---|
| | *ចាស់ជរា* | | |
| | *សុខុមាលភាពសង្គមសម្រាប់គ្រួសារជនពិការ* | មជ្ឈមណ្ឌលស្តារលទ្ធភាពពលកម្ម ឬសេវាកម្មស្តារលទ្ធភាពពលកម្មនៅសហគមន៍សម្រាប់ជនពិការ | |
| | *សុខុមាលភាពសង្គម និងការរៀបចំគោលនយោបាយសម្រាប់កុមារ និងកុមារកំព្រា* | សម្រាប់កុមារកំព្រា កុមាររងគ្រោះដោយសារការជួញដូរ អំពើរំលោភ និងអាជីវកម្មផ្លូវភេទ កុមារជាអនីតិជន និងកុមារគ្រឿងញៀន រួមមានប្រាក់ឧបត្ថម្ភ ឪពុកម្តាយចិញ្ចឹម ឬនៅមជ្ឈមណ្ឌល | |
| | | ការគាំពារកុមារតាមរយៈច្បាប់ គោលនយោបាយ បទដ្ឋាន និងការលើកកម្ពស់ការយល់ដឹង ដើម្បីគាំពារកុមារពីហានិភ័យជាក់លាក់មួយចំនួន | |
| | *សុខុមាលភាពសង្គមសម្រាប់គ្រួសារជនមានផ្ទុកមេរោគអេដស៍ និងរបេង* | សេវាកម្មសង្គម និងការថែរក្សាកុមារ និងគ្រួសារនៃជនរងគ្រោះ និងអ្នកផ្ទុកមេរោគអេដស៍ ក៏ដូចជាកុមារជាអនីតិជន និងកុមារគ្រឿងញៀន | |
| | | កម្មវិធីយល់ដឹងពីជំងឺអេដស៍នៅកន្លែងធ្វើការ សម្រាប់កម្មកររោងចក្រកាត់ដេរ | ក្រ.ការងារ |
| | | ជំនួយឧបត្ថម្ភស្បៀងសម្រាប់អ្នកមានផ្ទុកមេរោគអេដស៍ | ក្រ.សុខាភិបាល<br>ក្រ.សង្គមកិច្ច |
| | | ជំនួយឧបត្ថម្ភស្បៀងសម្រាប់អ្នកជំងឺរបេង | |
| ផ្សេងៗ (គោលនយោបាយទីផ្សារការងារ របបសន្តិសុខសង្គម និងការធានារ៉ាប់រង | *ធានាលក្ខខណ្ឌការងារ* | អធិការកិច្ចការងារ និងអធិការកិច្ចពេទ្យការងារ ដល់សហគ្រាសខ្នាតតូច និងសេដ្ឋកិច្ចក្រៅប្រព័ន្ធ | ក្រ.ការងារ |
| | | បញ្ជីការទំនាក់ទំនងវិជ្ជាជីវៈ យន្តការផ្សះផ្សាវិវាទនៅនឹងកន្លែង និងយន្តការក្រុមប្រឹក្សាអាជ្ញាកណ្តាល | |
| | | របបធានារ៉ាប់រងហានិភ័យការងារ (គ្រោះថ្នាក់ការងារ) | |
| | | សំណាញ់សុវត្ថិភាពសម្រាប់ពលករទេសន្តរប្រវេសន៍ | |
| | *ព័ត៌មានទីផ្សារការងារ* | ក្របខណ្ឌគុណវុឌ្ឍិជាតិ ស្តង់ដារជាតិសមត្ថភាព និងកញ្ចប់តេស្តសមត្ថភាព | |
| | | សេវាការងារសាធារណៈរបស់ទីភ្នាក់ងារជាតិមុខរបរនិងការងារ | |
| | | អធិការកិច្ចហ្វឹកហ្វឺនកូនជាងសំដៅបង្កើនសមត្ថភាពជំនាញ និងលទ្ធភាពទទួលបានពហុជំនាញ | |
| | | គោលនយោបាយការងារជំនាញវិជ្ជាជីវៈ | |
| | *របបសន្តិសុខ* | របបសន្តិសុខសង្គមគ្របដណ្តប់លើបញ្ហារបួសក្នុងការងារ | ក្រ.ការងារ |

| ហានិភ័យ/វិបត្តិ | ប្រភេទកម្មវិធី | កម្មវិធី | ក្រសួងដឹកនាំ |
|---|---|---|---|
| | *សង្គម និងរបបសោធន* | របបសោធនសម្រាប់មន្ត្រីរាជការស៊ីវិល របបសោធនអតីតយុទ្ធជន និងរបបសោធនសម្រាប់កម្មករនិយោជិតក្នុងរបបបេឡាសន្តិសុខសង្គម | ក្រ.សង្គមកិច្ច<br>ក្រ.ការងារ |
| | | ការទទួលប្រយោជន៍លំហែមាតុភាពសម្រាប់កម្មករទាំងអស់ (លើកលែងអ្នកបម្រើតាមផ្ទះ) មន្ត្រីរាជការស៊ីវិល កងកម្លាំងប្រដាប់អាវុធ និងប៉ូលីស (ការឈប់សម្រាកលំហែមាតុភាពចំនួន ៩០ ថ្ងៃ ទទួលប្រាក់បៀវត្សពាក់កណ្តាល ដោយនិយោជកជាអ្នកទទួលបន្ទុកតាមច្បាប់ស្តីពីការងារមាត្រា ១៨៣) | ក្រ.ការងារ<br>ក្រ.សង្គមកិច្ច |
| | | ប្រាក់វិភាជន៍សម្រាប់ឧត្តរជីវី ជាឪពុកម្តាយ ឬអាណាព្យាបាលសម្រាប់យុទ្ធជនពលី ប្តីឬប្រពន្ធនៃជនពិការ អ្នកចូលនិវត្តន៍ ឬសម្រាប់អ្នកបាត់បង់ សមត្ថភាពការងារ | |
| | *ការធានារ៉ាប់រង* | ការធានារ៉ាប់រងសុខភាពដោយរបបសន្តិសុខសង្គម (ផែនការ) សម្រាប់មន្ត្រីរាជការស៊ីវិល កងកម្លាំង ប្រដាប់អាវុធ និងប៉ូលីស និងកម្មករទាំងអស់ លើកលែងអ្នកបម្រើតាមផ្ទះ | ក្រ.ការងារ<br>ក្រ.សង្គមកិច្ច |

គ.ជ.គ.គ. = គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ

**អង្គការមិនមែនរដ្ឋាភិបាល** ដើរតួនាទីមួយចំនួនក្នុងការជួយដល់គ្រួសារដែលជួបទុក្ខលំបាក។ នៅក្នុងឆ្នាំ២០០៩ អង្គការមិនមែនរដ្ឋាភិបាលបានប្រើប្រាស់ប្រហែល១០,៤% នៃ**ជំនួយអភិវឌ្ឍផ្លូវការ**សម្រាប់ប្រទេសកម្ពុជា ហើយទំហំនៃការប្រើប្រាស់នេះអាចនឹងនៅថេរ (១០,៣%) សម្រាប់ឆ្នាំ២០១០ (ប្រភពព័ត៌មានទិន្នន័យជំនួយអភិវឌ្ឍផ្លូវការនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា)។ ភាគច្រើននៃជំនួយនៅក្នុងវិស័យសុខាភិបាល បានប្រើប្រាស់នៅក្នុងការថែរក្សាសុខភាពបឋម និងលទ្ធភាពទទួលយកបាននៃមន្ទីរពេទ្យនិងគ្លីនិក។ នៅក្នុងវិស័យអប់រំ ជំនួយទាំងនេះផ្តោតលើការអប់រំមូលដ្ឋានសម្រាប់ជនក្រីក្រ និងការបណ្តុះបណ្តាលជំនាញ។ អង្គការមិនមែនរដ្ឋាភិបាល ក៏មានសកម្មភាពច្រើននៅក្នុងការផ្តល់សេវាកម្មសុខុមាលភាពសង្គម និងសហគមន៍តាមរយៈជំនួយចំពោះកុមារកំព្រា ក៏ដូចជាជំនួយទូទៅសម្រាប់កុមារងាយរងគ្រោះ និងយុវជន។

ការជួយគ្នាទៅវិញទៅមក ដើរតួនាទីយ៉ាងសំខាន់ជាលក្ខណៈប្រពៃណីនៅក្នុងប្រទេសកម្ពុជា តាមរយៈសាច់ញាតិ ក្រុមគ្រួសារ និងបណ្តាញក្រៅផ្លូវការមួយចំនួន។ **សំណាញ់សុវត្ថិភាពសង្គមក្រៅផ្លូវការ** រួមមានជំនួយសម្រាប់គ្រួសារ ការប្រវាស់កម្លាំងពលកម្មនិងសត្វ ការចែករំលែកផលដំណាំ ការខ្ចីបុលក្រៅផ្លូវការ ការខ្ចីសម្ភារៈប្រើប្រាស់ ការផ្លាស់ប្តូរព័ត៌មាន ការឧបត្ថម្ភស្បៀង ការខ្ចីបុលថវិកាដោយមិនយកការប្រាក់ និងគំនិតផ្តួចផ្តើមនៃក្រុមជួយខ្លួនឯង (ឧទាហរណ៍សមាគមមរណសង្គ្រោះ)។ បណ្តាញ

សុវត្ថិភាពសង្គមក្រៅផ្លូវការអាចមានភាពទូលំទូលាយ ពិសេសនៅក្នុងពេលមានវិបត្តិទូទាំងសហគមន៍ ដែលកើតឡើងផ្ទួនៗគ្នា និងក្នុងស្ថានភាពគ្រោះអាសន្ន ប៉ុន្តែយន្តការនៅអាចនឹងមើលរំលងក្រុមគ្រួសារ ងាយរងគ្រោះបំផុតដែលខ្វះលទ្ធភាពសងបំណុល (ឧទាហរណ៍ជនចំណាកស្រុកក្នុងសហគមន៍គ្រួសារ ក្រីក្រខ្លាំង ក្រុមជនជាតិដើមភាគតិច ជនចាស់ជរាឬពិការ ជនដែលមានជំងឺរ៉ាំរ៉ៃ)។ ប៉ុន្តែយន្តការនិង មូលដ្ឋាននៃការជួយឧបត្ថម្ភគ្នាទៅវិញទៅមកជាលក្ខណៈប្រពៃណីនេះ កំពុងតែបាត់បង់ទៅយ៉ាងឆាប់ រហ័ស។ ទំនៀមទម្លាប់និងបណ្តាញសង្គម បានរងការផ្លាស់ប្តូរដោយសារកំណើនប្រជាជន កំណើននៃ ការប្រកួតប្រជែងជីវភាព និងការរេចរឹលនៃធនធានធម្មជាតិ ក៏ដូចជាដោយសារនិន្នាការនៃការអភិវឌ្ឍ រួមមានចលនការចំណូលស្រុក និងអន្តោប្រវេសន៍។

## ៤.៣. ចន្លោះប្រហោងនិងបញ្ហាប្រឈមក្នុងការផ្តល់សេវាគាំពារសង្គម

យោងលើការវិភាគស្តីពីភាពក្រីក្រ និងភាពងាយរងគ្រោះនៅក្នុងជំពូកទី៣ និងឆ្លងតាមការ ពិភាក្សាពិគ្រោះយោបល់រវាងស្ថាប័នពាក់ព័ន្ធជាច្រើនដងនាឆ្នាំកន្លងមកនេះ រាជរដ្ឋាភិបាលបានកំណត់ ចំណុចមួយចំនួនដូចខាងក្រោម ថាជាចន្លោះប្រហោងសំខាន់ៗនៅក្នុងការផ្តល់សេវាកិច្ចគាំពារសង្គម ៖

- នៅក្នុងស្ថានភាពគ្រោះអាសន្ន និងកលិយុគ កម្មវិធីសំណង់សាធារណៈគឺជាឧបករណ៍ដ៏ មានប្រសិទ្ធភាព ពិសេសនៅក្នុងដំណាក់កាលស្តារឡើងវិញ ប៉ុន្តែវិសាលភាពនិងការ សម្របសម្រួលសម្រាប់កម្មវិធីនេះនាពេលបច្ចុប្បន្ន នៅមានកម្រិតនៅឡើយ។
- កិច្ចអន្តរាគមន៍គាំពារសង្គមក្នុងការដោះស្រាយបញ្ហាកង្វះការងារ និងអសន្តិសុខស្បៀង ជាលក្ខណៈរដូវកាល រួមមានការចែកចាយស្បៀង ការផ្តល់ស្បៀងនៅសាលារៀន និង កម្មវិធីសំណង់សាធារណៈ ប៉ុន្តែវិសាលភាពនិងការសម្របសម្រួលសម្រាប់កម្មវិធីសំណង់ សាធារណៈនៅមានកម្រិតនៅឡើយ ហើយការផ្តល់ហិរញ្ញប្បទាននិងជំនួយសម្រាប់កម្ម វិធីទាំងនេះ នៅមានភាពពុំទៀងទាត់។
- កង្វះអាហារូបត្ថម្ភ និងសុខភាពមាតា និងទារក នៅតែជាបញ្ហាដែលទាមទារឲ្យមានការ ដោះស្រាយ ដោយសារវិសាលភាពនៃកម្មវិធីដែលមានស្រាប់ (កម្មវិធីអាហារូបត្ថម្ភ និង មូលនិធិសមធម៌សុខភាព) និងមធ្យោបាយសម្ភារៈនៅពុំទាន់ទូលំទូលាយនៅឡើយហើយ សកម្មភាពដែលសំដៅទៅដល់បម្រែបម្រួលអាកប្បកិរិយា នៅពុំទាន់ទទួលបានលទ្ធផល គួរជាទីមោទនៈដែរ។
- ឧប្បត្តិហេតុនៃពលកម្មកុមារ ពិសេសនៅក្នុងទម្រង់ធ្ងន់ធ្ងរនៅតែជាបញ្ហាដែលត្រូវដោះ ស្រាយ ដោយសារវិសាលភាពនៃដំណោះស្រាយនាពេលបច្ចុប្បន្ននៅមានកម្រិត។

- កម្មវិធីអាហារូបករណ៍ និងការផ្តល់អាហារនៅសាលារៀន ជាកម្មវិធីដែលទាមទារឲ្យមានការពង្រីកទៅកាន់តំបន់ដែលមានប្រជាជនក្រីក្រច្រើនរស់នៅ ប៉ុន្តែកិច្ចខិតខំប្រឹងប្រែងក្នុងការបង្កើនគុណភាពនៃការអប់រំ គឺជាកត្តាចាំបាច់បំផុតដើម្បីជំរុញឲ្យកូនសិស្សរៀន។
- វគ្គបណ្តុះបណ្តាលជំនាញ ជាកម្មវិធីដែលមានសក្តានុពលក្នុងការឈានទៅដល់យុវជនដែលពុំបានចូលសាលារៀនក្នុងទ្រង់ទ្រាយធំ ដើម្បីផ្សារភ្ជាប់តម្រូវការនៃនិយោជិតឲ្យកាន់តែសុក្រឹត ហើយនិងទទួលប្រយោជន៍កាន់តែប្រសើរពីប្រព័ន្ធវាយតម្លៃគុណភាពអប់រំ និងវិញ្ញាបនបត្រ។
- ទោះបីវិសាលភាពនៃមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈមានភាពធំទូលាយ គ្របដណ្តប់ស្ទើរទូទាំងប្រទេស (លើកលែងខេត្តព្រះវិហារ និងមណ្ឌលគីរី) ក៏មជ្ឈមណ្ឌលទាំងនេះនៅជួបប្រទះបញ្ហាថវិកានិងសមត្ថភាពបណ្តុះបណ្តាល (កង្វះអគារអន្តេវាសិកដ្ឋានសម្រាប់សិក្ខាកាម សិស្ស និងនិស្សិតជានារីភេទ កង្វះអគារនិងសម្ភារៈបរិក្ខាពិសោធន៍និងអនុវត្តន៍របស់គ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ) ហើយពុំអាចឆ្លើយតបឲ្យបានតាមគ្រប់តម្រូវការរបស់ប្រជាជន និងតម្រូវការទីផ្សារការងារ។
- ប្រព័ន្ធព័ត៌មានទីផ្សារការងារនៅមានកម្រិត ដែលទាមទារឲ្យមានការពង្រីក។
- ការគ្រប់គ្រងទិន្នន័យកម្មករ និយោជិត ទាំងនៅក្នុងប្រទេសនិងក្រៅប្រទេស ពុំទាន់សមស្របតាមស្ថានភាពសេដ្ឋកិច្ចបច្ចុប្បន្ន។
- លទ្ធភាពទទួលឥណទានខ្នាតតូចសម្រាប់បង្កើតមុខរបរដោយខ្លួនឯង នៅមានកម្រិត។
- ការអភិវឌ្ឍជំនាញបច្ចេកទេសវិជ្ជាជីវៈស្របតាមតម្រូវការទីផ្សារការងារ ដើម្បីបង្កើនផលិតភាព និងឱកាសការងារ នៅមានចន្លោះប្រហោង។
- ជំនួយសម្រាប់ជនងាយរងគ្រោះពិសេស នៅមានកម្រិតនៅឡើយ ដូចជាចំពោះជនចាស់ជរា ជនជាតិដើមភាគតិច ជនមានជំងឺរ៉ាំរ៉ៃ (អេដស៍ និងរបេង) និងជនពិការ។

តារាងទី៤ ធ្វើការសង្ខេបលើវឌ្ឍនភាពមកដល់ពេលបច្ចុប្បន្ន ក្នុងការផ្តល់កិច្ចគាំពារសង្គមចំពោះភាពក្រីក្រ និងភាពងាយរងគ្រោះ និងចន្លោះប្រហោងនិងការប្រឈម។

**តារាងទី៤. ចន្លោះប្រហោង និងបញ្ហាប្រឈមនៅក្នុងកិច្ចអន្តរាគមន៍ដែលមានស្រាប់**

| ហានិភ័យ និងវិបត្តិចម្បង | | ជនងាយរងគ្រោះ | វឌ្ឍនភាពនៃចម្លើយតប | ចន្លោះប្រហោង និងការប្រឈម |
|---|---|---|---|---|
| ស្ថានភាពគ្រោះអាសន្ន និងវិបត្តិ | *កលិយុគសេដ្ឋកិច្ច* | - អ្នកក្រ និងក្បែរបន្ទាត់នៃភាពក្រីក្រ | - កម្មវិធីសំណង់សាធារណៈ ជា | - វិសាលភាព និងការសម្របសម្រួលនៃកម្មវិធីសំណង់ |

| ហានិភ័យ និងវិបត្តិចម្បង | | ជនងាយរងគ្រោះ | វិឡូនទាព់នៃចម្លើយតប | ចន្លោះប្រហោង និងការប្រឈម |
|---|---|---|---|---|
| | *មហន្តរាយធម្មជាតិ បរិស្ថាន អាកាសធាតុ* | - អ្នកក្រ និងក្បែរបន្ទាត់នៃភាពក្រីក្រ<br>- អ្នករស់នៅតំបន់ដែលងាយរងគ្រោះដោយទឹកជំនន់ និងគ្រោះរាំងស្ងួត | ឧបករណ៍នៃបណ្ដាញសុវត្ថិភាពសង្គមដែលមានប្រសិទ្ធភាព និងពង្រីកបានយ៉ាងឆាប់រហ័ស ក្នុងពេលមានមហន្តរាយធម្មជាតិ និងកលិយុគ | សាធារណៈដែលមានស្រាប់ នៅមានកម្រិត |
| ឧបសគ្គលើការអភិវឌ្ឍមនុស្ស | *កង្វះអាហារូបត្ថម្ភ និងសុខភាពមាតា និង ទារកទាប* | - នារី និងស្ត្រីក្នុងវ័យបន្តពូជ<br>- ស្ត្រីមានផ្ទៃពោះ<br>- កុមារតូច (០-៥ឆ្នាំ) | - កម្មវិធីអាហារូបត្ថម្ភមាតា និងទារកមួយចំនួនកំពុងមានសកម្មភាព<br>- ការបំបៅកូនដោយទឹកដោះបានកើនឡើង | - វិសាលភាព និងគុណភាពនៃការផ្គត់ផ្គង់អាហារូបត្ថម្ភមាតា និងទារក នៅមានកម្រិត<br>- វិសាលភាពនៃសេវាកម្មនេះពុំមានលក្ខណៈទូលំទូលាយ<br>- កត្តាផ្នែកតម្រូវការដទៃ (ការបរិភោគ ផ្តល់អាហារ និងថែរក្សា) នៅពុំទាន់ដោះស្រាយឲ្យបានគ្រប់គ្រាន់ |
| | *ការទទួលបានការអប់រំដែលមានគុណភាព នៅមានកម្រិត* | - កុមារក្នុងវ័យចូលរៀន (៦-១៤ឆ្នាំ) | - កម្មវិធីអាហារូបករណ៍ និងការផ្តល់អាហារនៅសាលារៀនបានបង្កើនការមករៀន | - គុណភាពនៃការអប់រំនៅមានកម្រិត<br>- វិសាលភាពនៃសេវាអប់រំនៅមានភាពប្រែប្រួលខុសគ្នា<br>- វិសាលភាពនៃកម្មវិធីការផ្តល់អាហារនៅសាលារៀន និងអាហារូបករណ៍នៅពុំបានដល់គ្រប់តំបន់ក្រីក្រ |
| | *ការទទួលបានកម្មវិធីឱកាសថ្មីដែលមានគុណភាព នៅមានកម្រិត* | - យុវជន (១៥-២៤ឆ្នាំ) | - ការបង្កើតកម្មវិធីបណ្តុះបណ្តាល<br>- កម្មវិធីផ្តល់ឱកាសថ្មីមួយចំនួនកំពុងដំណើរការ | - គុណភាពនៃវគ្គបណ្តុះបណ្តាល នៅមានកម្រិត<br>- ការផ្តល់កម្មវិធីឱកាសថ្មីនៅមានកម្រិតយ៉ាងអប្បរមា<br>- ទំនាក់ទំនងទាបរវាងប្រភេទវគ្គបណ្តុះបណ្តាល |

| ហានិភ័យ និងវិបត្តិចម្បង | | ជនងាយរងគ្រោះ | វិសាលភាពនៃ ចម្លើយតប | ចន្លោះប្រហោង និងការប្រឈម |
|---|---|---|---|---|
| | | | | និងតម្រូវការនៃនិយោជិត<br>- ពុំទាន់មានប្រព័ន្ធវាយតម្លៃគុណភាពអប់រំ និងវិញ្ញាបនបត្រពីវិស័យឯកជន |
| ភាពគ្មានការងារជាលក្ខណៈរដូវកាល និងកាលានុវត្តភាពជីវភាព | *កង្វះ និងកម្រិតទាបនៃអាហារូបត្ថម្ភ* | - អ្នកក្រ និងក្បែរបន្ទាត់នៃភាពក្រីក្រ<br>- គ្រួសារដែលមានសមាជិកក្នុងបន្ទុកច្រើន<br>- អ្នកគ្មាន និងអ្នកខ្វះដីធ្លី | - ការចែកស្បៀងដោយមានគោលដៅ<br>- កម្មវិធីសំណង់សាធារណៈ ផ្តល់ជំនួយខ្លះក្នុងពេលមានកលិយុគ ឬនៅរដូវខ្វះខាត | - វិសាលភាព និងការសម្របសម្រួលនៃកម្មវិធីសំណង់សាធារណៈដែលមានស្រាប់ នៅមានកម្រិត<br>- ការផ្តល់ហិរញ្ញប្បទាន និងជំនួយនៅមានភាពពុំទៀងទាត់ |
| វិបត្តិសុខភាព | *សុខភាពខ្សោយ របួស ជំងឺ និងជំងឺរាតត្បាត មរណភាព* | - អ្នកក្រ និងក្បែរបន្ទាត់នៃភាពក្រីក្រ<br>- ស្ត្រីមានផ្ទៃពោះ<br>- កុមារក្មេង (០-៥ឆ្នាំ)<br>- ជនចាស់ជរា<br>- ជនពិការចាស់ជរា | - មូលនិធិសមធម៌សុខភាព ផ្តល់ជាហិរញ្ញប្បទានដល់ការថែរក្សាសុខភាពសម្រាប់ជនក្រីក្រនៅតំបន់ខ្លះ | - គុណភាពនៃការថែទាំសុខភាព នៅមានកម្រិត<br>- វិសាលភាព និងការទទួលបានមូលនិធិសមធម៌សុខភាពនៅពុំទាន់មានលក្ខណៈទូលំទូលាយ |
| ក្រុមជនងាយរងគ្រោះពិសេស | *អសមត្ថភាពការងារ ភាពឯកោ* | - ជនចាស់ជរា<br>- ជនពិការ<br>- អ្នកផ្ទុកជំងឺរ៉ាំរ៉ៃ<br>- ជនជាតិដើមភាគតិច<br>- កុមារកំព្រា<br>- ពលករកុមារ<br>- ជនរងគ្រោះដោយអំពើហិង្សា ការកេងប្រវ័ញ្ច និងការរំលោភ<br>- អតីតយុទ្ធជន<br>- គ្រួសារអ្នកចំណាកស្រុក<br>- ស្ត្រីជាមេគ្រួសារ | - របបសោធនសម្រាប់មន្ត្រីរាជការស៊ីវិល របបបេឡាសន្តិសុខសង្គមសម្រាប់និយោជកវិស័យឯកជន<br>- ជំនួយពីស្ថាប័នផ្តល់ជំនួយខ្លះសម្រាប់ពិការភាព<br>- ជំនួយមួយចំនួនសម្រាប់ជនជាតិដើមភាគតិច | - នៅពុំទាន់មានរបបសោធនសម្រាប់អ្នកក្រ<br>- ជំនួយសម្រាប់ជនពិការនៅមានកម្រិតតិចតួចបំផុត<br>- ជំនួយសម្រាប់ក្រុមជនងាយរងគ្រោះពិសេសដទៃទៀតនៅមានកម្រិត |

បន្ថែមលើនេះទៀត រាជរដ្ឋាភិបាលបានកំណត់ថាឧបសគ្គលើផ្នែកស្ថាប័ន និងក្នុងការអនុវត្ត ដូចខាងក្រោម ជាបញ្ហាដែលប៉ះពាល់ដល់ប្រសិទ្ធភាព និងភាពសក្តិសិទ្ធិនៃការផ្តល់កិច្ចគាំពារសង្គម ៖

- ការអនុវត្តកម្មវិធីបណ្តាញសុវត្ថិភាពសង្គម ច្រើនឆ្លុះបញ្ចាំងដល់សកម្មភាពបន្ទាន់ (ដូចជាក្នុងការឆ្លើយតបចំពោះកលិយុគហិរញ្ញវត្ថុនិងស្បៀងអាហារ) ជាងការបង្កើតបណ្តាញសុវត្ថិភាពក្នុងទស្សនវិស័យវែងឆ្ងាយ។
- កម្មវិធីជាច្រើនបានអនុវត្តស្របគ្នាជាមួយនឹងរចនាសម្ព័ន្ធនៃរាជរដ្ឋាភិបាល ហើយពុំបានផ្តល់ការកសាងសមត្ថភាពដល់រដ្ឋបាលមូលដ្ឋាន ក្នុងការទទួលគ្រប់គ្រងលើបណ្តាញសុវត្ថិភាពសង្គមដោយសន្សឹមៗ ធ្វើឲ្យបង្កើតឡើងនូវវដ្តនៃសមត្ថភាពទាបនៅថ្នាក់មូលដ្ឋាន និងបន្តឲ្យមានការអនុវត្តកម្មវិធីដោយស្ថាប័នថ្នាក់ជាតិ។
- ការសម្របសម្រួលដល់អន្តរាគមន៍កិច្ចគាំពារសង្គមនៅមានកម្រិត ហើយបណ្តាលឲ្យមានភាពពុំស្មើសាច់នៃវិសាលភាព ការត្រួតជាន់គ្នានៃកិច្ចខិតខំប្រឹងប្រែង កង្វះនិរន្តរភាពនិងឥទ្ធិពលនៃកម្មវិធីទាំងមូល។
- វិសាលភាពជាលក្ខណៈភូមិសាស្ត្រនៃកម្មវិធីដែលមានស្រាប់ ទោះជាសម្រាប់កម្មវិធីដែលមានវិសាលភាពធំក៏ដោយ ក៏នៅពុំទាន់មានលក្ខណៈទូលំទូលាយ ហើយកម្មវិធីទាំងនោះពុំបានកំណត់អាទិភាពដល់តំបន់ក្រីក្របំផុតនៅឡើយ។
- យន្តការកំណត់គោលដៅ នៅពុំទាន់បានបញ្ជ្រាបទៅដល់គ្រប់ការអនុវត្តកម្មវិធីបណ្តាញសុវត្ថិភាពសង្គម ហើយកម្មវិធីទាំងនេះភាគច្រើននៅពឹងផ្អែកលើនីតិវិធីកំណត់គោលដៅដែលមានលក្ខណៈជាទម្រង់បណ្តោះអាសន្ន ហើយនៅខ្វះការពិនិត្យតាមដានលើសុក្រឹតភាព ហើយបង្កើនឲ្យមានការចំណាយលើកម្រៃជើងសា និងខ្វះប្រសិទ្ធភាព។
- កម្មវិធីក៏ដូចជាស្ថាប័នមួយចំនួនតូច បានប្រមូលព័ត៌មានស្តីពីការពិនិត្យតាមដានគម្រោងដោយប្រើប្រាស់ទិន្នន័យត្រឹមតែអំពីធាតុចូល លទ្ធផល និងបញ្ជីនៃអ្នកទទួលផលតែប៉ុណ្ណោះ ដែលធ្វើឲ្យមានការលំបាកក្នុងការវាយតម្លៃលើប្រសិទ្ធភាពនៃកម្មវិធីដែលកំពុងអនុវត្ត និងដើម្បីកែលម្អកម្មវិធីទាំងនេះក្នុងដំណាក់កាលកំពុងអនុវត្ត។ បន្ថែមលើនេះកម្មវិធីនិងស្ថាប័នមួយចំនួនតូចប៉ុណ្ណោះ ដែលបានប្រើប្រាស់ទិន្នន័យពីការពិនិត្យតាមដានគម្រោង ដើម្បីកែលម្អនីតិវិធីជាបន្តបន្ទាប់។ ការវាយតម្លៃលើបណ្តាញសុវត្ថិភាពសង្គមទាំងមូលនៅមានកម្រិតតិចតួចនៅឡើយ ធ្វើឲ្យមានការលំបាកក្នុងការកំណត់លក្ខណៈសម្បត្តិនៃកម្មវិធីនេះទៅតាមបទដ្ឋានអន្តរជាតិ និងដើម្បីដៅរកចំណុចដែលត្រូវកែលម្អ។
- ប្រព័ន្ធដំណោះស្រាយការតវ៉ាជំទាស់និងការផ្តល់មតិ ជាសសរគ្រឹះសម្រាប់ធានាដល់អភិបាលកិច្ចល្អ តម្លាភាព និងប្រសិទ្ធភាពនៃអន្តរាគមន៍បណ្តាញសុវត្ថិភាពសង្គម តែនៅពុំទាន់មានការរៀបចំច្បាស់លាស់។ កម្មវិធីតិចតួចបំផុតបានវាយតម្លៃលើប្រសិទ្ធភាពនៃប្រព័ន្ធផ្តល់យោបល់។

- ហិរញ្ញប្បទានសម្រាប់ការអនុវត្តបណ្ដាញសុវត្ថិភាពសង្គម នៅតែជាបញ្ហាប្រឈម ដោយសារថវិកាសម្រាប់កម្មវិធីនេះភាគច្រើនទទួលបានពីដៃគូអភិវឌ្ឍ និងប្រើប្រាស់សម្រាប់អន្តរាគមន៍ដែលអនុវត្តជាន់គ្នាជាមួយប្រព័ន្ធនៃរាជរដ្ឋាភិបាល។

# ជំពូកទី៥

# យុទ្ធសាស្ត្រជាតិ
# គាំពារសង្គម
# សម្រាប់ជនក្រីក្រ
# និងជនងាយរងគ្រោះ

# ជំពូកទី៥
# យុទ្ធសាស្ត្រជាតិគាំពារសង្គម
# សម្រាប់ជនក្រីក្រនិងជនងាយរងគ្រោះ

យុទ្ធសាស្ត្រជាតិគាំពារសង្គម មានចរិតលក្ខណៈបំពេញបន្ថែមដល់យុទ្ធសាស្ត្រ និងផែនការតាមវិស័យផ្សេងៗទៀតរបស់រាជរដ្ឋាភិបាលកម្ពុជា ដែលមានការពាក់ព័ន្ធដោយផ្ទាល់ឬដោយប្រយោលជាមួយកិច្ចគាំពារសង្គម។ **យ.ជ.គ.ស.** មានភាពស្របគ្នា និងបង្កើតឲ្យមានដំណើរការសកម្មភាពជាអាទិភាព ដែលបានកំណត់ក្នុងយុទ្ធសាស្ត្រចតុកោណ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្មឆ្នាំ២០០៩-២០១៣។

## ៥.១. ទស្សនវិស័យ

ទស្សនវិស័យរយៈពេលវែងរបស់រាជរដ្ឋាភិបាលកម្ពុជាសម្រាប់កិច្ចគាំពារសង្គម គឺដើម្បីធានាឲ្យមានការធានារ៉ាប់រងជាមូលដ្ឋាននៃកិច្ចគាំពារសង្គមសម្រាប់ប្រជាជនទាំងអស់ តាមរយៈកញ្ចប់ផលប្រយោជន៍ និងសេវាកម្មបំពេញបន្ថែម។ ទស្សនវិស័យរបស់យុទ្ធសាស្ត្រជាតិគាំពារសង្គម រួមមាន **ការឧបត្ថម្ភដែលមានគោលដៅដល់ជនក្រីក្រ** និង **គម្រោងគាំពារសង្គមដោយមានតាគទាន**។ ទស្សនវិស័យនេះ គឺសំដៅសម្រេចឲ្យបានការអភិវឌ្ឍមនុស្សក្នុងកម្រិតខ្ពស់ ក៏ដូចជាជម្រើសនិងកាលានុវត្តភាពស្មើៗគ្នាសម្រាប់ប្រជាជនកម្ពុជាទាំងអស់ ហើយស្របតាមគោលគំនិតនៃកិច្ចគាំពារសង្គមមូលដ្ឋាន។

**ទស្សនវិស័យនៃកិច្ចគាំពារសង្គមសម្រាប់ជនក្រីក្រនិងងាយរងគ្រោះ**

ប្រជាជនកម្ពុជារាល់រូប ពិសេស ជនក្រីក្រនិងងាយរងគ្រោះ នឹងបានទទួលផលប្រយោជន៍ពីបណ្ដាញសុវត្ថិភាពសង្គម និងរបបសន្តិសុខសង្គម ឱ្យកាន់តែប្រសើរឡើង ដែលជាផ្នែកនៃប្រព័ន្ធគាំពារសង្គមដ៏មានប្រសិទ្ធភាព សមស្រប ដែលអាចអនុវត្ត និងមាននិរន្តរភាព។

## ៥.២. គោលបំណង

យុទ្ធសាស្ត្រជាតិគាំពារសង្គមមួយដ៏មានប្រសិទ្ធភាព សម្រាប់ជនក្រីក្រនិងជនងាយរងគ្រោះ គឺដើម្បីកាត់បន្ថយភាពក្រីក្ររ៉ាំរ៉ៃនិងអសន្តិសុខស្បៀង ទ្រទ្រង់ដល់ជនក្រីក្រក្នុងការដោះស្រាយវិបត្តិ និងកសាងមូលធនមនុស្សសម្រាប់ពេលអនាគតដើម្បីលុបបំបាត់វដ្តនៃភាពក្រីក្រ។ ដូច្នេះ គោលបំណងជាយុទ្ធសាស្ត្ររបស់ **យ.ជ.គ.ស.** មានសមាសភាគ៣ រួមមាន ៖

- ការគាំទ្រដល់ជនក្រីក្របំផុតនិងជនជួបការលំបាកបំផុត ដែលមិនអាចជួយខ្លួនឯងបាន
- ការកាត់បន្ថយផលប៉ះពាល់នៃហានិភ័យ ដែលអាចនាំឲ្យប្រជាជនត្រូវប្រើប្រាស់ដំណោះស្រាយបែបអវិជ្ជមាន និងការធ្វើឲ្យមានភាពក្រីក្របន្ថែមទៀត
- ការគាំទ្រដល់ជនក្រីក្រឲ្យចាកចេញផុតពីភាពក្រីក្រ តាមរយៈការកសាងមូលធនមនុស្ស និងការបង្កើនកាលានុវត្តភាព។

**គោលបំណងនៃគិច្ចគាំពារសង្គមសម្រាប់ជនក្រីក្រនិងជនងាយរងគ្រោះ**

ជនក្រីក្រនិងជនងាយរងគ្រោះកម្ពុជា នឹងទទួលការគាំពារកាន់តែប្រសើរឡើង ចេញពីភាពក្រីក្ររ៉ាំរ៉ៃនិងភាពអត់ឃ្លាន វិបត្តិ ភាពខ្វះខាត និងមូលហេតុសង្គម និងទទួលបានប្រយោជន៍ពីការធ្វើវិនិយោគលើធនធានមូលធនមនុស្សរបស់ពួកគាត់។

## ៥.៣. យុទ្ធសាស្ត្ររួមដើម្បីសម្រេចបានគោលបំណង

យុទ្ធសាស្ត្រជាតិគាំពារសង្គមសម្រាប់ជនក្រីក្រនិងជនងាយរងគ្រោះ ត្រូវបានរៀបចំឡើងក្នុងដំណាក់កាលនៃការប៉ះទង្គិចជាសកលនៃកលិយុគសេដ្ឋកិច្ច (វិបត្តិស្បៀងអាហារ ប្រេងឥន្ធនៈ និងហិរញ្ញវត្ថុ) ដែលបានបន្ថែមបន្ទុកទៅលើភាពក្រីក្ររ៉ាំរ៉ៃនៃជនក្រីក្រនិងជនងាយរងគ្រោះនៅកម្ពុជា។ ក្នុងក្របខណ្ឌឆ្ពោះទៅកាន់ឆ្នាំគោលដៅ២០១៥ **យ.ជ.គ.ស.** នឹងផ្សារភ្ជាប់ស្ថានភាពដែលមានស្រាប់នាពេលបច្ចុប្បន្ន ជាមួយនឹងការរៀបចំគោលដៅដែលមានលក្ខណៈចម្រុះនិងជាប្រព័ន្ធ និងឆ្ពោះទៅការផ្តល់ជូនដល់ប្រជាជនក្រីក្រនិងងាយរងគ្រោះនូវការគាំពារបានកាន់តែប្រសើរឡើងចេញពីភាពក្រីក្រ និងការវិនិយោគលើធនធានមនុស្ស។ ដើម្បីសម្រេចបានការផ្សារភ្ជាប់នេះ **យ.ជ.គ.ស.**បានរៀបចំជំហានមួយចំនួនដូចខាងក្រោម។

ការសម្រេចឲ្យបាននៃគោលបំណងទាមទារឲ្យមាន **ការបញ្ចូលគ្នានៃកម្មវិធីដែលគ្របដណ្តប់លើភាពក្រីក្ររ៉ាំរ៉ៃនិងភាពក្រីក្រដែលទើបនឹងកើតឡើង ក៏ដូចជាភាពអត់ឃ្លាន ព្រមទាំងជួយលើកកម្ពស់មូលធនមនុស្ស។** ការដោះស្រាយលើប្រភពសំខាន់ៗនៃភាពងាយរងគ្រោះ (ដែលពុំទាន់បានគ្របដណ្តប់) នឹងចាត់ទុកជា

អាទិភាព ទន្ទឹមនឹងនោះដែរ ក៏មានការបង្កើតចំណុចគោលដៅសំខាន់ៗនៃបណ្ដាញសុវត្ថិភាពសង្គម ដែលនឹងត្រូវរៀបចំនៅពេលបន្ទាប់។

ការផ្សារភ្ជាប់ប្រភពសំខាន់នៃភាពងាយរងគ្រោះ ទៅនឹងកម្មវិធីដែលមានស្រាប់ ទាមទារឲ្យមាន **ការសម្របសម្រួល ការពង្រីក និងការធ្វើសុខដុមនីយកម្មលើអន្តរាគមន៍ដែលមានស្រាប់**។ អន្តរាគមន៍មួយចំនួន ដូចជាមូលនិធិសមធម៌សុខភាព ការផ្ដល់អាហារនៅសាលារៀន អាហារូបករណ៍ និងកម្មវិធីសំណង់សាធារណៈ បាននិងកំពុងដោះស្រាយភាពងាយរងគ្រោះចម្បងៗដែលជនក្រីក្រជួបប្រទះ ហើយជាកម្មវិធីដែលមានប្រសិទ្ធភាព។ ទោះបីយ៉ាងណា កម្មវិធីមួយចំនួន ដូចជាកម្មវិធីសំណង់សាធារណៈកំពុងអនុវត្តដោយដៃគូអភិវឌ្ឍនៅច្រើនស្ថាប័ន ដោយមានលក្ខណៈជាបណ្ដោះអាសន្ន និងគ្មានការសម្របសម្រួល ហើយនិរន្តរភាពរយៈពេលមធ្យមរបស់កម្មវិធីទាំងនេះ នៅតែពុំទាន់មានភាពច្បាស់លាស់នៅឡើយ។ ក្នុងការពង្រីកវិសាលភាពនៃអន្តរាគមន៍ទាំងនេះ ប្រការសំខាន់បំផុតគឺការធ្វើសុខដុមនីយកម្មដំណើរការ ព្រមទាំងការធានាឲ្យមានហិរញ្ញប្បទានទៀងទាត់ ដែលការងារនេះនឹងធានាដល់និរន្តរភាពរយៈពេលមធ្យមនៃកម្មវិធី។ លើសពីនេះទៀត វិសាលភាពនៃកម្មវិធីដែលមានស្រាប់ទាមទារនូវការវាយតម្លៃជាថ្មីម្ដងទៀត ដើម្បីឲ្យមានភាពស៊ីចង្វាក់គ្នាទៅនឹងកម្រិតភាពក្រីក្រ និងភាពងាយរងគ្រោះនៅកម្រិតថ្នាក់ខេត្ត និងស្រុក ឲ្យបានកាន់តែប្រសើរ។

**យន្តការកំណត់អត្តសញ្ញាណគ្រួសារក្រីក្រដែលមានស្រាប់នាពេលបច្ចុប្បន្ន នឹងត្រូវវាយតម្លៃ** ដើម្បីធ្វើការកែលម្អក្នុងករណីចាំបាច់។ ការវាយតម្លៃនេះនឹងត្រូវធ្វើឡើងដើម្បីរកឲ្យឃើញនូវប្រសិទ្ធភាពយន្តការនិងការបំពេញបន្ថែមជាមួយ **ទិន្នន័យមូលដ្ឋានថ្នាក់ឃុំ** និងដើម្បីកំណត់ឲ្យបានកាន់តែប្រសើរឡើងនូវក្រុមជនក្រីក្រនិងក្រុមជនងាយរងគ្រោះពិសេសក្នុងប្រភេទមួយចំនួន ដែលយន្តការនាពេលបច្ចុប្បន្ននៅពុំទាន់អាចកំណត់បាន។

**អន្តរាគមន៍មួយចំនួនកំពុងតែដំណើរការ ប៉ុន្តែវិសាលភាពនៃអន្តរាគមន៍ទាំងនេះចាំបាច់ត្រូវពង្រីក** ហើយការអនុវត្តអន្តរាគមន៍ទាំងនេះត្រូវពង្រឹងបន្ថែមទៀត ដើម្បីបង្កើនឥទ្ធិពលនិងប្រសិទ្ធភាព។ អន្តរាគមន៍ដែលមានលក្ខណៈថ្មីសម្រាប់ប្រទេសកម្ពុជា នឹងយកមកសាកល្បង វាយតម្លៃ និងពង្រីកដោយផ្អែកលើប្រសិទ្ធភាពនិងនិរន្តរភាព។

**ចន្លោះប្រហោងនៃកិច្ចគាំពារសង្គមដែលមានស្រាប់ សម្រាប់ជនក្រីក្រនិងងាយរងគ្រោះ នឹងត្រូវដោះស្រាយតាមកម្មវិធីថ្មី** ដែលមានគោលបំណងជួយកាត់បន្ថយភាពក្រីក្ររ៉ាំរ៉ៃ និងលើកកម្ពស់មូលធនមនុស្ស ដូចជាការឧបត្ថម្ភសាច់ប្រាក់ដល់ជនក្រីក្រ ដោយផ្ដោតលើការបង្កើនគុណភាពអាហារូបត្ថម្ភកុមារនិង

មាតា សុខភាពនិងការអប់រំ និងការកាត់បន្ថយពលកម្មកុមារ ក៏ដូចជាកម្មវិធីផ្តល់ឱកាសថ្មី ដែលលើកកម្ពស់ដល់ការបង្កើតជំនាញសម្រាប់យុវជនដែលពុំបានចូលសាលារៀន និងផ្តល់ការគាំទ្រដល់ពលករជាកុមារ ដើម្បីឲ្យបានវិលត្រឡប់ចូលក្នុងប្រព័ន្ធអប់រំវិញជាថ្មី។

## ៥.៤. គោលដៅ

**យ.ជ.គ.ស.** លើកឡើងនូវគោលដៅចំនួន ៥ ព្រមទាំងអន្តរាគមន៍សំខាន់ៗ ដើម្បីសម្រេចបានគោលដៅទាំងនេះ ដោយផ្អែកលើភាពងាយរងគ្រោះ និងការវិភាគពីចន្លោះប្រហោងនៃកម្មវិធីគាំពារសង្គមដែលមានស្រាប់ ព្រមទាំងឆ្លងកាត់ដំណើរការពិគ្រោះយោបល់បច្ចេកទេសច្រើនលើក ក្នុងឆ្នាំ ២០០៩និង២០១០។ តារាងទី ៥ បង្ហាញដោយសង្ខេប ពីគោលដៅ និងជម្រើសកម្មវិធី ក្នុងរយៈពេលមធ្យម។ សូចនាករតាមដានវឌ្ឍនភាពទាក់ទងនឹងគោលដៅទាំងនេះ ត្រូវបានសង្ខេបនៅក្នុងតារាងទី ៨។

**តារាងទី ៥. គោលដៅរបស់ យ.ជ.គ.ស. និងការផ្សារភ្ជាប់ជាមួយគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា[១៥]**

| វិស័យអាទិភាព និងការផ្សារភ្ជាប់នឹង គ.អ.ស.ក. | គោលដៅ | ជម្រើសកម្មវិធី ឬឧបករណ៍សម្រាប់រយៈពេលមធ្យម |
|---|---|---|
| ឆ្លើយតបនូវតម្រូវការជាមូលដ្ឋានរបស់ជនក្រីក្រ និងជនងាយរងគ្រោះ ក្នុងស្ថានភាពរងគ្រោះអាសន្ន និង កលិយុគ (គ.អ.ស.ក. ១, ៩) | *ជនក្រីក្រ និងជនងាយរងគ្រោះ ទទួលបានការគាំទ្រ ដែលរួមមានស្បៀងអនាម័យ ទឹក និង ជម្រក ។ល។ ដើម្បីបំពេញតាមតម្រូវការរបស់ពួកគាត់ ក្នុងដំណាក់កាលមានគ្រោះអាសន្ន និងវិបត្តិ* | - ការចែកចាយស្បៀងដោយមានគោលដៅ<br>- ការចែកចាយទុន សម្ភារៈកសិកម្ម និង ប្រតិបត្តិការជំនួយក្នុងគ្រោះអាសន្នដទៃទៀត |
| កាត់បន្ថយភាពក្រីក្រ និង ភាពងាយរងគ្រោះនៃកុមារ | *ជនក្រីក្រ កុមារ និងមាតាងាយរងគ្រោះ ទទួលបានផលប្រយោជន៍ពីសំណាញ់* | - ការឧបត្ថម្ភសាច់ប្រាក់ ស្បៀង ឬ សម្ភារៈដទៃទៀតសម្រាប់កុមារនិងស្ត្រី |

[១៥] គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជាមាន៩ រួមមាន ការលុបបំបាត់ភាពក្រីក្រនិងភាពអត់ឃ្លាន ការសម្រេចឲ្យបាននូវការអប់រំមូលដ្ឋានសម្រាប់គ្រប់ៗគ្នា បង្កើនសមភាពយេនឌ័រ និងការផ្តល់អំណាចដល់ស្ត្រី ការកាត់បន្ថយមរណភាពកុមារ ការបង្កើនសុខភាពមាតា ការប្រយុទ្ធប្រឆាំងនឹងមេរោគអេដស៍ គ្រុនចាញ់ និងជំងឺផ្សេងៗទៀត ការធានានិរន្តរភាពបរិស្ថាន ការរៀបចំបង្កើតភាពជាដៃគូសកលសម្រាប់ការអភិវឌ្ឍ និង ការបោសសំអាតមីន យុទ្ធភណ្ឌមិនទាន់ផ្ទុះ និងការទ្រទ្រង់ដល់ជនរងគ្រោះ។

| វិស័យអាទិភាព និងការផ្សារភ្ជាប់នឹង គ.អ.ស.ក. | គោលដៅ | ជម្រើសកម្មវិធី ឬឧបករណ៍សម្រាប់រយៈពេលមធ្យម |
|---|---|---|
| និងមាតា និងបង្កើនការអភិវឌ្ឍធនធានមនុស្សសម្រាប់ពួកគាត់ (គ.អ.ស.ក. ១, ២, ៣, ៤, ៥) | *សុវត្ថិភាពសង្គម ដើម្បីកាត់បន្ថយភាពក្រីក្រនិងអសន្តិសុខស្បៀង និងពង្រឹងការអភិវឌ្ឍមូលធនមនុស្ស តាមរយៈការបង្កើនគុណភាពអាហារូបត្ថម្ភ សុខភាពមាតានិងកុមារ ការលើកកម្ពស់ការអប់រំ និងការលុបបំបាត់ពលកម្មកុមារ ជាពិសេសទម្រង់ធ្ងន់ធ្ងរ* | ដោយកម្មវិធីរួមមួយ (រួមមានការឧបត្ថម្ភសាច់ប្រាក់ដែលផ្តោតលើអាហារូបត្ថម្ភមាតា និងកុមារ ការឧបត្ថម្ភសាច់ប្រាក់ដែលលើកកម្ពស់ការអប់រំ និងកាត់បន្ថយពលកម្មកុមារ ការផ្តល់អាហារមានជីវជាតិបន្ថែមដល់ស្ត្រីមានផ្ទៃពោះ ម្តាយបំបៅដោះកូន និងកុមារ)<br>- ការផ្តល់អាហារនៅសាលារៀន របបស្បៀងយកទៅផ្ទះ<br>- សេវាកម្មផ្សព្វផ្សាយ និង កម្មវិធីឱកាសថ្មីសម្រាប់យុវជននៅក្រៅសាលារៀន និងការគាំទ្រដល់សេវាកម្មសុខុមាលភាពសង្គម |
| ឆ្លើយតបនូវភាពខ្វះការងារ និងភាពគ្មានការងារដែលកើតមានឡើងតាមរដូវកាល និងផ្តល់ឱកាសសម្រាប់ជនក្រីក្រ និងជនងាយរងគ្រោះ ដើម្បីលើកកម្ពស់ជីវភាពរស់នៅរបស់ពួកគាត់ (គ.អ.ស.ក. ១) | *ជនក្រីក្រ និងជនងាយរងគ្រោះដែលពេញវ័យធ្វើការងារ ទទួលបានផលប្រយោជន៍ពីកាលានុវត្តភាពការងារ ដើម្បីធានាឲ្យមានប្រាក់ចំណូល ស្បៀង និងមានការងារធ្វើ ព្រមទាំងចូលរួមក្នុងការកសាងធនធានរូបវន្ត និងធនធានហេដ្ឋារចនាសម្ព័ន្ធសង្គមប្រកបដោយនិរន្តរភាព* | - កម្មវិធីសំណង់សាធារណៈអតិពលកម្មជាតិ<br>- គម្រោងស្បៀងពលកម្ម និងសាច់ប្រាក់ពលកម្ម |
| បង្កើនការថែទាំសុខភាពដែលអាចទទួលយកបានដល់ជនក្រីក្រ និងជនងាយរងគ្រោះ (គ.អ.ស.ក. ៤, ៥, ៦) | *ជនក្រីក្រ និងជនងាយរងគ្រោះ ទទួលបានដោយមានប្រសិទ្ធភាព នូវការថែរក្សាសុខភាពដែលមានគុណភាព និងដែលអាចទទួលប្រើបាន និងការគាំពារផ្នែកហិរញ្ញវត្ថុ ពេលមានជំងឺ* | - ការពង្រីកមូលនិធិសមធម៌សុខភាព (សម្រាប់ជនក្រីក្រ) និងការធានារ៉ាប់រងសុខភាពនៅសហគមន៍ (សម្រាប់ប្រជាជនស្ថិតនៅក្បែរបន្ទាត់នៃភាពក្រីក្រ) ដូចមានចែងក្នុងផែនការមេស្តីពីការគាំពារសុខភាពសង្គម (នៅរង់ចាំការអនុម័ត) |
| បង្កើនការគាំពារសង្គមសម្រាប់ជនងាយរងគ្រោះពិសេសមួយចំនួន | *ក្រុមជនងាយរងគ្រោះពិសេស រួមមានក្មេងកំព្រា ចាស់ជរា ស្ត្រីជាមេគ្រួសារ ជនពិការ ជនផ្ទុកមេរោគអេដស៍ ឬអ្នក* | - សេវាកម្មសុខុមាលភាពសង្គមសម្រាប់ក្រុមជនងាយរងគ្រោះពិសេស<br>- ការឧបត្ថម្ភសង្គម និងប្រាក់សោធននិវត្តន៍ |

| វិស័យអាទិភាព និងការផ្សារភ្ជាប់នឹង គ.អ.ស.ក. | គោលដៅ | ជម្រើសកម្មវិធី ឬឧបករណ៍សម្រាប់រយៈពេលមធ្យម |
|---|---|---|
| (គ.អ.ស.ក. ១, ៦, ៩) | *ជំងឺរបេង ។ល។ ទទួលបាន ការគាំទ្រជាប្រាក់ចំណូល សម្ភារៈ និងចិត្តសាស្ត្រសង្គម ព្រមទាំងការថែទាំសង្គមគ្រប់គ្រាន់* | សង្គមសម្រាប់មនុស្សចាស់ និងអ្នកដែលមានជំងឺរ៉ាំរ៉ៃ ឬជនពិការ |

គ.អ.ស.ក. ៖ គោលដៅអភិវឌ្ឍន៍សហស្សវត្សកម្ពុជា

អត្ថបទខាងក្រោមនេះ គឺជាជំហានដែលនឹងត្រូវធ្វើ ដើម្បីសម្រេចបាននូវគោលដៅទាំង ៥ ដោយបង្ហាញពីសកម្មភាពអាទិភាព ឧបករណ៍ និងកម្មវិធី។ **ជំពូកទី៦** នៃឯកសារនេះ នឹងបកស្រាយយ៉ាងពិស្តារ នូវសកម្មភាពអាទិភាពសម្រាប់អនាគតដ៏ខ្លីខាងមុខ (២០១១-២០១៣) ដែលបង្ហាញវិសាលភាពនៃអន្តរាគមន៍ តម្រូវការធនធាន និងចន្លោះប្រហោងហិរញ្ញប្បទាន។

## ៥.៤.១. គោលដៅទី១

**គោលដៅទី ១**

ជនក្រីក្រនិងងាយរងគ្រោះ ទទួលបានការគាំទ្រ ដែលរួមមានស្បៀង អនាម័យ ទឹក និងជម្រក ។ល។ ដើម្បីបំពេញតាមតម្រូវការរបស់ពួកគាត់ ក្នុងពេលវេលាមានគ្រោះអាសន្ន និងវិបត្តិ។

ដូចបានកំណត់ក្នុង **ក្របខណ្ឌយុទ្ធសាស្ត្រសន្តិសុខស្បៀង និងអាហារូបត្ថម្ភនៅកម្ពុជា ឆ្នាំ២០០៨-២០១២** ការឧបត្ថម្ភសង្គមដើរតួនាទីយ៉ាងសំខាន់ ដើម្បីឲ្យគ្រួសារដែលជួបប្រទះអសន្តិសុខស្បៀងមានលទ្ធភាពទទួលបានស្បៀងឬមធ្យោបាយទិញស្បៀងអាហារ។ **ការឧបត្ថម្ភសង្គម** នេះត្រូវអនុវត្តចំពោះទាំងក្រុមប្រជាជនដែលពើបប្រទះនឹងអសន្តិសុខស្បៀងរ៉ាំរ៉ៃផង និងទាំងអ្នកដែលទទួលរងឥទ្ធិពលពីគ្រោះមហន្តរាយធម្មជាតិ គ្រោះអាសន្ន និងវិបត្តិដទៃទៀតផង។ កម្មវិធីសម្រាប់ដោះស្រាយអសន្តិសុខស្បៀងដែលកើតមានជាលក្ខណៈរ៉ាំរ៉ៃឬតាមរដូវ មានលក្ខណៈសម្បត្តិអាចពង្រីកទំហំបានយ៉ាងងាយស្រួលក្នុងពេលមានគ្រោះអាសន្ន និងវិបត្តិ ជាពិសេសក្នុងដំណាក់កាលក្រោយការសង្គ្រោះបន្ទាន់។ ការឆ្លើយតបទៅនឹងស្ថានភាពគ្រោះអាសន្ន និងវិបត្តិ ដោយប្រើប្រាស់កញ្ចប់ផលប្រយោជន៍អប្បបរមា និងសេវាកម្មដែលសមស្របទៅនឹងតម្រូវការបន្ទាន់របស់ប្រជាជនដែលរងគ្រោះ គឺជាប្រការចាំបាច់។

**កាកបាទក្រហមកម្ពុជា** គឺជាស្ថាប័នដ៏សំខាន់មួយដែលផ្តល់ជំនួយក្នុងស្ថានភាពគ្រោះអាសន្ន។ បន្ថែមលើនេះ **គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ** មានសមត្ថកិច្ចសហការបង្កើតផែនការរៀបចំ និងឆ្លើយតបទៅនឹងស្ថានភាពគ្រោះអាសន្ននិងវិបត្តិ ហើយក៏មានសមត្ថកិច្ចរៀបចំកម្មវិធី ដើម្បីធានាដល់សុខុមាលភាពរបស់ប្រជាជនដែលរងគ្រោះ។ ការរៀបចំត្រៀមទប់ទល់និងឆ្លើយតបទៅនឹងគ្រោះអាសន្ន គឺជាធាតុផ្សំដ៏សំខាន់នៃអាណត្តិការងាររបស់គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ។

ឧបករណ៍សំខាន់ក្នុងការរៀបចំត្រៀមទប់ទល់និងឆ្លើយតបទៅនឹងគ្រោះអាសន្ន ក្នុងបរិបទនៃ **យ.ជ.គ.ស.** គឺការចែកចាយស្បៀងដោយមិនគិតថ្លៃ ការផ្តល់ជម្រក សម្លៀកបំពាក់ ការផ្គត់ផ្គង់ថ្នាំពេទ្យនិងសេវា ព្រមទាំងសម្ភារៈចាំបាច់ដទៃទៀត ក្នុងរយៈពេលដំបូងនៃគ្រោះមហន្តរាយ។ ការផ្តល់ទាំងនេះគឺមានន័យថាជាការផ្តល់ជំនួយបន្ទាន់ និងជាការកាត់បន្ថយទុក្ខលំបាករបស់ប្រជាជនរងគ្រោះ ហើយការផ្តល់នេះក៏នឹងធ្វើឡើងដោយគ្មានលក្ខខណ្ឌដោះដូរនឹងការផ្តល់កម្លាំងពលកម្មពីអ្នកទទួលផលឡើយ ដោយសារគោលដៅនៃការឧបត្ថម្ភនេះគឺដើម្បីដោះស្រាយតម្រូវការមូលដ្ឋានរបស់ប្រជាជនដែលពុំមានលទ្ធភាពទទួលបានមធ្យោបាយជាជម្រើសដើម្បីរស់រានមានជីវិតនិងប្រកបរបរចិញ្ចឹមជីវិត។

បន្ទាប់ពីការឆ្លើយតបជាលក្ខណៈសង្គ្រោះបន្ទាន់បានបញ្ចប់ គឺជាដំណាក់កាលស្រោចស្រង់និងស្តារឡើងវិញ។ កម្មវិធីសាច់ប្រាក់ពលកម្ម និងស្បៀងពលកម្ម គឺជាឧបករណ៍គាំពារសង្គមដែលបានប្រើប្រាស់ជាញឹកញាប់ នៅក្នុងការគ្រប់គ្រងគ្រោះមហន្តរាយ។ ការប្រើប្រាស់ឧបករណ៍កម្មវិធីទាំងនេះគឺដោយសារមានតម្រូវការស្តារឡើងវិញនៃធនធានរូបវន្តបន្ទាប់ពីមានគ្រោះមហន្តរាយ ហើយឧបករណ៍សាច់ប្រាក់ឬស្បៀងពលកម្មនៃកម្មវិធីសំណង់សាធារណៈ ជាប្រភេទសកម្មភាពដែលមានរួចជាស្រេចនិងងាយស្រួលពង្រីកក្នុងពេលមានគ្រោះអាសន្ន ដោយផ្អែកលើលក្ខខណ្ឌតំបន់និងបរិបទ។ ដូច្នេះកម្មវិធីទាំងនេះអាចប្រើប្រាស់ហើយដោយភ្ជាប់ជាមួយគោលដៅបីយ៉ាង រួមមានការកសាងឡើងវិញនៅក្នុងមូលដ្ឋាន ការផ្តល់ស្បៀងអាហារ និងការផ្តល់ប្រាក់ចំណូល ដើម្បីជួយដល់ប្រជាជនក្នុងការកសាងជីវភាពរបស់ខ្លួនឡើង។ ទោះបីយ៉ាងណា វិសាលភាពរបស់កម្មវិធីទាំងនេះនៅមានកម្រិតក្នុងការជ្រើសរើសកម្មវិធី ក្រុមអ្នកទទួលផល (ប្រជាជនគ្រប់អាយុធ្វើការងារ ដែលមានកាយសម្បទាគ្រប់គ្រាន់អាចធ្វើការងារបាន) និងប្រភេទជំនួយ។ ហេតុដូចនេះ ជានិច្ចកាលកម្មវិធីទាំងនេះចាំបាច់ត្រូវបំពេញបន្ថែមដោយអន្តរាគមន៍ ដែលកំណត់គោលដៅលើស្ថានភាពនៃក្រុមងាយរងគ្រោះផ្សេងទៀត។

ដើម្បីធានាឲ្យមានកិច្ចគាំពារសង្គមបានទូលំទូលាយក្នុងពេលមានវិបត្តិ **យ.ជ.គ.ស.**កំណត់អាទិភាពសកម្មភាព ដូចខាងក្រោម ៖

- ការលើកកម្ពស់ការសម្របសម្រួលលើយន្តការឆ្លើយតបក្នុងគ្រាមានគ្រោះអាសន្ន និងធានាថា ក្រុមជនងាយរងគ្រោះទាំងអស់ ទទួលបានជំនួយសង្គ្រោះបន្ទាន់គ្រប់គ្រាន់ ដើម្បីបំពេញតម្រូវការមូលដ្ឋាន។
- ការធានាឲ្យមានការផ្តល់ជំនួយទាន់ពេលវេលាក្នុងទម្រង់ជាកញ្ចប់ជំនួយច្បាស់លាស់ រួមមានស្បៀង ទឹកនិងអនាម័យ ការផ្គត់ផ្គង់ថ្នាំពេទ្យ សម្លៀកបំពាក់ ជម្រក ។ល។
- ការកសាងសមត្ថភាពរបស់គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយថ្នាក់ក្រោមជាតិឲ្យបានទាន់ពេលវេលា និងការឆ្លើយតបសមស្របចំពោះគ្រោះអាសន្នដើម្បីកាត់បន្ថយទំហំនៃផលប៉ះពាល់។
- ការបង្កើនវិសាលភាពនិងប្រសិទ្ធភាពរបស់កម្មវិធីមានស្រាប់ ដែលអាចកាត់បន្ថយបញ្ហាអសន្តិសុខស្បៀង ក្នុងពេលមានគ្រោះអាសន្នឬកលិយុគ តាមរយៈការរៀបចំទុកជាមុន និងការចែកចាយស្បៀងដែលមានក្នុងស្តុកឲ្យបានគ្រប់គ្រាន់។ល។
- ការពង្រីកកម្មវិធីដែលមានស្រាប់ ដូចជាសាច់ប្រាក់ពលកម្មនិងស្បៀងពលកម្ម ពិសេសក្នុងដំណាក់កាលក្រោយការជួយសង្គ្រោះបន្ទាន់ នៅពេលដែលមានស្ថានភាពសមស្រប។
- ការធានាថា វិធានការដើម្បីឆ្លើយតបចំពោះគ្រោះអាសន្ននិងវិបត្តិ មានលក្ខណៈជាកុមារមេត្រី និងមិនជំរុញឲ្យមានពលកម្មកុមារ។

គោលដៅនេះបំពេញបន្ថែមដល់គោលដៅដទៃទៀត (ជាពិសេសគោលដៅទី២ និងទី៥)។ លើសពីនេះ កម្មវិធីនិងគម្រោងជាច្រើន ដែលបានលើកឡើងនៅក្នុងគោលដៅដទៃទៀត មានភាពស៊ីចង្វាក់គ្នាយ៉ាងជិតស្និទ្ធជាមួយនឹងប្រភេទឧបករណ៍គាំពារសង្គម ដែលចាំបាច់សម្រាប់ការឆ្លើយតបក្នុងពេលមានគ្រោះមានអាសន្ន និងដែលអាចពង្រីកបានក្នុងពេលមានគ្រោះមហន្តរាយឬវិបត្តិ។

### ៥.៤.២. គោលដៅទី២

**គោលដៅទី២**

ជនក្រីក្រ កុមារ និងមាតាងាយរងគ្រោះ ទទួលបានផលប្រយោជន៍ពីសំណាញ់សុវត្ថិភាពសង្គមដើម្បីកាត់បន្ថយភាពក្រីក្រ និងអសន្តិសុខស្បៀង និងពង្រឹងការអភិវឌ្ឍមូលធនមនុស្ស តាមរយៈការបង្កើនគុណភាពអាហារូបត្ថម្ភ សុខភាពមាតា និងកុមារ ការលើកកម្ពស់ការអប់រំ និងការលុបបំបាត់ពលកម្មកុមារ ជាពិសេសទម្រង់ធ្ងន់ធ្ងរ។

**អន្តរាគមន៍នៃការកាត់បន្ថយភាពក្រីក្រក្នុងវដ្តជីវិត** ទទួលស្គាល់ថា ដំណាក់កាលពិសេសៗដោយឡែកពីគ្នានៃជីវិត (ដូចជាពេលមានផ្ទៃពោះ ពេលឆ្លងទន្លេ វ័យកុមារតូច វ័យជំទង់) គឺជាពេលវេលាដែលមានភាពប្រឈមនឹងគ្រោះថ្នាក់ខ្ពស់ខុសៗគ្នា។ ពេលវេលាទាំងនេះជាដំណាក់កាលក្នុងជីវិតដែលមូលដ្ឋានគ្រឹះសម្រាប់ការអភិវឌ្ឍរាងកាយ អារម្មណ៍ និងបញ្ញាស្មារតីរបស់កុមារកើតមានឡើង។ ចន្លោះប្រហោងសំខាន់ៗ ផ្តោតលើ ៖

- លទ្ធភាពទទួលបាន និងការអនុវត្តការថែទាំមុនពេលសម្រាល ពេលសម្រាល និងក្រោយពេលសម្រាល ដើម្បីទទួលបានសុខភាពជាវិជ្ជមានសម្រាប់មាតា និងកុមារ
- លទ្ធភាពទទួលបានការអភិវឌ្ឍកុមារតូច ជាពិសេសអាហារូបត្ថម្ភកុមារ ដើម្បីធ្វើឲ្យកុមារអាចចុះឈ្មោះចូលរៀន និងមានវត្តមានក្នុងសាលារៀនបឋមសិក្សា
- ការបង្កើនអត្រាបន្តការសិក្សា អត្រាឡើងថ្នាក់ និងឆ្លងកម្រិតសិក្សា ពីការអប់រំកម្រិតបឋមសិក្សាទៅមធ្យមសិក្សាបឋមភូមិ
- ការការពារ និងការដកហូតកុមារពីពលកម្មកុមារ ជាពិសេសទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ។

ក្រុមដែលពាក់ព័ន្ធទៅនឹងគោលដៅនេះ រួមមាន ៖

- ស្ត្រីមានផ្ទៃពោះ ម្តាយទើបសម្រាលកូនរួច
- កុមារតូច (ជាពិសេសកុមារដែលមានអាយុក្រោមពីរឆ្នាំ)
- សិស្សបឋមសិក្សា (ជាពិសេសសិស្សរៀនថ្នាក់ទី៤ ទី៥ និងថ្នាក់ទី៦)
- យុវជន (អាយុចាប់ពី១៥ ដល់២៤ ឆ្នាំ)
- កុមារកំព្រានិងកុមារងាយរងគ្រោះ ឬដែលមានផ្ទុកមេរោគអេដស៍។

ការធ្វើវិនិយោគទៅលើកិច្ចគាំពារសង្គមសម្រាប់ស្ត្រីនិងកុមារ ផ្តល់នូវផលប្រយោជន៍សេដ្ឋកិច្ចយ៉ាងច្រើន។ ការសិក្សាជាច្រើនទៅលើកម្រិតនៃផលចំណេញលើការវិនិយោគក្នុងការអភិវឌ្ឍកុមារតូចបានបង្ហាញឲ្យឃើញថា រាល់ការដាក់វិនិយោគមួយឯកតានៃថវិកា ផលចំណេញនឹងមានចាប់ពី ២ ដល់ ១៧ ឯកតា។ ប្រសិនបើកុមារបានទទួលការអប់រំនៅមត្តេយ្យសិក្សាចំនួនមួយឆ្នាំ ពួកគេនឹងមានកំណើនសមត្ថភាពពី៧% ដល់១២% នៅពេលក្លាយខ្លួនជាមនុស្សពេញវ័យ។ ផ្ទុយទៅវិញ ការបាត់បង់ផ្នែកសេដ្ឋកិច្ចជាច្រើននឹងកើតឡើង ដោយសារកង្វះខាតលើការវិនិយោគក្នុងកិច្ចគាំពារសង្គមសម្រាប់ស្ត្រីនិងកុមារក្រីក្រដែលងាយរងគ្រោះទាំងនេះ។ ក្នុងករណីផ្សេងទៀត ការសិក្សាលើកុមារ អាយុក្រោមប្រាំឆ្នាំដែលពុំបានទទួលការវិវត្តពេញលេញបានបង្ហាញថា ការចំណាយនៃសេដ្ឋកិច្ចចំពោះបញ្ហាសង្គមស្មើនឹងការខាតបង់ចំណូលជាមធ្យមលើសពី ២០% ក្នុងមួយឆ្នាំ។ បន្ថែមលើនេះទៀត ការវិភាគស្តីពី

ប្រសិទ្ធភាពនៃការចំណាយ បានរកឃើញនូវផលប្រយោជន៍សេដ្ឋកិច្ចដ៏ធំធេង ក្នុងការវិនិយោគដើម្បីលុបបំបាត់ពលកម្មកុមារ។

**រូបទី៧. ការផ្សារភ្ជាប់កិច្ចគាំពារសង្គមសម្រាប់កុមារ ៖ វិធីសាស្ត្រវដ្តជីវិត**




ការផ្តល់កិច្ចគាំពារសង្គម ក្នុងលក្ខណៈជាការឧបត្ថម្ភប្រាក់ចំណូល និងសេវាសុខុមាលភាពសង្គមបំពេញបន្ថែម គឺជាមធ្យោបាយមួយដ៏មានប្រសិទ្ធភាពឆ្ពោះទៅកាត់បន្ថយភាពក្រីក្រនិងភាពងាយរងគ្រោះសម្រាប់មាតានិងទារក បានយ៉ាងទូលំទូលាយនិងប្រកបដោយនិរន្តរភាព។ ការទ្រទ្រង់វិស័យសន្តិសុខស្បៀងនិងអាហារូបត្ថម្ភសម្រាប់ស្ត្រីមានផ្ទៃពោះ ស្ត្រីមានកូនតូច និងកុមារមានអាយុក្រោមប្រាំឆ្នាំ ជាវិស័យអាទិភាពរបស់រាជរដ្ឋាភិបាលកម្ពុជា។ អន្តរាគមន៍ដែលមានស្រាប់ក្នុងវិស័យនេះរួមមានកម្មវិធីផ្តល់អាហារនៅសាលារៀន(ទាំងការផ្តល់ស្បៀងអាហារនៅនឹងសាលារៀនផ្ទាល់ ទាំងរបបស្បៀងយកទៅផ្ទះប្រចាំខែ) ការបញ្ចុះថ្លៃស្បៀង ការផ្តល់អាហារបំប៉នបន្ថែមដល់កុមារមានអាយុក្រោមពីរឆ្នាំ ស្ត្រីមានផ្ទៃពោះ ស្ត្រីបំបៅដោះកូន និងការបណ្តុះបណ្តាលពីអាហារូបត្ថម្ភ និងលទ្ធភាពទទួលបានកម្មវិធីអាហារូបត្ថម្ភ។ **យ.ជ.គ.ស.**កំណត់សកម្មភាពអាទិភាពខាងក្រោមដោយផ្អែកលើវិធីសាស្ត្រវដ្តជីវិតឆ្ពោះទៅកាត់បន្ថយភាពក្រីក្រ ជាពិសេសការដោះស្រាយបញ្ហាអសន្តិសុខស្បៀងនិងអាហារូបត្ថម្ភ ៖

- ផ្តល់ **"កញ្ចប់ផលប្រយោជន៍"** សម្រាប់កុមារនិងស្ត្រី ដើម្បីដោះស្រាយភាពងាយរងគ្រោះរបស់ពួកគាត់
- ដោះស្រាយតម្រូវការរបស់កុមារនិងស្ត្រីក្នុងវ័យបន្តពូជដែលក្រីក្រនិងងាយរងគ្រោះ តាមរយៈកម្មវិធី ឧបត្ថម្ភសាច់ប្រាក់ ឬការផ្តល់តាមសក្ខីបណ្ណ
- ពង្រីកកម្មវិធីអាហារូបករណ៍សម្រាប់កុមារនៅមធ្យមសិក្សាបឋមភូមិ ដោយបន្តការផ្តល់កម្មវិធីនេះនៅឆ្នាំសិក្សាចុងក្រោយនៃកម្រិតបឋមសិក្សានិងឆ្នាំទីមួយនៃកម្រិតមធ្យមសិក្សាបឋមភូមិ ដើម្បីកាត់បន្ថយការបោះបង់ការសិក្សា
- ផ្តល់អាហារូបករណ៍នៅបឋមសិក្សា និងអនុវត្តកម្មវិធីសាកល្បងដែលមានស្រាប់ ដើម្បីពង្រឹងការអប់រំ
- ពង្រីកកម្មវិធីដែលមានស្រាប់ ដូចជាការផ្តល់ស្បៀងនៅសាលារៀន កម្មវិធីសុខភាពមាតា និងទារក និងកម្មវិធីអាហារូបត្ថម្ភ
- បង្កើតជាការច្របាច់បញ្ចូលគ្នា និងទំនាក់ទំនងរវាងការផ្តល់ផលប្រយោជន៍ដល់កុមារ និងការផ្តល់សេវាសង្គម រួមមានមូលនិធិសមធម៌សុខភាព ការអប់រំ (ការអភិវឌ្ឍកុមារតូច អាហារូបករណ៍ ការផ្តល់ស្បៀងនៅសាលារៀន) និងសេវាសុខុមាលភាពសង្គម
- ពង្រីកកម្មវិធីអភិវឌ្ឍកុមារតូច
- ប្រយុទ្ធប្រឆាំងនឹងពលកម្មកុមារ តាមរយៈការផ្តល់អាហារូបករណ៍ សេវាផ្សព្វផ្សាយ និងកម្មវិធីសម្រាប់ឱកាសថ្មីដល់យុវជននៅក្រៅសាលារៀន និងគាំទ្រដល់សេវាសុខុមាលភាពសង្គម
- បង្កើនប្រសិទ្ធភាពកម្មវិធីដែលមានស្រាប់ ក្នុងការកាត់បន្ថយអសន្តិសុខស្បៀង តាមរយៈប្រព័ន្ធពិនិត្យតាមដាន និងវាយតម្លៃ និងការសម្របសម្រួល
- ធានាដល់ហិរញ្ញប្បទានប្រកបដោយនិរន្តរភាព និងភាពជាម្ចាស់នៃសំណាញ់សុវត្ថិភាពសង្គមកម្រិតជាតិ ក្នុងការដោះស្រាយអសន្តិសុខស្បៀង
- គាំទ្រដល់ការអភិវឌ្ឍបន្ថែមនៃប្រព័ន្ធដែលបានធ្វើសុខដុមនីយកម្ម ដើម្បីកំណត់តំបន់និងគ្រួសារដែលជួបប្រទះនឹងអសន្តិសុខស្បៀង រួមទាំងព័ត៌មានស្តីពីស្បៀងដែលអាចរកបាន និងអស្ថិរភាពទីផ្សារស្បៀង។

## ៥.៤.៣. គោលដៅទី៣

**គោលដៅទី៣**

ជនក្រីក្រនិងងាយរងគ្រោះដែលពេញវ័យធ្វើការងារ ទទួលបានផលប្រយោជន៍ពីកាលានុវត្តភាពការងារ ដើម្បីធានាឱ្យមានប្រាក់ចំណូលស្បៀង និងឱ្យមានការងារធ្វើ ព្រមទាំងចូលរួមក្នុងការកសាងធនធានរូបវន្ត និងធនធានហេដ្ឋារចនាសម្ព័ន្ធសង្គមដែលមាននិរន្តរភាព។

កម្មវិធីសំណង់សាធារណៈ មានគោលដៅសំខាន់ផ្តោតលើការប្រើប្រាស់កម្លាំងពលកម្ម។ កម្មវិធីនេះប្រើប្រាស់ពលករដែលមិនមានជំនាញនៅតាមមូលដ្ឋាន ដើម្បីកសាងហេដ្ឋារចនាសម្ព័ន្ធនៅក្នុងស្រុក ទោះបីជាមានភាពខុសគ្នាក្នុងកម្រិតបច្ចេកទេស និងក្នុងចំណាយដែលមិនមែនជាប្រាក់ឈ្នួលក៏ដោយ។ កម្មវិធីមួយចំនួនប្រើប្រាស់ **កម្លាំងពលកម្មមនុស្សជាអតិបរមា**។ កម្មវិធីទាំងនេះ ផ្តោតលើការផ្តល់ប្រភពនៃរបចិញ្ចឹមជីវិត បន្ទាប់ពីមានគ្រោះមហន្តរាយធម្មជាតិ និងការផ្តល់ស្បៀងឬសាច់ប្រាក់ក្នុងពេលមានទុក្ខលំបាកធ្ងន់ធ្ងរ។ **យ.ជ.គ.ស.**ចាត់ទុកថាការរៀបចំបង្កើត និងពង្រីកកម្មវិធីសាច់ប្រាក់ពលកម្ម និងកម្មវិធីស្បៀងពលកម្មដែលមានស្រាប់ ជាប្រការចាំបាច់។ ប្រការនេះ ធ្វើឲ្យមានតម្រូវការធនធានបន្ថែមទៀត ដើម្បីធានាឲ្យមាននិរន្តរភាពដល់ធនធានរូបវន្តនិងសង្គមដែលបានកសាងឡើង។ លើសពីនេះ **កម្មវិធីដែលប្រើប្រាស់កម្លាំងពលកម្ម** ដែលមានការចំណាយមិនមែនជាប្រាក់ឈ្នួលខ្ពស់ និងប្រើប្រាស់កម្លាំងពលកម្មមនុស្សក្នុងកម្រិតតិច ជាការផ្តល់បណ្តាញសុវត្ថិភាពដល់ជនក្រីក្រតាមជនបទ ហើយត្រូវអនុវត្តដោយឈរលើមូលដ្ឋានរយៈពេលវែង។ ស្ថិតក្នុងវិស័យអាទិភាពនៃការឆ្លើយតបទៅនឹងភាពខ្វះការងារនិងនិកម្មភាពដែលកើតមានឡើងតាមរដូវកាលពិសេសនៅតំបន់ជនបទ កម្មវិធីសំណង់សាធារណៈនឹងផ្តល់ការងារសម្រាប់ជនក្រីក្រនិងជនងាយរងគ្រោះ ដោយផ្តោតលើ ៖

- **ការធ្វើពិពិធកម្មលើគោលការណ៍មូលដ្ឋានរបស់កម្មវិធីសំណង់សាធារណៈ:** កម្មវិធីនេះនឹងផ្តោតលើការបង្កើតហេដ្ឋារចនាសម្ព័ន្ធជាច្រើនរួមបញ្ចូលគ្នា ក្នុងគោលដៅបង្កើតឲ្យមានការងារធ្វើចាប់ពីហេដ្ឋារចនាសម្ព័ន្ធរូបវន្តដល់ហេដ្ឋារចនាសម្ព័ន្ធសង្គម អាស្រ័យលើអាទិភាពតាមតំបន់។ សាច់ប្រាក់ពលកម្មនិងស្បៀងពលកម្ម ជាប្រភេទកម្មវិធីដែលត្រូវបានប្រើប្រាស់ក្នុងកម្រិតថ្នាក់ភូមិនិងឃុំ ដូចជានៅផ្លូវក្នុងភូមិ ស្រះសម្រាប់ប្រើប្រាស់រួម ការអភិរក្សទឹក ។ល។ កម្មវិធីសំណង់សាធារណៈ នឹងគ្របដណ្តប់លើ ៖
  - ទិដ្ឋភាពជាក់លាក់នៃកម្មវិធីដែលមានស្រាប់ ដែលមានវិធីសាស្ត្របង្កើតឲ្យមានការងារធ្វើជាអតិបរមា អាចនឹងយកមកប្រើប្រាស់ប្រកបដោយប្រសិទ្ធភាព ដូចជាការថែទាំផ្លូវលំនិងការធ្វើប្រព័ន្ធធារាសាស្ត្រខ្នាតតូច។

- កម្មវិធីថ្មីទាំងស្រុង ដូចជាការបង្កើតឬការស្តារហេដ្ឋារចនាសម្ព័ន្ធភូមិ ព្រមទាំងផ្សារភ្ជាប់កម្មវិធីជាតិសំណង់សាធារណៈ ជាមួយកម្មវិធីអាទិភាពដែលស្ថិតក្នុងកម្មវិធីសកម្មភាពជាតិបន្សាំនឹងការប្រែប្រួលអាកាសធាតុ ដើម្បីទប់ស្កាត់ បង្ការ និងការពារគ្រោះមហន្តរាយបណ្តាលមកពីការប្រែប្រួលអាកាសធាតុ។
- ការពង្រីកកម្មវិធីដែលមានស្រាប់ ដូចជាសាច់ប្រាក់ពលកម្មឬស្បៀងពលកម្ម។
- ការកសាងឬការស្តារហេដ្ឋារចនាសម្ព័ន្ធសង្គម (ឲ្យមណ្ឌលសុខភាពនិងអគារសិក្សា) ដែលជាមធ្យោបាយ ដើម្បីឲ្យប្រជាជនអាចទទួលប្រើប្រាស់បាននូវហេដ្ឋារចនាសម្ព័ន្ធទាំងនេះ។
- កម្មវិធីសំណង់សាធារណៈសម្រាប់ការគ្រប់គ្រងព្រៃសហគមន៍ ដែលជាអភិក្រមសំខាន់មួយសម្រាប់អ្នកគ្មានដីឬមានដីតិចតួច ដែលត្រូវពឹងផ្អែកលើជម្រើសជាច្រើនសម្រាប់រស់រាននិងសុខុមាលភាពរបស់ខ្លួន។
- ការបង្កើតការងារក្នុងរូបភាពជាការផ្តល់សេវាកម្មសង្គមកិច្ច ក្នុងលក្ខណៈជាផ្នែកមួយនៃកម្មវិធីសំណង់សាធារណៈ (ការថែទាំជនងាយរងគ្រោះពិសេសក្នុងសហគមន៍ ការធ្វើអនាម័យក្នុងសហគមន៍)។

- **ការពង្រីកកម្មវិធីដែលមានស្រាប់ឲ្យមានវិសាលភាពទូទាំងប្រទេស** ប្រពលភាពនៃកម្មវិធីដែលនឹងត្រូវអនុវត្តនៅក្នុងតំបន់មួយ គឺត្រូវអាស្រ័យលើតម្រូវការហេដ្ឋាចេនាសម្ព័ន្ធ និងកម្រិតនៃភាពក្រីក្រនិងភាពងាយរងគ្រោះនៅក្នុងតំបន់នោះ។ បន្ថែមលើនេះ ការវិភាគពិស្តារនឹងត្រូវធ្វើឡើងទៅលើបម្រែបម្រួលនៃប្រាក់ចំណូលនិងចំណាយរបស់គ្រួសារប្រចាំខែ ដើម្បីវាយតម្លៃលើពេលវេលានៃតម្រូវការការងារ និងកម្រិតប្រាក់ឈ្នួលសមស្រប។
- **ការបង្កើនហិរញ្ញប្បទានសម្រាប់ការថែទាំហេដ្ឋារចនាសម្ព័ន្ធសាធារណៈ:** ការថែទាំហេដ្ឋារចនាសម្ព័ន្ធក្នុងប្រទេសកម្ពុជាជួបការលំបាកដោយកង្វះខាតរ៉ាំរ៉ៃនៃហិរញ្ញប្បទាន។ កង្វះខាតនេះស្តែងឡើងយ៉ាងពិតប្រាកដក្នុងវិស័យគមនាគមន៍ផ្លូវគោក ដែលបណ្តាញផ្លូវជាច្រើនទទួលបានការថែទាំតិចតួច ឬគ្មានប្រសិទ្ធភាព។ ផលប្រយោជន៍សេដ្ឋកិច្ច និងសង្គមរបស់ហេដ្ឋារចនាសម្ព័ន្ធរូបវន្តនេះ នឹងត្រូវបាត់បង់ដោយសារកង្វះខាតក្នុងការថែទាំ។

ការយកចិត្តទុកដាក់ពិសេសនឹងត្រូវធ្វើឡើង ដើម្បីធានាឲ្យមានសមធម៌ក្នុងការបង្កើតការងារជាពិសេសការចាត់ចែងប្រកបដោយសមធម៌ចំពោះស្ត្រី សមភាពក្នុងការទទួលព័ត៌មានពីឱកាសការងារ ការជ្រើសរើសឲ្យទទួលការងារ សមភាពក្នុងការទទួលកម្រៃពីទិន្នផលការងារដូចគ្នា និងការលើកទឹកចិត្តស្ត្រីឲ្យធ្វើជាអ្នកដឹកនាំការដ្ឋាន។ កម្មវិធីសំណង់សាធារណៈនឹងត្រូវកំណត់នូវគោលដៅនិងបង្កើតយន្តការ ដើម្បីដាក់បញ្ចូលនូវក្រុមពិសេសមួយចំនួន ពោលគឺគ្រួសារដែលមានស្ត្រីជាមេគ្រួសារ យុវវ័យ

និងក្រុមដទៃទៀត។ បន្ថែមលើនេះទៀត ផ្នែកមួយនៃកម្មវិធីសំណង់សាធារណៈគឺត្រូវផ្តោតលើការផ្សព្វផ្សាយឲ្យបានស៊ីជម្រៅដល់អ្នកទទួលផលនៃកម្មវិធី នូវបញ្ហាទាក់ទងនឹងសុវត្ថិភាពការងារ និងការបង្ការការពារពីគ្រោះមហន្តរាយនិងគ្រោះអាសន្នដែលអាចកើតមានឡើង។

ក្តីកង្វល់ដ៏ចម្បង គឺការធានាថាកម្មវិធីសំណង់សាធារណៈនឹងមិនប្រើពលកម្មកុមារ ហើយការផ្តល់ការងារ ត្រូវស្ថិតក្នុងស្ថានភាពដែលអាចបំពេញតាមតម្រូវការរបស់ឪពុកម្តាយដែលកំពុងបំពេញការងារនិងកូនៗរបស់ពួកគាត់ (ឧទាហរណ៍ អាហារ ទឹក ទារកដ្ឋាន... នៅទីកន្លែងផ្ទាល់) ដើម្បីការពារកុមារពីការចូលរួមក្នុងការងារ ឬជួយឪពុកម្តាយរបស់ពួកគេ។ ទាំងជម្រើសការងារបណ្តោះអាសន្ន ទាំងការងាររយៈពេលវែង កម្មវិធីសំណង់សាធារណៈអាចជួយឲ្យគ្រួសារជាច្រើនឈប់ពឹងផ្អែកលើការរកប្រាក់ចំណូលរបស់កុមារសម្រាប់ចំណាយក្នុងគ្រួសារ និងផ្ទុយមកវិញលើកទឹកចិត្តពួកគាត់ឲ្យបញ្ជូនកុមារទៅសាលារៀន។

កម្មវិធីសំណង់សាធារណៈ អាចនឹងមានទំហំតូចឬធំយ៉ាងណា គឺអាស្រ័យលើលទ្ធភាពស្រូបយករបស់ស្ថាប័នអនុវត្តនៅគ្រប់កម្រិត ព្រមទាំងទំហំនៃការងារកសាងហេដ្ឋារចនាសម្ព័ន្ធអាចផ្តល់ការងារធ្វើជាអតិបរមា និងហិរញ្ញប្បទានដែលមាន។

ការធានាឲ្យអ្នកចូលបម្រើការងារថ្មី មានជំនាញសមស្របទៅនឹងតម្រូវការរបស់ការងារថ្មី គឺជាបញ្ហាប្រឈមមួយ ដែលទាមទារឲ្យមានកិច្ចខិតខំប្រឹងប្រែងជាច្រើនថែមទៀត ដែលផ្តោតលើការពង្រីកការអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ ការធ្វើឲ្យសម្រេចបាននូវការបង្កើតការងារឲ្យបានច្រើនជាងមុនថែមទៀត និងការធ្វើឲ្យប្រសើរឡើងនូវផលិតភាពនិងពិពិធកម្មក្នុងវិស័យកសិកម្ម។ ប្រការនេះគឺអាស្រ័យទៅនឹងពលកម្មជំនាញនិងមីក្រូឥណទាន ដែលអាចត្រូវបានបង្កើតឲ្យមានឡើងតាមរយៈការអប់រំបណ្តុះបណ្តាល វិជ្ជាជីវៈ បច្ចេកទេស និងការអភិវឌ្ឍមីក្រូហិរញ្ញវត្ថុ។

រាជរដ្ឋាភិបាលកម្ពុជា នឹងបន្តពង្រឹងភាពជាដៃគូជាមួយវិស័យឯកជន និងជាមួយសហគមន៍ជាតិនិងអន្តរជាតិ ដើម្បីបង្កើននិងលើកកម្ពស់គុណភាពសេវាអប់រំ។ ទន្ទឹមនេះដើម្បីកាត់បន្ថយគម្លាតរវាងការផ្គត់ផ្គង់និងតម្រូវការការងារ រាជរដ្ឋាភិបាលកម្ពុជានឹងបន្តអនុវត្តគោលនយោបាយ បណ្តុះបណ្តាលមុខវិជ្ជាជីវៈផ្សារភ្ជាប់នឹងទីផ្សារពលកម្ម ដោយសហការយ៉ាងជិតស្និទ្ធជាមួយតួអង្គពាក់ព័ន្ធ តាមរយៈវិធានការ ៖

- ផ្តល់សេវាសាធារណៈក្នុងការជួយស្វែងរកការងារដល់ជនងាយរងគ្រោះ
- ផ្តល់អាហារូបករណ៍សម្រាប់កម្មវិធីអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ ដើម្បីអភិវឌ្ឍជំនាញបច្ចេកទេសវិជ្ជាជីវៈដល់សិស្សដែលបានបោះបង់ការសិក្សា

- ផ្តល់ការបណ្តុះបណ្តាលជំនាញមូលដ្ឋាន ដល់ប្រជាពលករនៅជនបទ ដើម្បីបង្កើនប្រាក់ចំណូល
- ផ្តល់ការបណ្តុះបណ្តាលវិក្រឹតការដល់ពលករតាមរោងចក្រ ដោយសហការយ៉ាងជិតស្និទ្ធជាមួយនិយោជក
- បន្តជំរុញការអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងមុខវិជ្ជាជីវៈ ដោយពង្រីកសេវានេះឲ្យទៅដល់រាជធានី-ខេត្ត ក្នុងនោះរួមទាំងការបញ្ចូលការបណ្តុះបណ្តាលសហគ្រិនទៅក្នុងកម្មវិធី
- ការរៀបចំបង្កើតទីភ្នាក់ងារជាតិមុខរបរនិងការងារ និងមជ្ឈមណ្ឌលការងារតាមរាជធានី-ខេត្ត សម្រាប់ជាយន្តការសម្រួលដល់ការផ្សព្វផ្សាយព័ត៌មានទីផ្សារការងារ

## ៥.៤.៤. គោលដៅទី៤

**គោលដៅទី៤**

ជនក្រីក្រនិងងាយរងគ្រោះ ទទួលបានដោយមានប្រសិទ្ធភាពនូវការថែរក្សាសុខភាពដែលមានគុណភាព និងដែលអាចទទួលប្រើបាន និងការគាំពារផ្នែកហិរញ្ញវត្ថុពេលមានជំងឺ។

ជម្រើសវិធីសាស្ត្រជាច្រើនចំពោះហិរញ្ញប្បទានផ្នែកសុខភាពសម្រាប់ជនក្រីក្រ បានបង្កើតឡើងតាំងពីឆ្នាំ២០០០។ អភិក្រមដែលទទួលបានជោគជ័យបំផុត បានបញ្ចូលទៅក្នុង **ផែនការមេស្តីពីកិច្ចគាំពារសុខភាពសង្គម** ដែលផ្តល់មូលដ្ឋានសម្រាប់ប្រព័ន្ធគាំពារសុខភាពសង្គមដែលមានលក្ខណៈទូលំទូលាយ។ ផែនការនេះមានគោលដៅធានាឲ្យមានការគ្របដណ្តប់ជាសកល និងប្រកបដោយសមធម៌ ទប់ទល់នឹងវិបត្តិសុខភាពដែលកើតចេញមកពីវិបត្តិសង្គមនិងការខាតបង់ផ្នែកសេដ្ឋកិច្ច ដើម្បីការពារដល់ជនក្រីក្រ និងដើម្បីទូទាត់សងចំពោះចំណុចខ្វះខាតនៃប្រព័ន្ធលើកលែងថ្លៃ។ ផែនការមេប្រមើលមើលដល់ការសម្រេចបាននូវលទ្ធផលដែលប្រកបដោយប្រសិទ្ធភាពនិងសមធម៌ នៃការថែរក្សាសុខភាពប្រកបដោយគុណភាព និងដែលអាចទទួលប្រើបាន សម្រាប់ប្រជាជនកម្ពុជាគ្រប់រូប ត្រឹមឆ្នាំ២០១៥។

ប្រព័ន្ធគាំពារសុខភាពសង្គម គឺជាការរួមបញ្ចូលគ្នានៃយន្តការហិរញ្ញប្បទាន ដែលផ្តោតលើលទ្ធភាពទទួលបានជាសកលនិងប្រកបដោយសមធម៌ នូវការគាំពារហិរញ្ញវត្ថុក្នុងករណីមានជំងឺ និងការផ្តល់សេវាសុខភាពដោយសក្តិសិទ្ធិនិងប្រសិទ្ធភាព។ ប្រព័ន្ធនេះមានគោលដៅរៀបចំបង្កើតយន្តការដែលមាននិរន្តរភាពមួយសម្រាប់កិច្ចគាំពារសុខភាពសង្គម ដែលនឹងធានាឲ្យប្រជាជនទាំងអស់ទទួលបានការគាំពារសុខភាពសង្គម ពិសេសដោយផ្តល់អាទិភាពសម្រាប់ជនក្រីក្រ រួមមានកញ្ចប់ផលប្រយោជន៍ថៃទាំ

សុខភាពមូលដ្ឋានដែលមានតម្លៃអាចទទួលយកបាននិងសេវាថែទាំសុខភាពដែលមានគុណភាព និង ផ្តោតលើលទ្ធភាពទទួលបានសេវារបស់អតិថិជន។ គម្រោងគាំពារសុខភាពសង្គមដែលមានស្រាប់ជា ច្រើនគ្របដណ្តប់លើ ៖

- ការមិនយកថ្លៃសេវាពីអ្នកប្រើប្រាស់ ដូចជាការលើកលែងមិនយកថ្លៃសេវា។
- មូលនិធិសមធម៌សុខភាព ប្រើប្រាស់ក្នុងពេលដែលថ្លៃសេវារបស់អ្នកប្រើប្រាស់មិនត្រូវ បានលើកលែង។
- ការធានារ៉ាប់រងសុខភាពសហគមន៍ ពោលគឺគម្រោងចំណាយបង់ទុកមុនជាលក្ខណៈឯក ជន មិនយកប្រាក់ចំណេញ និងដោយស្ម័គ្រចិត្ត ដែលផ្តោតលើប្រជាជនគោលដៅ ដែល មានលទ្ធភាពបង់បុព្វលាភ ដើម្បីធានារ៉ាប់រងសុខភាពនៅសហគមន៍។
- គម្រោងធានារ៉ាប់រងសុខភាពសង្គមក្នុងវិស័យផ្លូវការឯកជននិងសាធារណៈមានលក្ខណៈ ជាកាតព្វកិច្ច រួមជាមួយនឹងបុព្វលាភដែលបានចូលរួមរវាងនិយោជកនិងនិយោជិត។

មូលនិធិសមធម៌សុខភាព ដែលជាមធ្យោបាយហិរញ្ញប្បទានសម្រាប់ជនក្រីក្រដោយការចេញ ថ្លៃចំណាយ លើសេវាសុខភាពនៅមណ្ឌលសុខភាពសាធារណៈ ត្រូវបានពង្រីកចេញពីគម្រោងសាក ល្បងដ៏ជោគជ័យ ដើម្បីឲ្យក្លាយទៅជាយន្តការដ៏សំខាន់ក្នុងការផ្តល់សេវាគាំទ្រដល់ជនក្រីក្រ របស់ ក្រសួងសុខាភិបាល។ យន្តការទាំងនេះ ជួយដល់គ្រួសារជាច្រើនឲ្យជៀសផុតពីការចំណាយលើសុខ ភាពដែលប៉ះពាល់ជាខ្លាំងដល់ទ្រព្យសម្បត្តិគ្រួសារ។ យន្តការទាំងនេះជាយុទ្ធសាស្ត្រកាត់បន្ថយភាពក្រី ក្រ និងគាំទ្រដល់ការសម្រេចឲ្យបាននៃគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា។ ក្នុងឆ្នាំ២០០៩ គម្រោងមូលនិធិសមធម៌បានដំណើរការក្នុងស្រុកប្រតិបត្តិចំនួន៥២ នៅក្នុងប្រទេសកម្ពុជា ដែលគ្រប ដណ្តប់លើប្រជាជនគោលដៅរបស់មូលនិធិប្រមាណ៧៣%[១៦]។ ក្រសួងសុខាភិបាលមានគោលដៅ សម្រេចឲ្យបាននូវការគ្របដណ្តប់ទូទាំងប្រទេសត្រឹមឆ្នាំ ២០១២។

ទោះបីជាមូលនិធិសមធម៌សុខភាពទទួលបានជោគជ័យយ៉ាងធំធេងក៏ដោយ ក៏បញ្ហាប្រឈម ផ្នែកគោលនយោបាយនិងការអនុវត្តជាច្រើន ចាំបាច់ត្រូវដោះស្រាយដើម្បីផ្តល់លទ្ធភាពដល់ការពង្រីក កម្មវិធីនេះនៅទូទាំងប្រទេស ដែលបញ្ហាប្រឈមទាំងនេះរួមមានការកាត់បន្ថយភាពខុសគ្នារវាងប្រភេទ គម្រោងដែលបានអនុវត្ត ការកាត់បន្ថយភាពខុសគ្នាក្នុងដំណើរការនិងនីតិវិធី និងការធានាឲ្យមាន សមធម៌ក្នុងការគ្របដណ្តប់។

[១៦] របាយការណ៍ហិរញ្ញប្បទានសុខភាពរបស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៩។

ដើម្បីសម្រេចបានការគ្របដណ្តប់ឲ្យកាន់តែទូលំទូលាយ និងប្រកបដោយសមធម៌សម្រាប់ជនក្រីក្រតាមរយៈកិច្ចគាំពារសុខភាពសង្គម **យ.ជ.គ.ស.** កំណត់សកម្មភាពអាទិភាពដូចខាងក្រោម ៖

- ការពង្រីកប្រភេទគម្រោងមូលនិធិសមធម៌សុខភាពដែលទទួលជោគជ័យ។
- ការពង្រឹងគម្រោងមូលនិធិសមធម៌សុខភាព ដើម្បីជៀសវាងនូវភាពខុសគ្នាដែលបង្កឲ្យមានវិសមភាព នៃលទ្ធភាពទទួលបានការថែទាំសុខភាពចាំបាច់។
- ការពង្រឹងកញ្ចប់ផលប្រយោជន៍ផ្នែកហិរញ្ញប្បទាន រវាងគម្រោងមូលនិធិសមធម៌សុខភាពផ្សេងៗ រួមទាំងការចំណាយលើការធ្វើដំណើរ ស្បៀងអាហារ និងចំណាយផ្សេងៗទៀត។
- ការធ្វើសុខដុមនីយកម្ម ទៅលើអភិក្រមនៃការកំណត់អ្នកទទួលផលរវាងគម្រោងមូលនិធិសមធម៌សុខភាពផ្សេងៗ និងការបង្កើតទំនាក់ទំនងជាមួយនឹងទិន្នន័យមូលដ្ឋាននៃអ្នកទទួលផលក្នុងគម្រោងដទៃទៀត។

### ៥.៤.៥. គោលដៅទី៥

**គោលដៅទី៥**

ក្រុមជនងាយរងគ្រោះពិសេស រួមមានក្មេងកំព្រា ចាស់ជរា ស្ត្រីជាមេគ្រួសារ ជនពិការ ជនផ្ទុកមេរោគអេដស៍ ឬអ្នកជំងឺរបេង ។ល។ ទទួលបានការគាំទ្រជាប្រាក់ចំណូល សម្ភារៈ និងចិត្តសាស្ត្រសង្គម ព្រមទាំងការថែទាំសង្គមគ្រប់គ្រាន់។

ការលើកឡើងពីសិទ្ធិរបស់ក្រុមងាយរងគ្រោះពិសេស ទាមទារឲ្យបង្កើតប្រព័ន្ធឆ្លើយតប និងការគាំពារសុខុមាលភាពសង្គម ដែលរារាំងដល់ភាពងាយរងគ្រោះនិងហានិភ័យមិនឲ្យកើតឡើង ព្រមទាំងការពារមនុស្សពីភាពងាយរងគ្រោះនិងហានិភ័យដោយផ្អែកលើនីតិរដ្ឋ អភិបាលកិច្ចល្អ និងពង្រឹងការអនុវត្តប្រកបដោយប្រសិទ្ធភាពនូវបទប្បញ្ញត្តិពាក់ព័ន្ធ។ ការទទួលបានសេវាសង្គមដូចជាការថែទាំសុខភាព ការអប់រំ ទឹកនិងអនាម័យ ព្រមទាំងសេវាសុខុមាលភាពសង្គមបំពេញបន្ថែម គឺជាប្រការដ៏មានសារៈសំខាន់សម្រាប់ពួកគាត់ ដើម្បីផ្តល់លទ្ធភាពក្នុងការទទួលបានសុខុមាលភាពក្នុងកម្រិតមួយគ្រប់គ្រាន់។

ខណៈពេលដែលក្រុមប្រជាជនទាំងនេះរងគ្រោះពីស្ថានភាពរ៉ាំរ៉ៃ (ភាពក្រីក្រ ជំងឺ ពិការភាព ។ល។) ការប្រឈមមុខនឹងហានិភ័យនឹងកើនឡើង ដោយសារគ្រោះមហន្តរាយធម្មជាតិ ការប្រែប្រួលអាកាសធាតុ ។ល។ ដូច្នេះទំនាក់ទំនងជាលក្ខណៈអន្តរស្ថាប័ន ពិសេសចំពោះស្ថាប័នដែលផ្តល់សេវា និងការគ្រប់គ្រងបញ្ហាទៅតាមតំបន់ ក្នុងការដោះស្រាយបញ្ហារបស់ក្រុមជនងាយរងគ្រោះ ជាប្រការចាំបាច់ដែលត្រូវរៀបចំឡើង ដោយសារក្រុមជនងាយរងគ្រោះពិសេសទាំងនេះ ពុំត្រឹមតែរងការលំបាក

ពីភាពងាយរងគ្រោះពិសេសដែលកើតមានចំពោះខ្លួនប៉ុណ្ណោះទេ តែថែមទាំងភាពងាយរងគ្រោះទូទៅដែលជនក្រីក្រទាំងឡាយជួបប្រទះ។ អភិក្រមបែបនេះ នឹងធានាឲ្យមានការផ្លាស់ប្តូរពីដំណោះស្រាយដែលផ្អែកលើស្ថានភាព ឲ្យក្លាយជាអភិក្រមជាលក្ខណៈអន្តរវិស័យដែលកាន់តែមានភាពទូលំទូលាយតាមរយៈការផ្តល់ការយកចិត្តទុកដាក់ទៅលើស្ថានភាពងាយរងគ្រោះជាច្រើនប្រភេទ ដែលជះឥទ្ធិពលមកលើមនុស្សតែម្នាក់ក្នុងពេលតែមួយ។ ការធ្វើបែបនេះ អាចធ្វើឲ្យមានការជ្រើសរើសវិធីសាស្ត្រដ៏សមរម្យសម្រាប់ការផ្តល់សេវា។

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា គឺជាក្រសួងពាក់ព័ន្ធដ៏សំខាន់ ដែលបានចូលរួមក្នុងការកាត់បន្ថយភាពងាយរងគ្រោះដែលជនក្រីក្រនិងជនងាយរងគ្រោះកំពុងជួបប្រទះ ដោយជួយជនក្រីក្រជួបការលំបាកបំផុត និងផ្តល់ការគាំទ្រចិត្តសាស្ត្រ សង្គមនិងសម្ភារៈ។ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ជួយជាវិភាគទានដ៏សំខាន់មួយចំពោះការពង្រឹងដល់ប្រព័ន្ធគាំពារសង្គមរបស់ប្រទេសកម្ពុជា ដែលមានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយប្រព័ន្ធយុត្តិធម៌។ ការទទួលបានប្រកបដោយប្រសិទ្ធភាពនិងសមធម៌ និងការផ្តល់សេវាសុខុមាលភាពសង្គមត្រូវការទាមទារឲ្យមានការពង្រឹងសមត្ថភាពស្ថាប័ន ភាពជាដៃគូនិងយន្តការហិរញ្ញប្បទាន។ ភាពសម្បូរបែបនៃធនធាន និងសមត្ថភាពមនុស្សនៅក្នុងក្រុមបុគ្គលិកសង្គមកិច្ចដែលមានតុល្យភាពយេនឌ័រ គឺជាស្នូលកណ្តាលនៃការផ្តល់សេវាសុខុមាលភាពសង្គម។

ដើម្បីអាចសម្រេចបាននូវការពង្រីកវិសាលភាពនៃសេវាសុខុមាលភាពសង្គម សម្រាប់ក្រុមជនងាយរងគ្រោះពិសេសឲ្យបានកាន់តែទូលំទូលាយ និងប្រកបដោយសមធម៌ **យ.ជ.គ.ស.**កំណត់សកម្មភាពអាទិភាពខាងក្រោមក្នុងលក្ខណៈជាសេវាសុខុមាលភាពសង្គម ៖

- ពង្រឹងសមត្ថភាពរដ្ឋបាលថ្នាក់មូលដ្ឋាន ដើម្បីកសាងផែនការ និងថវិកាសម្រាប់វិធានការគាំពារសង្គម រួមទាំងសុខុមាលភាពសង្គម។
- ពង្រឹងលទ្ធភាពទទួលបាននិងគុណភាពនៃសេវាសុខុមាលភាពសង្គម សម្រាប់គ្រួសារក្រីក្រនិងងាយរងគ្រោះ រួមទាំងសេវាដែលគាំទ្រដល់គ្រួសារ និងជួយរក្សាគ្រួសារទាំងនោះឲ្យរស់នៅជួបជុំគ្នា។
- ពង្រឹងយន្តការដែលជួយដល់រដ្ឋបាលមូលដ្ឋាន ធ្វើការកំណត់គ្រួសារងាយរងគ្រោះ និងផ្តល់ឬបញ្ជូនគ្រួសារទាំងនោះទៅរកសេវាសមស្រប។
- បង្កើតប្រព័ន្ធសុខុមាលភាពសង្គម រួមទាំងសមត្ថភាពរចនាសម្ព័ន្ធ យន្តការ និងសេវានានាដើម្បីផ្តល់ការថៃទាំឲ្យបានគ្រប់គ្រាន់ ព្រមទាំងកិច្ចខិតខំប្រឹងប្រែងផ្លាស់ប្តូរអាកប្បកិរិយា និងទម្លាប់អនុវត្តប្រកបដោយគ្រោះថ្នាក់នៅក្នុងសង្គម។

- ពង្រឹងការផ្តល់កញ្ចប់ថែទាំទូលំទូលាយ សម្រាប់ស្ត្រីនិងកុមារងាយរងគ្រោះ (រួមទាំងគ្រួសារក្រីក្រដែលមានស្ត្រីជាមេគ្រួសារ កុមារកំព្រា កុមារអនាថា កុមារពិការ ស្ត្រី និងកុមារផ្ទុកមេរោគអេដស៍។ល។)
- លើកកម្ពស់គុណភាពសេវានិងគ្រឿងបរិក្ខារស្តារនីតិសម្បទាយុវជន។
- ពង្រឹងសេវា និងគុណភាពគ្រឿងបរិក្ខារសុខុមាលភាពនិងស្តារលទ្ធភាពពលកម្មសម្រាប់ជនពិការ។
- ពង្រឹងនិងពង្រីកសេវាសុខុមាលភាពសង្គម សម្រាប់មនុស្សចាស់ជរានិងអតីតយុទ្ធជន។
- ពង្រឹងការថែទាំកុមារតាមរយៈឪពុកម្តាយចិញ្ចឹម និងការអនុវត្តបទដ្ឋានអប្បបរមានៃការថែទាំកុមារនៅតាមមជ្ឈមណ្ឌល។
- ពង្រឹងសេវាពីតំបន់មួយទៅតំបន់មួយ និងការធ្វើផែនទីលម្អិតពីភាពងាយរងគ្រោះ។
- ពង្រឹងការអនុម័តច្បាប់ និងការគ្រប់គ្រងជំនួយសុខុមាលភាពសង្គម។

**យ.ជ.គ.ស.**កំណត់សកម្មភាពអាទិភាពខាងក្រោម នៅក្នុងក្របខណ្ឌនៃការឧបត្ថម្ភសង្គម (ជាសាច់ប្រាក់ ឬ សម្ភារៈ) ៖

- ប្រាក់សោធននិវត្តន៍សង្គមសម្រាប់មនុស្សចាស់ជរាក្រីក្រ និងងាយរងគ្រោះ។
- ការឧបត្ថម្ភសង្គមសម្រាប់ជនពិការក្រីក្រនិងងាយរងគ្រោះ។
- ការឧបត្ថម្ភសង្គមសម្រាប់គ្រួសារងាយរងគ្រោះ ជាពិសេស អ្នកថែទាំកុមារកំព្រា គ្រួសាររងគ្រោះដោយអំពើហិង្សា ការប្រើប្រាស់គ្រឿងញៀន ឬជំងឺរ៉ាំរ៉ៃ គ្រួសារមានស្ត្រីជាមេគ្រួសារនិងគ្រួសារផ្ទុកមេរោគអេដស៍ឬអ្នកជំងឺរបេង ហើយដែលការឧបត្ថម្ភសង្គមសម្រាប់គ្រួសារនិងមនុស្សទាំងនេះ នឹងត្រូវបង្កើតឡើងដើម្បីគាំទ្រសមត្ថភាពគ្រួសារក្នុងការបន្តថែទាំកូនៗរបស់ពួកខ្លួន។

# ជំពូកទី៦

# ការសម្របសម្រួល លើការអនុវត្ត ការពិនិត្យតាមដាន និងវាយតម្លៃ យ.ជ.គ.ស.

# ជំពូកទី៦
# ការសម្របសម្រួលលើការអនុវត្ត ការពិនិត្យ តាមដាន និងវាយតម្លៃយ.ជ.គ.ស.

**ក.ក.ជ.**បានទទួលអាណត្តិការងារ ជាគណៈបញ្ជាការឯកភាពនៃរាជរដ្ឋាភិបាល ក្នុងការសម្របសម្រួលលើសកម្មភាពនានាដែលពាក់ព័ន្ធនឹងការអភិវឌ្ឍវិស័យកសិកម្ម និងជនបទ។ នៅឆ្នាំ ២០០៩ អាណត្តិរបស់ ក.ក.ជ. ត្រូវបានពង្រីក ដើម្បីសម្របសម្រួលដល់ការរៀបចំបង្កើត ការអនុវត្ត ការពិនិត្យតាមដាន និងការវាយតម្លៃ នៃ**យ.ជ.គ.ស.** ដើម្បីឲ្យមានលទ្ធភាពទទួលប្រើបាន និងប្រសិទ្ធភាពខ្ពស់។ ដូចដែលមានចែងនៅក្នុងឯកសារផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ បច្ចុប្បន្នកម្មឆ្នាំ ២០០៩-២០១៣ ក.ក.ជ. បានទទួលអាណត្តិការងារក្នុងការធានារៀបចំឲ្យមានយន្តការសម្របសម្រួលអន្តរក្រសួងប្រកបដោយប្រសិទ្ធភាព រវាងក្រសួងស្ថាប័នពាក់ព័ន្ធ ដែលមានតួនាទីផ្តល់កម្មវិធីសំណាញ់សុវត្ថិភាពសង្គមដល់ប្រជាជនក្រីក្រនិងងាយរងគ្រោះ។

ការគាំពារសង្គមជាការងារអន្តរវិស័យ ហើយទាមទារឲ្យមានការសម្របសម្រួល និងកិច្ចសហប្រតិបត្តិការប្រកបដោយប្រសិទ្ធភាពរវាងក្រសួងជំនាញនិងស្ថាប័នពាក់ព័ន្ធជាច្រើន ក៏ដូចជាការចូលរួមកិច្ចពិភាក្សាពីសំណាក់ដៃគូអភិវឌ្ឍនិងសង្គមស៊ីវិលជាច្រើនទៀត។ កម្មវិធីភាគច្រើនក្នុង **យ.ជ.គ.ស.** គឺជាការងារអន្តរវិស័យ ហើយកិច្ចសហប្រតិបត្តិការរវាងក្រសួងនានាជាកត្តាចាំបាច់ ដើម្បីជៀសវាងការជាន់ភារកិច្ចគ្នាតាមវិស័យនិងតាមតំបន់ភូមិសាស្ត្រ ដើម្បីសម្របសម្រួលនីតិវិធីអនុវត្ត និងសម្របសម្រួលការប្រើប្រាស់មូលនិធិដែលទទួលបានពីថវិកាជាតិ និងបានពីដៃគូអភិវឌ្ឍប្រកបដោយប្រសិទ្ធភាព និងភាពសក្តិសិទ្ធិ។

## ៦.១. ការសម្របសម្រួលលើការអនុវត្តយុទ្ធសាស្ត្រជាតិគាំពារសង្គម

ការអនុវត្តសកម្មភាពគាំពារសង្គម គឺជាតួនាទីរបស់ក្រសួងពាក់ព័ន្ធនិងស្ថាប័នរដ្ឋបាលថ្នាក់ក្រោមជាតិ។ **យ.ជ.គ.ស.** ផ្តល់គុណតម្លៃទៅដល់សកម្មភាពនេះ តាមរយៈការផ្តល់នូវក្របខណ្ឌការងារដើម្បីគាំទ្រដល់ក្រសួងនិងស្ថាប័នរដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងការផ្តល់អន្តរាគមន៍គាំពារសង្គមប្រកបដោយនិរន្តរភាព ប្រសិទ្ធភាព និងភាពសក្តិសិទ្ធិ។ កត្តាចាំបាច់ដើម្បីសម្រេចបាននូវអន្តរាគមន៍បែបនេះ គឺការរៀបចំស្ថាប័ននិងការសម្របសម្រួលដែលរួមមាន ការត្រួតពិនិត្យគោលនយោបាយ ការពិនិត្យតាមដាននិងវាយតម្លៃ ការគ្រប់គ្រងចំណេះដឹងនិងគ្រប់គ្រងព័ត៌មាន និងការកសាងសមត្ថភាព។

ការសម្របសម្រួល គឺជាការពិនិត្យវាយតម្លៃយ៉ាងទៀតទាត់ និងជាការលើកកម្ពស់កិច្ចខិតខំប្រឹងប្រែងក្នុងការធ្វើសុខដុមនីយកម្មលើកម្មវិធី និងលើអន្តរាគមន៍។ ការសម្របសម្រួលដល់សកម្មភាពអនុវត្តអន្តរាគមន៍គាំពារសង្គម ធ្វើឡើងដើម្បី ៖

- ជៀសវាងការផ្តល់កិច្ចគាំពារសង្គមជាន់គ្នាក្នុងទីតាំងភូមិសាស្ត្រតែមួយ ឬចន្លោះប្រហោងក្នុងការផ្តល់កិច្ចគាំពារសង្គម
- ជៀសវាងការកំណត់គោលដៅច្រើនហួស ឬចន្លោះប្រហោងក្នុងការជ្រើសរើសអ្នកទទួលផល
- ធ្វើសុខដុមនីយកម្មនីតិវិធីអនុវត្ត
- ពង្រឹងសមត្ថភាពរបស់ក្រសួង និងស្ថាប័នអនុវត្តអន្តរាគមន៍គាំពារសង្គម
- គាំទ្រដល់រចនាសម្ព័ន្ធវិមជ្ឈការនៅថ្នាក់ក្រោមជាតិ ដើម្បីចូលរួមក្នុងការអនុវត្តកិច្ចគាំពារសង្គម
- ពង្រឹងការត្រួតពិនិត្យ និងវាយតម្លៃលើស្ថានភាពនៃភាពងាយរងគ្រោះ
- ពង្រឹងការពិនិត្យតាមដាន និងការវាយតម្លៃអន្តរាគមន៍កិច្ចគាំពារសង្គម
- ពង្រឹងការគ្រប់គ្រងព័ត៌មាន និងចំណេះដឹងសម្រាប់កិច្ចគាំពារសង្គម
- ពង្រឹងការចូលរួមរបស់អ្នកទទួលផល (ក្នុងយន្តការរៀបចំ វាយតម្លៃ និងផ្តល់យោបល់ត្រឡប់)
- សម្របសម្រួលការប្រើប្រាស់មូលនិធិដែលមាន។

**សកម្មភាពទី១**

បង្កើតរចនាសម្ព័ន្ធនិងយន្តការសមស្របមួយ ដើម្បីសម្របសម្រួលដល់ការបង្កើត និងការអនុវត្ត **យជគស** ដែលធានាឱ្យមានការត្រួតពិនិត្យគោលនយោបាយ ការត្រួតពិនិត្យនិងវាយតម្លៃ ការគ្រប់គ្រងចំណេះដឹងនិង ព័ត៌មាន និងការកសាងសមត្ថភាព។

តួនាទីនិងមុខងារ ក៏ដូចជាសមាសភាព និងវិធីសាស្ត្រប្រតិបត្តិ នៅក្នុងការសម្របសម្រួល នឹងត្រូវរៀបចំលម្អិតបន្ថែមទៀត ដោយមានការពិភាក្សាជាមួយភាគីពាក់ព័ន្ធ។ **ក.ក.ផ.** នឹងរៀបចំបង្កើតអង្គភាពសម្របសម្រួល ព្រមទាំងមានលេខាធិការដ្ឋានមួយ ដើម្បីអនុវត្តការងារនេះ។

ការរៀបចំបង្កើតក្របខណ្ឌស្ថាប័នប្រកបដោយប្រសិទ្ធភាពមួយ សម្រាប់ការសម្របសម្រួល គឺជាការងារអាទិភាពមួយ ដែលនឹងត្រូវធ្វើឡើងក្នុងឆ្នាំដំបូងនៃការអនុវត្តរបស់ **យ.ជ.គ.ស.**។

### ៦.១.១. ការត្រួតពិនិត្យគោលនយោបាយ

ការអនុវត្តកម្មវិធីគាំពារសង្គម គឺជាតួនាទីរបស់ក្រសួងពាក់ព័ន្ធនានានិងរបស់ស្ថាប័នរដ្ឋបាលមូលដ្ឋាន ដោយផ្អែកលើគោលការណ៍ណែនាំរួមមួយ។ រាជរដ្ឋាភិបាលកម្ពុជានឹងបង្កើតយន្តការ និង រចនាសម្ព័ន្ធសម្របសម្រួលសមស្រប រវាងក្រសួងស្ថាប័នពាក់ព័ន្ធសំខាន់ៗ ដើម្បីធានាឲ្យការសម្របសម្រួល និងការពិនិត្យតាមដានរបស់ **យ.ជ.គ.ស.** នេះមានប្រសិទ្ធភាព។

ការសម្របសម្រួលលើការគាំពារសង្គមនៅប្រទេសកម្ពុជា ក៏ត្រូវទាមទារឲ្យមានទំនាក់ទំនងប្រកបដោយប្រសិទ្ធភាព រវាងស្ថាប័នរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍ តាមរយៈយន្តការក្រុមការងារបច្ចេកទេស[១៧]។ លើសពីនេះ ដើម្បីឲ្យការអនុវត្តប្រព្រឹត្តទៅបានប្រកបដោយជោគជ័យ ប្រការចាំបាច់បំផុតគឺការចូលរួមពីរចនាសម្ព័ន្ធរដ្ឋបាលថ្នាក់ក្រោមជាតិ (ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និង ឃុំ សង្កាត់)។ រាជរដ្ឋាភិបាលកម្ពុជា ក៏នឹងធានាឲ្យមានការសម្របសម្រួលសកម្មភាពគាំពារសង្គមប្រកបដោយប្រសិទ្ធភាព រវាងមន្ទីររបស់ក្រសួងនានា និងសង្គមស៊ីវិលដែលកំពុងអនុវត្តការងារនៅថ្នាក់ខេត្ត ក្រុង និងស្រុក។ ក្រុមប្រឹក្សាឃុំ សង្កាត់ (រួមមានគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារ) នឹងត្រួតពិនិត្យការកំណត់គោលដៅ និងការអនុវត្តសកម្មភាពគាំពារសង្គមនៅថ្នាក់មូលដ្ឋាន។

### ៦.១.២. ការពិនិត្យតាមដាននិងវាយតម្លៃ

**ការពិនិត្យតាមដាននិងវាយតម្លៃដោយផ្អែកលើលទ្ធផល** ទៅលើកម្មវិធីនីមួយៗដាច់ដោយឡែកពីគ្នា និងទៅលើយុទ្ធសាស្ត្រទាំងមូល គឺជាតម្រូវការចាំបាច់មួយសម្រាប់ប្រសិទ្ធភាពនៃការគាំពារសង្គមនៅកម្ពុជា និងការបន្តរៀបចំនិងកែលម្អ **យ.ជ.គ.ស.** បន្ថែមទៀត។ **យ.ជ.គ.ស.** នឹងត្រូវមានភាពទន់ភ្លន់សម្រាប់ការកែតម្រូវទៅតាមបរិយាកាសដែលកំពុងប្រែប្រួល និងប្រភពនៃភាពងាយរងគ្រោះ ហើយ យុទ្ធសាស្ត្រនេះក៏ត្រូវពិចារណាជាលក្ខណៈប្រព័ន្ធ ទៅលើមេរៀនជាបទពិសោធក្នុងអំឡុងពេលកំពុងអនុវត្ត។

ការពិនិត្យតាមដានលើអន្តរាគមន៍ និងលើកម្មវិធីជាក់លាក់មួយចំនួន នឹងត្រូវធ្វើឡើងដោយក្រសួងស្ថាប័នជំនាញដែលកំពុងអនុវត្តសកម្មភាពការងារ។ ប៉ុន្តែ **ក.ក.ជ.** ក្នុងនាមជាស្ថាប័នសម្របសម្រួលលើ **យ.ជ.គ.ស.** និងដោយមានកិច្ចសហប្រតិបត្តិការយ៉ាងស្អិតរមួតជាមួយនឹងស្ថាប័នសំខាន់ៗផ្សេងទៀត នឹងត្រូវទទួលខុសត្រូវក្នុងការសម្របសម្រួលការពិនិត្យតាមដាននិងវាយតម្លៃ ព្រមទាំងផ្តល់

[១៧] បច្ចុប្បន្ននេះ ក.ក.ជ ដឹកនាំជាប្រចាំនូវកិច្ចប្រជុំរវាងស្ថាប័នរដ្ឋាភិបាល ដៃគូអភិវឌ្ឍ និងសង្គមស៊ីវិលមួយចំនួន តាមរយៈយន្តការក្រុម**ការងារបណ្តោះអាសន្នស្តីពីបណ្តាញសុវត្ថិភាពសង្គម** ដែលជាយន្តការបើកទូលាយមួយ ដើម្បីធានាដល់ការស្ម័គ្រចិត្តនិងការចូលរួមពីគ្រប់ស្ថាប័នពាក់ព័ន្ធ។

អនុសាសន៍សម្រាប់កិច្ចគាំពារសង្គមទាំងមូល និងដើម្បីរៀបចំ **ការវាយតម្លៃ យ.ជ.គ.ស. នៅពាក់កណ្តាលអាណត្តិដោយឯករាជ្យ** មួយ (ក្នុងឆ្នាំ២០១៣) ដើម្បីផ្សព្វផ្សាយនូវព័ត៌មានស្តីពីការសម្របសម្រួលរួម និងបន្តការរៀបចំ និងអភិវឌ្ឍយុទ្ធសាស្ត្រ។ ដើម្បីអនុវត្តសកម្មភាពនេះ រាជរដ្ឋាភិបាលនឹងបន្តកសាងសមត្ថភាពបន្ថែមទៀតលើ **ការពិនិត្យតាមដានកិច្ចគាំពារសង្គមដោយផ្អែកលើលទ្ធផល** សម្រាប់ **ក.ក.ជ.**។

**សកម្មភាពទី២**

រៀបចំបង្កើតក្របខណ្ឌការងារត្រួតពិនិត្យនិងវាយតម្លៃសម្រាប់ **យ.ជ.គ.ស.** ដើម្បីធានាឱ្យមានការអនុវត្តប្រកបដោយប្រសិទ្ធភាព ភាពសក្តិសិទ្ធិក្នុងការចំណាយនិងតម្លាភាព និងផ្តល់មតិអនុសាសន៍ដោយផ្អែកលើភស្តុតាងសម្រាប់ បន្តការរៀបចំអភិវឌ្ឍកម្មវិធី និងអន្តរាគមន៍នានារបស់ **យ.ជ.គ.ស.** ទៀត។

ក្របខណ្ឌការងារនេះនឹងផ្តោតលើលទ្ធផលនិងសូចនាករ ដែលទាក់ទងនឹងការអនុវត្ត និងការសម្របសម្រួលយុទ្ធសាស្ត្រ ហើយនឹងពង្រីកសមាសភាគជាច្រើនឲ្យបានកាន់តែធំទូលាយថែមទៀត រួមមាន ៖

- ធ្វើបច្ចុប្បន្នកម្មបញ្ជីសារពើភណ្ឌរបស់កម្មវិធីដែលមានស្រាប់ ជាមួយនឹងព័ត៌មានបឋមមួយចំនួន ដូចជាវិសាលភាពភូមិសាស្ត្រ ប្រភេទ និងចំនួនអ្នកទទួលផលនិងថវិកា ដើម្បីសម្រួលដល់ការស្វែងយល់លើបញ្ហាចន្លោះប្រហោងឬការត្រួតស៊ីគ្នា។
- បង្កើតប្រព័ន្ធពិនិត្យតាមដានដោយផ្អែកលើលទ្ធផលនៅថ្នាក់ជាតិ សម្រាប់កម្មវិធីសំណាញ់សុវត្ថិភាពសង្គមដែលនឹងត្រូវបង្កើតថ្មី។
- បង្កើតប្រព័ន្ធពិនិត្យតាមដាននិងវាយតម្លៃភាពងាយរងគ្រោះ ដែលមានលក្ខណៈចម្រុះមួយដោយផ្អែកលើប្រព័ន្ធដែលមានស្រាប់ (ឧទាហរណ៍ ប្រព័ន្ធពិនិត្យតាមដានសន្តិសុខស្បៀងនិងអាហារូបត្ថម្ភ និងប្រព័ន្ធទិន្នន័យកម្មវិធីអត្តសញ្ញាណគ្រួសារក្រីក្រ)។ ប្រព័ន្ធនេះនឹងផ្តល់នូវទិន្នន័យនិងការវិភាគទៅតាមពេលវេលាពិតប្រាកដ ព្រមទាំងបង្ហាញពីភាពងាយរងគ្រោះដែលលេចឡើងថ្មីៗ និងការឆ្លើយតបទាន់ពេលវេលា។ ការធ្វើបែបនេះនឹងជួយសន្សំធនធានហិរញ្ញវត្ថុ តាមរយៈការឆ្លើយតបយ៉ាងឆាប់រហ័ស។
- រៀបចំការវាយតម្លៃកម្មវិធីគាំពារសង្គមជាក់លាក់ ដែលរួមមានការសិក្សាបែបគុណភាពដើម្បីស្វែងយល់ពីភាពពេញចិត្តរបស់អ្នកទទួលផលនិងបញ្ហាប្រឈមក្នុងការអនុវត្ត ព្រមទាំងការវាយតម្លៃលើផលប៉ះពាល់តាមបែបបរិមាណដែលមានលក្ខណៈស៊ីជម្រៅ ដើម្បីវិភាគលើប្រសិទ្ធភាពនិងភាពសក្តិសិទ្ធិរបស់កម្មវិធីទាំងនោះដោយផ្អែកលើលទ្ធផល។

- រៀបចំការវាយតម្លៃពីសមិទ្ធផលពាក់កណ្តាលអាណត្តិកម្មវិធី និងផលប៉ះពាល់របស់យុទ្ធសាស្ត្រជារួម ដើម្បីធានាដល់ការគាំទ្រនិងការពិភាក្សាដោយផ្អែកលើភស្តុតាង លើការបន្តរៀបចំអភិវឌ្ឍយុទ្ធសាស្ត្រ ការសម្របសម្រួល និងការធ្វើសុខដុមនីយកម្ម។
- ជំរុញការពិនិត្យតាមដានការអនុវត្តកម្មវិធីដោយមានការចូលរួម ដើម្បីកាត់បន្ថយកំហុសឆ្គងនៃការកំណត់គោលដៅអ្នកទទួលផលលើសឬតិចជាងចំនួនជាក់ស្តែង ក៏ដូចជាការប្រឹក្សាជាមួយនឹងអ្នកទទួលផលស្តីពីការរៀបចំ និងលទ្ធផលដែលទទួលបានពីការអនុវត្តកម្មវិធី (ឧទាហរណ៍ តាមរយៈឯកសាររបាយការណ៍របស់ប្រជាជន។ល។)
- រៀបចំការពិនិត្យតាមដានដំណើរការហិរញ្ញវត្ថុ ដើម្បីគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ និងបង្កើនប្រសិទ្ធភាពចំណាយរបស់អន្តរាគមន៍។

ប្រភពទិន្នន័យសម្រាប់ការពិនិត្យតាមដាននិងការវាយតម្លៃរបស់**យ.ជ.គ.ស.** នឹងដាក់បញ្ចូលស្ថិតិផ្លូវការ (ការអង្កេតប្រជាសាស្ត្រនិងសុខភាពកម្ពុជា ឬការអង្កេតសេដ្ឋកិច្ច សង្គមកម្ពុជា) ព្រមទាំងស្ថិតិរដ្ឋបាលដែលទទួលបានពីក្រសួងជំនាញ ប្រព័ន្ធពិនិត្យតាមដានកម្មវិធី រួមជាមួយនឹងការអង្កេត និងវាយតម្លៃបន្ថែម។

**សកម្មភាពទី៧**

រៀបចំរបាយការណ៍វឌ្ឍនភាពប្រចាំឆ្នាំស្តីពី **យ.ជ.គ.ស.** តាមរយៈដំណើរការពិភាក្សាពិគ្រោះយោបល់បច្ចេកទេសជាមួយស្ថាប័នពាក់ព័ន្ធ។

**ក.ក.ជ.** នឹងរៀបចំរបាយការណ៍វឌ្ឍនភាពប្រចាំឆ្នាំស្តីពី **យ.ជ.គ.ស.** ដោយផ្អែកលើសូចនាករក្នុងក្របខណ្ឌពិនិត្យតាមដាន និងព័ត៌មានដែលទទួលបានពីស្ថាប័នអនុវត្ត។ លទ្ធផលនៃការពិនិត្យតាមដាននឹងត្រូវដាក់បង្ហាញដល់គ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ ស្ថាប័នអនុវត្ត និងដៃគូអភិវឌ្ឍយ៉ាងទៀងទាត់ (ក្នុងក្របខណ្ឌរបស់គណៈកម្មាធិការសម្របសម្រួលរវាងរាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍ និងវេទិកាកិច្ចសហប្រតិបត្តិការអភិវឌ្ឍកម្ពុជា) ដើម្បីជាជំនួយដល់ការរៀបចំផែនការកម្មវិធី និងរៀបចំអន្តរាគមន៍នៅពេលអនាគត និងការគ្រប់គ្រងធនធានរួម។

## ៦.១.៣. ការគ្រប់គ្រងព័ត៌មាននិងចំណេះដឹងស្តីពីការគាំពារសង្គម

ការគ្រប់គ្រងព័ត៌មាននិងចំណេះដឹង ជាកត្តាចាំបាច់មួយសម្រាប់ការសម្របសម្រួល ប៉ុន្តែនាពេលបច្ចុប្បន្ននេះ ព័ត៌មានស្តីពីសំណាញ់សុវត្ថិភាពសង្គមដែលមានស្រាប់នៅកម្ពុជា នៅតែស្ថិតនៅ

ដាច់ដោយឡែក និងមិនគ្រប់គ្រាន់នៅឡើយ។ ការគ្រប់គ្រងព័ត៌មាននិងចំណេះដឹងដែលមានលក្ខណៈប្រសើរ នឹងលើកកម្ពស់ទំនាក់ទំនងនិងលំហូរព័ត៌មានរវាងដៃគូពាក់ព័ន្ធទាំងអស់។ ទំនាក់ទំនង និងលំហូរព័ត៌មាននេះទាក់ទងនឹងការប្រមូលនិងការគ្រប់គ្រងព័ត៌មាន ព្រមទាំងការបង្កើតនិងការអប់រំផ្សព្វផ្សាយនូវផលិតផលចំណេះដឹងនិងសេវា។ លទ្ធភាពទទួលបានព័ត៌មានស្តីពីនវានុវត្តន៍ និងមេរៀនស្តីពីបទពិសោធ ព្រមទាំងសមត្ថភាពដើម្បីបង្កើតនិងផ្ទេរចំណេះដឹង ជាប្រការចាំបាច់ក្នុងការជំរុញឲ្យកម្មវិធីគាំពារសង្គមទទួលបានជោគជ័យ។

**សកម្មភាពទី៤**

ពង្រឹងការគ្រប់គ្រងព័តិមាននិងចំណេះដឹងស្តីពីការគាំពារសង្គម ដើម្បីធានាឱ្យបាននូវបច្ចុប្បន្នភាពនៃការប្រមូល បង្កើត និងផ្សព្វផ្សាយព័តិមានសម្រាប់ស្ថាប័នពាក់ព័ន្ធ។

យុទ្ធនាការផ្សព្វផ្សាយព័ត៌មាន នឹងបង្កើនការយល់ដឹងអំពីកម្មវិធីគាំពារសង្គម។ លទ្ធផលរបស់ **យ.ជ.គ.ស.** និងកម្មវិធីផ្សេងៗនៅក្នុង **យ.ជ.គ.ស.** នឹងត្រូវបានចែករំលែកតាមរយៈសិក្ខាសាលាថ្នាក់ជាតិ សិក្ខាសាលាផ្លាស់ប្តូរយោបល់ថ្នាក់តំបន់ និងសិក្ខាសាលាតាមវិស័យផ្សេងៗ។ ការជជែកពិភាក្សាស្តីពីកិច្ចគាំពារសង្គមនៅកម្រិតថ្នាក់ស្រុក និងឃុំ នឹងធានាឲ្យមានយន្តការផ្តល់យោបល់ត្រឡប់ទៅកាន់ថ្នាក់ខេត្ត និងជាតិ។ **ក.ក.ជ.** នឹងរៀបចំ និងធ្វើបច្ចុប្បន្នភាពព័ត៌មាននិងកម្មវិធីផ្តល់ចំណេះដឹងនៅលើវេបសាយស្តីពីកិច្ចគាំពារសង្គម ដើម្បីណែនាំនូវគំនិតថ្មីៗ ព្រមទាំងជំរុញឲ្យមានទំនាក់ទំនងជាលក្ខណៈអន្តរក្រសួងនិងដៃគូអភិវឌ្ឍស្តីពីកិច្ចគាំពារសង្គម។ ទោះបីជាគេហទំព័រនេះ នឹងផ្តល់សារៈប្រយោជន៍ដល់បុគ្គល និងស្ថាប័នជាច្រើនក៏ដោយ ក៏រដ្ឋបាលមូលដ្ឋាននៅថ្នាក់ក្រោមជាតិឬស្ថាប័នថ្នាក់ជាតិមួយចំនួន នឹងនៅមានការលំបាកក្នុងការប្រើប្រាស់បច្ចេកវិទ្យានេះ។ ដូច្នេះដើម្បីបំពេញបន្ថែមទៅលើបច្ចេកវិទ្យាព័ត៌មានទំនើបបែបនេះ ការបង្កើតព្រឹត្តិបត្រនិងទស្សនាវដ្តីតាមពេលវេលាទៀតទាត់ គឺជាជម្រើសមួយ។

## ៦.១.៤. ការកសាងសមត្ថភាពសម្រាប់ការគាំពារសង្គម

ដើម្បីឲ្យការអនុវត្តកម្មវិធីគាំពារសង្គមប្រព្រឹត្តទៅបានដោយជោគជ័យ ការពង្រឹងសមត្ថភាពស្ថាប័ននៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ គឺជាកត្តាចាំបាច់ ដែលក្នុងនោះរួមមានចំណេះដឹង បច្ចេកទេស និងធនធាន ក្នុងការរៀបចំបង្កើត ការអនុវត្ត ការសម្របសម្រួល និងការពិនិត្យតាមដានយុទ្ធសាស្ត្រជាតិគាំពារសង្គមជាលក្ខណៈអន្តរវិស័យ។

សមត្ថភាពក្នុងការធ្វើវិភាគលើស្ថានភាពនៃភាពក្រីក្រនិងភាពងាយរងគ្រោះ ព្រមទាំងការរៀបចំ និងការកែសម្រួលលើអន្តរាគមន៍សំណាញ់សុវត្ថិភាពសង្គម នៅក្នុងបរិយាកាសសង្គមសេដ្ឋកិច្ចដែលកំពុងផ្លាស់ប្តូរ នឹងត្រូវរៀបចំបន្ថែមទៀតសម្រាប់មន្ត្រីរាជការនៅ**ក.ក.ជ.** និងនៅក្រសួងពាក់ព័ន្ធផ្សេងៗ ក្នុងដំណាក់កាលដំបូងនៃការអនុវត្ត **យ.ជ.គ.ស.**។ ការពង្រឹងសមត្ថភាពក៏ត្រូវធ្វើឡើងសម្រាប់រដ្ឋបាលមូលដ្ឋានថ្នាក់ក្រោមជាតិ ទៅតាមស្ថានភាពសមស្របមួយ ស្របទៅតាមសកម្មភាពពង្រឹងសមត្ថភាពដែលមានស្រាប់ នៅក្នុងបរិបទរបស់កម្មវិធីជាតិស្តីពីការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។

**សកម្មភាពទី៥**

កសាងសមត្ថភាព ដើម្បីធានាឱ្យមានការយល់ដឹង និងកសាងជំនាញ សម្រាប់ការអនុវត្តប្រកបដោយប្រសិទ្ធភាពនៃ យ.ជ.គ.ស. នៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ។

ការវាយតម្លៃលើ**សេចក្តីត្រូវការកសាងសមត្ថភាព** ដើម្បីបំពេញបន្ថែមទៅលើការវាយតម្លៃដែលមានស្រាប់ នឹងកំណត់ពីតម្រូវការជាក់លាក់នៅថ្នាក់ជាតិ ថ្នាក់ក្រោមជាតិនិងថ្នាក់មូលដ្ឋាន។ ផែនការអភិវឌ្ឍធនធានមនុស្សនិងកម្មវិធីបណ្តុះបណ្តាល នឹងត្រូវរៀបចំឡើងនៅឆ្នាំ ២០១១ ដោយផ្អែកលើលទ្ធផលនៃការអនុវត្តនេះ។

គ្រូឧទ្ទេសមកពីក្រសួងនិងស្ថាប័នជំនាញ នឹងត្រូវរៀបចំឲ្យមាន ដើម្បីធានាដល់ការកសាងសមត្ថភាពស្តីពីកិច្ចគាំពារសង្គម នៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ក្នុងអំឡុងឆ្នាំ២០១២-២០១៣។ មន្ត្រីបង្គោលនៅថ្នាក់ខេត្ត និងថ្នាក់ស្រុកនឹងត្រូវបណ្តុះបណ្តាលក្នុង **លក្ខណៈជាប្រព័ន្ធនៃការបង្រៀនបន្តគ្នា** ដើម្បីបង្រៀនបន្តដល់ក្រុមប្រឹក្សាឃុំ។ ប្រព័ន្ធនៃការបង្រៀននេះ នឹងត្រូវបង្កើតឡើងដោយផ្អែកលើបទពិសោធដែលបានមកពីគម្រោងអត្តសញ្ញាណកម្មគ្រួសារក្រីក្រ ដែលបានអនុវត្តប្រកបដោយជោគជ័យតាមរយៈមធ្យោបាយនៃការបង្រៀនបន្តគ្នាបែបនេះ។

## ៦.២. ការជ្រើសរើសនិងការកំណត់អត្តសញ្ញាណអ្នកទទួលផល

**យន្តការជ្រើសរើសនិងកំណត់អត្តសញ្ញាណអ្នកទទួលផល** សមស្របមួយមានសារៈសំខាន់សម្រាប់ការអនុវត្ត**យ.ជ.គ.ស.** ប្រកបដោយប្រសិទ្ធភាព និងភាពសក្តិសិទ្ធិក្នុងការចំណាយ។ វិធីសាស្ត្រមួយ

ចំនួន ក្នុងការជ្រើសរើសអ្នកទទួលផលសម្រាប់អន្តរាគមន៍គាំពារសង្គមនឹងត្រូវរៀបចំឡើង រួមមានវិធីសាស្ត្រការកំណត់អត្តសញ្ញាណដោយអ្នកទទួលផលខ្លួនឯង តាមលក្ខណៈភូមិសាស្ត្រនិងគ្រួសារ។

**ការកំណត់អត្តសញ្ញាណដោយអ្នកទទួលផលខ្លួនឯង** ឬ **ការកំណត់អត្តសញ្ញាណដោយស្ម័គ្រចិត្ត** គឺជាយន្តការកំណត់អត្តសញ្ញាណមួយដែលចំណាយតិចបំផុត ដែលក្នុងនោះកម្មវិធីកិច្ចគាំពារសង្គមនឹងត្រូវរៀបចំឡើងក្នុងលក្ខណៈមួយដែលមានតែគ្រួសារដែលគួរទទួលបានសិទ្ធិតែប៉ុណ្ណោះ ដែលអាចចូលរួមក្នុងកម្មវិធីនេះបាន។ ការកំណត់អត្តសញ្ញាណបែបនេះនឹងត្រូវយកមកអនុវត្តឲ្យបានច្រើនតាមដែលអាចធ្វើទៅបាននៅក្នុងកម្មវិធីសំណង់សាធារណៈ តាមរយៈការផ្តល់ប្រាក់កម្រៃក្នុងកម្រិតមួយថេរ ប្រហាក់ប្រហែលនឹងអត្រាប្រាក់ឈ្នួលតាមតម្លៃទីផ្សារទូទៅ សម្រាប់ពលករគ្មានជំនាញនៅតាមតំបន់ជនបទ។ ប្រសិនបើប្រាក់កម្រៃមានកម្រិតខ្ពស់ពេក កម្មវិធីនឹងជួបហានិភ័យខ្ពស់ដោយសារពលករដែលចូលរួមអាចនឹងពុំមែនជាជនក្រីក្រ។ ក្នុងករណីដែលតម្រូវការការងារពីកម្មវិធីសំណង់សាធារណៈមានច្រើនលើសពីលទ្ធភាពដែលកម្មវិធីអាចផ្តល់ជូនបាន ការកំណត់អត្តសញ្ញាណដោយអ្នកទទួលផលខ្លួនឯងនឹងត្រូវដាក់បញ្ចូលជាមួយនឹងការកំណត់អត្តសញ្ញាណដោយលក្ខណៈភូមិសាស្ត្រ និងយន្តការកំណត់អត្តសញ្ញាណគ្រួសារតាមរយៈនីតិវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្ររបស់ក្រសួងផែនការ។ ការផ្តោតការយកចិត្តទុកដាក់ពិសេសនឹងត្រូវធ្វើឡើង ដើម្បីកំណត់រកប្រភេទការងារនិងវិធីទូទាត់ប្រាក់ឈ្នួល ដើម្បីជៀសវាងការរើសអើងដែលអាចកើតឡើងដោយយថាហេតុចំពោះស្ត្រី និងអ្នកដែលពុំមានសមត្ថភាពគ្រប់គ្រាន់ក្នុងការបំពេញការងារ ពិសេសនៅពេលដែលគ្មានជំនួយពីសមាជិកគ្រួសាររបស់ខ្លួន (រួមទាំងកុមារ)។ វិធានការពិសេសនឹងត្រូវធ្វើឡើងដើម្បីធានាថា ការដ្ឋានសំណង់សាធារណៈនឹងមានលក្ខណៈ **កុមារមេត្រី** (ដែលរួមមាន ការផ្តល់ទឹក អាហារ និងទារកដ្ឋាន។ល។) និងមិនមានការប្រើប្រាស់ពលកម្មកុមារ។

**ការកំណត់អត្តសញ្ញាណអ្នកទទួលផលតាមលក្ខណៈភូមិសាស្ត្រ** ផ្តល់អាទិភាពដល់តំបន់ក្រីក្រ ឬងាយរងគ្រោះបំផុត (ពោលគឺ ខេត្ត ស្រុក និងឃុំ និងរហូតដល់ថ្នាក់ភូមិ)។ ទិន្នន័យនៃកម្មវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ អាចនឹងត្រូវប្រើប្រាស់ដើម្បីរៀបចំបង្កើតជាផែនទីមួយដែលបង្ហាញពីភាពក្រីក្រនៅកម្រិតថ្នាក់តំបន់ភូមិសាស្ត្រតូចណាមួយ។ ទិន្នន័យនៃកម្មវិធីនេះ ក៏ដូចជាផែនទីនៃភាពក្រីក្រ និងភាពងាយរងគ្រោះដែលមានស្រាប់ នឹងត្រូវបន្តប្រើប្រាស់ និងធ្វើបច្ចុប្បន្នកម្ម។ ដូច្នេះ ផែនទីមួយដែលអាចផ្តល់លទ្ធភាពក្នុងការប៉ាន់ស្មានទៅលើការកកើតឡើងនៃភាពក្រីក្រ និងភាពងាយរងគ្រោះជាក់លាក់ណាមួយនៅកម្រិតតំបន់ភូមិសាស្ត្រតូចមួយ (ឧទាហរណ៍នៅកម្រិតថ្នាក់ឃុំ) អាចនឹងត្រូវបង្កើតឡើង និងប្រើប្រាស់ដោយបូកបន្ថែមជាមួយនឹងទិន្នន័យដែលបានមកពីជំរឿននៅឆ្នាំ២០០៨ និងការអង្កេតសេដ្ឋកិច្ច-សង្គមកម្ពុជា។

**ការកំណត់អត្តសញ្ញាណគ្រួសារក្រីក្រ** នឹងប្រើប្រាស់ជាចំបងនូវបញ្ជីគ្រួសារក្រីក្រ និងសមាជិករបស់គ្រួសារទាំងនេះ ដែលបានបង្កើតដោយកម្មវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ។ ទិន្នន័យទាំងនេះអាចប្រើប្រាស់ក្នុងកម្មវិធីការឧបត្ថម្ភសង្គម និងការលើកលែងមិនយកថ្លៃសេវាជាច្រើនប្រភេទ។ ចាប់ពីឆ្នាំ២០០៧ ដល់ឆ្នាំ២០០៩ កម្មវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ បានអនុវត្តជាសរុបលើភូមិចំនួនជាង ៧១០០ ក្នុងខេត្តចំនួន១៧ ហើយកម្មវិធីនេះគ្រោងនឹងគ្របដណ្តប់ទៅលើគ្រប់ភូមិទាំងអស់នៅតំបន់ជនបទ នៅឆ្នាំ២០១០-២០១១។ វិធីសាស្ត្រនេះ ដែលផ្អែកលើលក្ខណៈវិនិច្ឆ័យនិងនីតិវិធីបទដ្ឋាន បានបង្កើតឡើងដោយក្រសួងផែនការ និងដោយមានការពិភាក្សាជាមួយស្ថាប័នពាក់ព័ន្ធជាច្រើន ហើយមានប្រសិទ្ធភាពខ្ពស់ និងមានអត្រាកំហុសឆ្គងទាបនៃការរាប់បញ្ចូល ឬការមិនរាប់បញ្ចូលគ្រួសារក្រីក្រ។ វិធីសាស្ត្រនេះត្រូវបានទទួលស្គាល់ដោយសហគមន៍ភាគច្រើន និងទទួលបានការប្រើប្រាស់កាន់តែច្រើន ក្នុងការកំណត់អត្តសញ្ញាណអ្នកទទួលផល សម្រាប់កម្មវិធីសំណាញ់សុវត្ថិភាពសង្គម។ អនុក្រឹត្យមួយ ដែលតម្រូវឲ្យមានការប្រើប្រាស់ទិន្នន័យអត្តសញ្ញាណកម្មគ្រួសារក្រីក្រជាប្រភពទិន្នន័យមូលដ្ឋាននៃកម្មវិធីសង្គមកិច្ចភាគច្រើន ក្នុងការកំណត់គ្រួសារក្រីក្រគោលដៅ ត្រូវបានព្រាងឡើងនិងកំពុងតែរង់ចាំការអនុម័តពីគណៈរដ្ឋមន្ត្រី។ ប៉ុន្តែបញ្ហាដែលចោទនៅចំពោះមុខ គឺនិរន្តរភាពហិរញ្ញវត្ថុក្នុងរយៈពេលវែងសម្រាប់កម្មវិធី ដូច្នេះយន្តការហិរញ្ញប្បទានសមស្របមួយ នឹងត្រូវកំណត់ក្នុងអំឡុងពេលនៃការអនុវត្ត **យ.ជ.គ.ស.**។

សកម្មភាពអាទិភាពខាងក្រោមនឹងត្រូវអនុវត្ត ដើម្បីធានាដល់ការកំណត់អត្តសញ្ញាណគ្រួសារឲ្យបានប្រសើរ ៖

- ពង្រីកវិសាលភាពរបស់កម្មវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ ឲ្យបានទៅដល់គ្រប់ភូមិនៅតំបន់ជនបទទាំងអស់នៅត្រឹមចុងឆ្នាំ ២០១១។
- រៀបចំនីតិវិធី និងលក្ខណៈវិនិច្ឆ័យសម្រាប់នីតិវិធីសមស្របមួយសម្រាប់ការកំណត់អត្តសញ្ញាណគ្រួសារក្រីក្រនៅតំបន់ប្រជុំជន។
- វាយតម្លៃលើសុក្រឹតភាព និងកម្រិតនៃការទទួលស្គាល់កម្មវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រនៅថ្នាក់សហគមន៍ និងកែលម្អនីតិវិធីអនុវត្តនៃកម្មវិធីនេះជាបន្តបន្ទាប់។
- ធានាឲ្យមានយន្តការហិរញ្ញប្បទានរយៈពេលវែងសម្រាប់កម្មវិធីនេះ (ដើម្បីផ្តល់លទ្ធភាពធ្វើបច្ចុប្បន្នកម្មឲ្យបានទៀងទាត់ រៀងរាល់២ឆ្នាំម្តងលើបញ្ជីគ្រួសារក្រីក្រ)។

ការកំណត់អត្តសញ្ញាណគ្រួសារក្រីក្រ ដោយផ្អែកលើទិន្នន័យមូលដ្ឋាននៃកម្មវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រនៅក្នុងកម្មវិធីអន្តរាគមន៍មួយចំនួន នឹងត្រូវរួមបញ្ចូលបន្ថែមដោយ **ការកំណត់អត្តសញ្ញាណអ្នកទទួលផលតាមលក្ខណៈសម្បត្តិ** (ពោលគឺការជ្រើសរើសគ្រួសារផ្អែកតាមចរិតលក្ខណៈពិសេសមួយចំនួន

ដូចជាគ្រួសារដែលមានកូនតូច ឬដែលមានកូនទៅរៀន គ្រួសារដែលមានស្ត្រីជាមេគ្រួសារ គ្រួសារដែលមានសមាជិកជាជនពិការ។ល។) ហើយនឹងត្រូវបំពេញបន្ថែម ដោយយន្តការកំណត់អត្តសញ្ញាណក្នុងពេលផ្តល់សេវាកម្ម ដើម្បីផ្ទៀងផ្ទាត់និងកែលម្អ។ វិធីសាស្ត្រក្នុងការកំណត់អត្តសញ្ញាណជាលក្ខណៈបំពេញបន្ថែមទាំងនេះអាចនឹងត្រូវប្រើប្រាស់ រហូតដល់ពេលដែលមានការធានានូវការគ្របដណ្តប់ដ៏ទូលំទូលាយរបស់កម្មវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រក្នុងរយៈពេលវែង និងក្នុងករណីដែលតម្រូវឲ្យមានការប្រើប្រាស់នូវលក្ខណៈវិនិច្ឆ័យលម្អិតផ្សេងទៀត ក្នុងការកំណត់អត្តសញ្ញាណ។ ឧទាហរណ៍មួយនៃឧបករណ៍បំពេញបន្ថែមក្នុងការកំណត់អត្តសញ្ញាណដែលមានសក្តានុពល គឺ **វិធីសាស្ត្រផែនទីសៅសង្គម** ដែលបានអនុវត្តសាកល្បងដោយ UNICEF ដែលរួមមានសូចនាករសមស្រប ដើម្បីស្វែងយល់ពីភាពងាយរងគ្រោះត្រួតស៊ីគ្នា ដែលកំពុងប៉ះពាល់ដល់កុមារ ឬគ្រួសារដែលមានកូនច្រើន ពោលគឺជាក្រុមអ្នកទទួលផលពីកិច្ចគាំពារសង្គមភាគច្រើន។ ក្នុងពេលអនាគត សូចនាករនិងវិធីសាស្ត្រមួយចំនួនអាចនឹងត្រូវបញ្ជ្រាបទៅក្នុងកម្មវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ ដើម្បីធានាឲ្យមានសង្គតិភាពនៃអភិក្រម និងការឆ្លើយតបនឹងតម្រូវការនានាយ៉ាងហ្មត់ចត់។ តារាងទី៦ បង្ហាញដោយសង្ខេបនូវយន្តការកំណត់អត្តសញ្ញាណផ្សេងៗ ដែលនឹងត្រូវប្រើប្រាស់ក្នុង **យ.ជ.គ.ស.**។

**តារាងទី៦. ការកំណត់អត្តសញ្ញាណសម្រាប់ យ.ជ.គ.ស.**

| យន្តការកំណត់អត្តសញ្ញាណ | អ្នកទទួលផល | អន្តរាគមន៍ |
|---|---|---|
| ការកំណត់អត្តសញ្ញាណដោយអ្នកទទួលផលខ្លួនឯង<br>(និងការកំណត់អត្តសញ្ញាណអ្នកទទួលផលតាមលក្ខណៈភូមិសាស្ត្រ)<br>(និងការកំណត់គ្រួសារគោលដៅ-ដោយធ្វើអត្តសញ្ញាណកម្មគ្រួសារក្រីក្រ) | និកម្មជន (តាមរដូវ) | កម្មវិធីសំណង់សាធារណៈ |
| ការកំណត់គ្រួសារគោលដៅ-ដោយធ្វើអត្តសញ្ញាណកម្មគ្រួសារក្រីក្រ (និងការកំណត់អត្តសញ្ញាណអ្នកទទួលផលតាមលក្ខណៈភូមិសាស្ត្រ)<br>(និងយន្តការកំណត់អត្តសញ្ញាណក្នុងពេលផ្តល់សេវាកម្ម) | កុមារអាយុក្រោម ៥ឆ្នាំក្នុងគ្រួសារក្រីក្រ ឬកុមារក្នុងវ័យសិក្សាក្នុងគ្រួសារក្រីក្រ | កម្មវិធីឧបត្ថម្ភសាច់ប្រាក់ដោយមានលក្ខខណ្ឌ (លើការទ្រទ្រង់អាហារូបត្ថម្ភ)<br>កម្មវិធីឧបត្ថម្ភសាច់ប្រាក់ដោយមានលក្ខខណ្ឌ (ការអប់រំ និងកាត់បន្ថយពលកម្មកុមារ) |
| ការកំណត់អត្តសញ្ញាណអ្នកទទួលផលតាមលក្ខណៈសម្បត្តិ (និងការកំណត់គ្រួសារគោលដៅ-ដោយធ្វើអត្តសញ្ញាណកម្មគ្រួសារក្រីក្រ) | ក្រុមងាយរងគ្រោះពិសេស | |
| ការកំណត់គ្រួសារគោលដៅ-ដោយធ្វើអត្តសញ្ញាណកម្មគ្រួសារក្រីក្រ | គ្រួសារក្រីក្រ | មូលនិធិសមធម៌សុខភាព |

## ៦.៣. តម្រូវការធនធានថវិកា

ថវិកាជាតិសម្រាប់ក្រសួងនានាក្នុងវិស័យសង្គម[១៨] បានកើនឡើងប្រមាណ០,៨% ចាប់ពីឆ្នាំ២០០៦ដល់ឆ្នាំ២០១០ ដែលត្រូវជា៣,៩%នៃផលិតផលក្នុងស្រុកសរុប (GDP)។ ថវិកាសម្រាប់ក្រសួងសុខាភិបាល និងក្រសួងអប់រំ យុវជន និងកីឡា រួមបញ្ចូលគ្នា មានចំនួនលើសពី៧០%នៃថវិកាជាតិសរុបដែលចំណាយលើវិស័យសង្គម។ ក្នុងអំឡុងពេលនេះ ថវិកាសម្រាប់ក្រសួងសុខាភិបាលបានកើនឡើងប្រហែល០,៥% (រូបទី៨)។

**រូបទី៨. និន្នាការក្នុងការចំណាយលើកិច្ចការសង្គមទាំងមូល (គិតជាភាគរយនៃផលិតផលក្នុងស្រុកសរុប)**




ប្រភព ៖ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

នៅក្នុងរចនាសម្ព័ន្ធថវិកាថ្មីដែលបានប្រើចាប់ពីឆ្នាំ២០០៧ មានពីរជំពូក (៦៤ និង ៦៥) ដែលមានចំណុចជាច្រើនប្រើពាក្យថាអន្តរាគមន៍សង្គម[១៩]។ ការចំណាយរបស់រាជរដ្ឋាភិបាលលើចំណុច

[១៨] រួមមានក្រសួងអប់រំ យុវជន និងកីឡា ក្រសួងសុខាភិបាល ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងកិច្ចការនារី ក្រសួងពត៌មាន ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ក្រសួងបរិស្ថាន និងក្រសួងធម៌ការ និងកិច្ចការសាសនា

[១៩] បញ្ជីសារពើភណ្ឌក្នុងឧបសម្ព័ន្ធ នឹងបង្ហាញពីការបែងចែងដោយពិស្តារនៃថវិកាក្នុងជំពូកទាំងពីរនេះ សម្រាប់គ្រប់ស្ថាប័នរដ្ឋទាំងអស់។ ជំពូក៦៤.៥ មានឈ្មោះថា**ប្រាក់ឧបត្ថម្ភនិងការឧបត្ថម្ភសង្គម** និងរួមបញ្ចូលទាំង ១.គ្រួសារ ២.សុខភាពនិងការផ្តល់កំណើត ៣.មរណភាព ៤.ការចូលនិវត្តន៍ ៥.ការលាលែងពីតំណែង ៦.គ្រោះថ្នាក់ការងារនិងការបាត់បង់លទ្ធភាពការងារ ៧.កុមារកំព្រា ៨.ផ្សេងៗ ៩.ការចុះខ្សោយផ្នែកចំណូល។ ជំពូក៦៥.៧ សំដៅទៅលើ**ជំនួយផ្នែកសង្គម** ដែលរួមមាន ១.ជំនួយសម្រាប់ការចូលសម្រាកក្នុងមន្ទីរពេទ្យ ២.ថ្នាំពេទ្យ ៣.ស្បៀងអាហារនិងសម្ភារៈ ៤.គ្រោះមហន្តរាយធម្មជាតិ ៥.ការចំណាយលើការងារស្រាវជ្រាវ ៦.ការស្រាវជ្រាវនិងអាហារូបករណ៍ក្នុងស្រុក ៧.ការស្រាវជ្រាវនិងអាហារូបករណ៍សម្រាប់ទៅសិក្សានៅបរទេស ៨.ផ្សេងៗ។ ជំពូក៦៥.៨ សំដៅទៅលើ **ជំនួយទ្រទ្រង់ដល់អង្គភាពខាង**

ទាំងនេះ មានចំនួនសរុបស្មើនឹង១៨១លានដុល្លារអាមេរិក សម្រាប់ស្ថាប័នរដ្ឋទាំងអស់នៅក្នុងឆ្នាំ ២០០៨ ដែលកើនឡើង៥៥% ធៀបនឹងឆ្នាំ២០០៧។ ដោយសារកម្រិតនៃការចំណាយថវិកានេះ បានបង្ហាញជាចំនួនសរុប ដូច្នេះការគណនាទៅលើបរិមាណថវិកាដែលនឹងត្រូវចំណាយទៅលើសកម្មភាពកិច្ចគាំពារសង្គម និងប្រភេទផ្សេងៗទៀតនៃអន្តរាគមន៍សង្គម នៅពុំអាចធ្វើបាននៅឡើយ។ ការចំណាយនៅក្នុងកិច្ចគាំពារសង្គមដែលអាចឃើញជាក់ស្តែង គឺផ្តោតគោលដៅចំពោះនិយោជិតរបស់រដ្ឋ និងអ្នកធ្វើការក្នុងវិស័យផ្លូវការ។

ការប៉ាន់ប្រមាណលើថវិកាចំណាយសម្រាប់រយៈពេលមធ្យមនិងរយៈពេលវែង ក្នុងការអនុវត្ត **យ.ជ.គ.ស.** នឹងត្រូវរៀបចំឡើងជាការងារអាទិភាពក្នុងអំឡុងឆ្នាំដំបូងនៃការអនុវត្ត (ដោយរួមមានការចំណាយដោយលម្អិតនៃអន្តរាគមន៍ដែលមានស្រាប់និងដែលបានគ្រោងទុក និងការវិភាគពីចន្លោះប្រហោងផ្នែកសារពើពន្ធ)។ រាជរដ្ឋាភិបាលនឹងពិភាក្សាជាមួយដៃគូអភិវឌ្ឍ លើការគ្រប់គ្រងផ្នែកហិរញ្ញវត្ថុ ពិសេសលើការប្រមូលមូលនិធិរួមគ្នា និងដើម្បីបង្កើតឲ្យមានកិច្ចអន្តរាគមន៍សង្គមដែលមានលក្ខណៈជាកម្មវិធីទ្រង់ទ្រាយធំមួយ និងដើម្បីធ្វើឲ្យមានសុខដុមនីយកម្មដល់ការគាំទ្ររបស់ស្ថាប័នផ្តល់ជំនួយសម្រាប់ **យ.ជ.គ.ស.**។

ដើម្បីផ្តល់ហិរញ្ញប្បទានសម្រាប់ការសម្របសម្រួលក្នុងការអនុវត្ត**យ.ជ.គ.ស.** (ការកសាងសមត្ថភាព ការធ្វើផែនការ ការពិនិត្យតាមដាន និងការគ្រប់គ្រងព័ត៌មាននិងចំណេះដឹង) រាជរដ្ឋាភិបាលកម្ពុជាដាក់ឲ្យមានការរៀបចំមូលនិធិជាកញ្ចប់រួម ដើម្បីឲ្យមានសុខដុមនីយកម្មលើការគាំទ្រជំនួយការបច្ចេកទេសពីដៃគូអភិវឌ្ឍ។

## ៦.៤. សកម្មភាពអាទិភាពសម្រាប់អនាគតដ៏ខ្លី

ការកំណត់អាទិភាពសម្រាប់បង្កើតអន្តរាគមន៍កិច្ចគាំពារសង្គម ក្នុងដំណាក់កាលខ្លីខាងមុខនេះ ធ្វើឡើងដោយសារសមត្ថភាពនៃស្ថាប័នក្នុងការអនុវត្តនៅមានកម្រិត និងចន្លោះប្រហោងផ្នែកសារពើពន្ធ។ តារាងទី៧នឹងបង្ហាញនូវកម្មវិធីនិងសកម្មភាពជាអាទិភាព សម្រាប់រយៈពេលពីរទៅបីឆ្នាំខាងមុខនេះ និងផ្តល់ការប៉ាន់ប្រមាណនូវចំណាយជាបឋម[២០]។

---

***សង្គមនិងវប្បធម៌*** រួមមានជំនួយឧបត្ថម្ភដល់ ១.សហគមន៍ ២.មណ្ឌលកុមារកំព្រា ៣.អាហារូបករណ៍សម្រាប់ការធ្វើដំណើរ ៤.កាកបាទក្រហមកម្ពុជា ៥.សហគមន៍វប្បធម៌និងកីឡា ៦.មជ្ឈមណ្ឌលស្តារនីតិសម្បទា ៧.ព្រះរាជកិច្ច (កម្មវិធីមនុស្សធម៌របស់ព្រះមហាក្សត្រ)។

[២០] ព័ត៌មានពិស្តារស្តីពីការប៉ាន់ប្រមាណលើការចំណាយសម្រាប់កម្មវិធី បានបង្ហាញនៅក្នុងឯកសារមូលដ្ឋានមួយចំនួនទាក់ទងនឹង យ.ជ.គ.ស.។

សកម្មភាពជាអាទិភាព រួមមានការបង្កើតឡើងនូវកម្មវិធីថ្មី (ដូចជាកម្មវិធីឧបត្ថម្ភសាច់ប្រាក់ថ្នាក់ជាតិ ឬកម្មវិធីសំណង់សាធារណៈ) កម្មវិធីដែលកំពុងដំណើរការនិងដែលត្រូវការពង្រីកបន្ថែម (ដូចជាមូលនិធិសមធម៌សុខភាព) ការឧបត្ថម្ភលើការកសាងសមត្ថភាពសម្រាប់ការសម្របសម្រួល និងការពិនិត្យតាមដាន និងវាយតម្លៃលើកម្មវិធី **យ.ជ.គ.ស.** នៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ[២១]។

កម្មវិធីគាំពារសង្គមដែលមានស្រាប់និងកម្មវិធីដែលត្រូវបង្កើតថ្មី នឹងត្រូវធ្វើសុខដុមនីយកម្ម និងប្របាច់បញ្ចូលគ្នាបន្ថែមទៀត នៅក្នុងអំឡុងពេលអនុវត្ត**យ.ជ.គ.ស.**នៅកម្រិតថ្នាក់ជាតិ ដោយអនុវត្តទៅតាមគោលការណ៍ណែនាំ[២២]និងនីតិវិធីដូចគ្នា និងដើម្បីដោះស្រាយភាពងាយរងគ្រោះដែលមានស្រាប់។ ជាទស្សនវិស័យរយៈពេលវែង គឺការដាក់បញ្ចូលគ្នានូវគម្រោងផ្សេងៗគ្នាឲ្យចូលទៅក្នុងកម្មវិធីរួមតែមួយ (យ៉ាងហោចណាស់សម្រាប់ដោះស្រាយគោលបំណងណាមួយនៃ **យ.ជ.គ.ស.**) ដើម្បីជៀសវាងស្ថានភាពដែលគម្រោងផ្តោតលើសលប់តែទៅលើភាពងាយរងគ្រោះតែមួយ ឬកង្វះលក្ខណៈឯកភាពគ្នានៃបទដ្ឋានអនុវត្តដែលមានគុណភាពក្នុងសេវាគាំពារសង្គម។

កម្មវិធីដែលកំពុងអនុវត្ត ដើម្បីឆ្លើយតបទៅនឹងវិបត្តិថ្លៃស្បៀងនិងកលិយុគសេដ្ឋកិច្ចនាពេលថ្មីៗនេះ នឹងជាមេរៀនមួយសម្រាប់ការចង្អុលបង្ហាញថាតើកម្មវិធីណាដែលនឹងត្រូវពង្រីកបន្ថែម ហើយត្រូវពង្រីកបន្ថែមដោយរបៀបណា។ ការកសាងសមត្ថភាពស្ថាប័នសម្រាប់ **ក.ក.ជ.** និងក្រសួងពាក់ព័ន្ធនឹងក្លាយជាអាទិភាពស្រមាប់អនាគតដ៏ខ្លីខាងមុខ ព្រោះការរៀបចំស្ថាប័ន ការទ្រទ្រង់ដល់តួនាទីសម្របសម្រួល ព្រមទាំងរចនាសម្ព័ន្ធពិនិត្យតាមដាន គឺជាបុរេលក្ខខណ្ឌដើម្បីរំកិល **យ.ជ.គ.ស.** ទៅកាន់រយៈពេលមធ្យមនិងវែង។

[២១] មកដល់បច្ចុប្បន្ននេះ ការងារគាំពារសង្គមបានអនុវត្តដោយក្រសួងផ្សេងៗជាច្រើន ដោយខ្វះការសម្របសម្រួលជារួម។ ជាលទ្ធផល យុទ្ធសាស្ត្រនិងផែនការសកម្មភាពសម្រាប់អន្តរាគមន៍ក្នុងកម្មវិធីនីមួយៗ ស្ថិតនៅដំណាក់កាលខុសៗគ្នានៃការបង្កើតនិងការអនុវត្ត។ ក្រសួងដែលបានកំណត់អាទិភាពរយៈពេលខ្លីរួច មានដូចជាក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងសុខាភិបាល ក្រសួងអប់រំ យុវជន និងកីឡា និងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។ អាទិភាពដែលមានទាំងអស់នេះ ត្រូវបានបញ្ចូលទៅក្នុងកម្មវិធីយ.ជ.គ.ស.។ ក.ក.ជ បានដឹកនាំកិច្ចពិភាក្សាពិគ្រោះយោបល់បច្ចេកទេសមួយចំនួន ដើម្បីកំណត់រកនូវអាទិភាពមួយចំនួនទៀតសម្រាប់កិច្ចគាំពារសង្គមក្នុងដំណាក់កាលខ្លីដែលនឹងត្រូវផ្តល់ដោយរាជរដ្ឋាភិបាល។

[២២] គោលការណ៍ទាំងនេះ រួមមានអន្តរាគមន៍ពាក់ព័ន្ធដោយមានភស្តុតាង (ផ្អែកលើភស្តុតាងនិងតម្រូវការ) ប្រសិទ្ធភាពនិងភាពសក្តិសិទ្ធិ និរន្តភាពនៃវិធានការការចូលរួម និងការផ្តល់អំណាចដល់អ្នកទទួលផល (រួមបញ្ចូលទាំងការចូលរួមក្នុងការរៀបចំ ការពិនិត្យតាមដាន និងយន្តការក្នុងការផ្តល់យោបល់ត្រឡប់) ភាពរីកចម្រើន ការពង្រីកកម្មវិធីជាបន្តបន្ទាប់ និងការបំពេញបន្ថែម (ចៀសវាងការត្រួតស៊ីគ្នា និងអន្តរទំនាក់ទំនង)នៃកម្មវិធី។

ការប៉ាន់ប្រមាណចំណាយដែលមានបរិយាយនៅក្នុងតារាងទី៧នេះ គ្រាន់តែជាសូចនាករតែប៉ុណ្ណោះ ហើយការវិភាគលើតម្រូវការហិរញ្ញប្បទានដែលមានលក្ខណៈពិស្តារ នឹងត្រូវធ្វើឡើងជាបន្តទៀត។ រាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍ បានធ្វើការព្រមព្រៀងរួចជាស្រេចលើសកម្មភាពជាអាទិភាពមួយចំនួនរួចហើយ។ ចំណែកសកម្មភាពអាទិភាពមួយចំនួនទៀត គឺជាប្រភេទអន្តរាគមន៍ថ្មី។

## តារាងទី៧. សកម្មភាពជាអាទិភាពក្នុងដំណាក់កាលខ្លីរបស់ យ.ជ.គ.ស. និងការប៉ាន់ស្មានចំណាយ

| កម្មវិធី និងសកម្មភាពអាទិភាពរយៈពេលខ្លី | | ស្ថាប័នអនុវត្ត | ចំនួនប៉ាន់ស្មាននៃកម្រិត និងអ្នកទទួលផល | ស្ថានភាពហិរញ្ញប្បទាន | តម្រូវការថវិកា (គិតជាលានដុល្លារ) | | |
|---|---|---|---|---|---|---|---|
| | | | | | ២០១០-២០១១ | ២០១២ | ២០១៣ |
| **សកម្មភាពជាអាទិភាព** | | | | | | | |
| ០.១ | ផ្សព្វផ្សាយ **យ.ជ.គ.ស.** នៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ | ក.ក.ជ. | | កំពុងរក | ០,០៥ | | |
| ០.២ | កំណត់តួនាទី មុខងារ និងរចនាសម្ព័ន្ធសម្របសម្រួលរវាងស្ថាប័នផ្តល់ជំនួយនិងស្ថាប័នរដ្ឋាភិបាល | ក.ក.ជ. | | កំពុងរក | ០,០៥ | | |
